# ការវាយតម្លៃពីជីវៈចម្រុះនៅតំបន់ព្រៃឡង់

## ស្ថិតក្នុងខេត្តក្រចេះ កំពង់ធំ ស្ទឹងត្រែង និងខេត្តព្រះវិហារ



## ខែឧសភា ឆ្នាំ២០១៥

រៀបរៀងចងក្រងដោយ បេនចាមីន ហាយេស, យូ អៀងហួត, នាង ធី, នីល ហ្វូរ៉េ,
ឈិន សុភា, ជេរេមី ហូលឌិន, ហ៊ុន សីហា, ផែន សារិទ្ធិ, ឡា ប៉េងលី និងវើជីណា សាំសុន

# តារាងមាតិកា

**សេចក្តីថ្លែងអំណរគុណ** 7

**ពាក្យបំប្រួញ & អក្សរកាត់** 8

**ការសន្ទត** 9

**១. សេចក្តីផ្តើម** 10

*គោលដៅ និងគោលបំណងនៃការធ្វើអង្កេតស្រាវជ្រាវ* 14

*ចំនុចខ្វះខាតនៃការធ្វើអង្កេតស្រាវជ្រាវ* 14

**២. រុក្ខជាតិ** 16

*សេចក្តីផ្តើម* 16

*វិធីសាស្ត្រស្រាវជ្រាវ* 17

*លទ្ធផលស្រាវជ្រាវ* 24

*កិច្ចពិភាក្សា* 51

**៣. ថនិកសត្វ** 58

*សេចក្តីផ្តើម* 58

*វិធីសាស្ត្រស្រាវជ្រាវ* 58

*លទ្ធផលស្រាវជ្រាវ* 59

*ការពិភាក្សា* 69

**៤. សត្វប្រចៀវ** 72

*សេចក្តីផ្តើម* 72

*វិធីសាស្ត្រស្រាវជ្រាវ* 73

*លទ្ធផលស្រាវជ្រាវ* 79

*ការពិភាក្សា* 89

**៥. សត្វស្លាប** .......... 92

*សេចក្តផ្តើម* .......... 92

*វិធីសាស្ត្រស្រាវជ្រាវ* .......... 93

*លទ្ធផលស្រាវជ្រាវ* .......... 95

*ការពិភាក្សា* .......... 104

**៦. ថលជលិកនិងឧរង្គសត្វ** .......... 108

*សេចក្តីផ្តើម* .......... 108

*វិធីសាស្ត្រស្រាវជ្រាវ* .......... 109

*លទ្ធផលស្រាវជ្រាវ* .......... 112

*ការពិភាក្សា* .......... 120

**៧. សេចក្តីសង្ខេប** .......... 125

*សារៈសំខាន់នៅក្នុងតំបន់និងលើសកលលោក* .......... 125

*កត្តាគម្រាមកំហែង* .......... 127

*ការផ្តល់អនុសាសន៍និងការពិចារណាលើការគ្រប់គ្រង* .......... 129

**ឯកសារយោង** .......... 132

## បញ្ជីរាយផែនទី

ផែនទី 1 ទីតាំងភូមិសាស្ត្រតំបន់ព្រៃឡង់ ....12
ផែនទី 2 ការបែងចែកទីជម្រាលនៃតំបន់ព្រៃឡង់ ....12
ផែនទី 3 ការកាប់ព្រៃឈើនៅតំបន់ព្រៃឡង់ ចន្លោះឆ្នាំ២០០១-២០១១ ....12
ផែនទី 4 ការផ្តល់ដីសម្បទានសេដ្ឋកិច្ចនៅជុំវិញតំបន់ព្រៃឡង់ ឆ្នាំ២០១៣ ....12
ផែនទី 5 តំបន់ដែលត្រូវបានធ្វើអង្កេតស្រាវជ្រាវ ....13
ផែនទី 6 ប្រភេទព្រៃឈើនៅតំបន់ព្រៃឡង់ ទិន្នន័យរបស់ រដ្ឋបាលព្រៃឈើ ឆ្នាំ២០១០ ....16
ផែនទី 7 ការផ្តល់ដីសម្បទានរុករករ៉ែ និងឆ្នាំនៃការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្ម ....52

## បញ្ជីរាយតារាង

តារាង 1 ទីតាំងអង្កេតស្រាវជ្រាវរុក្ខជាតិ ....19
តារាង 2 ស្ថានភាពនៃប្រភេទរុក្ខជាតិសំខាន់ៗរបស់កម្ពុជានៅក្នុងតំបន់ព្រៃឡង់ ....46
តារាង 3 ការប្រមូលសំណាកក្នុងអំឡុងពេលអង្កេតស្រាវជ្រាវនៅតំបន់ព្រៃឡង់ ....77
តារាង 4ប្រភេទសត្វប្រចៀវដែលត្រូវបានកត់ត្រានៅក្នុងតំបន់ចំនួនបីនៃព្រៃឡង់ ....81
តារាង 5 រូងថ្ម (ឬល្អាងភ្នំ) ដែលត្រូវបានអង្កេតស្រាវជ្រាវនៅចំនុចភាគខាងជើងនៃព្រៃឡង់ ....84
តារាង 6 កាលបរិច្ឆេទ និងទីតាំងនៃការប្រមូលសំណាកសត្វស្លាបនៅព្រៃឡង់ ....93
តារាង 7 កាលបរិច្ឆេទនិងទីតាំងនៃការអង្កេតស្រាវជ្រាវថលជលិក-ឧរង្គសត្វ ....111
តារាង 8 សេចក្តីសង្ខេបនៃប្រភេទថលជលិក-ឧរង្គសត្វនៅព្រៃឡង់ដែលត្រូវបានចុះបញ្ជីដោយ IUCN ....115

## បញ្ជីរាយរូបភាព

រូបភាព 1 ចំនួនប្រភេទរុក្ខជាតិនៅតំបន់ព្រៃឡង់ ....24
រូបភាព 2 ផ្កាអ័រគីដេ *Peristylus goodyeroides* ដែលដុះនៅលើថ្មកំបោរនៃតំបន់ព្រៃឡង់ ....25
រូបភាព 3 ព្រៃជាំទឹក នៅក្នុងតំបន់ព្រៃឡង់ ....39
រូបភាព 4 ព្រៃឈើដុះតាមមាត់ទឹកនៃតំបន់ព្រៃឡង់ ក្នុងខេត្តស្ទឹងត្រែង ....42
រូបភាព 5 ស្នាមជានជើងដំរីតាមវាលស្មៅ ក្នុងតំបន់ព្រៃឡង់ ....44
រូបភាព 6 ការកាត់ដើមឈើយកជ័រថ្មី នៅតំបន់ព្រៃឡង់ ....49
រូបភាព 7 តំណក់ជ័រឈើ នៅតំបន់ព្រៃឡង់ ....50
រូបភាព 8 ទីតាំងព្រៃជាំទឹកដែលសម្បូរ ដើមផ្តៅ នៅតំបន់ព្រៃឡង់ ....50
រូបភាព 9 ការកាប់ព្រៃឈើ និងការដុតព្រៃ នៅតំបន់ព្រៃឡង់ ....55
រូបភាព 10 ការកាប់ព្រៃឈើ និងការដុតព្រៃ នៅតំបន់ព្រៃឡង់ ....55

រូបភាព 11 សត្វទន្សោងដែលថតបានដោយម៉ាស៊ីនថតរូបស្វ័យប្រវត្តក្នុងអំឡុងពេលស្រាវជ្រាវ ក្នុងតំបន់ព្រៃឡង់ ....61
រូបភាព 12 ដំរី ELEPHAS MAXIMUS ដែលថតបានដោយម៉ាស៊ីនថតស្វ័យប្រវត្ត ក្នុងអំឡុងពេលស្រាវ ជ្រាវ នៅតំបន់ព្រៃឡង់....63
រូបភាព 13 កំប្រុកធំ RATUFA BICOLOR ដែលថតបានពីម៉ាស៊ីនថតរូបស្វ័យប្រវត្តក្នុងអំឡុងពេលស្រាវជ្រាវនៅតំបន់ព្រៃឡង់....66
រូបភាព 14 រូបភាពភ្នំធំថតចំពីខាងត្បូង នៅភាគខាងជើងព្រៃឡង់....78
រូបភាព 15 ព្រៃដើមស្រឡៅនៅភ្នំធំ ភាគខាងជើងព្រៃឡង់....78
រូបភាព 16 ប្រចៀវប្រភេទ RHINOLOPHUS SHAMELI នៅតំបន់ព្រៃឡង់ ....80
រូបភាព 17 ប្រចៀវប្រភេទ RHINOLOPHUS ACUMINATUS នៅតំបន់ព្រៃឡង់ ....80
រូបភាព 18 ប្រចៀវប្រភេទ R. MARSHALLI នៅតំបន់ព្រៃឡង់....80
រូបភាព 19 ប្រចៀវប្រភេទ MURINA WALSTONI នៅតំបន់ព្រៃឡង់ ....80
រូបភាព 20 ក្ងោកបៃតង ....97
រូបភាព 21 ត្រដក់តូច នៅតំបន់ព្រៃឡង់....99
រូបភាព 22 សត្វក្រៀលក្បាលក្រហម ....101
រូបភាព 23 សំណល់ស្លាបត្រដក់តូចដែលព្រានព្រៃបានបន្សល់ចោល នៅក្នុងព្រៃឡង់....106
រូបភាព 24 កញ្ចាញ់ចេកប្រភេទHYLARANA ERYTHRAEA នៅក្នុងព្រៃឡង់....109
រូបភាព 25 អណ្តើកក្អែកខ្មៅ (SIEBENROCKIELLA CRASSICOLIS) ប្រភេទងាយរងគ្រោះក្នុងតំបន់ព្រៃឡង់ ....118
រូបភាព 26 សត្វកន្ធ្រង PHYSIGNATHUS COCINCINUS នៅក្នុងព្រៃឡង់....121
រូបភាព 27 សត្វស្កាធំ (HERPESTES URVA) ជាប់អន្ទាក់ទាក់អណ្តើក នៅក្នុងព្រៃឡង់....122
រូបភាព 28 ត្វអណ្តើកដែលត្រូវអ្នកលួចប្រមាញសត្វចាប់បាន នៅក្នុងព្រៃឡង់ ....122
រូបភាព 29 អ្នកប្រមូលជ័រឈើ នៅក្នុងព្រៃឡង់ ....127
រូបភាព 30 ការដឹកជញ្ជូនឈើចេញពីក្នុងព្រៃដោយរទេះគោ នៅតំបន់ព្រៃឡង់....128

## បញ្ជីរាយ ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ 1 ប្រភេទរុក្ខជាតិនៅតំបន់ព្រៃឡង់....144
ឧបសម្ព័ន្ធ 2 ប្រភេទថនិកសត្វ នៅតំបន់ព្រៃឡង់ ....161
ឧបសម្ព័ន្ធ 3 ទីតាំងប្រមូលសំណាកក្នុងអំឡុកពេលអង្កេតស្រាវជ្រាវសត្វប្រចៀវ នៅតំបន់ព្រៃឡង់ ....163
ឧបសម្ព័ន្ធ 4 ប្រភេទសត្វស្លាប នៅតំបន់ព្រៃឡង់....166

# សេចក្តីសង្ខេប

ដោយមានកិច្ចសហការជាមួយរដ្ឋបាលព្រៃឈើនៃប្រទេសកម្ពុជា អង្គការអភិរក្សអន្តរជាតិ (CI) បានអនុវត្តការអង្កេតស្រាវជ្រាវអំពីជីវៈចម្រុះនៅតំបន់ព្រៃឡង់ នៅចន្លោះខែមិថុនា ឆ្នាំ២០១៤ និងខែកុម្ភៈ ឆ្នាំ២០១៥។ គោលបំណងនៃការអង្កេតស្រាវជ្រាវនេះ គឺផ្តោតទៅលើការកំណត់ពីគុណ តម្លៃនៃជីវៈចម្រុះ និងការកំណត់អាទិភាពនៃកិច្ចអភិរក្សនៅតំបន់ព្រៃឡង់ កំណត់រកឲ្យឃើញពីកត្តាគម្រាមកំហែង និងធ្វើអនុសាសន៍សម្រាប់កាត់បន្ថយការគម្រាមកំហែងទាំងនេះ។

ការអង្កេតស្រាវជ្រាវនេះផ្តោតជាសំខាន់ទៅលើរុក្ខជាតិ ថនិកសត្វ (ដោយរួមមានទាំងការសិក្សាជាពិសេសទៅលើសត្វប្រចៀវ) សត្វស្លាប ថលជលិក និងឧរង្គសត្វ។ ក្រុមការងារស្រាវជ្រាវបានធ្វើការកត់ត្រានូវភស្តុតាងនៃវត្តមានរបស់ប្រភេទសត្វនិងរុក្ខជាតិទាំងនេះ ដោយការប្រើប្រាស់ម៉ាស៊ីនថតរូបស្វ័យប្រវត្ត (អន្ទាក់កាមេរ៉ា) អន្ទាក់សំណាញ់ អន្ទាក់រាំង ការសង្កេតដោយផ្ទាល់ភ្នែក និងការចាប់យកមកពិនិត្យជាក់ស្តែង។ ការអង្កេតដោយការសម្គាល់ភិនភាគសញ្ញា និងការធ្វើសម្ភាស ក៏ត្រូវបានអនុវត្តផងដែរ។ ការចុះធ្វើអង្កេតស្រាវជ្រាវដល់ទីកន្លែងនេះ មានបំណងប្រមូលចងក្រងលទ្ធផលស្រាវជ្រាវមានស្រាប់ ដែលត្រូវបានធ្វើរួចហើយនៅតំបន់នេះ និងបង្ហាញជូននូវលទ្ធផលដែលបានពីការគួបផ្សំឡើងពីទិន្នន័យបឋមនិងទិន្នន័យបន្ទាប់។ លទ្ធផលទាំងនេះរួមមានដូចខាងក្រោមៈ

## រុក្ខជាតិ

នៅក្នុងតំបន់ទេសភាពព្រៃឡង់មានប្រភេទព្រៃឈើ/ប្រភេទជម្រកចំនួន៨ខុសៗគ្នា។ ភាគច្រើននៃព្រៃឈើនេះ ត្រូវបានគ្របដណ្តប់ដោយព្រៃស្រោង ព្រៃរបោះ និងព្រៃពាក់កណ្តាលស្រោង ប៉ុន្តែការលាយចម្រុះនៃព្រៃរបោះ ព្រៃស្រល់និងស្លឹកធំចម្រុះ ព្រៃស្រោងជាំទឹក ព្រៃតាមដងទន្លេ និងវាលស្មៅក៏មាននៅទីនោះដែរ។ កំណត់ត្រារុក្ខជាតិសរុបនៅតំបន់ព្រៃឡង់មានចំនួន៥៣០ប្រភេទ ដែលរួមមានទាំងផ្កាអរគីដេប្រភេទ (Peristylus goodyeroides) ដែលជាកំណត់ត្រាថ្មីសម្រាប់ប្រទេសកម្ពុជា។ រុក្ខជាតិចំនួន១១ប្រភេទត្រូវបានចុះក្នុងបញ្ជីក្រហមថាជាប្រភេទដែលកំពុងទទួលរងការគម្រាមកំហែងដោយអង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) ។

ព្រៃជាំទឹកត្រូវបានចាត់ទុកជាប្រភេទព្រៃ ដែលមានលក្ខណៈដោយឡែកតែមួយគត់នៅក្នុងតំបន់ និងដែលមានប្រភេទសត្វនិងរុក្ខជាតិកម្រមានតែនៅទីនោះ និងរងគ្រោះជិតផុតពូជមួយចំនួន។

មានតំបន់តូចមួយនៃថ្មខ្ពស់ៗទម្រង់ស្រទាប់ថ្មកាស (karst) នៅដាច់ដោយឡែកនៅភាគខាងជើងនៃតំបន់ព្រៃឡង់ ដែលជាទីកន្លែងមួយផ្តល់ចំណាប់អារម្មណ៍និងការផ្តោតអារម្មណ៍ជាពិសេសដោយសារលក្ខណៈជីវសាស្ត្រដោយឡែករបស់វា។

ការរេចរឹលជម្រកធំៗកំពុងកើតមានឡើង ដែលភាគច្រើនបង្កឡើងដោយការប្រែក្លាយដីព្រៃទៅជាដីកសិកម្ម នៅក្រោមរូបភាពជាការផ្តល់ដីសម្បទានសេដ្ឋកិច្ច និងការប្រើប្រាស់ដីកសិកម្មខ្នាតតូច ការកាប់ព្រៃឈើ ការធ្វើចំណាកស្រុករបស់ប្រជាជនចូលមករស់នៅតំបន់ព្រៃ និងសកម្មភាពរុករករ៉ែមាស។

## ថនិកសត្វ

ថនិកសត្វសរុបចំនួន៦០ប្រភេទ ត្រូវបានរកឃើញតាមរយៈការសង្កេតដោយផ្ទាល់ ការប្រមូលសំណាក ឬតាមរយៈរូបភាពថតបានពីម៉ាស៊ីនថតរូបស្វ័យប្រវត្ត។ ក្នុងចំណោមប្រភេទថនិកសត្វទាំងនោះ មានសត្វប្រចៀវចំនួន២៨ប្រភេទ។ ថនិកសត្វ១៨ប្រភេទ ត្រូវបានបញ្ជាក់ថាមានការយកចិត្តទុកដាក់ជាអន្តរជាតិសម្រាប់ព្រៃឡង់ ក្នុងនោះសំខាន់បំផុតគឺ ទោចម្កុដ (Pileated Gibbon) ទន្សោង (Banteng) និងដំរី (Asian Elephant)។

## សត្វប្រចៀវ

សត្វប្រចៀវចំនួន២៨ប្រភេទដែលស្ថិតនៅក្នុង៦អំបូរ និងត្រូវបានកត់ត្រានៅក្នុងតំបន់ព្រៃឡង់តាងឱ្យយ៉ាងហោចណាស់មួយភាគបី (ស្មើនឹង២៨/៧១) នៃពពួកសត្វប្រចៀវដែលត្រូវបានស្គាល់នៅប្រទេសកម្ពុជា។ ថ្វីបើមានភាពពេញលេញនៃសារពើភណ្ឌសត្វប្រចៀវរហូតដល់ទៅ៨៦-៩២%ក្តី ក៏ការប្រមូលសំណាបន្តនឹងអាចរកឃើញប្រភេទសត្វប្រចៀវផ្សេងៗបន្ថែមទៀតនៅតំបន់នោះ។

ភោគទ្រព្យនិងភាពសម្បូរបែបនៃប្រភេទសត្វប្រចៀវ គឺភាគច្រើនមាននៅភាគខាងជើង ដែលមានរហូតដល់ទៅ១៥ប្រភេទនិងមាន៧៤%នៃចំនួនចាប់បានសរុប បន្ទាប់មកនៅភាគកណ្តាលមានចំនួន៨ប្រភេទនិងមាន១៤,៩%នៃចំនួនចាប់បានសរុប ហើយនិងនៅឯភាគខាងត្បូងមានចំនួន៨ប្រភេទនិងមាន១១,១%នៃចំនួនចាប់បានសរុប ។

ប្រភេទសត្វប្រចៀវទាំងអស់នៅតំបន់ព្រៃឡង់ ដែលបានកត់ត្រារួច គឺជាប្រភេទដែលអង្គការ IUCN (ឆ្នាំ២០១៤) បានចាត់ទុកថាជាប្រភេទប្រឈមនឹងការព្រួយបារម្ភតិចតួចប៉ុណ្ណោះ។ ប៉ុន្តែ ការសន្និដ្ឋានបែបនេះ អាចជាការយល់ច្រឡំ ពីព្រោះ បច្ចុប្បន្ន មានប្រចៀវជាច្រើនប្រភេទ ដែលគេពុំទាន់បានដឹងពីចំនួនរបស់វា (ការកំណត់ចំនួនសត្វប្រចៀវឱ្យស្ថិតក្រោមបន្ទាត់នៃប្រភេទក្នុងបញ្ជីក្រហម IUCN)។

ប្រចៀវមួយប្រភេទគឺ R. marshalli ដែលត្រូវបានប្រទះឃើញនៅតំបន់រូងថ្មទំរង់កាសភាគខាងជើងព្រៃឡង់ ជាកំណត់ត្រាថ្មីនៃប្រភេទសត្វប្រចៀវសម្រាប់ប្រទេសកម្ពុជា។

## សត្វស្លាប

សត្វស្លាបសរុបចំនួន២៦៦ប្រភេទ ដែលត្រូវបានកត់ត្រាក្នុងអំឡុងពេលអង្កេតស្រាវជ្រាវនេះ តាងឱ្យប្រមាណជា៤៩%នៃប្រភេទសត្វស្លាបសរុបដែលគេស្គាល់នៅក្នុងប្រទេសកម្ពុជា។ សត្វស្លាបបង្គោលចំនួន១៥ប្រភេទត្រូវបានបញ្ជាក់អះអាងថាមានៅក្នុងតំបន់ព្រៃឡង់។ សត្វស្លាបសំខាន់បំផុតនៃប្រភេទសត្វស្លាបបង្គោលទាំងនេះគឺ ទទាទ្រូងលឿង (Arborophila davidi) ក្ងោក (Pavo muticus), ត្រសេះធំប្រផេះ (Mulleripicus pulverulentus) កេងកងធំ (Buceros bicornis) ត្រដក់ធំ (Leptoptilos dubius) និងត្រដក់តូច (Leptoptilos javanicus)។ ថ្លុកត្រពាំងតាមរដូវកាល និងវាលស្មៅ នៅជុំវិញជម្រកព្រៃស្រោង និងជម្រកព្រៃរបោះ ត្រូវបានគេ រកឃើញថា អាចជួយទ្រទ្រង់ដល់ប្រភេទសត្វស្លាបមួយចំនួនដែលកំពុងរងការគម្រាមកំហែងទាំងនៅក្នុងតំបន់និងនៅលើសកលលោក ដូចជាត្រដក់តូច (Lesser Adjutant) និងសត្វកស ឬត្រុំ (Woolly-necked Stork)។ ជម្រកទាំងនេះ ទំនងជាមានសារៈប្រយោជន៍ខ្លាំងណាស់ចំពោះបក្សីទឹកធំៗ ដែលកំពុងរងការគម្រាមកំហែងជាសកល ហើយគួរតម្រូវឲ្យមានការអង្កេតស្រាវជ្រាវលម្អិតបន្ថែមទៀត។

គេក៏បានសង្កេតឃើញថាប្រភេទសត្វស្លាបដែលមានតែនៅក្នុងតំបន់ ឬមានតែនៅជិតតំបន់ក៏មាននៅព្រៃឡង់ដែរ ដូចជាមាន់ទោរប្រភេទ Lophura diardi ប៉ាកខៀវពោះបង្កង់ (Pitta elliottii) និងចាបដូនតាព្រៃចិញ្ចើមវែង (Alcippe grotei)។ ចំណែកសត្វស្លាបដែលរងការគម្រាមកំហែងក្នុងតំបន់មានដូចជាកេងកងធំ (Buceros bicornis) ព្រាំង (Aceros undulates) និងសត្វកស ឬត្រុំ (Ciconia episcopus)។

## ថលជលិក និងឧរង្គសត្វ

ថលជលិក-ឧរង្គសត្វ សរុបចំនួន៦៧ប្រភេទត្រូវបានកត់ត្រា ក្នុងនោះមានថលជលិកចំនួន២២ប្រភេទ (នៅក្នុង៥អម្បូរ និង១៤ពូក) និងឧរង្គសត្វមានចំនួន៤៥ប្រភេទ (នៅក្នុង១៤អម្បូរ និង៣៥ពូក)។ ដោយឡែក ឧរង្គសត្វមួយប្រភេទគឺតុកកែក្រាំងថ្ម (Gekko petricolus) ត្រូវបានគេប្រទះឃើញ ហើយវាជាកំណត់ត្រាថ្មីមួយសម្រាប់ប្រទេសកម្ពុជា។

ជាសរុប ថលជលិក-ឧរង្គសត្វចំនួន១១ប្រភេទត្រូវបានចុះក្នុងបញ្ជីក្រហមដោយអង្គការ IUCN ថាជាប្រភេទរងការគម្រាមកំហែង ក្នុងនោះអណ្តើកចំនួន៥ប្រភេទត្រូវបានកត់ត្រាថាជាប្រភេទប្រឈមនឹងការគម្រាមកំហែងធ្ងន់ធ្ងរបំផុតនៅតំបន់ព្រៃឡង់។

## ស្ថានភាពជារួម

តំបន់ទេសភាពព្រៃឡង់ នៅមានតំបន់ព្រៃឈើធំៗបំផុតមួយចំនួនរបស់ប្រទេសកម្ពុជា ដែលមិនស្ថិតនៅក្រោមការការពារជាផ្លូវការរបស់រដ្ឋាភិបាលឡើយ។ តំបន់នេះក៏ទំនងជាស្ថិតក្នុងចំណាត់ថ្នាក់ជាតំបន់ព្រៃមួយក្នុងចំណោមតំបន់សំខាន់ៗជាច្រើនទៀតនៃទំនាបព្រៃស្រោងក្នុងតំបន់ឥណ្ឌូភូមា ដែលជាតំបន់ជីវៈចម្រុះសំខាន់បំផុតមួយនៃតំបន់ទាំង១០នៅលើពិភពលោក ពោលគឺជាទីកន្លែងដែលមានភាពសម្បូរបែបផ្នែកជីវសាស្ត្រ និងរងការគម្រាមកំហែងបំផុតលើ ពិភពលោក។

ជារួម ព្រៃឡង់គឺជាទីជំរកសំរាប់សត្វចំនួន៥៥ប្រភេទដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជា និងនៅក្នុងតំបន់ ហើយសត្វទាំងនេះកំពុងរងនូវការគំរាមកំហែងជាសលក។ ជាពិសេស តំបន់នេះគឺជាទីកន្លែងដ៏សំខាន់សម្រាប់ការអភិរក្សសត្វស្លាបរបស់ប្រទេសកម្ពុជា និងជាទីជម្រកសម្រាប់សត្វ ៥៤%នៃប្រភេទ ទាំងអស់។

ព្រៃឡង់មានសក្តានុពលដ៏វិសេសវិសាល ក្នុងការទ្រទ្រង់ដល់ការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពសម្រាប់សហគមន៍ដែលពឹងផ្អែកលើព្រៃឈើ និងរួមវិភាគទានដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ តាមរយៈការនាំចេញអនុផលព្រៃឈើ (NTFP) និងការផ្តល់នូវប្រព័ន្ធអេកូឡូស៊ីដ៏មានសារៈសំខាន់ៗ។ ព្រៃឡង់គឺជាទីជម្រាលរបស់បឹងទន្លេសាប ដែលបម្រើសេចក្តីត្រូវការរបស់ប្រជាជនកម្ពុជារាប់លាននាក់ និងរួមចំណែកមួយភាគធំដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

**កត្តាគម្រាមកំហែង និងការផ្តល់អនុសាសន៍:**

ការល្បាតព្រៃនិងការអនុវត្តច្បាប់នៅមិនទាន់មានប្រសិទ្ធភាពនៅឡើយទេ ដែលជាហេតុនាំឲ្យមានការកើនឡើងនូវការចូលទន្ទ្រានដីព្រៃ ការតាំងទីលំនៅ ការកាប់ឈើ និងការបរបាញ់សត្វ ជាដើម។ និន្នាការទាំងនេះ បានបន្ថែមបន្ទុកទៅលើការអភិវឌ្ឍហេដ្ឋាចរនាសម្ព័ន្ធ និងការកែប្រែដីព្រៃ ទៅជាដីសម្រាប់ប្រកបរបរកសិកម្ម ជាហេតុធ្វើឲ្យខូចខាតដល់ធម្មជាតិព្រៃឈើ និងបង្កជាការគម្រាមកំហែងយ៉ាងខ្លាំងទៅលើប្រភេទសត្វបង្គោលភាគច្រើននៃថនិកសត្វធំៗ ថលជលិក-ឧរង្គសត្វ និង ប្រភេទសត្វស្លាបបង្គោលមួយចំនួនទៀត។ ក្រុមការងារអង្កេតស្រាវជ្រាវសូមផ្តល់អនុសាសន៍ជូនរាជ រដ្ឋាភិបាលកម្ពុជាដូចតទៅ:

➢ គួរផ្តួចផ្តើមឲ្យមានការការពារព្រៃឡង់ ដោយការកំណត់ថាជាតំបន់ព្រៃការពារដែលស្ថិតក្រោមការយកចិត្តទុកដាក់ខ្ពស់ នៅក្រោមអំណាចច្បាប់នៃប្រទេសកម្ពុជា និងធានាឲ្យមានរាល់កិច្ចខិតខំ

ប្រឹងប្រែង ដើម្បីដាក់បញ្ចូលតំបន់ទេសភាពព្រៃឡង់ជាតំបន់អាទិភាពខ្ពស់នៅក្នុងរបៀបវារៈស្តីពីការអភិរក្សនៅថ្នាក់ជាតិនិងអន្តរជាតិ។

➢គួរចាប់ផ្តើមបណ្តុះបណ្តាលនិងបំពាក់បរិក្ខាឲ្យបានភ្លាមៗទៅដល់ក្រុមល្បាតព្រៃ ដើម្បីអាចឲ្យពួកគេមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចាប់ផ្តើមអនុវត្តច្បាប់ ដើម្បីការពារសត្វព្រៃនិងជម្រកធម្មជាតិរបស់វា។ គួរបញ្ឈប់ជាបន្ទាន់នូវសកម្មភាពកាប់ឈើខុសច្បាប់ទាំងឡាយ និងការឈូសឆាយដីព្រៃដែលកំពុងកើតមាននៅទូទាំងតំបន់ព្រៃឡង់។

➢គួរបង្ការកុំឲ្យប្រជាជនធ្វើចំណាកស្រុកចូលមករស់នៅក្នុងតំបន់ទេសភាពព្រៃឡង់បន្ថែមទៀត ជាពិសេសអ្នកដែលចូលទៅរុករករ៉ែមាស នៅក្នុងតំបន់ភាគខាងត្បូងនៃព្រៃឡង់ និងនៅជុំវិញភ្នំជីក៏ដូចជានៅតាមបណ្តោយផ្លូវពីស្ទឹងត្រែងទៅត្បែងមានជ័យ។

➢គួរបង្ការកុំឲ្យមានការផ្តល់ដីសម្បទានសេដ្ឋកិច្ចណាមួយបន្ថែមទៀតនៅតំបន់ព្រៃឡង់ និងត្រូវត្រួតពិនិត្យឲ្យបានហ្មត់ចត់លើការអនុវត្តសកម្មភាពរបស់ក្រុមហ៊ុនសម្បទានសេដ្ឋកិច្ច និង ក្រុមហ៊ុនធ្វើអាជីវកម្មរុករករ៉ែទាំងអស់នៅក្នុងតំបន់ព្រៃឡង់។

➢គួរធ្វើការស្រាវជ្រាវលម្អិតបន្ថែមទៀត ដើម្បីវាយតម្លៃឲ្យបានត្រឹមត្រូវបន្ថែមទៀតអំពីស្ថានភាពរស់នៅរបស់សត្វព្រៃ របាយសត្វព្រៃ និងកត្តាគម្រាមកំហែងនានាទៅលើប្រភេទបង្គោលនៃសត្វព្រៃ និងដើម្បីអភិវឌ្ឍយុទ្ធសាស្ត្រសមស្របសម្រាប់ការអភិរក្សនិងត្រួតពិនិត្យ ជាពិសេសទៅលើទំនាស់ដែលអាចកើតមានរវាងសត្វដំរីនិងមនុស្ស។

➢គួរបង្កើតឲ្យមានកិច្ចសន្ទនាឲ្យបានល្អប្រសើរជាងមុនជាមួយភាគីពាក់ព័ន្ធទាំងអស់ទាក់ទងនឹងការអភិរក្សតំបន់ព្រៃឡង់ ក៏ដូចជាការចូលរួមចែករំលែកមូលដ្ឋានបទពិសោធជំនាញឲ្យបានទូលំទូលាយជាងនេះទៀត។ ការបើកឱកាសឲ្យមានការចូលរួមបែបនេះនឹងអាចបញ្ចៀស កុំឱ្យមានទស្សនៈយល់ថា ការខិតខំប្រឹងប្រែងក្នុងកិច្ចការអភិរក្សគឺជាភារកិច្ចដឹកនាំសម្រាប់តែអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការផ្នែកអភិរក្សតែឯកឯងប៉ុណ្ណោះ ក៏ដូចជាអាចផ្តល់ឱកាស ក្នុងការបង្កើនសមត្ថភាពលើការគ្រប់គ្រងតំបន់ព្រៃឡង់ឲ្យបានកាន់តែល្អប្រសើរឡើង។

➢គួរបង្កើតឲ្យមានយុទ្ធនាការផ្សព្វផ្សាយតាមសហគមន៍មូលដ្ឋាន និងការចងក្រងបណ្តាញផ្សព្វផ្សាយសង្គម ដើម្បីលើកកម្ពស់តម្រូវការបន្ទាន់ក្នុងការការពារតំបន់ព្រៃឡង់។

➢គួរអនុវត្តការអង្កេតស្រាវជ្រាវឲ្យបានទូលំទូលាយបន្ថែមទៀត នៅតាមតំបន់ទាំងឡាយណាដែលមិនទាន់បានទៅដល់ ក្នុងការសិក្សាស្រាវជ្រាវកន្លងមក ជាពិសេសនៅត្រង់ចំនុចភាគខាងលិចនៃតំបន់ព្រៃស្រោងភាគកណ្តាល។ គួរធ្វើការវាយតម្លៃទៅលើទំនាក់ទំនងរវាងជម្រកនិងច្រករបៀងឆ្លងកាត់នានារបស់សត្វព្រៃនៅតំបន់ព្រៃការពារព្រះវិហារ និងគួរកំណត់ផែនទីភូមិសាស្រ្តដែលមានលក្ខណៈពិសេសសម្រាប់សត្វព្រៃ ដោយរួមមានទាំងភូមិសាស្រ្តនៃទន្លេ ស្ទឹង ត្រពាំង និងទីកន្លែងសម្រាប់សត្វស្វែងរកចំណីជាដើម។

➢គួររៀបចំឲ្យមានការវាយតម្លៃពេញលេញទៅលើគុណតម្លៃនៃតំបន់ទីជម្រាលនៃព្រៃឡង់ និងគុណតម្លៃផ្នែកសេដ្ឋកិច្ចនៃតំបន់ព្រៃឡង់ចំពោះប្រទេសកម្ពុជា។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះការគាំទ្រពីសំណាក់ ឯកឧត្តមបណ្ឌិត ឆេង គឹមស៊ុន ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ លោកបណ្ឌិត កែវ អូម៉ាលីស ប្រធាននាយកដ្ឋានការពារសត្វព្រៃនិងជីវៈចម្រុះ លោក សៅ វណ្ណនី នាយខ័ណ្ឌរដ្ឋបាលព្រៃឈើ ប្រចាំខេត្តកំពង់ធំ។

យើងខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះការសម្រួលផ្តល់លទ្ធភាពក្នុងការចុះសិក្សាស្រាវជ្រាវដល់ទីកន្លែងពីសំណាក់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋសហគមន៍ព្រៃឈើក្នុងភូមិស្រែព្រីង ឃុំសុជាតិ និងភូមិក្រាំង ឃុំតាំងរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ; ភូមិសៀមបូក ខេត្តស្ទឹងត្រែង; ភូមិផ្លង់ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង; លោក ឡុង សំផាត មេឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ; ភូមិ ភ្វាក់រលឹក ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ; ភូមិស្តុង ឃុំអន្លង់ផៃ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង និងអ្នកស្រី ភោគ ហុង គណៈកម្មការសម្របសម្រួលព្រៃឡង់ ភូមិភ្វាក់រលឹក ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ។

សូមអរគុណជាពិសេសដល់ក្រុមការងារអង្កេតស្រាវជ្រាវនៅមូលដ្ឋាន ដែលរួមមាន លោក ឡា ប៉េងលី និងបុគ្គលិកសម្របសម្រួលនៃអង្គការអភិរក្សអន្តរជាតិ (CI), លោក យូ អៀងហួត, លោក ឈិន សុភា , លោក នាង ធី, លោក បេន ហាយេស (Ben Hayes), លោកជេរ៉េមី ហូលដិន (Jeremy Holden), លោកបណ្ឌិត នីល ហ្វូរ៉ៃ (Neil Furey)។ អរគុណផងដែរដល់អ្នកដែលបានចូលរួមពិនិត្យផ្ទៀងផ្ទាត់ និងផ្តល់ជាការណែនាំទូទៅ រួមមាន អ៊ីដា ថីឡេដ (Ida Theilade), ម៉ាកឃើស ហាតខេ (Marcus Hardtke), ដេវីដ អាស្សវេល (David Ashewell), ជោ វលស្តុន (Joe Walston), អាឡិច ឌីមិន (Alex Diment), ហ្វ្រេឌ្រិច ហ្គោស (Fredric Goes), ហូវី នេលសុន (Howie Nielson), ដេវីដ វ៉ារ (David Ware) និងបុគ្គលិកនៃអង្គការវីនរ៉កអន្តរជាតិ (Winrock International)។

សូមថ្លែងអំណរគុណដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) ដែលបានផ្តល់មូលនិធិសម្រាប់អនុវត្តគម្រោងទ្រទ្រង់ព្រៃឈើ និងជីវៈចម្រុះ។

រូបភាពទាំងអស់ដែលបានប្រើប្រាស់នៅក្នុងរបាយការណ៍វាយតម្លៃនេះ គឺជាកម្មសិទ្ធិរបស់លោកជេរ៉េមី ហូលដិន (Jeremy Holden) លើកលែងតែរូបភាពណាដែលមានបញ្ជាក់ឈ្មោះកម្មសិទ្ធិករផ្សេង។

# ពាក្យបំប្រួញ & អក្សរកាត់

| | |
|---|---|
| Asl | ស្ថិតនៅលើកម្រិតកម្ពស់ទឹកសមុទ្រ |
| c. | កម្រិតប្រហាក់ប្រហែល |
| CITES | សន្ធិសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វព្រៃជិតផុតពូជ |
| CI | អង្គការអភិរក្សអន្តរជាតិ |
| dbh | បន្ទាត់ផ្ចិតនៅកំម្ពស់ត្រឹមដើមទ្រូង (១៣០សម) |
| DAFF | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| DD | ពុំទាន់មានទិន្នន័យគ្រប់គ្រាន់ |
| FFI | អង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ |
| GPS | ប្រព័ន្ធគ្រប់គ្រងទីតាំងភូមិសាស្រ្ត |
| GT | វងការគម្រាមកំហែងជាសកល |
| GT-CR | វងការគម្រាមកំហែងជាសកល-ប្រភេទជិតផុតពូជបំផុត |
| GT-EN | វងការគម្រាមកំហែងជាសកល-ប្រភេទជិតផុតពូជ |
| GT-VU | វងការគម្រាមកំហែងជាសកល-ប្រភេទងាយរងគ្រោះ |
| GNT | កំពុងឈានទៅរងការគម្រាមកំហែងជាសកល |
| IUCN | អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ |
| Lao PDR | សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិកឡាវ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MoE | ក្រសួងបរិស្ថាន |
| NE | មិនទាន់វាយតម្លៃ |
| NP | ឧទ្យានជាតិ |
| NTFP | អនុផលព្រៃឈើ |
| Prey Lang | តំបន់ទេសភាពព្រៃឡង់ |
| PVPF | ព្រៃការពារខេត្តព្រះវិហារ |
| REDD+ | ការកាត់បន្ថយការបំភាយឧស្ម័នដោយសារការកាប់និងការសឹករេចរឹលនៃព្រៃឈើ |
| UTM | ចំនុចទីតាំងសកល |
| WCS | អង្គការសមាគមអភិរក្សសត្វព្រៃ |
| WWF | អង្គការមូលនិធិអភិរក្សសត្វព្រៃពិភពលោក |

# ការសន្មត

ឈ្មោះ និងការសរសេរតាមអក្ខរាវិរុទ្ធនៃភូមិ ទីកន្លែងនៅតាមតំបន់ដែលបានធ្វើការសិក្សាស្រាវជ្រាវនេះ ជាទូទៅផ្អែកតាមអ្វីដែលមាននៅក្នុងប្រភេទផែនទីសណ្ឋានដី ១:៥០.០០០។ ប្រសិនបើគ្មានឈ្មោះណាបង្ហាញ នៅក្នុងផែនទីទាំងនោះទេ នឹងមានការបកប្រែជាភាសាខ្មែរត្រង់ឈ្មោះហៅតាមតំបន់។

ប្រភេទសត្វនិងរុក្ខជាតិបង្គោលត្រូវបានវិនិច្ឆ័យថាជាប្រភេទជិតផុតពូជជាសកល ប្រភេទជិតផុតពូជបំផុតជាសកល ប្រភេទងាយរងគ្រោះជាសកល ប្រភេទកំពុងឈានទៅរងការគម្រាមកំហែងជាសកល ឬពុំទាន់មានទិន្នន័យគ្រប់គ្រាន់ ដោយផ្អែកតាមនិយមន័យរបស់អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) ឆ្នាំ២០១៥ (http://jr.iucnredlist.org/documents/redlist_cats_crit_en.pdf)

# ១. សេចក្តីផ្តើម

តំបន់ទេសភាពព្រៃឡង់ (ឬហៅថាព្រៃឡង់) មានទីតាំងស្ថិតនៅភាគខាងលិចនៃទន្លេមេគង្គ ចំភាគកណ្តាលនៃប្រទេសកម្ពុជា និងលាតសន្ធឹងលើខេត្តចំនួន៤គឺ ខេត្តក្រចេះ កំពង់ធំ ស្ទឹងត្រែង និងខេត្តព្រះវិហារ (សូមមើលផែនទី១)។ តំបន់នេះស្ថិតនៅលើទីជម្រាលចំនួន៣គឺ ទីជម្រាលស្ទឹងសែន ស្ទឹងជីនិត និងទីជម្រាលសៀមបូក និងឆ្លងកាត់ផ្លូវទឹកបែងចែករវាងបឹងទន្លេសាប និងអាងទន្លេមេគង្គ (សូមមើលផែនទី២)។ តំបន់នេះគឺជាផ្នែកមួយនៃតំបន់ដ៏ធំបំផុតនៃទំនាបព្រៃស្រោងក្នុងតំបន់ឥណ្ឌូភូមា ដែលជាតំបន់ជីវៈចម្រុះសំខាន់បំផុតមួយ ក្នុងចំណោមតំបន់ទាំង៣៤នៅលើពិភពលោក (Mittermeier, et al., 2004)។ McDonald (2004) បានពិពណ៌នាអំពីលក្ខណៈធំធេងនៃតំបន់ព្រៃឡង់ ដូចខាងក្រោម:

> ព្រៃទំនាបដ៏ធំមួយរបស់ប្រទេសកម្ពុជា បច្ចុប្បន្ននេះនៅសេសសល់តែត្រឹមខណ្ឌសីមាភាគខាងជើងនៃខេត្តកំពង់ធំ ដែលផ្នែកសំខាន់ៗជាងនេះលាតសន្ធឹងទៅទិសខាងត្បូង ចេញពីភូមិតូចមួយឈ្មោះភូមិស្តុង (រយៈទទឹង១៣° ៣០′ ឆ្ពោះទៅទិសខាងលិចនៃខេត្តស្ទឹងត្រែង នៅលើដងទន្លេមេគង្គ) ស្ថិតក្នុងស្រុកសណ្តាន់ និងស្រុកមានរិទ្ធ។ ប្រជាជនរស់នៅក្នុងតំបន់នេះកំណត់ថា ផ្នែកខ្ពស់ៗបំផុតនៃព្រៃឈើនេះថាជា "ព្រៃឡង់" និងផ្នែកផ្សេងៗទៀតនៃព្រៃនេះដែលស្ថិតនៅចម្ងាយជាង២០គីឡូម៉ែត្រទៅភាគខាងត្បូងនៃភូមិស្តុងថាជា "ព្រៃស្តុង"។

នៅក្នុងរបាយការណ៍វាយតម្លៃនេះ ព្រៃទាំងនេះគឺសំដៅដល់ព្រៃឡង់ ប៉ុន្តែពាក្យថាព្រៃឡង់នេះក៏មានរួមបញ្ចូលព្រៃនិងជម្រកនានា ដែលលាតសន្ធឹងទៅភាគខាងត្បូង និងភាគខាងជើងផងដែរ។

មិនមានការការពារជាផ្លូវការចំពោះតំបន់ទេសភាពព្រៃនេះទេ ហើយក៏គ្មានការកំណត់ឲ្យបានច្បាស់លាស់អំពីព្រំប្រទល់ដែនព្រៃឡង់នេះដែរ។ អនុក្រឹត្យមួយត្រូវបានរៀបចំឡើងដោយរដ្ឋបាល ព្រៃឈើនៃប្រទេសកម្ពុជា (FA) នៅឆ្នាំ២០០៨ ដោយបានចង្អុលបង្ហាញអំពីចំនុចខណ្ឌសីមាព្រៃឡង់ដូចដែលបានស្នើឡើង ដោយគ្របដណ្តប់លើផ្ទៃក្រឡាចំនួន៤៨០,០០០ហិកតា។ បើយោងតាម ការកំណត់ទំហំធំបំផុត (Ashwell et al., 2004) ព្រៃឡង់គ្របដណ្តប់លើផ្ទៃក្រឡា ប្រមាណជា ៥២០,០០០ ហិកតា។ ទោះជាយ៉ាងណា ស្ថានភាពព្រៃឡង់បានប្រែប្រួលយ៉ាងខ្លាំងនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ នៅទូទាំងតំបន់ទាំងអស់នៃព្រៃឡង់ ត្រូវទទួលរងនូវការសឹករេចរឹលទីជម្រកជាច្រើន ហើយនៅទីនោះទៀតសោតមិនមានការតភ្ជាប់ពេញលេញរវាងគម្របព្រៃឈើ ឬជម្រកសមស្រប និងព្រំប្រទល់ដែនដែលបានស្នើឡើងពីដំបូងនោះទេ។ នេះគឺជាចំនុចមួយគួរឱ្យកត់សម្គាល់បំផុតសម្រាប់តំបន់ភាគខាងត្បូងនិងភាគខាងជើងនៃតំបន់ព្រៃស្រោងភាគកណ្តាល (សូមមើលផែនទី ៣)។ ការតភ្ជាប់បណ្តាញរវាងជម្រកព្រៃឡង់ជាមួយនឹងតំបន់ដែនជម្រកសត្វព្រៃបឹងពារ ត្រូវបានកាត់ផ្តាច់រួចទៅហើយ។

ដីសម្បទានសេដ្ឋកិច្ចជាច្រើនកន្លែង ត្រូវបានចេញអាជ្ញាប័ណ្ណឲ្យដំណើរការនៅតាមបណ្ដោយព្រំដែនភាគខាងកើត និងនៅភាគខាងត្បូងនៃតំបន់ព្រៃឡង់ (សូមមើលផែនទី៨) ដែលដីព្រៃភាគច្រើនត្រូវបានប្រើប្រាស់ជាចម្ការដំណាំកៅស៊ូ។




ផែនទី 1 ទីតាំងភូមិសាស្ត្រតំបន់ព្រៃឡង់




ផែនទី 2 ការបែងចែកទីជម្រាលនៃតំបន់ព្រៃឡង់




ផែនទី 3 ការកាប់ព្រៃឈើនៅតំបន់ព្រៃឡង់ ចន្លោះឆ្នាំ២០០១-២០១១




ផែនទី 4 ការផ្តល់ដីសម្បទានសេដ្ឋកិច្ចនៅជុំវិញតំបន់ព្រៃឡង់ ឆ្នាំ២០១៣

មុននឹងឈានដល់ការវាយតម្លៃនេះ ការអង្កេតស្រាវជ្រាវជាច្រើនពីជីវៈចម្រុះត្រូវបានអនុវត្តឡើងនៅក្នុងតំបន់ព្រៃឡង់នេះ។ ភាគច្រើននៃការអង្កេតស្រាវជ្រាវទាំងនោះ បានប្រព្រឹត្តទៅ យ៉ាងឆាប់រហ័ស ហើយត្រូវបានធ្វើឡើងនៅចន្លោះឆ្នាំ២០០២-២០០៨ (សូមមើល Olsson & Emmett, 2007)។ រីឯការអង្កេតស្រាវជ្រាវបច្ចុប្បន្ននេះវិញ ត្រូវបានធ្វើឡើងនៅចន្លោះខែមិថុនា ឆ្នាំ២០១៤ និងខែកុម្ភៈ ឆ្នាំ២០១៥។ ការចុះសិក្សាស្រាវជ្រាវដល់ទីកន្លែងផ្តោតជាសំខាន់ទៅលើតំបន់ព្រៃស្រោង ជាមួយនឹងការយកចិត្តទុកដាក់តិចតួចប៉ុណ្ណោះនៅភាគខាងជើងនិងភាគខាងត្បូង (សូមមើលផែនទី ៥)។




ផែនទី 5 តំបន់ដែលត្រូវបានធ្វើអង្កេតស្រាវជ្រាវ

## គោលដៅ និងគោលបំណងនៃការធ្វើអង្កេតស្រាវជ្រាវ

ការអង្កេតស្រាវជ្រាវនេះមានគោលបំណងពិនិត្យមើលឡើងវិញទៅលើការយកចិត្តទុកដាក់ចំពោះជីវៈចម្រុះនិងការអភិរក្ស ក៏ដូចជាគុណតម្លៃនានានៃតំបន់ទេសភាពព្រៃឡង់ ជាមួយនឹងគោលដៅធ្វើយ៉ាងណាឲ្យទទួលបានការការពារជាផ្លូវការចំពោះតំបន់ទេសភាពនេះពីសំណាក់រាជរដ្ឋាភិបាល។ ដើម្បីសម្រេចបាននូវគោលបំណងនេះ រុក្ខជាតិ ថនិកសត្វ (រួមទាំងការសិក្សាជាក់លាក់ទៅលើសត្វប្រចៀវ) សត្វស្លាប ថលជលិក និងឧរង្គសត្វ ត្រូវបានសម្រិតសម្រាំងសម្រាប់ធ្វើប្រព័ន្ធចំណែកថ្នាក់សមស្រប ដោយធ្វើការងារជាមួយជីវវិទូនានា សំរាប់វត្ថុបំណងដូចខាងក្រោមៈ

- ដំណើរការអង្កេតស្រាវជ្រាវជាមូលដ្ឋានទៅលើរុក្ខជាតិ ថនិកសត្វ (រួមទាំងការសិក្សាជាក់លាក់ទៅលើសត្វប្រចៀវ) សត្វស្លាប ថលជលិក និងឧរង្គសត្វ នៅតាមជម្រកពាក់ព័ន្ធទាំងអស់នៅក្នុងតំបន់ទេសភាពព្រៃឡង់ និងបំពេញបន្ថែមលើការយល់ដឹងពីមុនទាក់ទងនឹងប្រព័ន្ធអេកូឡូស៊ីនៅតំបន់ទេសភាពនេះ។
- ប្រមូលព័ត៌មានលម្អិតបន្ថែមទៀតស្តីពីប្រភេទសត្វនិងរុក្ខជាតិ ដែលពិភពលោកកំពុងព្រួយបារម្ភក្នុងការអភិរក្ស។
- ផ្តល់អនុសាសន៍និងកំណត់អាទិភាពសម្រាប់ការអភិរក្សនៅតំបន់ទេសភាពព្រៃឡង់។
- វាយតម្លៃនិងបញ្ជាក់ពីកត្តាគម្រាមកំហែងដែលកំពុងបន្តកើតមាននៅតាមតំបន់ដែលត្រូវបានអង្កេតស្រាវជ្រាវ និងផ្តល់អនុសាសន៍សម្រាប់កែលម្អឲ្យបានល្អប្រសើរឡើងវិញ។

ដោយសារតែវិធីសាស្ត្រអនុវត្តមានលក្ខណៈខុសគ្នាទៅតាមប្រព័ន្ធចំណែកថ្នាក់ ទើបអ្នកចងក្រងរបាយការណ៍ បានពិពណ៌នាអំពីវិធីសាស្ត្រជាក់លាក់ក្នុងការអង្កេតស្រាវជ្រាវនេះជាជំពូកៗ។

## ចំនុចខ្វះខាតនៃការធ្វើអង្កេតស្រាវជ្រាវ

ការស្រាវជ្រាវនេះត្រូវបានធ្វើឡើងនៅក្នុងទម្រង់ជាការវាយតម្លៃឆាប់រហ័ស ទៅលើប្រព័ន្ធអេកូឡូស៊ីព្រៃឈើនៃតំបន់ទេសភាពព្រៃឡង់។ ដោយសារតែពេលវេលាមានកំណត់សម្រាប់ការសិក្សានៅក្នុងតំបន់ព្រៃដ៏ធំល្វឹងល្វើយ ទើបការស្រាវជ្រាវនេះត្រូវបានធ្វើឡើងតែនៅតំបន់ណាដែលគេបានស្គាល់ ឬសង្ស័យថាមានគុណតម្លៃជីវៈចម្រុះខ្ពស់។ បញ្ជីរាយឈ្មោះប្រភេទសត្វនិងរុក្ខជាតិដែលមាននៅក្នុងរបាយការណ៍នេះនៅខ្លីនៅឡើយទេ បើប្រៀបធៀបទៅនឹងចំនួននៃប្រភេទសត្វ និងរុក្ខជាតិ ប្រភេទខុសៗគ្នានៃជម្រក និងលក្ខណៈធម្មជាតិជាច្រើនទៀតដែលមាននៅតំបន់ទេសភាពនេះ។ ក៏នៅមានគំលាតព័ត៌មានមួយចំនួនដែរទាក់ទងនឹងរុក្ខជាតិ ដូចជាបាតុភូតក្នុងជីវិតរបស់វា សារៈប្រយោជន៍របស់វា

និងអេកូឡូស៊ីដែលវាចូលចិត្តរស់នៅ។ ដូច្នេះអ្វីដែលជាលទ្ធផលមាននៅក្នុងរបាយការណ៍វាយតម្លៃនេះគ្រាន់តែជាលទ្ធផល បឋមដែលបានរកឃើញជាក់ស្តែងតែប៉ុណ្ណោះ។ ទោះយ៉ាងណា ឈ្មោះតំបន់ និងជម្រកព្រៃដែលគេបានទៅឃើញជាក់ស្តែង នឹងអាចជាជំនួយដល់អ្នកស្រាវជ្រាវដទៃឲ្យបន្តធ្វើការសិក្សាឱ្យបានស៊ីជម្រៅបន្ថែមទៀត។ គេចាំបាច់ត្រូវខិតខំប្រឹងប្រែងសិក្សាអំពីផ្កាបន្ថែមទៀត ដើម្បីចងក្រងទុកជាឯកសារស្តីពីប្រភេទខុសៗគ្នាទាំងអស់នៅតំបន់ព្រៃឡង់ ដើម្បីជួយគាំទ្រដល់ការរៀបចំជាគោលនយោបាយ និងការស្វែងយល់ពីសក្តានុពលនៃគុណតម្លៃផ្នែកសេដ្ឋកិច្ចនៃតំបន់នេះ ដូចជាតាមរយៈការសិក្សាលើរុក្ខជាតិឱសថ និងការអភិវឌ្ឍផលិតផលដែលមិនប៉ះពាល់ដល់អេកូឡូស៊ីជាដើម។

ការសិក្សាទៅលើសត្វស្លាបត្រូវបានធ្វើឡើងតែក្នុងអំឡុងរដូវវស្សា (ខែមិថុនា និងខែតុលា) ហើយបានធ្វើតែម្តងគត់នៅដើមរដូវប្រាំង (កាលពីខែធ្នូ) ចំពេលដែលតំបន់ស្រាវជ្រាវភាគច្រើន នៅសើមប៉ប៉ាច់នៅឡើយ ជាហេតុមិនអាចទាញការសន្និដ្ឋានណាមួយបានអំពីរបាយសត្វស្លាបនៅក្នុង រដូវប្រាំងដែលមាននៅក្នុងតំបន់នេះ។ តំបន់ជាច្រើននៅក្នុងព្រៃឡង់ត្រូវបានរងការរំខានដោយសារសកម្មភាពរបស់មនុស្សរួចស្រេចទៅហើយ មុនពេលចាប់ផ្តើមការអង្កេតស្រាវជ្រាវយ៉ាងត្រឹមត្រូវ ទៅលើពពួកសត្វស្លាប ដូច្នេះគេចាំបាច់ត្រូវបន្តសិក្សារយៈពេលវែងបន្ថែមទៀត ដើម្បីបំពេញបន្ថែមលើភាពខ្វះចន្លោះក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលដោយសារការរំខាន ឬទម្លាប់នៃការរស់នៅរបស់សត្វទាំងនេះ។

# ២. រុក្ខជាតិ

លោក យូ អ៊ាងហួត

## សេចក្ដីផ្ដើម

ការស្រាវជ្រាវរុក្ខសាស្ត្រនៅប្រទេសកម្ពុជាបានត្រូវចាប់ផ្ដើម ជាលើកដំបូង ដោយរុក្ខវិទូជនជាតិបារាំងកាលពីឆ្នាំ១៩០៧ (Le compte et al.,1907- 1942)។ ក្រោយមកទៀត ការបោះពុម្ពផ្សាយពីរុក្ខជាតិនៃប្រទេសកម្ពុជា ឡាវ និងវៀតណាម នៅឆ្នាំ១៩៦០ (Flore du Cambodge, du Laos et du Viêt Nam) បានផ្ដល់ការពន្យល់ល្អិតល្អន់ពីអម្បូររុក្ខជាតិនៃប្រទេសកម្ពុជា ឡាវ និងវៀតណាម (ibid)។ នៅចន្លោះឆ្នាំ១៩៧០ និងឆ្នាំ១៩៧២ លោកស្រី ឌី ផុន ដែលជាប្រព័ន្ធចំណែកថ្នាក់វិទូកម្ពុជា (Cambodian taxonomist) បានធ្វើការ ស្រាវជ្រាវរុក្ខសាស្ត្រយ៉ាងទូលំទូលាយនៅក្នុងតំបន់ជាច្រើន ជាពិសេសនៅតំបន់ជួរភ្នំដំរី និងឧទ្យានជាតិគិរីរម្យ។ ការសិក្សាដំណុះរុក្ខជាតិ និងផ្ការុក្ខជាតិត្រូវបានអាក់ដំណើរការនៅរវាងឆ្នាំ១៩៧៥ និងឆ្នាំ១៩៩២ ដោយសារ ភាពចលាចលក្នុងប្រទេស។ ការស្រាវជ្រាវរុក្ខសាស្ត្របានចាប់ដំណើរការឡើងវិញតាំងពីឆ្នាំ១៩៩៣ ប៉ុន្តែ ការសិក្សានោះត្រូវបានធ្វើឡើងជារយៈៗ ទៅតាមគម្រោងរយៈពេលខ្លី (ដែលជាធម្មតាគួរមានរយៈពេលពី៣ទៅ៥ឆ្នាំ)។




ផែនទី 6 ប្រភេទព្រៃឈើនៅតំបន់ព្រៃឡង់ ទិន្នន័យរបស់ រដ្ឋបាលព្រៃឈើ ឆ្នាំ២០១០

ឧបសគ្គមួយក្នុងចំណោមឧបសគ្គនានាក្នុងការសិក្សាស្រាវជ្រាវរុក្ខសាស្ត្រ ប្រកបដោយ ចីរភាពនៅប្រទេសកម្ពុជា គឺកង្វះតិណាល័យជាតិ និងកង្វះរុក្ខវិទូ ដែលបានទទួលការបណ្ដុះបណ្ដាលត្រឹមត្រូវ។ ទើបតែនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ការស្រាវជ្រាវពីដំណុះរុក្ខជាតិ សត្វព្រៃ និងរុក្ខជាតិ ត្រូវបានធ្វើឡើងដោយស្ថាប័នអន្តរជាតិនានា ដោយសហការជាមួយក្រុមអ្នកស្រាវជ្រាវមកពីរដ្ឋបាលព្រៃឈើ។ ស្ថាប័នអន្តរជាតិសំខាន់ៗដែលបានដឹកនាំការស្រាវជ្រាវនេះ រួមមានសាកលវិទ្យាល័យនៃទីក្រុងក្យូប៉េនហាជិននៃប្រទេសដាណឺម៉ាក សាកលវិទ្យាល័យតិចសាសផេនអាមេរិកាំងនៃ

សហរដ្ឋអាមេរិក និងសាកលវិទ្យាល័យឈៀងម៉ៃនៃប្រទេសថៃ។

អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដែលពាក់ព័ន្ធនឹងការអភិរក្ស មានដូចជាអង្គការអភិរក្សអន្តរជាតិ (CI) អង្គការសត្វស្លាបអន្តរជាតិ (Birdlife International) និងទីភ្នាក់ងារផ្តល់ជំនួយផ្សេងៗទៀតដែលបានវិនិយោគ ដើម្បីស្វែងយល់អំពីសារៈសំខាន់នៃតំបន់ទំនាបព្រៃស្រោង ដែលនៅសេសសល់ចុងក្រោយក្នុងតំបន់ព្រៃឡង់នេះ។ លើសពីនេះទៅទៀត ការស្តុកកាបូននៅតំបន់ព្រៃឡង់ក៏ត្រូវបានគេធ្វើការគណនាផងដែរសម្រាប់ការពិចារណាក្នុងការអនុវត្តគម្រោងផ្តួចផ្តើមគំនិតស្តីពីរេដបូក (ការកាត់បន្ថយការបំភាយឧស្ម័នដោយសារការកាប់និងការសឹករេចរឹលនៃព្រៃឈើ)។ ថ្វីដ្បិតតែការស្រាវជ្រាវនេះ បានបង្ហាញពីលទ្ធផលគួរឱ្យកត់សម្គាល់អំពីភាពសម្បូរបែបនៃជម្រកព្រៃនិងរុក្ខជាតិក្តីក៏គេនៅតែរំពឹងថាមានប្រភេទសត្វ និងរុក្ខជាតិជាច្រើនទៀតដែលនៅមិនទាន់រកឃើញអស់នៅឡើយ។ ការគ្របដណ្តប់នៃប្រភេទព្រៃផ្សេងៗគ្នាដែលបានផ្សព្វផ្សាយដោយរដ្ឋបាលព្រៃឈើកាលពីឆ្នាំ ២០១០ មានបង្ហាញនៅក្នុងផែនទី៦។

## *វិធីសាស្ត្រស្រាវជ្រាវ*

ដើម្បីប្រមូលព័ត៌មានបន្ថែមឲ្យបានទូលំទូលាយនិងត្រឹមត្រូវជាងនេះ គេត្រូវអនុវត្តតាមជំហានដូចខាងក្រោម:

➢ការសិក្សាលើទិន្នន័យបន្ទាប់ និងការរៀបចំចងក្រងបញ្ជីសារពើភ័ណ្ឌប្រភេទសត្វនិងរុក្ខជាតិដែលត្រូវបានកត់ត្រានៅក្នុងតំបន់ព្រៃឡង់និងតំបន់ផ្សេងទៀត ដែលមានប្រភេទព្រៃស្រដៀងគ្នានេះដែរ។

➢ការពឹងផ្អែកលើការសិក្សាស្រាវជ្រាវពីមុន ដែលមានផែនទីប្រភេទព្រៃឈើនៅជុំវិញតំបន់ព្រៃឡង់ ជាពិសេសផ្អែកលើប្រភព Aruna (2009) និង Theilade et al., (2011b) ស្តីពីការជ្រើសរើសទីតាំងសម្រាប់ការសិក្សាស្រាវជ្រាវអំពីដំណុះរុក្ខជាតិ និងពពួករុក្ខជាតិ។

➢ការធ្វើសម្ភាសតាមទូរស័ព្ទជាមួយសមាជិកសហគមន៍ដែលរស់នៅក្នុងតំបន់ព្រៃឡង់ ដើម្បីៈ

- កំណត់ភាពងាយស្រួលនឹងចូលទៅដល់ទីតាំងដែលបានជ្រើសរើស សម្រាប់ការអង្កេតស្រាវជ្រាវ។
- បញ្ជាក់ផ្ទៀងផ្ទាត់ពីវត្តមាននៃប្រភេទជម្រកព្រៃនានានៅទីតាំងដែលបានជ្រើសរើសសម្រាប់ការអង្កេតស្រាវជ្រាវ។

➢ការចុះទៅពិនិត្យជាក់ស្តែងរបស់ក្រុមអ្នកស្រាវជ្រាវទៅដល់ទីកន្លែង មានរាយឈ្មោះនៅក្នុងតារាង១ ខាងក្រោម។

➢តំបន់ដែលត្រូវបានជ្រើសរើស បានបញ្ចូលទីតាំងជាតំណាងនៃប្រភេទជម្រកនីមួយៗខុសៗគ្នាទាំង៨ ដែលបានកំណត់ឃើញនៅក្នុងលទ្ធផលដែលបានបង្ហាញ។

➢ការបង្កើត និងការប្រើប្រាស់ទម្រង់បែបបទនៃការវាយតម្លៃអេកូឡូស៊ី និងចំណែកថ្នាក់នៃប្រភេទព្រៃដែលត្រូវធ្វើឡើងដោយការប្រើប្រាស់ទម្រង់មួយនេះ។
➢កិច្ចសហប្រតិបត្តិការជាមួយក្រុមអ្នកឯកទេសខាងប្រព័ន្ធចំណែកថ្នាក់ដែលបានរួមដំណើរជាមួយ ក្រុមអ្នកស្រាវជ្រាវទៅកាន់តំបន់នីមួយៗ ដើម្បីជួយផ្ទៀងផ្ទាត់ឈ្មោះប្រភេទសត្វនិង រុក្ខជាតិដែលបានប្រទះឃើញ។ ប្រសិនបើក្នុងករណីណាដែលក្រុមអ្នកឯកទេសស្គាល់ឈ្មោះប្រភេទសត្វនិងរុក្ខជាតិ ប៉ុន្តែក្រុមអ្នកស្រាវជ្រាវមិនស្គាល់ គេត្រូវតែកត់ត្រាសត្វនិងរុក្ខជាតិទាំងនោះទៅតាមឈ្មោះហៅតាមតំបន់ (ហៅតាមអ្នកស្រុក)។

ប៉ុន្តែយ៉ាងណាក៏ដោយ ស្ថានភាពនៃការអង្កេតស្រាវជ្រាវយ៉ាងឆាប់រហ័សបែបនេះ មិនអាចផ្តល់ពេលវេលាគ្រប់គ្រាន់ក្នុងការប្រមូលសំណាកផ្សេងៗ សម្រាប់ធ្វើការវិភាគបន្ថែមទៀតបានឡើយ។

តារាង 1 ទីតាំងអង្កេតស្រាវជ្រាវរុក្ខជាតិ

| ទីតាំងអង្កេតស្រាវជ្រាវ | ទីតាំងភូមិសាស្ត្រ | ចំណុចទីតាំងសកល UTM | កម្ពស់ អតិបរមា (គិតជាម៉ែត្រ) | ប្រភេទព្រៃឈើ |
|---|---|---|---|---|
| បឹងពារ | ភូមិស្តុង ឃុំអន្លង់ផែ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង | 0554733-1486690 | ៩០ ម | ព្រៃស្រោងជាំទឹក |
| អន្តរតំបន់នៃព្រៃជាំទឹកនិងព្រៃស្រោង | ភូមិស្តុង ឃុំអន្លង់ផែ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង | 0557774-1486625 | ១១៨ ម | ព្រៃស្រោងទាបៗ |
| ព្រៃស្រោង | ភូមិស្តុង ឃុំអន្លង់ផែ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង | 0555028-1486586 | ១២៦ ម | ព្រៃស្រោង |
| ចោមធំ | ជាប់ព្រំប្រទល់រវាងភូមិស្តុងនិងភូមិភ្វាក់រលឹក ឃុំធ្មា ស្រុកជ័យសែន ខេត្តព្រះវិហារ | 0553820-1587457 | ១២៩ ម | ព្រៃស្រោងជាំទឹក |
| អូរពោរុង | ភូមិភ្វាក់រលឹក ឃុំធ្មា ស្រុកជ័យសែន ខេត្តព្រះវិហារ | 0553570-1488025 | ១១០ ម | ដំណុះរុក្ខជាតិតាមមាត់ទឹក |
| ព្រៃភ្នំសសិត | ភូមិភ្វាក់រលឹក ឃុំធ្មា ស្រុកជ័យសែន ខេត្តព្រះវិហារ | 0553032-1492796 | ១២៣ ម | ព្រៃពាក់កណ្តាលស្រោង |

| | | | | |
|---|---|---|---|---|
| ព្រៃភ្នំសសិត | ភូមិភ្នាក់រលឹក ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ | 0552582-1493709 | ១២៣ ម | ព្រៃរបោះ |
| ព្រៃទទឹង | ភូមិផ្ទា ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ | 0549901-1500992 0549506-1500907 | ១៥៥ ម | ព្រៃរបោះចម្រុះ |
| ព្រៃទួលទទឹង | ភូមិផ្ទា ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ | 0549413-1500751 | ១១៧ ម | ព្រៃរបោះដែលសម្បូរដើមរាំងភ្នំ (Shorea siamensis) |
| អូរត្រាំជុំ | ភូមិផ្ទា ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ | 0549517-1500764 | ១០៣ ម | ដំណុះរុក្ខជាតិតាមមាត់ទឹក |
| អូរត្រាំជុំ | ភូមិផ្ទា ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ | 0548218-1501136 | ១១៦ ម | ព្រៃរបោះ |
| ទួលកូនដំរី | ភូមិផ្ទា ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ | 0550584-1504608 | ១៥៦ ម | ព្រៃរបោះ |
| ត្រពាំងរពក | ភូមិផ្ទា ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ | 0552470-1504563 | ១៥៥ ម | ស្រះទឹកដែលមានព្រៃរបោះ |
| អណ្តូងជីករករ៉ែមាសរបស់ចិន | ភូមិកំពង់ដំរី ឃុំបឹងចារ ស្រុកសម្បូរ ខេត្តក្រចេះ | 600953-1447287 | ៧១ ម | ព្រៃរបោះចម្រុះ |

| | | | | |
|---|---|---|---|---|
| វាលភ្នំដំបូកខ្ពស់ (តំបន់វាលស្មៅ) | ភូមិកំពង់ដំរី ឃុំបឹងចារ ស្រុកសម្បូរ ខេត្តក្រចេះ | 598510-1448122 | ៧៤ ម | តំបន់វាលស្មៅ |
| អូរឫស្សី | ភូមិកំពង់ដំរី ឃុំបឹងចារ ស្រុកសម្បូរ ខេត្តក្រចេះ | 597322-1447850 | ៦៦ ម | ដំណុះរុក្ខជាតិតាមមាត់ទឹក ប្រឡាយទឹកហូរតាមកាលកំណត់ |
| តំបន់នៅជាប់វាលហ្លួង | ភូមិកំពង់ដំរី ឃុំបឹងចារ ស្រុកសម្បូរ ខេត្តក្រចេះ | 596535-1448069 | ៦៨ ម | តំបន់វាលស្មៅ |
| វាលហ្លួង | ភូមិកំពង់ដំរី ឃុំបឹងចារ ស្រុកសម្បូរ ខេត្តក្រចេះ | 595864-1448246 | ៦៤ ម | តំបន់វាលស្មៅ |
| ព្រំប្រទល់រវាងវាលស្មៅ និងព្រៃពាក់កណ្តាលស្រោង | ភូមិកំពង់ដំរី ឃុំបឹងចារ ស្រុកសម្បូរ ខេត្តក្រចេះ | 595646-1448252 | ៧១ ម | តំបន់វាលស្មៅ |
| តាមផ្លូវទៅអូរក្រៃក | ភូមិកំពង់ដំរី ឃុំបឹងចារ ស្រុកសម្បូរ ខេត្តក្រចេះ | 590084-1449645 | ៨៥ ម | ព្រៃពាក់កណ្តាលស្រោង |
| អូរក្រៃក | ភូមិកំពង់ដំរី ឃុំបឹងចារ ស្រុកសម្បូរ ខេត្តក្រចេះ | 589746-1449181 | ៩២ ម | ដំណុះរុក្ខជាតិតាមមាត់ទឹក |
| ការិយាល័យក្រុមហ៊ុនចិនរុករករ៉ែមាសនៅដំបូកស | ភូមិកំពង់ដំរី ឃុំបឹងចារ ស្រុកសម្បូរ ខេត្តក្រចេះ | 601341-1446702 | ៧៧ ម | ព្រៃរបោះចម្រុះ |

| | | | | |
|---|---|---|---|---|
| អូរជន្ទល់ | ភូមិស្រែវាល ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ | 545741-1490979 | ១០៦ ម | ដំណុះរុក្ខជាតិតាមមាត់ទឹក |
| អូរស្វាយលាំង | ភូមិស្រែវាល ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ | 545692-1489883 | ៩៩ ម | ដំណុះរុក្ខជាតិតាមមាត់ទឹក |
| តំបន់វាលត្រពាំងរាំ | ភូមិស្រែវាល ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ | 545948-1489059 | ១២៤ ម | ព្រៃពាក់កណ្ដាលស្រោង |
| ចម្ការត្រពាំងរាំ | ភូមិស្រែវាល ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ | 546134-1488836 | ១២៨ ម | កសិដ្ឋាន |
| ត្រពាំងរាំ | ភូមិស្រែវាល ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ | 546615-1488483 | ១២៧ ម | តំបន់វាលស្មៅស្រះ |
| ព្រៃត្រពាំងរាំ | ភូមិស្រែវាល ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ | 548754-1487880 | ១៣៤ ម | ព្រៃស្រល់និងស្លឹកធំចម្រុះ |
| ព្រៃត្រពាំងរាំ | ភូមិស្រែវាល ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ | 548934-1488157 | ១៣៦ ម | ព្រៃស្រល់និងស្លឹកធំចម្រុះ |
| ប្រឡាយច្រឹក ភ្នំ១០០ | ភូមិផ្ទា ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ | 550120-1498479 | ១៣៩ ម | ព្រៃរបោះដែលសម្បូរដើមរាំងភ្នំ |
| ភ្នំក្លែងធំ | ភូមិផ្ទា ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ | 556247-1504536 | ១៥៣ ម | ព្រៃពាក់កណ្ដាលស្រោង |

| | | | | |
|---|---|---|---|---|
| ភ្នំក្លែងធំ | ភូមិផ្ចា ឃុំផ្ចា ស្រុកជ័យសែន ខេត្តព្រះវិហារ | 556195-1504878 | ១៥៩ ម | ព្រៃពាក់កណ្តាលស្រោង |
| ទឹកចេញ ប្រឡាយ ដំរីទុក | ភូមិផ្ចា ឃុំផ្ចា ស្រុកជ័យសែន ខេត្តព្រះវិហារ | 556104-1504972 | ១៥២ ម | ព្រៃពាក់កណ្តាលស្រោង |
| ភ្នំក្លែងធំ | ភូមិផ្ចា ឃុំផ្ចា ស្រុកជ័យសែន ខេត្តព្រះវិហារ | 555934-1504835 | ១៦១ ម | ព្រៃពាក់កណ្តាលស្រោង |
| តំបន់ជាប់ភ្នំក្លែងធំ | ភូមិផ្ចា ឃុំផ្ចា ស្រុកជ័យសែន ខេត្តព្រះវិហារ | 555293-1505238 | ១៨៤ ម | ព្រៃពាក់កណ្តាលស្រោង |

# លទ្ធផលស្រាវជ្រាវ

ការរកឃើញជារួម

មានការរួមចំណែកយ៉ាងច្រើនដល់មូលដ្ឋានចំណេះដឹងពីពពួករុក្ខជាតិនៅតំបន់ព្រៃឡង់ពី Mc Donald (2004), Olsson & Emmett (2007), Francke et al.,(មិនបានបោះពុម្ពផ្សាយ), Schmidt and Theilade (2010) និង Theilade et al., (2011)។ ផ្នែកនៃការរកឃើញជារួមនេះក៏បានមកពីការសិក្សាស្រាវជ្រាវទាំងអស់ពីមុនៗរបស់អ្នកទាំងនោះដែរ។

សរុបរុក្ខជាតិចំនួន១៥៣ប្រភេទ ដែលបានមកពីឯកសារមានស្រាប់ រួមមានទាំងរុក្ខជាតិខ្លះដែលមិនត្រូវបានស្គាល់ឈ្មោះផងទេ។ ការអង្កេតស្រាវជ្រាវបច្ចុប្បន្ននេះបានជួយបំពេញបន្ថែមលើតារាងរាយឈ្មោះដែលមានស្រាប់ តាមរយៈការធ្វើសម្ភាសនៅទីនោះ និងការអង្កេតស្រាវជ្រាវដល់ទីកន្លែង ដែលឃើញមានចំនួនរហូតដល់ទៅ៥៣០ប្រភេទ: ដើមឈើចំនួន១៩៨ប្រភេទ កូនឈើចំនួន៨៧ប្រភេទ រុក្ខជាតិវល្លិ៍៦៩ប្រភេទ រុក្ខជាតិពពួកស្មៅចំនួន៦៨ប្រភេទ ដើមឈើគុម្ពោតចំនួន៣៧ប្រភេទ វល្លិ៍ផ្លែចង្កោមចំនួន២០ប្រភេទ ពពួកត្នោតដូងចំនួន១៥ប្រភេទ បណ្ណង្គជាតិចំនួន១២ប្រភេទ រុក្ខជាតិជំពូកផ្សិតចំនួន៧ប្រភេទ រុក្ខជាតិពាក់កណ្តាលអេពីភីតចំនួន៧ប្រភេទ ឫស្សីចំនួន៣ប្រភេទ បញ្ញើក្អែកចំនួន២ប្រភេទ រុក្ខជាតិពពួកតយ ចំនួន២ប្រភេទ រុក្ខជាតិពពួកប្រង់ចំនួន១ប្រភេទ និងរុក្ខជាតិអេពីភីតចំនួន១ប្រភេទ (សូមមើលរូបភាព១ ខាងក្រោមនេះ)។




រូបភាព 1 ចំនួនប្រភេទរុក្ខជាតិនៅតំបន់ព្រៃឡង់

ផ្កាអ័រគីដេម្យ៉ាងដែលបានរកឃើញក្នុងអំឡុងពេលស្រាវជ្រាវ ដោយមានឈ្មោះថា Peristylus goodyeroides គឺជាកំណត់ត្រាថ្មីមួយសម្រាប់ប្រទេសកម្ពុជា។



រូបភាព 2 ផ្កាអ័រគីដេ **Peristylus goodyeroides** ដែលដុះនៅលើថ្មកំបោរនៃតំបន់ព្រៃឡង់

ព្រៃឡង់ គឺជាតំបន់ព្រៃមួយដែលត្រូវបានគេរកឃើញថាផ្ដុំឡើងដោយព្រៃចំនួន៨ប្រភេទ រួមមានព្រៃរបោះ ព្រៃរបោះចម្រុះ ព្រៃស្រល់និងស្លឹកធំចម្រុះ ព្រៃពាក់កណ្ដាលស្រោង ព្រៃស្រោងព្រៃស្រោងជាំទឹក ព្រៃតាមមាត់ទឹក និងវាលស្មៅចំហ។ ពាក្យបច្ចេកទេសនៃការពណ៌នាអំពីជម្រកព្រៃដែលត្រូវបានប្រើប្រាស់នៅក្នុងរបាយការណ៍នេះ គឺយកតាមប្រព័ន្ធចំណែកថ្នាក់ព្រៃរបស់ Rundel ឆ្នាំ ១៩៩៨។ ប៉ុន្តែ ពាក្យបច្ចេកទសក្នុងចំណែកថ្នាក់ព្រៃដែលបានប្រើដោយអ្នកស្រាវជ្រាវពីមុនៗនៅព្រៃឡង់ នឹងត្រូវបានចាត់ទុកថាត្រឹមត្រូវ។

ផ្នែកខាងក្រោមនេះ គឺជាការពណ៌នាអំពីប្រភេទជម្រកព្រៃនីមួយៗៈ

➢ **ព្រៃរបោះ**

ព្រៃរបោះនៅតំបន់ព្រៃឡង់ ត្រូវបានកំណត់និយមន័យដោយផ្អែកលើទម្រង់តែមួយគត់នៃស្រទាប់គម្របព្រៃចំហ លក្ខណៈស្លឹកជ្រុះនៅរដូវប្រាំង សំបូរទៅដោយប្រភេទដើមខ្លងត្បែងជ្រុះស្លឹកប្រចាំឆ្នាំ រុក្ខជាតិស្មៅតាមរដូវកាល ដែលរួមមានពពួកស្មៅពីរប្រភេទ គឺស្បូវ និងប្រភេទឫស្សីព្រិច ។ ដើមឈើពពួកខ្លុងត្បែងចំនួន៥ប្រភេទដែលរួមមាន *D. obtusifolius*, *D. tuberculatus*, *D. intricatus*, *Shorea obtusa* និង *S. siamensis* ដុះរាយប៉ាយពេញក្នុងព្រៃប្រភេទនេះ។ ដំបូកកណ្តៀរនិងស្រះទឹកមានពាសពេញប្រភេទនេះ និងអាចទ្រទ្រង់ដល់ជីវិតសត្វនិងរុក្ខជាតិជាច្រើន។ ជាធម្មតា ដំបូកកណ្តៀរគ្មានស្មៅដុះទេ ប៉ុន្តែឃើញមានដើម រុក្ខជាតិបៃតងរហូត និងរុក្ខជាតិវល្លិ៍ជាច្រើនប្រភេទ។ ស្រះទឹកភាគច្រើនគឺជាប្រភេទស្រះដែលមានទឹកតាមរដូវកាល ពោលគឺមានទឹកតែនៅក្នុងរដូវវស្សាតែប៉ុណ្ណោះ ហើយចាប់ផ្តើមរីងស្ងួតទៅវិញពីខែវិច្ឆិកា ប៉ុន្តែស្រះទឹកធំៗមួយចំនួនមានទឹកជានិច្ច ដូច្នេះ ហើយស្រះទឹកទាំងនេះ គឺជាប្រភពទឹកដែលអាចបម្រើដល់សេចក្តីត្រូវការរបស់ពពួកសត្វ ព្រៃបាននារដូវប្រាំង។ ស្រះទឹកទាំងអស់ គឺជាកន្លែងដំណុះរុក្ខជាតិស្មៅដែលដុះក្នុងទឹកផងលើគោកផងជាច្រើនប្រភេទ។ បើយោងតាមកការសិក្សាស្រាវជ្រាវពីមុននិងបច្ចុប្បន្ន មានប្រភេទរុក្ខជាតិចំនួន១៩១ប្រភេទ ដែលក្នុងនោះមានរុក្ខជាតិបៃតងរហូតចំនួន១៨ប្រភេទ (សូមមើលត្រង់ឧបសម្ព័ន្ធ១)។

បើផ្អែកតាមទំរង់ធម្មជាតិរបស់រុក្ខជាតិ ដោយមិនរាប់បញ្ចូលនូវស្រទាប់ ដែលដុះផុតគេនោះ ព្រៃស្រោងអាចចែកចេញជាបីស្រទាប់គឺ ស្រទាប់គម្របព្រៃខាងលើ ស្រទាប់គម្របព្រៃខាងក្រោម និងស្រទាប់ព្រៃជាន់ក្រោម។

- *ស្រទាប់គម្របព្រៃខាងលើ:* រួមមានដើមឈើគ្រប់ប្រភេទទាំងអស់ដែលដុះនៅក្នុងព្រៃនេះ។ កម្ពស់អតិបរមាជាមធ្យមនៃដើមឈើទាំងនេះ គឺប្រហែល១៥ម៉ែត្រ រីកម្ពស់អប្បបរមាជាមធ្យមចាប់ពីប្រហែល៨ម៉ែត្រ ទៅ១២ម៉ែត្រ។ ប្រភេទដើមឈើព្រៃរបោះតួយ៉ាង ដែលត្រូវបានកត់ត្រានៅក្នុងប្រភេទព្រៃនេះ រួមមានដើមរាំងភ្នំ (Shorea siamensis, Dipterocarpaceae), ដើមឈ្លិច (Terminalia alata, Combretaceae), ដើមខ្វាវ (Haldina cordifolia, Rubiaceae), ដើមធ្នឹក (Shorea obtuse, Dipterocarpaceae), ដើមប្រាំដំឡឹង (Terminalia mucronata, Combretaceae), ដើមរកា (Bombax anceps, Malvaceae), ដើមសម្រាំង - វេញខ្សែ (Sterculia villosa, Malvaceae), ដើមសុក្រម (Xylia xylocarpa, Mimosoideae), ដើមផ្លូធំ (Dillenia ovate, Dilleniaceae), ដើមរលាយតូច (Lasianthus hirsutus, Rubiaceae), និងដើមត្រាច (Dipterocarpus intricatus, Dipterocarpaceae)។ ប្រភេទដើមឈើព្រៃស្រោងមួយចំនួន ដុះលូតលាស់ជាមួយប្រភេទដើមឈើព្រៃរបោះដទៃទៀតនៃប្រភេទព្រៃឈើនេះដែរ រួមមាន ដើម

លាំងជ័យស្លឹកធំ (Buchanania reticulate, Anacardiaceae), ដើមស្គុកស្គុល (Petes thorelii, Euphorbiaceae), ដើមចំបក់ (Irvingia malayana, Irvingiaceae), ដើមព្រីងបាយ (Syzygium fruticosa, Myrtaceae), ដើមស្គុកស្គុល (Walsura robusta, Meliaceae), ដើមធ្លក (Parinari anamensis, Chrysobalanaceae) និងដើមត្រយឹង (Diospyros pilosanthera, Ebenaceae)។ ប្រភេទដើមឈើមួយចំនួន មានកម្ពស់ខុសគ្នាច្រើន និងអាស្រ័យលើលក្ខខណ្ឌដី។ អ្វីដែលគួរកត់សម្គាល់នោះ គឺថាមានប្រភេទរុក្ខជាតិអេពីភីតជាច្រើន ច្រើនតែដុះតោងលើដើមឈើធំៗ មានដូចជាអរគីដេ និងបណ្ណង្គជាតិ។

- *ស្រទាប់គម្របព្រៃខាងក្រោម:* រួមផ្សំពីកូនរុក្ខជាតិឬកូនឈើតូចៗ ពពួកដូងត្នោត និងចុលព្រឹក្ស ដែលមានកម្ពស់ខុសៗគ្នាចាប់ពីរង្វង់២ម៉ែត្រទៅ៦ម៉ែត្រ ហើយកម្រមានកម្ពស់លើសពីនេះណាស់ ដោយភាគច្រើនគឺជាប្រភេទរុក្ខជាតិជ្រុះស្លឹកប្រចាំឆ្នាំ ប្រភេទដើមឈើស្រោងដែលច្រើនដុះលូតលាស់នៅក្នុងប្រភេទព្រៃនេះ រួមមានដើមបាយក្តាំង (Gardenia philastrei, Rubiaceae), ដើមអាចម៍សត្វ (Brownlowia emarginata, Malvaceae), ដើមក្រុមពួក (Randia uliginosa, Rubiaceae), ដើមកណ្តោល (Careya arborea, Lecythidaceae), ដើមគ្រុងសមុទ្រ (Aporosa octandra, Phyllanthaceae), ដើមញ្ញូតូច (Morinda coreia, Rubiaceae), ដើមកន្ទួតព្រៃ (Phyllanthus emblica, Phyllanthaceae), ដើមភ្លូ (Dillenia parviflora, Dilleniaceae), ដើមអំពុកភ្លើង (Dioecrescis erythroclada, Rubiaceae), ដើមអំពុកស (Tamilnadia uliginosa, Rubiaceae), ដើមពិកា (Oroxylum indicum, Bignoniaceae) និងដើមរៀង (Randia tomentosa, Rubiaceae)។

- *ស្រទាប់ព្រៃជាន់ក្រោម:* សំដៅទៅលើរុក្ខជាតិទាំងឡាយណាដែលដុះជាប់នឹងដីក្នុងកម្ពស់ប្រហែលជាពីរម៉ែត្រពីកម្ពស់ដី។ រុក្ខជាតិប្រភេទនេះ គឺតាងដោយ ប្រភេទរុក្ខជាតិជាច្រើន នៃប្រភេទជ្រុះស្លឹកប្រចាំឆ្នាំតូចៗ មានសភាពជារុក្ខជាតិស្លឹកជី ចុលព្រឹក្សធំៗ ចុលព្រឹក្ស បណ្ណង្គជាតិទាបៗជាប់ដី ប្រង់ ពពួកដូងត្នោត និងកូនរុក្ខជាតិទើបដុះជាដើម។ ប្រភេទរុក្ខជាតិដែលតំណាងឱ្យស្រទាប់នេះរួមមានស្បូវ (Imperata cylindrical, Gramineae) ព្រិច (Vietnamosasa pusilla, Gramineae)។ ចំពោះប្រភេទដទៃទៀតដែលមានដុះនៅក្នុងព្រៃប្រភេទនេះ មានដូចជាបាយញេញឈ្មុល (Melastoma villosum, Melastomataceae), ទន់ដៃ (Droogmansia godefroyana, Papilionoideae), ផ្លូបាត (Dillenia hookeri, Dilleniaceae), ដូងព្រះឬដូងទន្សាយ (Phoenix loureiri, Palmae), ចាហ្វួយ (Curcuma petiolata, Zingiberaceae), ព្រោះ (mem) (Kaempferia galangal, Zingiberaceae), តាថុក (Costus speciosus, Zingiberaceae), ទាល់ (Amorphophallus harmandii, Araceae), និងប្រាងព្រៃ (Cycas siamensis, Cycadaceae)។

ប្រភេទរុក្ខជាតិវល្លិ៍ដែលដុះជាទូទៅនៅក្នុងប្រភេទ ព្រៃនេះរួមមានក្លិនទា (Harrisonia perforate, Simaroubaceae), អង្រ្គង (Ziziphus cambodiana, Rhamnaceae), វល្លិ៍ចារ (Butea superba, Papilionoideae), សង្កៀ (Ziziphus oenopolia, Rhamnaceae), វល្លិ៍ដោះគុណ (Tetracera loureiri, Dilleniaceae) និងវល្លិថ្មឹង (Aganonerion polymorphum, Apocynaceae)។

ប្រភេទសខុសៗគ្នានៃដើមឈើព្រៃរបោះចាប់ផ្ដើមជ្រុះស្លឹកពីខែធ្នូដល់ខែមីនា ហើយគ្រប់ចំណែកនៃប្រភេទរុក្ខជាតិនានាចាប់ផ្ដើមងាប់ជាបន្តបន្ទាប់ក្នុងអំឡុងពេលជាមួយគ្នានេះដែរ។ បន្ទាប់ពីជ្រុះស្លឹកអស់ទៅ ដើមឈើទាំងនោះមួយចំនួនចាប់ផ្ដើមលាស់ស្លឹកភ្លាមៗវិញ ប៉ុន្តែមួយចំនួនទៀតនៅមិនទាន់អាចលូតលាស់នៅឡើយទេ។ ចំណែកនៅលើផ្នែករុក្ខជាតិណាដែលងាប់ត្រូវបានគ្របដណ្ដប់ដោយស្លឹកនិងមែករបស់ដើមឈើជ្រុះលើ បង្កើតបានជាប្យូម៉ាស (ជីវម៉ាស់) ដែលងាយនឹងបង្កជាភ្លើងឆេះព្រៃនៅរដូវប្រាំង។ ជាមួយនឹងភ្លើងឆេះព្រៃប្រចាំឆ្នាំ ដើមឈើព្រៃរបោះអាចធន់ទ្រាំនឹងកម្ដៅភ្លើងបាន ហើយនៅតែអាចរក្សាទម្រង់ព្រៃរបស់ខ្លួនបាន។ អគ្គិភ័យនេះមិនអាចសម្លាប់ដើមឈើ ដែលមានអាយុកាលយូរឆ្នាំ ចុលព្រឹក្ស ឬរុក្ខជាតិវល្លិ៍នានាបានទេ ដោយហេតុថាប្រភេទដើមឈើទាំងនេះមានសម្បកក្រាស់ដែលអាចធន់ទ្រាំទៅនឹងកម្ដៅភ្លើងបាន។ ទោះយ៉ាងណា ប្រសិនបើមានគំនរប្យូម៉ាសកាន់តែច្រើនទៅៗក្នុងរយៈពេលជាច្រើនឆ្នាំបន្តបន្ទាប់ ហើយចៃដន្យមានភ្លើងឆេះព្រៃធ្ងន់ធ្ងរកើតឡើង នោះដើមឈើដែលមានអាយុកាលយូរឆ្នាំ អាចនឹងត្រូវរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារភ្លើងឆេះសន្ធោសន្ធៅខ្លាំងពេក ហើយទីបំផុតអាចបណ្ដាលឲ្យដើមឈើទាំងនោះងាប់អស់តែម្ដង។ កូនរុក្ខជាតិដែលដុះឡើងវិញពីឫស បណ្ដុលគល់ និងគ្រាប់ត្រូវរងផលប៉ះពាល់យ៉ាងខ្លាំង ដោយសារកម្ដៅភ្លើង ដែលធ្វើឱ្យពពួកកូនរុក្ខជាតិទាំងនេះពិបាកក្នុងការរីកលូតលាស់ទៅជាដើមឈើដែលមានទំហំធំបាន។ ត្រង់ចំនុចនេះ គេអាចពន្យល់បានអំពីថាតើមកពីមូលហេតុអ្វីទើបបានជាព្រៃរបោះ ជាទូទៅឃើញមានដុះដើមឈើនិងរុក្ខជាតិ និងចុលព្រឹក្សរាយប៉ាយចន្លោះៗគ្នាដូច្នេះ។

រុក្ខជាតិស្មៅទាំងអស់បានចាប់ផ្ដើមដុះលូតលាស់ពីមើមឫសរបស់វា ហើយភាគច្រើនបំផុតនៃដើមឈើឬកូនរុក្ខជាតិតូចៗ ចុលព្រឹក្ស និងរុក្ខជាតិស្មៅចាប់ផ្ដើមរីកលូតលាស់ពេញទំហឹងស៊ីបទ្រុបនៅដើមរដូវវស្សា ចាប់ពីខែមេសាដល់ខែមិថុនា។ ហេតុនេះហើយបានជានៅក្នុងរដូវវស្សា សត្វព្រៃ ជាពិសេសថនិកសត្វធំៗនិយមចូលចិត្តរស់នៅក្នុងព្រៃរបោះ ដោយសារតែសម្បូរទៅដោយចំណីអាហារ។ គេបានកត់សម្គាល់ឃើញថាមិនត្រឹមតែមានស្មៅសម្រាប់ជាចំណីរបស់ថនិកសត្វប៉ុណ្ណោះទេ ប៉ុន្តែក៏មានផ្លែឈើនៃប្រភេទដើមឈើហូបផ្លែមួយចំនួនផងដែរ ដូចជាដើមកន្ទួតព្រៃ (Phyllanthus emblica), ដើមស្រម៉ (Terminalia chebula) និងដើមចំបក់ (Irvingia malayana) ដែលសុទ្ធសឹងជាប្រភពអាហារដ៏សំខាន់ ជាពិសេសសម្រាប់ប្រភេទសត្វក្ដាន់។

ភាគច្រើននៃព្រៃរបោះ ច្រើនមានដុះនៅក្នុងតំបន់ទំនាប ហើយច្រើនតែហ៊ុំព័ទ្ធទៅដោយតំបន់លំនៅដ្ឋាន ដែលជាទូទៅតំបន់ព្រៃទាំងនេះត្រូវរងការគម្រាមកំហែងដោយសារការកាប់ឆ្ការយកដីព្រៃធ្វើជាចម្ការដាំដុះពីក្រុមអ្នកភូមិ និងគម្រោងកសិកម្មទ្រង់ទ្រាយធំជាងនេះ។ លើសពីនេះទៅទៀត ព្រៃប្រភេទនេះក៏មានប្រភេទឈើប្រណីតមួយចំនួនផងដែរ ដែលត្រូវបានគេកាប់យកអស់ជាច្រើនរួចទៅហើយ។ បច្ចុប្បន្នមានប្រភេទឈើប្រណីតដូចជា គ្រញូង (D. cochinchinensis), នាងនួន (D. olivery), ថ្នង់ (P. macrocarpus), កកោះ (Sindora. Siamensis) និងបេង (Afzelia xylocarpa) ត្រូវបានគេកាប់យកយ៉ាងច្រើនហួសប្រមាណសម្រាប់ធ្វើជាជំនួញយកផលចំណេញ។ ប្រភេទឈើ ប្រណីតទាំងនេះត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទឈើជិតផុតពូជ។ ភាគច្រើននៃប្រភេទឈើទាំងនេះច្រើនត្រូវគេគាស់រំលើងយកទាំងគល់ទាំងឬសតែម្តង ប៉ុន្តែប្រសិនបើកាប់តែត្រឹមគល់ វាអាចនឹងដុះពន្លកចេញពីគល់នោះវិញបាន។

➢ **ព្រៃរបោះចម្រុះ**

ព្រៃរបោះចម្រុះ ត្រូវបានសម្គាល់ដោយភាគរយទាបនៃដើមឈើព្រៃរបោះច្រើនប្រភេទ ឬគ្មានប្រភេទដើមឈើខ្លួងត្បែងដុះនៅតាមតំបន់មួយចំនួន។ លោក Rollet (1952, 1962, 1972) បានសិក្សាស្រាវជ្រាវទៅលើប្រភេទព្រៃនេះ នៅជិតខេត្តសៀមរាប និងបុបលុក ហើយត្រូវបានហៅជាភាសាបារាំងថា: *ព្រៃរបោះដ៏ស៊ុបទ្រុប* (forêst denses décidues)។ លោកម៉ាទីន (ឆ្នាំ១៩៧៣) បានធ្វើការសិក្សាស្រាវជ្រាវទៅលើដំណុះរុក្ខជាតិនៅតាមជម្រាលភ្នំទាបៗនៃតំបន់ជួរភ្នំក្រវាញ ភាគខាងជើង និងបានហៅព្រៃ នេះថាជា *ព្រៃរបោះដ៏ក្រៀមក្រោះ*។ ប្រភេទដើមឈើនៃស្រទាប់គម្របព្រៃខាងក្រោម និងស្រទាប់ព្រៃជាន់ក្រោមសំបូរទៅដោយប្រភេទដើមឈើ របោះដែលជ្រុះស្លឹកនៅក្នុងរដូវប្រាំង។ ប្រភេទរុក្ខជាតិវល្លិ៍តោងឡើងមានចំនួនតិចតួចណាស់ និងមានតែប្រភេទមួយចំនួនតែប៉ុណ្ណោះ។ រុក្ខជាតិស្មៅនៅក្នុងប្រភេទព្រៃនេះ គឺស្រដៀងគ្នាទៅនឹងតិណជាតិដែលមាននៅក្នុងព្រៃរបោះដែរ ប៉ុន្តែមានចំនួនតិចជាង។ ជាធម្មតាភ្លើងឆេះព្រៃច្រើនកើតមាននៅក្នុងប្រភេទព្រៃនេះ នៅត្រឹមកម្រិតទាបប៉ុណ្ណោះ។ ផ្អែកលើការសង្កេតជាក់ស្តែងដែលត្រូវបានធ្វើនៅតំបន់មួយចំនួន ជាទូទៅ ព្រៃរបោះចម្រុះច្រើនដុះនៅតំបន់ដែលទាបៗនៃព្រៃឡង់ តំបន់ដីដែលសម្បូរដោយល្បាយខ្សាច់ ឬដីឥដ្ឋ។ តំបន់ចំនួនពីរនៅព្រៃទទឹងនិងអូរត្រាំកង់ និងតំបន់ឯទៀតនៅជុំវិញនោះ ដែលមានទីតាំងស្ថិតនៅភាគខាងត្បូងនៃភូមិផ្លា ឃុំផ្លា ស្រុក ជ័យសែន ខេត្តព្រះវិហារ សុទ្ធសឹងជាទីដែលតំណាងឲ្យ ព្រៃរបោះចម្រុះ។ ព្រៃសហគមន៍ចំនួនពីរគឺ ព្រៃក្រោមនិងព្រៃក្រឡាពាស និងតំបន់ឯទៀតដែលនៅជុំវិញ ដែលមានទីតាំងស្ថិតនៅក្នុងឃុំព្រះរំកិល ស្រុកថាឡាបរិវ៉ាត់ នៅភាគឦសាននៃព្រៃឡង់ក៏ជាទីដែលគ្របដណ្តប់ដោយប្រភេទព្រៃនេះផងដែរ ហើយបើនិយាយពីសមាសភាពនិងរចនាសម័ន្ធព្រៃវិញ គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងព្រៃដែលមាននៅក្នុងភូមិផ្លាដែរ។ ក្រុមអ្នកស្រាវជ្រាវ ក៏បានសង្កេតឃើញថាមានព្រៃរបោះចម្រុះ នៅក្នុងព្រៃសហគមន៍ពូក្រូច ក្នុងខេត្តមណ្ឌលគីរីផងដែរ។ ប្រភេទព្រៃឈើនេះ ដុះឡើងនៅក្នុងទំហំខុសៗ

គ្នាពីតូចទៅធំ ហើយដុះនៅរួមជាមួយប្រភេទព្រៃរបោះ ទោះបីជាពេលខ្លះវាដុះនៅតាមតំបន់ចន្លោះរវាងព្រៃរបោះនិងព្រៃពាក់កណ្តាលស្រោង ឬចន្លោះរវាងព្រៃរបោះនិងព្រៃតាមមាត់ទឹកក្តី។ រចនាសម្ព័ននៃព្រៃប្រភេទនេះ ក៏អាចស្ថិតនៅចំពាក់កណ្តាលរវាងព្រៃរបោះនិងព្រៃពាក់កណ្តាលស្រោង ដូច្នេះហើយទើបគេពិបាកញែកឲ្យបានច្បាស់លាស់ពីភាពខុសគ្នារវាងព្រៃទាំងពីរនេះណាស់។ ដោយសារមូលហេតុនេះ ទើបបានជាផែនទីគំនូសព្រាងនៃប្រភេទព្រៃឈើនេះមិនអាចមានភាពច្បាស់លាស់ទេលុះត្រាតែធ្វើការស្រាវជ្រាវជាក់ស្តែង តាមរយៈការពិនិត្យផ្ទៀងផ្ទាត់ បូករួមនឹងរូបថតពីលើអាកាស ឬរូបភាពផ្កាយរណប ។ នេះអាចជាហេតុផលមួយដែលមិនឃើញគេរាប់បញ្ចូលប្រភេទព្រៃនេះនៅក្នុងផែនទីគម្របព្រៃឈើជាតិ ដែលបានផលិតដោយរដ្ឋបាលព្រៃឈើ ក្នុងឆ្នាំ២០១០ (ផែនទី៦)។ ជាសរុបរុក្ខជាតិ២០៥ប្រភេទ ត្រូវបានកត់ត្រានៅក្នុងលទ្ធផលនៃការអង្កេតស្រាវជ្រាវអំឡុងពេលនេះ និងពេលកន្លងមក ដែលរួមមានដើមឈើព្រៃស្រោងចំនួន២២ប្រភេទ តាងឱ្យប្រមាណជា១០,៧% នៃប្រភេទសរុបទាំងអស់ ដែលមាននៅក្នុងប្រភេទព្រៃរបោះចម្រុះនេះ (សូមមើលឧបសម្ព័ន្ធ១)។ ប្រភេទព្រៃឈើនេះត្រូវបានរួមផ្សំឡើងដោយព្រៃបីស្រទាប់គឺ ស្រទាប់គម្របព្រៃខាងលើ ស្រទាប់គម្របព្រៃខាងក្រោម និងស្រទាប់ព្រៃជាន់ក្រោម។ ដើមឈើខ្លះលូតលាស់ខ្ពស់ខ្លាំងជាងគេ ហើយក្លាយទៅជាស្រទាប់លយចេញទៅលើ។ ដើមឈើដែលមានអាយុកាលយូរឆ្នាំជាច្រើនដើម និងដើមឈើដែលមានសភាពទ្រុឌទ្រោម ជាធម្មតាដុះនៅចន្លោះរវាងគម្របព្រៃខាងលើ និងគម្របព្រៃខាងក្រោម ដូច្នេះហើយទើបនៅពេលខ្លះ វាបង្កើតបានជាស្រទាប់ដែលពិបាកសម្គាល់ណាស់ ។

- *ស្រទាប់គម្របព្រៃខាងលើ:* មានកម្ពស់ជាមធ្យមប្រមាណជា១៧ម៉ែត្រ។ គម្របព្រៃនេះ អាចប្រែប្រួលប្រមាណជា៦០-៨០% ដែលអាចឱ្យពន្លឺព្រះអាទិត្យចាំងប៉ះដល់ដីបាន។ ដើមឈើមានចំនួន៨០%នៃប្រភេទនេះ។ ប្រភេទសំខាន់ៗមួយចំនួនដែលតំណាងឱ្យស្រទាប់នេះមានដូចជា ដើមស្រឡៅ Kanhchhreab (Lagerstroemia-duperreana, Lythraceae), ដើមល្ហៅ (Dillenia pentagyna, Dilleniaceae), ដើមត្រាច (Dipterocarpus intricatus, Dipterocarpaceae), ដើមខ្វាវ (Haldina cordifolia, Rubiaceae), ដើមចំបក់ (Irvingia malayana, Irvingiaceae), ដើមស្វាយព្រៃ (Mangifera duperreana, Anacardiaceae), ដើមស្មាក្របីធំ/ដោះក្របី (Miliusa velutina, Annonaceae), ដើមពពិល (Shorea roxburghii, Dipterocarpaceae), ដើមសង្កួតត្នោត (Stereospermum cylindricum, Bignoniaceae) និងសុក្រំ (Xylia xylocarpa, Mimosoideae)។

- *ស្រទាប់គម្របព្រៃខាងក្រោម:* សំដៅដល់កូនដើមឈើតូចៗ ចុលព្រឹក្ស និងកូន រុក្ខជាតិនៅខ្ចីដែលមានកម្ពស់ចាប់ពី៣ទៅ៧ម៉ែត្រ។ ភាគច្រើននៃប្រភេទដើមឈើ ទាំងនេះ គឺជាប្រភេទដើមឈើព្រៃរបោះដែលជ្រុះរុះរោយស្លឹកនៅខែធ្នូ និងលាស់ស្លឹកខ្ចី និងផ្កានៅក្នុងខែមេសា និងខែ

ឧសភា។ ប្រភេទដើមឈើតំណាងឱ្យស្រទាប់នេះគឺមានដូចជា ដើមឆ្កែស្រែង (Cananga latifolia, Annonaceae), ដើមរំដួល (Melodorum fruticosum, Annonaceae), ដើមក្លែងគង់ (Wrightia pubescens, Apocynaceae), ដើមដកពោធិ៍ (Markhamia stipulacea, Bignoniaceae), ដើមហៃសាន (Senna garrettiana, Caesalpinioideae) និងដើមដៃខ្លា (Gardenia angkoreansis, Rubiaceae)។ គេកត់សម្គាល់ឃើញថាដើមដៃខ្លា (Gardenia angkoreansis) ច្រើនដុះនៅតាមផ្លូវទៅវាលហ្លួង ស្ថិតនៅក្នុងភូមិកំពង់ជំរី ឃុំបឹងចារ។

- *ស្រទាប់ព្រៃជាន់ក្រោម:* ជាធម្មតាមើលទៅមិនសូវជាស៊ុបទ្រុបទេ ដូច្នេះហើយបានជា វាមិនសូវកើតមានភ្លើងឆេះព្រៃខ្លាំងដូចព្រៃរបោះទេ។ នៅតាមកន្លែងខ្លះ ដែលពន្លឺ ព្រះអាទិត្យអាចចាំងឆ្លុះទៅដល់ដីបាន ច្រើនសម្បូរទៅដោយប្រភេទរុក្ខជាតិស្បូវយ៉ាងច្រើនស្មែកស្កុះ (Imperata cylindrical) ហើយពេលខ្លះមានដុះដើមឫស្សីគៀ/ឫស្សីព្រិច (Vietnamosasa pusilla) និងអម្បូរស្មៅកក់ (Cyperaceae)។ ចំណែកឯនៅតំបន់ដែលដីត្រូវពន្លឺព្រះអាទិត្យបានតិចតួច ដូចជានៅអូរត្រាំជំ ដែល ស្ថិតនៅគៀកប្រឡាយទឹក គេពុំឃើញមានស្បូវ និងឫស្សីគៀ ដុះនៅទីនោះទេ ប៉ុន្តែត្រូវ ដុះជំនួសដោយកូនឈើទើបដុះផ្សេងទៅវិញ។ ប្រភេទមួយចំនួនដែលបានកត់ត្រា រួមមាន តឺលធំ (Amorphophallus paeoniifolius, Araceae), ស្អែកក់ (Synedrella nodiflora, Compositae), តាធុក (Costus speciosus, Zingiberaceae), ផ្កាសរ (Globba cambodgensis, Zingiberaceae), ព្រោះ (mem) (Kaempferia galangal, Zingiberaceae) និងខ្ញីៃ (Zingiber zerumbet, Zingiberaceae)។

ប្រភេទរុក្ខជាតិវល្លិ៍តោងឡើងមានចំនួនតិចតួចប៉ុណ្ណោះនៅក្នុងប្រភេទព្រៃនេះ ហើយភាគច្រើនជាតំណាងឱ្យប្រភេទដើមឈើព្រៃរបោះ ដែលមានដុះជាញឹកញាប់នៅក្នុងតំបន់ព្រៃរបោះ។ ឧទាហរណ៍ មានដូចជា វល្លិ៍ចារ (Butea superba, Papilionoideae), ក្លែងពណ៌ (Bauhiniabracteata, Caesalpinioideae), ក្លិនទា (Harrisonia perforate, Simaroubaceae), ខ្សោះ (Getonia floribunda, Combretaceae), ផ្តៅក្រែក (Calamus viminalis, Palmae), ទំពាំងបាយជូរព្រៃ (Ampelocissus martini, Vitaceae) និងវល្លិស្លែង (Strychnos rupicola, Loganiaceae).

ប្រភេទរុក្ខជាតិអេពីភីត និងពាក់កណ្តាលអេពីភីតត្រូវបានតាងដោយ អរគីដេ សួតជំរី (Hydnophytum formicarium, Rubiaceae), ពុកមាត់ព្រះរាម (Platycerium wallichii, Polypodiaceae), ត្រចៀកជំរី (Hoya diversifolia, Asclepiadaceae) និងបញ្ញើក្អែក (Dendrophthoe pentandra, Loranthaceae)។

បើគិតពីតម្លៃសេដ្ឋកិច្ច ប្រភេទព្រៃឈើនេះ គឺសម្បូរទៅដោយប្រភេទឈើប្រណីត៤ប្រភេទគឺ នាងនួន (Dalbergia olivery), គ្រញូង (D. cochinchinensis), ធ្នង់ (Pterocarpus macrocarpus) និង បេង (Afzelia xylocarpa) និងប្រភេទឈើមានតម្លៃខ្ពស់ផ្សេងទៀត ពិសេសគឺឈើទាល (dipterocarp), ស្រឡៅ (lagerstroemia) និងអម្បូររុក្ខជាតិបន្លែផ្សេងៗទៀត។ វាលស្រែតូចៗដែលមានទំហំប្រមាណ ជាកន្លះហិកតា មាននៅរាយប៉ាយពាសពេញព្រៃប្រភេទនេះ នៃព្រៃឡង់ ជាពិសេសនៅតំបន់ទាបៗ ដែលជាកន្លែងមានប្រភពទឹកច្រើន និងដីមានជីជាតិល្អ ដោយសារមានប្រូម៉ាស។

➢ **ព្រៃស្រល់និងស្លឹកធំចម្រុះ**

ចំណែកដ៏ធំនៃព្រៃនេះមានទីតាំងស្ថិតនៅវាលអាមូលនៃតំបន់ត្រពាំងព្រៃ ភូមិស្រែវាល ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ នៅរយៈកម្ពស់១៣៦លើកម្រិតកម្ពស់ទឹកសមុទ្រ។ តាមរយៈការ ទំនាក់ទំនងសួរព័ត៌មានបានឲ្យដឹងថា ក៏នៅមានចំណែកមួយទៀតនៃព្រៃស្រល់ផងដែរនៅតំបន់អូរឡង់ ក្នុងខេត្តស្ទឹងត្រែងដែលមានចម្ងាយប្រហែលជា២គីឡូម៉ែត្រ ភាគឦសាននៃប្រឡាយអូរក្រេក លាតសន្ធឹងដល់អូរខ្យាច់ (តាមអ្នកភូមិកំពង់ក្បឿង ខេត្តក្រចេះ)។ តាមរយៈការសិក្សាស្រាវជ្រាវមុនៗបានឲ្យដឹងថា ព្រៃស្រល់មានដុះនៅតំបន់ជាច្រើន ចាប់ពីភាគខាងត្បូងទៅភាគខាងជើងនៃបឹងទន្លេសាប រហូតទៅដល់តំបន់ទំនាបខាងជើងនៃប្រទេសកម្ពុជា (Dy Phon 1970, Legris and Blasco, 1972; Martin 1973, and Rollet, 1972) ដោយដុះនៅរាយប៉ាយ ចន្លោះខេត្តសៀមរាប និងខេត្តកំពង់ធំ និងមួយចំនួនទៀតមាននៅជិតសៀមបូក ស្ថិតក្នុងភាគខាងលិចនៃទន្លេមេគង្គ (Legris and Blasco, 1972)។ ព្រៃស្រល់ស្លឹកធំចម្រុះ ក៏ត្រូវបានកត់ត្រាថាមានផងដែរនៅក្នុងដែនជម្រកសត្វព្រៃបឹងពារ ក្នុងខេត្តកំពង់ធំ (Eanghourt K. 2014)។ ផ្អែកតាមការរកឃើញទាំងនេះ យើងអាចធ្វើការសន្និដ្ឋានបានថា ព្រៃស្រល់ដែលមានស្លឹកពីរៗរាងដូចម្ជុល គឺមានដុះនៅពាសពេញភាគនិរតី និងតំបន់ភាគកណ្តាលនៃប្រទេសកម្ពុជា។

ប្រភេទព្រៃឈើនេះត្រូវបានសម្គាល់លក្ខណៈដោយការរួមផ្សំគ្នារវាងប្រភេទដើមស្រល់ស្លឹកពីរៗរាងដូចម្ជុលនិងប្រភេទដើមឈើស្លឹកធំដទៃៗទៀត។ ប្រភេទដើមឈើដែលដុះនៅក្នុងព្រៃនេះ មានលាយឡំគ្នាទៅដោយប្រភេទដើមឈើព្រៃស្រោង និងដើមឈើព្រៃរបោះផងដែរ។ ស្រទាប់គម្របព្រៃនៃប្រភេទព្រៃនេះប្រែប្រួលពីសភាពបើកចំហជាង ទៅជាស៊ុបទ្រុបល្មម អាស្រ័យលើប្រភេទដើមឈើភាគច្រើនដែលលាយចម្រុះគ្នា។ នៅតំបន់ណាដែលសំបូរប្រភេទដើមស្រល់ និងមានប្រភេទដើមឈើព្រៃរបោះច្រើន ស្រទាប់គម្របព្រៃបើកចំហជាងដែលអាចឱ្យពន្លឺព្រះអាទិត្យចាំងចូលដល់ដីបាន និងជំរុញរុក្ខជាតិពពួកស្មៅ ជាពិសេសស្មៅឱ្យលូតលាស់បានល្អ។ នៅក្នុងព្រៃស្រល់នៃតំបន់ព្រៃឡង់ មានរុក្ខជាតិចំនួនសរុបតែ៥៧ប្រភេទប៉ុណ្ណោះដែលត្រូវបានកត់ត្រា ហើយ ៤៥,៦% គឺជាប្រភេទរុក្ខជាតិព្រៃ

ស្រោង (សូមមើលឧបសម្ព័ន្ធ១)។ ជាទូទៅ ស្រទាប់ចុងឈើអាចចែកចេញបីប្រភេទផ្សេងគ្នាគឺស្រទាប់គម្របព្រៃខាងលើ ស្រទាប់គម្របព្រៃខាងក្រោម និងស្រទាប់ព្រៃជាន់ក្រោម។

- *ស្រទាប់គម្របព្រៃខាងលើ:* នៃប្រភេទព្រៃឈើនេះ កើតឡើងពីការរួមផ្សំគ្នារវាងប្រភេទដើមស្រល់ស្លឹកពីរពងម្ជុលពណ៌បៃតងជានិច្ច និងប្រភេទដើមឈើស្លឹកធំដទៃទៀត មានដូចជា ដើមពពេល (Shorea roxburghii), ផ្ដៀក (Anisoptera costata), ដើមត្រាច (Dipterocarpus intricatus), ដើមច្រាម៉ាស (Vatica odorata), ដើមឈើទាលក្រើស (Dipterocarpus costatus), ដើមធ្លក (Parinari anamensis, Chrysobalanaceae), ដើមធ្នង់ (Pterocarpus macrocapus, Papilionoideae) និងដើមអង្កត់ខ្មៅ (Diospyros bejaudii, Ebenaceae)។

- *ស្រទាប់គម្របព្រៃខាងក្រោម:* រួមផ្សំឡើងពីសមាសភាពនៃប្រភេទដើមឈើ ដូចជា ក្រាយក្រហម (Xylopia vielana, Annonaceae), ក្រាយស (Xylopia pierrei, Annonaceae), ពពូលថ្ម (Vitex pinnata, Labiatae), ល្ងៀងកូនង៉ា (Cratoxylum formosum, Hypericaceae), ត្បែង (Dipterocarpus obtusifolius, Dipterocarpaceae), ម្រេចទន្សាយ (Baeckea frutescens, Myrtaceae), ក្រុងសមុទ្រ (Aporosa octandra, Phyllanthaceae) និងរវៀង (Randia tomentosa, Rubiaceae)។

- រុក្ខជាតិពពួកស្មៅដែលដុះទាបជាប់នឹងដី សម្បូរទៅដោយស្មៅ លាយឡំជាមួយគុម្ពរបោះដែលដុះរ៉ុយៗនៃបាយញេញ (Melastoma saigonense, Melastomataceae) និងតាធុក (Costus speciosus, Zingiberaceae)។ អតីតប្រធានក្រុមប្រឹក្សាឃុំផ្លា ស្រុកជ័យសែនធ្លាប់បានផ្ដល់ព័ត៌មានថាកាលពីឆ្នាំ២០០៦ សហគមន៍ក្នុងឃុំទាំងប៉ុន្មាននៅក្នុងស្រុកសណ្ដាន់ ខេត្តកំពង់ធំ ធ្លាប់បានប្រកបរបរដុតយកជ័រឈើពីដើមស្រល់ ប៉ុន្តែសកម្មភាពប្រមូលផល ជ័រឈើទាំងនេះ ត្រូវបានបោះបង់ចោលទៅវិញ ដោយសារដើមស្រល់ជាច្រើនបានងាប់អស់ បន្ទាប់ពីដុតយកជ័ររួចមក (តាមរយៈការសាកសួរព័ត៌មាន)។

### ➢ព្រៃពាក់កណ្ដាលស្រោង

ដោយសារតែបម្រែបម្រួលនៃរចនាសម្ព័ន្ធព្រៃ និងនានាភាពនៃប្រភេទរុក្ខជាតិ ទើបធ្វើឲ្យអ្នកស្រាវជ្រាវខុសៗគ្នាដែលមកស្រាវជ្រាវទាំងនោះនិងបានដាក់ឈ្មោះថា ព្រៃពាក់កណ្ដាលស្រោង។ Lagris and Blasco (1972) បានហៅឈ្មោះព្រៃនេះជាភាសាបារាំងថា ព្រៃស៊ុបទ្រុបពាក់កណ្ដាលរបោះ (*forêt dense semi-decidue*) និងជាភាសាអង់គ្លេសគឺ ព្រៃស្រោងដ៏ស្ងួតក្រៀមក្រោះ (*dry evergreen forest*) ចំណែក James F. Maxwell (2006-2007) បានស្នើឲ្យហៅជាក់លាក់បន្ថែមទៀតថា ព្រៃស្រោង

លាយចម្រុះព្រៃរបោះស្ងួត *Mixed Evergreen + Deciduous Hard Wood Forest* (MXF)។ រីឯប្រភព Rundel (1999) និយមហៅឈ្មោះព្រៃនេះថាជាព្រៃពាក់កណ្តាលស្រោង ដោយសារតែសមាមាត្រប្រែប្រួលរវាងដើមឈើព្រៃស្រោង និងដើមឈើព្រៃរបោះ។ ព្រៃពាក់កណ្តាលស្រោងត្រូវបានសម្គាល់លក្ខណៈដោយប្រភេទរុក្ខជាតិមានផ្កាចម្រុះច្រើនយ៉ាង ហើយមានរចនាសម្ព័ន្ធព្រៃដែលមានដើមឈើ ខ្ពស់ៗ និងមានច្រើនស្រទាប់ ហើយមានដុះនៅតំបន់ដីទំនាប និងទទួលរបបទឹកភ្លៀងតាមរដូវកាលច្រើន (Rundel, 1999)។ លោក McDonald បានពន្យល់ថា វាជាប្រភេទព្រៃម្យ៉ាងស្ថិតនៅចន្លោះ តំបន់ព្រៃរបោះនិងព្រៃស្រោង ហើយប្រែប្រួលយ៉ាងខ្លាំងអំពី ទំហំធំ សមាសភាពប្រភេទ និងរចនា សម្ព័ន្ធស្រទាប់បញ្ឈរ (McDonald, 2004)។ កាលដើមឡើយ (Rollet, 1972) គេបានកំណត់ជារួមថា ព្រៃនេះគឺជាប្រភេទព្រៃដែលមានកម្ពស់៥០ម៉ែត្រ និងមានអង្កត់ផ្ចិតទំហំជាងមួយម៉ែត្រ។ តំបន់មួយ ចំនួននៃព្រៃពាក់កណ្តាលស្រោង សម្បូរទៅដោយពពួកស្រឡៅ (Lagerstroemia spp) ដុះឡូកឡំ ជាមួយប្រភេទឈើទាលគ្រើះ (Dipteroarpus costatus), សុក្រំ (Xylia xylocarpa), ផ្ដៀក (Anisoptera costata) និងចំបក់ (Irvingia malayana)។ ដោយសារតែព្រៃនេះ មានកម្ពស់ខ្ពស់ និងមានអង្កត់ ផ្ចិតធំផងនោះទើបប្រជាសហគមន៍មូលដ្ឋានតែងតែសម្គាល់ថាប្រភេទព្រៃនេះមានឈ្មោះបច្ចេកទេស ហៅជាភាសាខ្មែរថា "ព្រៃស្រោង" ឬហៅជាពាក្យបច្ចេកទេសខ្មែរថា "ព្រៃពាក់កណ្តាលស្រោង"។ ដោយសារតែមានប្រភេទដើមឈើ ភាគច្រើនដុះខ្ពស់ពីដី ហើយមានដើមឈើពណ៌បៃតងរហូតធំៗ ជាច្រើនផងនោះទើបជាធម្មតាមិនត្រូវបានញាំញីដោយភ្លើងឆេះព្រៃទេនៅរដូវប្រាំង។ ព្រៃនេះមាន ប្រភេទដើមឈើសម្បូរបែបច្រើនយ៉ាង ប៉ុន្តែទាំងអ្នកស្រាវជ្រាវបច្ចុប្បន្ននិងពីមុនបានកត់ត្រាបានតែ ចំនួន១៥២ដើមប៉ុណ្ណោះ ក្នុងនោះមាន៧៧ដើមជាប្រភេទដើមឈើព្រៃស្រោងគឺស្មើនឹង ៥០,៦៥% នៃប្រភេទដើមឈើទាំងអស់ ដែលមាននៅក្នុងព្រៃពាក់កណ្តាលស្រោងនេះ។

លោក McDonald បានសង្កេតឃើញមានតំបន់ព្រៃពាក់កណ្តាលស្រោងចំនួនពីរកន្លែង ស្ថិតនៅគៀកខាងលើប្រឡាយអូរលាំង (ក្បាលអូរលាំង) នៅក្នុងឆ្នាំ២០០៤ និងបានប្រទះឃើញទីតាំងចំនួនពីរកន្លែងទៀតដែលមានព្រៃពាក់កណ្តាលស្រោងមិនទាន់ប៉ះពាល់នៅឡើយដុះនៅជាជួរចាប់ពីកម្ពស់២៥ម៉ែត្រទៅ៣៥ម៉ែត្រ និងមានអង្កត់ផ្ចិតចាប់ពី៤០ទៅ៨០សង់ទីម៉ែត្រ។ ជាមួយនឹងរចនាសម្ព័ន្ធព្រៃដែលប្រែប្រួលយ៉ាងខ្លាំងបែបនេះ និងមានបណ្តុំរុក្ខជាតិច្រើនយ៉ាងផងនោះ គឺពិតមានការលំបាកណាស់ក្នុងការពិពណ៌នាឲ្យបានប្រាកដអំពីប្រភេទព្រៃនេះ នេះបើយោងតាមការសង្កេតនៅតាមតំបន់មួយចំនួននៅទីនោះ។ លើសពីនេះទៅទៀត កម្ពស់ជំហរដើមចេះតែបន្តលូតពីដីទៅដល់ស្រទាប់ ដែលលយចេញមកក្រៅ ជាហេតុពិបាកក្នុងការបែងចែកស្រទាប់ទាំងនេះ។ ប្រសិនបើផ្អែកលើទម្រង់ ធម្មជាតិរបស់រុក្ខជាតិ ស្រទាប់រាងដូចម្កុដទាំងបី អាចបែងចែកបានដូចខាងក្រោម:

- *ស្រទាប់លយចេញមកក្រៅ និងស្រទាប់គម្របព្រៃខាងលើ:* រួមផ្សំដោយសមាសភាគនៃប្រភេទដើមឈើព្រៃស្រោងសំខាន់ៗច្រើយ៉ាង ឧទាហរណ៍នៃប្រភេទដើមឈើព្រៃរបោះ រួមមាន ច្រាម៉ាស (Vatica odorata) និងឈើទាលបង្គួយ/ឈើទាលក្រើស/ឈើទាលឈ្សរ (Dipterocarpus costatus); ផ្លក (Parinari annamensis, Chrysobalanaceae), ចំបក់ (Irvingia malayana, Irvingiaceae), ឈើស/ថៅ (Alstonia spatulacea, Apocynaceae); និងត្រសេក (Peltophorum dasyrrachis, Caesalpinioideae)។ ដើមឈើធំជាច្រើនសុទ្ធសឹងជាជម្រករបស់រុក្ខជាតិអេពីភីត ដូចជាអរគីដេ និងបណ្ណង្គជាតិ។

- *ស្រទាប់គម្របព្រៃខាងក្រោម:* រួមផ្សំដោយបណ្តុំដើមឈើជាច្រើននៃប្រភេទក្នុងអំបូរ Myrtaceae ដូចជាស្មាច់/ស្មាច់ដោម /ព្រីងក្រហម (Syzygium zeylanica) និងព្រីង (Syzygium spp.); ប្រភេទរុក្ខជាតិក្នុងអំបូរ Guttiferae ដូចជាហ្វាអុង (Calophyllum saigonense) និងត្រមូង (Garcinia oliveri, Guttiferae), ប្រភេទរុក្ខជាតិក្នុងអំបូរ Sapindaceae ដូចជាមៀនព្រៃ (Dimocarpus longan) និងសេមាន់សាច់ (Nephelium hypoleucum), គ្រប់ទុំ (Crypteronia paniculata, Crypteroniaceae), នាងផ្អែក/អាទិត (Dehaasia cuneata, Lauraceae), និងពពូលថ្ម (Vitex pinnata, Verbenaceae)។

- *ស្រទាប់ព្រៃជាន់ក្រោម:* មានដុះនូវរុក្ខជាតិបៃតងរហូត រុក្ខជាតិពពួកស្មៅ និងកូនរុក្ខជាតិ ទើបដុះជាច្រើន។ នៅរដូវប្រាំង ដំណុះរុក្ខជាតិជានក្រោមមានពណ៌បៃតងស្រស់ជានិច្ច ប៉ុន្តែស្ងួតក្រៀមក្រោះ។ នៅតាមតំបន់ដែលមានគម្របព្រៃធំៗច្រើននិងស៊ុបទ្រុបជាង គេអាចធ្វើដំណើរឆ្លងកាត់បានយ៉ាងងាយស្រួល។ តំបន់ដែលមានការរំខាន គឺតំបន់ដែលសម្បូរទៅដោយក្រកោ (Amomum ovoidium, Zingiberaceae) និងរុក្ខជាតិអម្បូរខ្ញីជាច្រើនផ្សេងៗទៀត។ ប្រភេទរុក្ខជាតិពាក់កណ្តាលអេពីភីតដែលគេសង្កេតឃើញមាន ដូចជា វល្លិ៍ក្អែប (Rhaphidophora peepla and Rhaphidophora Montana, Araceae), ម្រេចព្រៃ (Piper sp., Piperaceae) និងផ្កាកណ្តៀង (Hoya oblongacutifolia, Asclepiadaceae)។

ចំពោះប្រភេទឈើវល្លិដែលមានរាងធំៗជាងនេះត្រូវបានតាងដោយខាន់ម៉ា (Ancistrocladus cochinchinensis, Ancistrocladaceae), វល្លិ៍ខ្លុត (Gnetum gnemon, Gnetaceae), អង្គុញស្វា (Archidendron lucidum, Mimosoideae), វល្លិ៍អង្គុញ (Entada phaseoloides, Mimosoideae), វល្លិ៍ចេកទុំ (Artabotrys hexapetalus, Annonaceae), កណ្តាប់ចង្អេរ (Salacia typhina, Celastraceae), គុយ (Willughbeia edulis, Apocynaceae), វល្លិ៍តាលីង (Coptosapelta flavescens, Rubiaceae), វល្លិ៍

ដែក (Dendrotrophe varians, Santalaceae), និងផ្ដៅ (Calamus spp., Plectocomia pierreana, Myrialepis paradoxa and Korthalia laciniosa)។

### ➢ព្រៃស្រោង

ព្រៃស្រោង សំដៅទៅលើព្រៃឈើដែលមានដុះទៅដោយប្រភេទដើមឈើព្រៃស្រោងចាប់ពីគម្របព្រៃខាងលើរហូតដល់ស្រទាប់ព្រៃជាន់ក្រោម និងមានពពួកស្មៅចម្រុះជាមួយប្រភេទរុក្ខជាតិច្រើនប្រភេទនៃអេពីភីត ដូចជាអរគីដេ បណ្ណង្គជាតិ រុក្ខជាតិវល្លិ៍ និងប្រភេទរុក្ខជាតិវារលើដី។ របាយការណ៍ក្នុងសម័យបារាំងមិនបានបញ្ជាក់ពីការសិក្សាស្រាវជ្រាវទៅលើប្រភេទព្រៃស្រោងនៅតំបន់ព្រៃឡង់ឡើយ។ ស្រដៀងគ្នានេះដែរ ការសិក្សាថ្មីៗនេះក៏មិនបានពិពណ៌នាច្បាស់លាស់ដែរនូវប្រភេទព្រៃបែបនេះនៅតំបន់ទេសភាពមួយនេះ។ ភាគច្រើននៃការសិក្សាលើប្រភេទព្រៃនេះត្រូវបានធ្វើឡើងនៅក្នុងរង្វង់ជុំវិញវាលដំរីនៃឧទ្យានជាតិបូកគោ ស្ថិតនៅភាគខាងត្បូងនៃប្រទេសកម្ពុជា កាត់តាមតំបន់វាលនៃជួរភ្នំក្រវាញភាគកណ្ដាលនៅប៉ែកនិរតីនៃប្រទេសកម្ពុជា (Rundel 1999)។ ទីតាំងអង្កេតស្រាវជ្រាវលើប្រភេទព្រៃនេះ គឺស្ថិតនៅតំបន់ក្បែរបឹងពារ និងអូរក្រែក។ កំណត់ត្រារុក្ខជាតិគិតមកត្រឹមពេលនេះ គឺមានចំនួនតែ១១១ប្រភេទតែប៉ុណ្ណោះ ដែលក្នុងនោះ៩១ ប្រភេទ (ស្មើនឹងប្រហែល៨២%) ជាប្រភេទរុក្ខជាតិព្រៃស្រោង។ ផ្អែកតាមការពិពណ៌នាអំពីព្រៃស្រោង ដែលមាននៅក្នុងសៀវភៅ Rundel ដែលបានសរសេរថា "ជម្រកព្រៃ និងរុក្ខជាតិនៅក្នុងប្រទេសឡាវ កម្ពុជា និងវៀតណាម និងផ្នែកធំៗនៃព្រៃឈើនៅជិតព្រៃស្រោងជាំទឹកនៅព្រៃឡង់ អាចចាត់ថ្នាក់ថាជាប្រភេទព្រៃស្រោង។ រចនាសម្ព័ន្ធស្រទាប់ចុងស្លឹកបញ្ឈរចេះតែបន្តលូតលាស់ ជាហេតុធ្វើឱ្យមានការលំបាកក្នុងការកំណត់ស្រទាប់របស់វាឱ្យបានត្រឹមត្រូវ។ ទោះយ៉ាងណា ផ្អែកលើមូលដ្ឋាននៃទម្រង់ធម្មជាតិរបស់រុក្ខជាតិ (ឧទាហរណ៍ ដើមឈើ កូនឈើ ចុលព្រឹក្ស រុក្ខជាតិពពួកស្មៅ និងរុក្ខជាតិវល្លិ៍តោងឡើង) ស្រទាប់ចុងស្លឹកអាចត្រូវបានកំណត់ដូចខាងក្រោម:

- *ស្រទាប់គម្របព្រៃខាងលើ*: ដុះលូតលាស់មិនស្មើគ្នាទេ ហើយជាធម្មតាមានកម្ពស់ពី១៥ទៅ២០ម៉ែត្រ ប៉ុន្តែជួនកាលអាចលូតទៅដល់កម្ពស់ពី៣០ទៅ៣៥ម៉ែត្រក៏មាន។ បើតាមមគ្គុទេសក៍ដើរព្រៃនៅមូលដ្ឋានបានឲ្យដឹងថាកម្ពស់ទាបជាងជាមធ្យមនៃដើមឈើទាំងនេះ គឺជាធម្មជាតិមិនមែនជាលទ្ធផលនៃការកាប់ឈើនោះឡើយ។ ដើមឈើនៃស្រទាប់គម្របព្រៃខាងលើនេះមានដូចជាដើមឈើទាលគ្រើៈ (Dipterocarpus costatus), ឈើទាលទឹក (D. alatus), ត្រាច (D. intricartus), គគីម្សៅ (Hopea odorata), ផ្ដៀក (Anisoptera costata), និងចំបក់ (Irvingia malayana)។ គេឃើញមានប្រភេទដើមឈើដទៃទៀតដែលដុះឡូកឡំជាមួយប្រភេទព្រៃនេះផងដែរ ដូចជាដើមថ្លក (Parinari anamensis, Chrysobalanaceae), ដើមបង្គួយហូបផ្លែ (Aglaia cambodiana, Meliaceae), បង្គួយស្វា (Aglaia elaeagnoidea, Meliaceae), កំពីងរាជ

(Sandoricum koetjape, Meliaceae), តាត្រាវ (Fagraea fragrans, Loganiaceae) និងត្រសេក (Peltophorum dasyrrhachis, Caesalpinioideae)។ ភាគច្រើនបំផុតនៃដើមឈើទាំងនេះមានរាងជាស៊ីឡាំងនិងទម្រតូចៗ មានសំបកពណ៌ប្រផេះ ហើយចំនួន២/៣មានរាងជាម្កុដបញ្ឈរ។ ដោយសារតែដើមឈើទាំងនេះដុះនៅរង្វើលៗពាសពេញព្រៃ គម្របព្រៃច្រើនតែបើកចំហ និងអាចឱ្យពន្លឺព្រះអាទិត្យចាំងចូលទៅក្នុងស្រទាប់ខាងក្រោមបាន។ ផ្នែកខាងលើនៃដើមឈើទាំងនេះ ច្រើនតែមានដុះពពួករុក្ខជាតិអេពីភីត ដូចជាអរគីដេ និងបណ្ណង្គជាតិនានា ហើយពេលខ្លះស្រទាប់ខាងចុងធំៗ ជាជម្រករបស់ប្រភេទសត្វបក្សីធំៗទៀតផង។ គេកម្រឃើញមានដើមឈើដែលមានអង្កត់ផ្ចិតធំជាងមួយម៉ែត្រណាស់ លើកលែងតែប្រភេទដើមខ្លុងត្បែង។

- *ស្រទាប់គម្របព្រៃបន្ទាប់:* មានសភាពក្រាស់ជាង។ ភាគច្រើននៃដើមឈើទាំងនេះមានរាងជាស៊ីឡាំង ហើយអាចមានកម្ពស់ពី១៤ទៅ១៧ម៉ែត្រ និងមានអង្កត់ផ្ចិតពី៣០ទៅ៤០សង់ទីម៉ែត្រ។ ស្រទាប់ព្រៃនេះមានប្រភេទរុក្ខជាតិក្នុងអំបូរ Ebenaceae ដូចជា អង្កត់ខ្មៅ (Diospyros bejaudii), ឈើខ្មៅ (Diospyros crumenata) និងឈើភ្លើង (Diospyros undulata var. cratericalyx); ប្រភេទរុក្ខជាតិក្នុងអំបូរ Guttiferae មួយចំនួន ដូចជាត្រមូង (Garcinia oliveri), ព្រហូត (Garcinia vilersiana); ខុស (Lithocarpus polystachyus, Fagaceae); ប្រាម៉ាស (Vatica odorata, Dipterocarpaceae); ប្រភេទ២ក្នុងអំបូរ Annonceae គឺក្រាយក្រហម (Xylopia vielana) និងក្រាយស (Xylopia pierrei), និងផ្ដុង (Memecylon laevigalum, Melastomataceae)។

- *ស្រទាប់គម្របព្រៃខាងក្រោម:* មានរាប់បញ្ចូលទាំងប្រភេទកូនឈើទាំងឡាយ និងចុលព្រឹក្សដែលមានកម្ពស់អតិបរមាពី១ទៅ៦ម៉ែត្រ។ ប្រភេទរុក្ខជាតិទាំងនេះអាចដុះលូតលាស់បានយ៉ាងល្អនៅក្រោមម្លប់ឈើ។ ប្រភេទរុក្ខជាតិទាំងនេះ រួមមានអង្គារបាត (Gomphia serrate, Ochnaceae), អង្រ្កាដែក (Dracaena cambodiana, Asparagaceae), កូនឃ្មុំ (Dracaena fragrans, Asparagaceae), ចន្លុះ (Lepisanthes rubiginosa, Sapindaceae), ផ្លូវនាង (Cleistanthus tomentosus, Phyllanthaceae), ស្លង់ (Ardisia sanguinolenta, Primulaceae), ស្នាយ (Streblus asper, Moraceae), ផ្អាវ (Licuala spinosa, Palmae) និងជម្ពូព្រៃ /ផ្ទុកថ្នាតបាត (Ardisia helferiana, Primulaceae)។

- *ស្រទាប់ព្រៃជាន់ក្រោម:* រួមផ្សំពីពពួកស្មៅគ្រប់ប្រភេទ កូនឈើមួយចំនួន កូនរុក្ខជាតិគុម្ពោត និងកូនឈើទើបដុះទាំងអស់។ កម្ពស់របស់វាចាប់រាប់ពីផ្ទៃស្រទាប់ទៅគឺប្រហែលមួយម៉ែត្រ។ ស្រទាប់នេះទទួលបានពន្លឺព្រះអាទិត្យតិចតួចណាស់ ដូច្នេះកម្រមានដុះស្មៅ និងពពួករុក្ខជាតិ

ស្បូវណាស់។ ប្រភេទរុក្ខជាតិនៃស្រទាប់នេះមានប្រភេទរុក្ខជាតិក្នុងអំបូរ Primulaceae ដូចជា សាគូភ្នំ (Ardisia smaragdina) និងសេដាព្រៃ (Ardisia villosa), ប្រភេទរុក្ខជាតិក្នុងអំបូរ Zingiberaceae ដូចជាក្រាកី (Alpinia oxymitra) និងក្រាកោ (Amomum ovoideum, Zingiberaceae), រំចេកភ្នំ (Pandanus capusii, Pandanaceae) និងស្នែងទន់ (Aglaonema modestum, Araceae)។

ប្រភេទរុក្ខជាតិវល្លិ៍តោងឡើងមានច្រើនប្រភេទផ្សេងៗគ្នា ប៉ុន្តែអត្រារបស់ វាមានតិចនៅក្នុងប្រភេទព្រៃនេះ ជាពិសេសមានដុះនៅតាមចន្លោះគម្របព្រៃ។ រុក្ខជាតិទាំងនេះរួមមានរុក្ខជាតិពពួកផ្ដៅជាច្រើន ដូចជាផ្ដៅផ្ទាំង (Calamus palustris), ផ្ដៅស្នោ (Plectocomia pierreana), ផ្ដៅសោម (Daemonorops jenkinsiana), សេសឹង (Calamus tetradactylus); ប្រភេទបន្លែជាច្រើនដូចជា អង្គុញស្វា/ជណ្ដើរស្វា (Archidendron lucidum), អង្គុញ (Entada phaseoloides), វល្លិអន្ទង់ (Derris elliptica); ខាន់ម៉ា (Ancistrocladus cochinchinensis, Ancistrocladaceae); វល្លិ៍ខ្លូត (Gnetum gnemon, Gnetaceae), និងវល្លិធ្លក (Toxocarpus lagenifer, Apocynaceae)។ រុក្ខជាតិពាក់កណ្ដាលអេពីភីតសំបូរទៅដោយចង្កេះអង្រ្កង (Pothos scandens, Araceae), ម្រេចទន្សាយ (Piper sp.,Piperaceae), វល្លិ៍ក្អែប (Rhaphidophora peepla, Araceae), និង Hoya spp។

- **ព្រៃស្រោងជាំទឹក**

ក្រុមអ្នកស្រាវជ្រាវពីមុនៗបានឲ្យឈ្មោះព្រៃនេះដូច្នេះ ប្រហែលជាដោយសារនៅតំបន់ភាគកណ្ដាលនៃព្រៃឡង់ដែលគ្របដណ្ដប់មួយចំណែកធំនៃទឹកនៅរដូវវស្សា ដែលបន្ទាប់មកត្រូវថយត្រឹមមួយចំណែកតូចនៅរដូវប្រាំង។ បើនិយាយពីការលូតលាស់របស់រុក្ខជាតិ សមាសភាពនៃប្រភេទដើមឈើដែលមាននៅតំបន់ទេសភាពនេះ គឺជាប្រភេទតំណាងឱ្យព្រៃស្រោងនេះឯង ប៉ុន្តែមិនមានទំនាក់ទំនងជាមួយព្រៃជាំទឹកនៅជុំវិញបឹងទន្លេសាបទេ (McDonald 2004)។ ដោយសារតែដើមឡើយតំបន់ព្រៃទាំងនោះ មានទំហំធំល្វឹងល្វើយ និងមិនត្រូវបានប៉ះពាល់នៅឡើយ ទឹកក្រោមដីនៃតំបន់ទេសភាពនេះ ត្រូវបានរក្សាទុក និងរំដោះចេញបានយ៉ាងច្រើនសន្ធឹកសន្ធាប់។ ហេតុនេះហើយបានជាតំបន់ដែលមានទឹកចេញពីក្រោមដីជាច្រើនកន្លែង ស្រះឬបឹងដែលមានទឹកជាប្រចាំ និងតំបន់ដីភក់ល្បាប់ជាអចិន្ត្រៃច្រើនតែ ដុះហ៊ុំព័ទ្ធទៅដោយស្មៅនៅពាសពេញតំបន់ទេសភាពនេះតែម្ដង។ លក្ខណៈពិសេសនៃតំបន់ទេសភាពនេះដើរតួនាទីយ៉ាងសំខាន់ទាំងក្នុងការស្តុកទឹកនៅរដូវវស្សា និងស្តុកទឹកនៅរដូវប្រាំងសម្រាប់បម្រើដល់សេចក្តីត្រូវការរបស់ពពួកសត្វព្រៃ និងមនុស្សផងដែរ។ តំបន់ទាំងនេះក៏អាចផ្ដល់ផងដែរនូវប្រភពទឹកក្រោមដីដ៏វិសេសវិសាល ដើម្បីទ្រទ្រង់ដល់ដំណាំកសិកម្ម និងដល់ប្រជាជនដែលរស់នៅតំបន់ដីទំនាប ដូចជាការជីកអណ្ដូងយកទឹកសម្រាប់ប្រើប្រាស់ជាដើម (McDonald 2004)។


រូបភាព 3 ព្រៃជាំទឹក នៅក្នុងតំបន់ព្រៃឡង់

ការសិក្សាស្រាវជ្រាវអំពីព្រៃស្រោងជាំទឹកនៅក្នុងប្រទេសកម្ពុជា ត្រូវបានធ្វើឡើងដោយលោក McDonald (ឆ្នាំ ២០០៤) ហើយក្រោយមកទៀតមានការសិក្សាស្រាវជ្រាវជាបន្តបន្ទាប់នៅក្នុងឆ្នាំ២០០៨ ឆ្នាំ២០០៩ និង២០១០ ដោយក្រុមអ្នកស្រាវជ្រាវមកពីសាកលវិទ្យាល័យទីក្រុងកូពេនហាចេន (ប្រទេសដាណឺម៉ាក) សាកលវិទ្យាល័យតិចសាស់ (សហរដ្ឋអាមេរិក) និងរដ្ឋបាលព្រៃឈើ នៃប្រទេសកម្ពុជា។ តំបន់ព្រៃជាំទឹកជាច្រើនក្នុងប្រទេសត្រូវបានគេដឹងថាស្ថិតនៅរប៉ាត់រប៉ាយ ចន្លោះរវាងទន្លេពោធិ៍រុង និងទន្លេអូរឡង់ នៅរយៈកម្ពស់មានចាប់ពី ៥០-១០០ ម៉ែត្រលើកម្រិតកម្ពស់ទឹកសមុទ្រ ដែលក្នុងនោះមានតំបន់ចំនួន៥កន្លែងដែលគេបានធ្វើការសិក្សាស្រាវជ្រាវទាំងទៅលើផ្នែករុក្ខសាស្រ្ត ឬនានាភាពនៃប្រភេទអេកូឡូស៊ី និងជលសាស្រ្ត រួមមាននៅតំបន់ចោមភាគខាងជើងស្តុង ចោមស្តុង ចោមតាគង់ ចោមភាគខាងលិចតាគង់ និងចោមស្វាយ។ ចោមតាគង់ត្រូវបានគេដឹងថាជាតំបន់វាលភក់ល្បាប់ធំជាងគេបំផុត ដែលមានប្រវែងទទឹង២គីឡូម៉ែត្រ និងប្រវែងបណ្តោយ១គីឡូម៉ែត្រ (McDonald 2004)។ ទោះបីជាមានភាពខុសគ្នាមួយចំនួននៅក្នុងសមាសភាព ប្រភេទរុក្ខជាតិនៅតំបន់វាលភក់ល្បាប់ក្តី ក៏គេនៅតែអាចសម្គាល់លក្ខណៈនៃព្រៃស្រោងជាំទឹក ដែលជាទូទៅមានដំណុះរុក្ខជាតិនៅក្នុងទឹកដែលមានឫសនៅលើគោកនិងក្នុងដី ស្រទាប់គម្របព្រៃខាងក្រោមដុះស៊ុបទ្រុប ដែលអាចបើកចំហកាន់តែទូលាយ ហើយស្រទាប់គម្របព្រៃមានកម្ពស់ចាប់ពី៨-៣៥ម៉ែត្រ និងជាស្រទាប់រង្វើលៗលេចចេញពី

ដើមឈើ និងរុក្ខជាតិពពង់ត្នោត (Livistona saribus) ដែលមានកម្ពស់ចាប់ពី៣០-៣៥ម៉ែត្រ (McDonald 2014)។ ប្រភេទរុក្ខជាតិមួយចំនួនមានដុះនៅតែក្នុងតំបន់វាលភក់នេះតែប៉ុណ្ណោះ ប៉ុន្តែគេក៏អាចប្រទះឃើញប្រភេទរុក្ខជាតិទាំងនេះ មានដុះនៅលើតំបន់ខ្ពស់រាបផងដែរ (Theilade et al., 2011)។ ផ្អែកលើសមាសភាពរបស់រុក្ខជាតិ ស្រទាប់គម្របព្រៃស្រោងជាំទឹកអាចត្រូវបានចែកចេញជា៣ស្រទាប់ដូចខាងក្រោម:

- *ស្រទាប់គម្របព្រៃខាងលើ:* ត្រូវបានតាងដោយកក់ (Myristica iners, Myristicaceae), ប្រភេទរុក្ខជាតិពីរយ៉ាងដែលគេមិនស្គាល់ឈ្មោះនៅក្នុងពួក Litsea spp., ព្រីងអង្កាំ (Syzygium sp., Myrtaceae), ព្រលប់ (Mastixia pentandra, Nyssaceae), ស្រឹង (Ploiarium alternifolium, Bonnetiaceae), ដើមទ្រនំកំភេម (Archidendron clypearia, Mimosoideae) និងពពួកល្វាមួយចំនួនទៀត (Ficus spp., Moraceae)។

- *ស្រទាប់គម្របព្រៃខាងក្រោម:* ត្រូវបានតាងដោយស្លាប៉ាងស្លឹកឆែក (Macaranga triloba, Euphorbiaceae), ចង្កត់ប្រែក (Pternandra caerulescens, Melastomataceae), ភ្ញៀវទឹក (Baccaurea bracteata, Euphorbiaceae), ស្រាលក (Euonymus glaber, Celastraceae), Memecylon umbellatum (Melastomataceae), ព្រីងក្រហម /ស្នាច់ដោម (Syzygium zeylanicum, Myrtaceae) និងផ្គោងចម (Calophyllum spectabile, Guttiferae)។ ប្រភេទរុក្ខជាតិមានគុម្ពមានដូចជាស្លាព្រៃ (Areca triandra, Palmae), ផ្អាវ (Licuala spinosa, Palmae), សោម (Daemonorops jenkinsiana, Palmae) និងបណ្ណង្គជាតិ (Cibotium barometz, Cibotiaceae)។ កូនឈើតូចៗ និងរុក្ខជាតិវល្លិ៍មួយចំនួន ដូចជាអង្រែដែក (Dracaena gracilis, Asparagaceae) និងប្រភេទរុក្ខជាតិមំសាសី (Nepenthes) ដែលឃើញមានដុះនៅត្រឹមព្រំដែនតំបន់ភក់ល្បាប់តែប៉ុណ្ណោះ។

- *ស្រទាប់ព្រៃជាន់ក្រោម:* សម្បូរទៅដោយប្រភេទរុក្ខជាតិក្នុងអំបូរ Cyperaceae គឺត្រសិតជាំ (Mapania macrocephala) និង Hypolythrum nemorum។ ប្រភេទរុក្ខជាតិរស់ក្នុងទឹក ផ្សេងទៀតដែលរស់នៅតាមផ្ទៃទឹកចំហ ឬស្រះទឹកដែលនៅក្បែរនោះ មានដូចជាគោកមូល (Isolepis crassiuscula, Cyperaceae), សារាយ (Najas indica, Najadaceae), និង Utricularia aurea, Lenthibulariaceae (មិនស្គាល់ឈ្មោះក្នុងស្រុក)។ បើផ្អែកលើការប្រៀបធៀបរវាងសមាសភាពប្រភេទរុក្ខជាតិជាមួយព្រៃជាំទឹកដទៃទៀតក្នុងតំបន់ បង្ហាញឲ្យឃើញច្បាស់ណាស់ថា ព្រៃកម្ពោតក្នុងស្រុកអាចមានដុះរាលឆ្លងទៅតំបន់ទំនាបកណ្តាលនៃប្រទេសកម្ពុជាផងដែរ (Theilade, 2010)។

តំបន់ដែលស្ថិតនៅចន្លោះរវាងព្រៃជាំទឹក និងព្រៃស្រោងនៅលើដីគោក ត្រូវបានគេស្គាល់ថាជា "ព្រៃសែល ឬព្រៃតឿ" នេះបើហៅតាមភាសារបស់ជនជាតិដើមភាគតិចកួយ។ ស្រដៀងគ្នាទៅនឹងព្រៃជាំទឹកដែរ ព្រៃនៅតំបន់នេះទាបៗដែលមានកម្ពស់អតិបរមាជាមធ្យមប្រមាណជា៨ម៉ែត្រ និងមានអង្កត់ផ្ចិតត្រឹមដើមទ្រូង៥០សង់ទីម៉ែត្រ។ ឋានប្រព័ន្ធព្រៃឈើបឹងពារ គឺជាឧទាហរណ៍ជាក់ស្តែងមួយនៃប្រភេទព្រៃឈើនេះ។ ដើមឈើភាគច្រើនរួមផ្សំឡើងពីប្រភេទព្រៃឈើស្រោងលាយឡំជាមួយនឹងប្រភេទព្រៃរបោះមួយចំនួនផងដែរ។ ប្រភេទដើមឈើដែលដុះនៅក្នុងតំបន់នេះ រួមមានប្រភេទដើមខ្លងត្បែង ដូចជាផ្ដៀក (Anisoptera glabra), ត្រាច (Dipterocarpus intricatus) និងច្រាម៉ាស (Vatica odorata); ប្រភេទ២យ៉ាងនៃ Annonaceae - ក្រាយក្រហម (Xylopia vielana) និងក្រាយស (Xylopia pierrei); កកោះ (Sindora siamensis, Caesalpinioidae), និងរុក្ខជាតិ៣ប្រភេទនៃអំបូរ Ebenaceae ដូចជាឈើភ្លើង (Diospyros undulata var. cratericalyx), អង្គុតខ្មៅ (Diospyros bejaudii) និងឈើខ្មៅ (Diospyros crumenata)។

**➢ព្រៃឈើតាមមាត់ទឹក**

ពាក្យរុក្ខជាតិតាមមាត់ទឹក គឺសំដៅដល់រុក្ខជាតិទាំងឡាយណាដែលដុះនៅតាមមាត់ទន្លេ ស្ទឹង បឹងបួតូចធំ ហើយដែលមានមុខងារការពារការហូរច្រោះ។ សមាសភាពនៃប្រភេទរុក្ខជាតិដែលដុះនៅតាមមាត់ទឹក អាចឆ្លុះបញ្ចាំងពីប្រភេទព្រៃដែលនៅជាប់ទីនោះ។ ទោះជាយ៉ាងណា ប្រភេទរុក្ខជាតិមួយចំនួនដូចជារាំងទឹក (Barringtonia acutangula, Lecythidaceae), ខ្ទុមទឹក (Nauclea officinalis, Rubiaceae), គុមភ្នាង (Hymenocardia punctate, Phyllanthaceae), ផ្តៅទឹក (Calamus siamensis, Palmae), អំពង់ត្រាំង (Lasia spinosa, Araceae), ផ្តៅស្វា (Flagellaria indica, Flagellariaceae) ជារុក្ខជាតិច្រើនដុះនៅតាមមាត់ទឹក ។



រូបភាព 4 ព្រៃឈើដុះតាមមាត់ទឹកនៃតំបន់ព្រៃឡង់ ក្នុងខេត្តស្ទឹងត្រែង

ដំណុះរុក្ខជាតិតាមមាត់ទឹកដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារដីពីការហូរច្រោះ និងអាចរក្សាទឹកឲ្យនៅថ្លាល្អ ហើយក៏ជាជម្រកដ៏សុខសាន្តសម្រាប់សត្វព្រៃនៅក្នុងរដូវប្រាំងផងដែរ។ ជាទូទៅ ដីនៅតាមប្រភេទព្រៃនេះមានសភាពសើមជានិច្ច និងមានជីជាតិល្អ ដោយសារតែការប្រមូលផ្តុំនៃកម្ទេចកម្ទីរុក្ខជាតិពុកផុយ។

### ➢តំបន់វាលស្មៅ

តំបន់វាលស្មៅ ត្រូវបានសម្គាល់លក្ខណៈថាជាតំបន់ដែលគ្របដណ្តប់ដោយស្មៅស្ពែកស្គះ និងគុម្ពចុលព្រឹក្សដុះរង្វើលៗ និងកូនដើមឈើតូចៗ។ វាលហ្លួង នៅតាមបណ្តោយផ្លូវទៅអូរក្រៃក តាងឱ្យជម្រកវាលស្មៅប្រភេទនេះ។ តំបន់នេះត្រូវបានហ៊ុំព័ទ្ធដោយព្រៃរបោះចម្រុះទាបៗ និងព្រៃពាក់កណ្តាលស្រោង។ តំបន់នេះខ្សោះជីជាតិ ជាដីខ្សាច់គ្រាប់ល្អិតៗ ដែលរុក្ខជាតិពិបាកលូតលាស់។ តំបន់នេះសម្បូរទៅដោយស្មៅដែលជាធម្មតាមានកម្ពស់០.៣ម៉ែត្រ និងដុះលាយឡំជាមួយរុក្ខជាតិដទៃទៀត ដូចជាប្រភេទរុក្ខជាតិពពួកស្មៅ រុក្ខជាតិវល្លិ៍ផ្លែចង្កោម និងចុលព្រឹក្សជាដើម។ គេមិនស្គាល់ឈ្មោះក្នុងស្រុក ចំពោះពពួកស្មៅច្រើនប្រភេទដែលដុះនៅតំបន់វាលស្មៅនេះទេ ដូចជា Rhynchospora rubra,

Ischaemum indicum, Mnesithea mollicoma, Eremochloa ciliaris, Fimbristylis distycha, Burmannia wallichii, Burmannia coelestis, Eriocaulon truncatum។ រុក្ខជាតិពពួកស្មៅផ្សេងទៀត និងរុក្ខជាតិតូចៗត្រូវបានតាងដោយចាហួយ (Curcuma petiolata, Zingiberaceae) និងវល្លិ៍ជុយ (Streptocaulon juventas, Asclepiadaceae)។ ចុលព្រឹក្សខ្លះ កូនឈើតូចៗ និងដើមឈើមួយចំនួនដុះរង្វើលៗជាក្រុមតូចៗ មានដូចជាទឹកដោះខ្លាតូច (Holarrhena curtissii, Apocynaceae), ភ្លូបាត (Dillenia hookeri, Dilleniaceae), ព្រាលចន្លុះ (Corona auriculata, Malvaceae), ល្ងាងអាចម៍កូនញ៉ា (Cratoxylon formosum, Hypericaceae), ដៃខ្លា (Gardenia angkorensis, Rubiaceae), ត្រាច (D. intricatus, Dipterocarpaceae), ត្រសេក (Peltophorum dasyrrhachis, Caesalpinioideae)។ ដើមឈើទាំងនេះកម្រនឹងលូតលាស់ដល់ពេញវ័យណាស់ ដោយសារតំបន់វាលស្មៅនេះកើតមានភ្លើងឆេះព្រៃបង្កដោយមនុស្សជារៀងរាល់ឆ្នាំ។



រូបភាព 5 ស្នាមដានជើងដំរីតាមវាលស្មៅ ក្នុងតំបន់ព្រៃឡង់

ប្រភេទដើមឈើ*សំខាន់ៗ*

ដើមឈើចំនួន១៣ប្រភេទក្នុងចំណោមដើមឈើសរុបចំនួន៥៣០ប្រភេទ ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN (សូមមើលតារាង 2)។ ប្រភេទដើមឈើទាំងនេះរួមមានបេង (Afzelia xylocarpa), ផ្ដៀក (Anisoptera costata), ប្រាង (Cycas siamensis), នាងនួន (Dalbergia olivery), ក្រញូង (Dalbergia cochinchinsis), ឈើទាលទឹក (Dipterocarpus alatus), យាងដេង (Dipterocarpus costatus), គគីថ្ម (Hopea ferrea) គគីម្សៅ (Hopea odorata), ច្រម៉ាសត្រង់/ពពេល (Hopea recopei), ស្រល់ស្លឹកពី (Pinus merkusii), ធ្នង់ (Pterocarpus macrocarpus), ពពេល (Shorea roxburghii)។ ដើមជ័រជុង (Shorea guiso) ក្លាយជាប្រភេទឈើកម្រមែនទែន ដោយសារតែឥទ្ធិពលនៃការកាប់យកជ្រុលហួសហេតុពេកកាលពីអំឡុង១០ទៅ១៥ឆ្នាំកន្លងទៅ ប៉ុន្តែមិនត្រូវបានដាក់នៅក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ទេ រីឯដើមកកោះ (Sindora siamensis) បច្ចុប្បន្ននេះ ក៏ស្ថិតក្រោមការគម្រាមកំហែងដោយសារកាប់យកពីក្នុងព្រៃច្រើនពេកផងដែរ។ នៅពេលបច្ចុប្បន្ននេះ ប្រភេទដែលនៅសម្បូរបំផុតមានច្រើន គឺស្រឡៅ (Lagerstroemia calyculata) ដែលកំពុងរងការកាប់យកយ៉ាងសម្បើមហើយអាចប្រឈមនឹងការគម្រាមកំហែងនាពេលអនាគត។ ដើមឈើចំនួន៥ប្រភេទផ្សេងទៀត ដែលមានចំនួនជាមធ្យម នៅតំបន់ព្រៃឡង់មាន គឺផ្ដៀក (Anisoptera costata), ប្រាង (Cycas siamensis), ឈើទាលទឹក (Dipterocarpus alatus), ឈើទាលគ្រឹះ (Dipterocarpus costatus) និងពពេល (Shorea roxburghii)។ ដើមស្រល់ស្លឹងពីរ (Pinus murkusii) នៅមានចំនួនច្រើននៅឡើយនៅក្នុងព្រៃស្រល់និងស្លឹកធំចម្រុះ។

ប្រភេទដើមឈើទុកជាសំខាន់របស់ជាតិសរុបចំនួន១២ក្នុងចំណោម២១ ដែលកំពុងប្រឈមនឹងការព្រួយបារម្ភសម្រាប់ការអភិរក្ស ដែលបានកំណត់ដោយរដ្ឋបាលព្រៃឈ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (FA's Tree Monographs 2004)។ កំពុងមានវត្តមានដុះនៅក្នុងតំបន់ព្រៃឡង់។ ប្រភេទដើមឈើទាំងនេះរួមមានបេង (Afzelia xylocarpa), ច្រេស (Albizia lebbeck), ផ្កៃស្រែង (Canang latifolia), ក្រញូង (Dalbergia cochinchinensis), នាងនួន (Dalbergia oliveri), អង្កត់ខ្មៅ (Diospyros bejaudii), ឈើខ្មៅ (Diospyros crumenata), តាត្រាវ (Fagraea fragrans), ដៃខ្លា (Gardenia angkorensis), គគីម្សៅ (Hopea odorata), ស្រល់ស្លឹកពីរ (Pinus merkusii), ពពេល (Shorea roxburghii)។ ប្រភេទដើមឈើ ទុកជាសំខាន់បំផុតប្រមាណជា៧៥% នៃចំនួន២០ប្រភេទដែលបានកំណត់ដោយគម្រោងគ្រាប់ពូជឈើកម្ពុជានៃរដ្ឋបាលព្រៃឈើកាលពីឆ្នាំ២០០៣ ក៏ត្រូវបានគេប្រទះឃើញមាននៅតំបន់ព្រៃឡង់ផងដែរ។

## តារាង 2 ស្ថានភាពនៃប្រភេទរុក្ខជាតិសំខាន់ៗរបស់កម្ពុជានៅក្នុងតំបន់ព្រៃឡង់

| រុក្ខជាតិ | | សៀវភៅក្រហម របស់ IUCN | | | ស្ថានភាពនៅព្រៃឡង់ | | | | |
|---|---|---|---|---|---|---|---|---|---|
| ឈ្មោះរុក្ខជាតិ | ភាសាហៅក្នុងស្រុក | ជិតផុតពូជខ្លាំង | ជិតផុតពូជ | ងាយរងគ្រោះ | គ្មានវត្តមាន | កម្រមានណាស់ | កម្រមាន | មានជាមធ្យម | មានជាទូទៅ |
| *Afzelia xylocarpa* | បេង | | EN | | | 1 | | | |
| *Aglaia pleuropteris* | គ្មាន | CR | | | 1 | | | | |
| *Anisoptera costata* | ផ្ដៀក | | EN | | | | | 1 | |
| *Aquilaria crassna* | ចាន់ក្រឹស្នា | CR | | | 1 | | | | |
| *Cycas siamensis* | ប្រោង | | | VU | | | | 1 | |
| *Dalbergia olivery* | នាងនួន | | EN | | | 1 | | | |
| *Dalbergia cambodiana* | គ្មាន | | EN | | 1 | | | | |
| *Dalbergia cochinchinsis* | ក្រញូង | | | VU | | | | 1 | |
| *Dipterocarpus alatus* | ឈើទាលទឹក | | EN | | | | | 1 | |
| *Dipterocarpus baudii* | គ្មាន | CR | | | 1 | | | | |
| *Dipterocarpus costatus* | យាងដែង | | EN | | | | | 1 | |
| *Dipterocarpus dyeri* | ឈើទាលឆ្ងរ | | EN | | 1 | | | | |
| *Dipterocarpus turbinatus* | ឈើទាលដង់<br>ឈើទាលក្ង | CR | | | 1 | | | | |
| *Hopea ferrea* | គគីរថ្ម | | EN | | | | 1 | | |
| *Hopea helferi* | គគីរដែក | CR | | | 1 | | | | |
| *Hopea latifolia* | គ្មាន | CR | | | 1 | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| *Hopea odorata* | គគីម្សៅ | | | VU | | 1 | | | |
| *Hopea pedicellata* | គ្មាន | | EN | | 1 | | | | |
| *Hopea pierrei* | គគីរខ្សាច់ | | EN | | 1 | | | | |
| *Hopea recopei* | ច្រម៉ាសត្រង់/ ពពេល| | | EN | | | | | 1 | |
| *Hopea siamensis* | គ្មាន | CR | | | 1 | | | | |
| *Intsia bijuga* | កកោះព្រែក | | | VU | 1 | | | | |
| *Mangifera flava* | គ្មាន | | | VU | 1 | | | | |
| *Pinus merkusii* | ស្រល់ស្លឹកពីរ | | | VU | | | | | 1 |
| *Pterocarpus macrocarpus* | ធ្នង់ | | | VU | | 1 | | | |
| *Shorea henryana* | គ្មាន | | EN | | 1 | | | | |
| *Shorea hypochra* | គគីរភ្នង់/ កំញ៉ាន់ | CR | | | 1 | | | | |
| *Shorea roxburghii* | ពពេល | | EN | | | | | 1 | |
| *Shorea thorelii* | ខ្មៅ/ ផ្ទឹកឧត្តម | CR | | | 1 | | | | |
| *Vatica cinerea* | គ្មាន | | EN | | 1 | | | | |
| *Sindora siamensis* | កកោះ | គ្មាន | គ្មាន | គ្មាន | | | 1 | | |
| *Sindora siamensis* | កកោះ | គ្មាន | គ្មាន | គ្មាន | | | 1 | | |
| *Shorea guiso* | ជ័រចុង | គ្មាន | គ្មាន | គ្មាន | | 1 | | | |

ព្រៃស្រោងជាំទឹកនៅព្រៃឡង់ គឺជាព្រៃដែលមានលក្ខណៈពិសេសពីធម្មជាតិដែលមានតែមួយគត់ ដោយផ្តល់ជាកន្លែងរស់នៅរបស់ប្រភេទសត្វនិងរុក្ខជាតិដែលរស់នៅក្នុងទឹកនិងនៅលើគោកជាច្រើនប្រភេទ គឺសម្រាប់ជ្រកកោន និងជាប្រភពចំណីអាហារ ក៏ដូចជាផ្តល់នូវមុខងារអេកូឡូស៊ីដ៏មានតម្លៃ។ យោងតាមការសិក្សាស្រាវជ្រាវពីមុនដោយបរិស្ថានវិទូនិងរុក្ខវិទូនានាបានឲ្យដឹងថា ព្រៃស្រោងជាំទឹកមានលក្ខណៈខុសគ្នាពីព្រៃជាំទឹកនៅបឹងទន្លេសាបនិងនៅស្ទឹងសែន បើនិយាយពីសមាសភាពរបាយរុក្ខជាតិ និងរចនាសម្ព័ន្ធរុក្ខជាតិ (McDonald 2004)។

បើគិតពីលក្ខណៈបរិស្ថាន ឋានប្រព័ន្ធព្រៃឈើនៅព្រៃឡង់គឺជាជម្រកដ៏សុខសាន្តសម្រាប់សត្វព្រៃនិងរុក្ខជាតិ និងជាជម្រករបស់ពពួកថនិកសត្វធំៗ ដូចជាដំរី ទន្សោង គោព្រៃ និងខ្លាឃ្មុំ ព្រមទាំង

ប្រភេទសត្វព្រៃបង្គោលផ្សេងៗទៀត (Olsson and Emmett 2007)។ ក្រុមអ្នកស្រាវជ្រាវបានសង្កេតឃើញថា ដើមឈើដែលមានអាយុកាលយូរឆ្នាំ និងមានកម្ពស់ខ្ពស់ៗ ដែលដុះនៅក្នុងព្រៃផ្តល់ជាជម្រកដ៏សំខាន់សម្រាប់ប្រភេទសត្វ និងរុក្ខជាតិផ្សេងៗ។ ភាគច្រើននៃ ដើមឈើទាំងនេះ គឺជាទីពំនាក់របស់ប្រភេទខុសៗគ្នានៃពពួករុក្ខជាតិអេពីភិត ដូចជាអរគីដេ បណ្ណង្គជាតិ រុក្ខជាតិវល្លិ៍ ស្លែ លីកែន និងពពួកសត្វមួយចំនួន ដូចជាពពួកជីងចក់ បក្សីធ្វើសំបុក និងពពួកសត្វល្អិត។ ប្រភេទ ទាំងនេះក៏ក្លាយជាប្រភពអាហារ សម្រាប់ភាវរស់ធំជាង។ ដោយមិនគិតពីចំនួនព្រៃឈើដែលនៅសេសសល់ផ្សេងទៀត ការថយចុះនៃបរិមាណដើមឈើទាំងនេះអាចបំផ្លាញជីវៈចម្រុះឲ្យហិនហោចបាន។

ព្រៃឡង់ គឺជាព្រៃដែលសម្បូរទៅដោយធនធានជីវសាស្ត្រដែលទ្រទ្រង់ដល់ជីវភាពរស់នៅរបស់សហគមន៍អាស្រ័យលើព្រៃឈើ ក៏ដូចជារួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈការនាំចេញអនុផលព្រៃឈើ (NTFP) និងសេវាកម្មបរិស្ថានផ្សេងៗទៀត។ គួរកត់សម្គាល់ផងដែរថាប្រភេទដើមខ្លុងត្បែងចំនួន៥ប្រភេទ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សហគមន៍ដែលរស់នៅក្នុងតំបន់ព្រៃ និងពឹងអាស្រ័យលើព្រៃឈើ។ ប្រភេទទាំងនេះរួមមានប្រភេទដើមឈើផ្តល់ជ័ររាវចំនួន៣ប្រភេទគឺឈើទាលបង្គួយឬនាងដែងក្រហម (Dipterocarpus costatus), ដើមឈើទាលបាយ (D. alatus) និងដើមត្រាច (D. intricatus) និងប្រភេទផ្តល់ជ័ររឹង២ប្រភេទគឺធ្មឹក (Shorea obtusa) និងដើមពាំងភ្នំ (*S. siamensis*)។ ប្រភពជ័រមួយក្នុងចំណោមប្រភពជ័រសំខាន់ៗនៃដើមឈើទាលបង្គួយ (D. costatus), ដើមត្រាច (D. intricatus) និងឈើទាលបាយ (D. alatu) ត្រូវបានទាញយកផលពីតំបន់ទេសភាពនេះ។ ឈ្មួញក្នុងស្រុកបានប្រាប់ក្រុមអ្នកស្រាវជ្រាវថា ជ័រឈើរាវចំនួន ១០.០០០ កាន (មួយកានស្មើ៣០លីត្រ ឬស្មើ២៨គីឡូក្រាម) ដែលអ្នកភូមិចំនួន៤ (ភូមិស្ពុង បដិវត្តិ ភ្នាក់រលើក និងស្រែវាល) បានផ្គត់ផ្គង់ជារៀងរាល់ឆ្នាំទៅដល់ឈ្មួញកណ្តាល៤នាក់ នៅក្នុងភូមិ២ គឺភូមិភ្នាក់រលើក និងភូមិស្រែវាល។ ជ័រឈើនេះត្រូវបានដឹកជញ្ជូនទៅកាន់ដេប៉ូធំនៅក្នុងស្រុកឆែបនៃខេត្តព្រះវិហារសម្រាប់កែច្នៃបន្ថែម និងនាំចេញទៅកាន់ប្រទេសវៀតណាម និងប្រទេសថៃ (តាមរយៈការទំនាក់ទំនងព័ត៌មានជាមួយឈ្មួញប្រកបរបរទិញជ័រឈើក្នុងស្រុក នៅភូមិភ្នាក់រលើក កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤)។ ប្រេងជ័រឈើដែលបានពីដើមស្រល់ស្លឹកពីរ (Pinus murkusii) ក៏ត្រូវបានសហគមន៍នៅខេត្តកំពង់ធំចម្រាញ់យកផងដែរកាលពីមុន ប៉ុន្តែក៏ត្រូវបានបញ្ឈប់ទៅវិញ ដោយសារការទាញផលជ័រឈើនេះបានបណ្តាលឲ្យដើមស្រល់ទាំងប៉ុន្មានត្រូវងាប់អស់ជាច្រើន (តាមរយៈការទំនាក់ទំនងព័ត៌មានជាមួយអតីតប្រធានក្រុមប្រឹក្សាឃុំ កាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៤)។

ប្រភេទអនុផលព្រៃឈើមួយចំនួនទៀត ឧទាហរណ៍ដូចជាក្រវាញបៃតង ទឹកឃ្មុំ ផ្តៅ ឫស្សី ជ័ររឹង ផ្លែឈើព្រៃជាដើម អាចផ្តល់ជាប្រភពធនធានដ៏ចាំបាច់សម្រាប់ទាំងការចិញ្ចឹមជីវិត ទាំងការប្រ កបរបរពាណិជ្ជកម្ម។ បច្ចុប្បន្ននេះមិនមានតម្រូវការទីផ្សារក្នុងស្រុកសម្រាប់អនុផលព្រៃឈើទាំងនេះទេ

ប៉ុន្តែមានតម្រូវការលើទីផ្សារអន្តរជាតិ។ ព្រៃឡង់ក៏ជាជម្រកនៃរុក្ខជាតិឱសថ ដូច្នេះវាមានសារៈប្រយោជន៍ណាស់សម្រាប់ការស្រាវជ្រាវខាងវិទ្យាសាស្ត្រនាពេលអនាគតទៅតាមវិស័យពាក់ព័ន្ធ។

បើគិតពីលក្ខណៈជលសាស្ត្រ ព្រៃឡង់បានដើរតួនាទីជាតំបន់ផ្ទៃរងទឹកភ្លៀងយ៉ាងសំខាន់សម្រាប់បឹងទន្លេសាប និងទន្លេមេគង្គ ព្រមទាំងរួមចំណែកបានមួយកម្រិតធំ ដល់ការគ្រប់គ្រងទឹកជំនន់នារដូវវស្សាក្នុងរវាងខែសីហា និងខែកញ្ញា (Schmidt L. & Thailade I., 2010) ក៏ដូចជាផ្តល់នូវសេវាកម្មបរិស្ថានដ៏ល្អប្រសើរផងដែរ។ យ៉ាងណាមិញ ព្រៃឡង់ក៏បានរួមចំណែកយ៉ាងធំធេងក្នុងការសម្របសម្រួលទឹកក្រោមដីនារដូវប្រាំងថែមទៀតផង។

ជារួម គេឃើញច្បាស់ណាស់ថាព្រៃឡង់ពិតជាផ្តល់នូវសារប្រយោជន៍ជាច្រើនយ៉ាង ទាំងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងតុល្យភាពអាកាសធាតុនៅក្នុងស្រុក។



រូបភាព 6 ការកាត់ដើមឈើយកជ័រថ្មី នៅតំបន់ព្រៃឡង់



រូបភាព 7 តំណក់ជ័រឈើ នៅតំបន់ព្រៃឡង់



រូបភាព 8 ទីតាំងព្រៃជាំទឹកដែលសម្បូរ ដើមផ្តៅ នៅតំបន់ព្រៃឡង់

# កិច្ចពិភាក្សា

កត្តាគម្រាមកំហែង

បើយោងតាមការសង្កេតរបស់ក្រុមអ្នកស្រាវជ្រាវបានឲ្យដឹងថា មានកត្តាជំរុញ៥ចំនុច សំខាន់ៗដែលនាំឲ្យមានកាប់ព្រៃឈើនៅតំបន់ព្រៃឡង់ ក្នុងនោះរួមមានការកែប្រែដីព្រៃទៅជាដីសម្រាប់ប្រកបរបរកសិកម្មនៅក្នុងទម្រង់ជាដីសម្បទានសេដ្ឋកិច្ច រួមមានទាំងការដាំដំណាំកៅស៊ូ និងការធ្វើអាជីវកម្មរុករករ៉ែមាស ការធ្វើកសិកម្មខ្នាតតូចគ្មានប្រសិទ្ធភាពរបស់សហគមន៍ និងការធ្វើ ចំណាកស្រុកចូលមករស់នៅក្នុងតំបន់ព្រៃ ការកាប់ឈើដ៏ច្រើនសន្ធឹកសន្ធាប់ដែលមិនអាចការពារបានពីសំណាក់អ្នកដែលរស់នៅក្នុងសហគមន៍នោះ និងអ្នកដែលមកពីក្រៅសហគមន៍។

ការផ្តល់សម្បទានដីសេដ្ឋកិច្ចជាច្រើនទាំងនៅក្នុង និងនៅជាប់តំបន់ព្រៃឡង់ ត្រូវបានផ្តល់ទៅឱ្យក្រុមហ៊ុនបរទេស និងក្រុមហ៊ុនក្នុងស្រុកសម្រាប់ការធ្វើអាជីវកម្មរុករករ៉ែ និងសកម្មភាព កសិឧស្សាហកម្ម (ប្រភព Aruna 2009 & Allan Michaud 2013) ដែលជាការបន្ថែមសម្ពាធ យ៉ាងធ្ងន់ធ្ងរដល់ការខូចរេចរឹលនៃឋានប្រព័ន្ធ។ ការផ្តល់ដីសម្បទានមួយចំនួនស្ថិតនៅក្នុង តំបន់ដែលមានគុណតម្លៃជីវៈចម្រុះមហាសាល (ប្រភព NGO Forum 2013)។ តំបន់ដ៏ធំមួយដែលមានទីតាំងស្ថិតនៅក្នុងឃុំដំកំបែត ស្រុកសណ្តាន់ ត្រូវបានកាប់ឈូសឆាយទាំងស្រុងសម្រាប់ដាំ ដំណាំកៅស៊ូ (ibid)។ ជាធម្មតាទៅហើយនៅទូទាំងប្រទេសកម្ពុជា បុគ្គលិកសន្តិសុខ និងកម្មករ ដែលក្រុមហ៊ុនបានជួលឲ្យបម្រើការងារនៅទីនោះ ក៏បានរួមចំណែកពាក់ព័ន្ធក្នុងការបរបាញ់សត្វព្រៃ ការកាប់ឈើ និងការនេសាទខុសច្បាប់។

ការជីកកកាយរុករករ៉ែមាស បានធ្វើឡើងទាំងគ្រួសារសហគមន៍ និងក្រុមហ៊ុននានា ដែលបានទទួលអាជ្ញាប័ណ្ណធ្វើអាជីវកម្មរុករករ៉ែពីរាជរដ្ឋាភិបាល (តាមរយៈការសង្កេតដោយផ្ទាល់ និងការសាកសួរព័ត៌មានពីសមាជិកសហគមន៍ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤)។ ភ្នំដីដែលស្ថិតក្នុងភូមិសាស្រ្តស្រុកណ្តាន់ ត្រូវបានគេស្គាល់ច្បាស់ថាមានការ ជីកកកាយរុករករ៉ែមាសពីសំណាក់ប្រជាសហគមន៍មូលដ្ឋាន និងស្ថិតនៅក្រោមការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនចិន (Aruna 2009)។ នៅមានតំបន់ជីករុករករ៉ែតូចៗមួយទៀតស្ថិតនៅភូមិដំបូកស ជាប់នឹងភូមិកំពង់ដំរី ឃុំបឹងចារ ស្រុកសំបូរ ក៏ត្រូវបានធ្វើឡើងទាំងគ្រួសារសហគមន៍ ឬក្រុមហ៊ុនចិន (តាមរយៈការសង្កេតដោយផ្ទាល់ និងការសាកសួរព័ត៌មានពីសមាជិកសហគមន៍ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤)។ តំបន់ជីករ៉ែនេះមានទីតាំងភូមិសាស្រ្តស្ថិតនៅជាប់តំបន់ព្រៃឡង់តែម្តង។ ផ្ទាំងថ្មត្រូវបានវាយបំបែក និងរែងកកាយត្រងយកមាស។ មានការរាយការណ៍ថា មានការប្រើប្រាស់សារធាតុគីមីក្នុងការទាញយករ៉ែមាស នៅក្នុងតំបន់នេះផងដែរ (តាមរយៈការសាកសួរព័ត៌មានពីសមាជិកសហគមន៍ ក្នុងឃុំបឹងចារ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ

២០១៨)។ ការប៉ាន់ស្មានលើការផ្តល់ដីសម្បទានសម្រាប់រុករករ៉ែ មានបង្ហាញនៅក្នុងផែនទី៧ ដែលជាប្រភពបានមកពីទិន្នន័យអំពីការអភិវឌ្ឍបើកចំហ (Open Development ឆ្នាំ២០១៥)។




ផែនទី 7 ការផ្តល់ដីសម្បទានរុករករ៉ែ និងឆ្នាំនៃការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្ម

(យោងតាមការសង្កេតរបស់ក្រុមស្រាវជ្រាវ) អ្នកភូមិគ្រប់ភូមិទាំងអស់ដែលក្រុមការងារស្រាវជ្រាវបានចុះទៅជួបសួរនាំ សុទ្ធតែមានជាប់ពាក់ព័ន្ធនឹងការកាប់ឈើនាពេលបច្ចុប្បន្ន ដើម្បីយកទៅសាងសង់លំនៅដ្ឋាន និងលក់នៅទីផ្សារក្នុងស្រុក។ ឈើត្រូវបានកាត់ និងច្រៀកជាបន្ទះៗ ដោយការប្រើប្រាស់រណារអារឈើ រួចដឹកជញ្ជូនចេញពីក្នុងព្រៃចូលទៅក្នុងភូមិ។ គោយន្ត និងជួនពេលខ្លះរថយន្តកែច្នៃដោយខ្លួនឯងត្រូវបានប្រើប្រាស់ធ្វើជាមធ្យោបាយក្នុងការដឹកជញ្ជូនឈើ ដែលកាប់រួច ជាជាងការប្រើប្រាស់រទេះគោ (តាមរយៈការទំនាក់ទំនងព័ត៌មានជាមួយសមាជិក សហគមន៍ក្នុងឃុំផ្ទា កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ ២០១៥)។ ការកាប់ឈើច្រើនតែធ្វើឡើងនៅរដូវប្រាំង ដោយសាររដូវនេះមានអំណោយផលងាយស្រួលក្នុងការដឹកជញ្ជូនឈើពីក្នុងព្រៃ។ តាមការរាយការណ៍បានឲ្យដឹងថា ភូមិផ្ទា ឃុំផ្ទា ស្ថិតនៅក្នុងភូមិសាស្ត្រព្រៃឡង់ ត្រូវបានគេកាប់យកឈើប្រមាណជា៧០ម៉ែត្រគូបជារៀងរាល់ថ្ងៃនារដូវប្រាំង (តាមរយៈការទំនាក់ទំនងព័ត៌មានជាមួយក្រុមប្រឹក្សាឃុំផ្ទា កាលពីថ្ងៃ១៨ ខែកុម្ភៈ ឆ្នាំ២០១៥)។ ប្រសិនបើគ្មានការយកចិត្តទុកដាក់ទប់ស្កាត់ ការកាប់ឈើនៅតាមភូមិទាំងអស់នៃខេត្តទាំង៤នៅជុំវិញតំបន់ព្រៃឡង់ទេនោះ ការកាប់ឈើខ្នាតតូច ដោយគ្រួសារប្រជាសហគមន៍ អាចកើតឡើងកាន់តែច្រើនឡើងៗជាក់ជាមិនខាន។ ការកាប់ឈើមិនត្រឹមតែបណ្តាលឱ្យបាត់បង់ដើមឈើដ៏មានតម្លៃតែប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការបំផ្លិចបំផ្លាញរុក្ខជាតិដែលនៅជុំវិញនោះផងដែរ ដូចជាកូនទើបដុះ និងរុក្ខជាតិតូចៗដទៃទៀត និងធ្វើឲ្យគម្លាតព្រៃត្រូវបើកចំហ ជាហេតុបណ្តាលឲ្យប្រភេទរុក្ខជាតិរាតត្បាតនានាងាយស្រួលជ្រៀតជ្រែក។ លើសពីនេះទៅទៀត ប្រសិនបើមានការកាប់ព្រៃកើតឡើងជាបន្តបន្ទាប់នៅក្នុងតំបន់ដ៏ធំណាមួយ វានឹងអាចបណ្តាលឲ្យមានភ្លើងឆេះព្រៃមិនខាន។ ភាគច្រើននៃប្រភេទឈើប្រណីតមានតម្លៃដូចជាឈើគ្រញូង ដែលបានក្លាយទៅជាប្រភេទឈើកម្រណាស់រួចទៅហើយ ហើយអ្នកកាប់ឈើបានបង្វែរការស្វែងរកប្រភេទឈើមានតម្លៃបំផុតបន្ទាប់ពីឈើគ្រញូងនេះ។ ដើមស្រឡៅ (Largestroemia calyculata) ដែលដុះនៅក្នុងព្រៃពាក់កណ្តាលស្រោង និងព្រៃរបោះចម្រុះ ទំនងជានឹងត្រូវកាប់យ៉ាងច្រើនសន្ធឹកសន្ធាប់ជាបន្តទៀត (ibid)។ ប្រភេទព្រៃនេះនឹងក្លាយជាងាយប្រឈមនឹងភ្លើងឆេះព្រៃនាពេលអនាគតដ៏ខ្លី ដោយសារតែមានកម្ទេចកាកសំណល់ជាច្រើន ដែលនៅសេសសល់បន្ទាប់ពីកាប់ឈើរួច។ ភ្លើងឆេះព្រៃដែលកើតឡើងនៅក្នុងព្រៃពាក់កណ្តាលស្រោង នឹងបំផ្លាញឋានប្រព័ន្ធទាំងមូល និងធ្វើឱ្យខូចសមាសភាពរុក្ខជាតិ ដោយសារតែការរាតត្បាតពីសំណាក់ប្រភេទរុក្ខជាតិជ្រុះស្លឹកប្រចាំឆ្នាំចម្លែកៗ បន្ទាប់ពីអស់ព្រៃចាស់ៗ។

ក្រុមអ្នកស្រាវជ្រាវ ក៏បានប្រទះឃើញថាមានការប្រកបរបរកសិកម្មខ្នាតតូចនៅតាមតំបន់មួយចំនួននៃព្រៃឡង់ផងដែរ។ ការប្រកបរបរកសិកម្មខ្នាតតូចទាំងនេះ ភាគច្រើនស្ថិតនៅក្នុងតំបន់ព្រៃរបោះ ព្រៃរបោះចម្រុះ និងព្រៃពាក់កណ្តាលស្រោង ដែលសុទ្ធសឹងជាព្រៃដែលសម្បូរទៅដោយដើមឈើមានតម្លៃខ្ពស់។ ចំណែកដ៏តូចមួយចំនួននៃព្រៃស្រោងជាំទឹកនៅចំកណ្តាលទ្រូងព្រៃឡង់ ដែល

មានទីតាំងស្ថិតនៅក្នុងភូមិភ្នាក់រលឹក តាមដងផ្លូវទៅភូមិស្អាង ឃើញថាមានសកម្មភាពកាប់ឆ្ការព្រៃថ្មីៗនៅឡើយ ដោយមិនដឹងថាក្នុងគោលបំណងអ្វីទេ។

ក្រុមអ្នកស្រាវជ្រាវបានសង្កេតឃើញថាបច្ចុប្បន្ននេះ គ្រួសារជាច្រើនដែលគ្មានដីធ្លី ឬក្រុមគ្រួសារដែលបានកាន់កាប់ដីធ្លីតិចតួចសម្រាប់ប្រកបរបរកសិកម្ម បានធ្វើចំណាកស្រុកចូលទៅរស់នៅតំបន់ព្រៃ ដែលមាន ប្រជាជនតិចនៅឡើយ ក្នុងគោលបំណងស្វែងរកដីសម្រាប់ដាំដំណាំស្រូវ ដាំដំណាំកៅស៊ូ សណ្តែក ដំឡូងមី ដើមស្វាយចន្ទី និងដំណាំយកផលដទៃទៀត ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេ។ ចំណែកសកម្មភាពដែលកើតមានជាទូទៅនៅតាមតំបន់ផ្សេងទៀតនៃប្រទេសកម្ពុជានោះ គឺការទិញដីពីប្រជាសហគមន៍មូលដ្ឋានរបស់ជនចំណាកស្រុក បន្ទាប់មកក៏ចាប់ផ្តើមដាំដុះដំណាំផ្សេងៗរបស់ខ្លួន ដែលបញ្ហានេះត្រូវគេសង្ស័យថាកំពុងកើតមាននៅក្នុងតំបន់ព្រៃឡង់។ ស្រដៀងគ្នានេះដែរ គ្រួសារក្រីក្រដែលធ្វើចំណាកស្រុកមកពី ស្រុកផ្សេងៗ ឬខេត្តផ្សេងៗ តែងរំពឹងថាអាចស្វែងរកទីតាំងជ្រកកោនណាមួយនៅក្នុងព្រៃ រួចចាប់ផ្តើមកាប់ឆ្ការព្រៃដោយខ្លួនឯងសម្រាប់ធ្វើជាលំនៅដ្ឋាន និងធ្វើកសិកម្មតែម្តង។ សូចនាករនានាបានបង្ហាញថាការឈូសឆាយដីព្រៃនឹងបន្តកើតមានជាដរាបប្រសិនណាគ្មានការគ្រប់គ្រងឲ្យបានត្រឹមត្រូវទេនោះ។

ការគម្រាមកំហែងមួយទៀតទៅលើធនធានធម្មជាតិដែលមិនជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងការគម្រាមកំហែងដល់ព្រៃឈើនោះគឺ ការនេសាទខុសច្បាប់ដោយប្រើប្រាស់អគ្គិសនីឆក់។ ការនេសាទបែបនេះអាចប៉ះពាល់ដោយប្រយោងដល់ព្រៃឈើ ពីព្រោះនៅពេលដែលប៉ូពុយឡាស្យុងត្រីនៅក្នុងតំបន់នេះធ្លាក់ចុះ នោះជាហេតុធ្វើឲ្យអ្នកស្រុកត្រូវចាប់យកមុខរបរកសិកម្ម និងមុខរបរកាប់ឈើដើម្បីដោះស្រាយជីវភាពរស់នៅរបស់ខ្លួនទៅវិញ។ ស្ទើរតែគ្រប់ក្រុមគ្រួសារ ក៏ដូចជាសមត្ថកិច្ចមូលដ្ឋានដែលរស់នៅក្នុងភូមិធ្នា សុទ្ធតែបានប្រើប្រាស់ឧបករណ៍នេសាទឆក់ដោយអគ្គិសនី (តាមរយៈទំនាក់ទំនងព័ត៌មានជាមួយសមាជិកសហគមន៍ ភូមិធ្នា កាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៤)។ ត្រីងៀតត្រូវបាន ដឹកជញ្ជូនតាមម៉ូតូជារៀងរាល់ថ្ងៃចេញពីខេត្តព្រះវិហារសំដៅមកភូមិធ្នា និងភូមិផ្សេងទៀតបន្តទៅភូមិស្អាង និងឆ្លងកាត់តំបន់ទ្រូងព្រៃឡង់ ដើម្បីយកទៅលក់ឱ្យអ្នករស់នៅក្នុងព្រៃ ដែលធ្លាប់តែពឹងអាស្រ័យលើសាច់ត្រីយ៉ាងហូរហៀរនៅក្នុងតំបន់ដែលពួកគេរស់នៅ (ibid)។



រូបភាព 9 ការកាប់ព្រៃឈើ និងការដុតព្រៃ នៅតំបន់ព្រៃឡង់



រូបភាព 10 ការកាប់ព្រៃឈើ និងការដុតព្រៃ នៅតំបន់ព្រៃឡង់

## ការផ្តល់ជាអនុសាសន៍

➢គួរផ្សព្វផ្សាយអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារនិងអភិរក្សជីវៈចម្រុះ "ព្រៃឡង់" ដែលមានផ្ទៃដីសរុប៤៨០.០០០ហិកតា ដែលនឹងត្រូវអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា និងត្រូវអនុវត្តឲ្យមានប្រសិទ្ធភាពក្នុងតំបន់ព្រៃឡង់។

➢គួរពង្រឹងការអនុវត្តច្បាប់ស្តីពីបទល្មើសព្រៃឈើ ការប្រមាញ់ និងការនេសាទខុសច្បាប់ ឲ្យបានជាបន្ទាន់ ដើម្បីកាត់បន្ថយសម្ពាធដែលចេះតែបន្តកើតមានទៅលើធនធានធម្មជាតិ។

➢គួរបង្កើនការយល់ដឹងអំពីអនុក្រឹត្យ និងច្បាប់ព្រៃឈើ ក៏ដូចជាគុណតម្លៃដ៏ធំធេងនៃឋានប្រព័ន្ធតំបន់ទេសភាពព្រៃឡង់ និងសេដ្ឋកិច្ចក្នុងតំបន់នៅទូទាំងសហគមន៍ក្នុងខេត្តចំនួនបួននេះ។ គួរបញ្ចូលទៅក្នុងកម្មវិធីសិក្សាអប់រំស្តីពីបរិស្ថាន តាមរយៈការបង្រៀន ផ្ទាំងរូបភាពឬខ្សែភាពយន្តខ្លី ដើម្បីអប់រំសិស្សានុសិស្សឲ្យយល់ដឹងពីគុណតម្លៃនៃព្រៃឈើ សត្វព្រៃ និងបរិស្ថាននៅជុំវិញតំបន់ដែលពួកគេកំពុងរស់នៅ។

➢គួរអនុញ្ញាតឲ្យមានការចូលរួមពាក់ព័ន្ធពីភាគីសំខាន់ៗ ជាពិសេសប្រធានភូមិ ក្រុមប្រឹក្សាឃុំ នគរបាលឃុំ មន្ត្រីយោធា និងប្រជាសហគមន៍ ទាក់ទងនឹងការការពារ និងការគ្រប់គ្រងព្រៃឡង់។ ភាគីទាំងនេះគួរតែបានចូលរួមនៅក្នុងគ្រប់សកម្មភាពទាំងអស់ រាប់ចាប់តាំងពីការផ្សព្វផ្សាយការយល់ដឹង រហូតដល់ការចូលរួមក្នុងភារកិច្ចល្បាតព្រៃ ដោយមិនគិតពីការចំណាយ និងកម្រិតនៃឆន្ទៈចូលរួមជាក់ស្តែងដែលពួកគេមាន។ វិធីជាយុទ្ធសាស្រ្តនេះនឹងអាចផ្តល់នូវលទ្ធផលរយៈពេលវែងសម្រាប់ការការពារព្រៃឡង់ផងដែរ។

➢គួរផ្តោតការយកចិត្តទុកដាក់ទៅលើតម្រូវការរបស់អ្នកភូមិ និងអ្នករស់នៅតាមឃុំនីមួយៗ ក្នុងតំបន់ព្រៃឡង់ ក៏ដូចជាការកំណត់ឲ្យបានច្បាស់លាស់អំពីព្រំតំបន់សម្រាប់ធ្វើជាដីកសិកម្ម សម្រាប់ការតាំងទីលំនៅ និងសម្រាប់រក្សាទុកជាព្រៃបម្រុង។ គួរបង្កើតឲ្យបានកាន់តែច្រើននូវសហគមន៍ព្រៃឈើ ដើម្បីធានាមិនឲ្យកើតមានផលរំខានដោយសារការប្រែប្រួលលើការប្រើប្រាស់ដីនៅតាមតំបន់ក្បែរៗភូមិ ក៏ដូចជាដើម្បីធានាលើការប្រើប្រាស់តំបន់ទេសភាពនេះ ប្រកបដោយនិរន្តរភាព និងសម្រាបធ្វើជាទ្រនាប់ការពារព្រៃផងដែរ។

➢គួរធ្វើយ៉ាងណាឲ្យប្រជាសហគមន៍ដែលពឹងអាស្រ័យលើព្រៃឈើនៅតំបន់ព្រៃឡង់អាចប្រកបរបរចិញ្ចឹមជីវិតបានច្រើនយ៉ាង តាមរយៈការធ្វើឱ្យប្រសើរឡើងនូវការប្រកបរបរកសិកម្ម អេកូ

ទេសចរណ៍ និងប្រព័ន្ធកសិកម្មអតិផល និងការណែនាំបង្ហាញអំពីប្រព័ន្ធកសិរុក្ខកម្មដែលមានគុណប្រយោជន៍ប្រសើរជាងសម្រាប់ការចិញ្ចឹមជីវិតក្នុងគ្រួសារ។ គួរលើកកម្ពស់ការអភិវឌ្ឍអនុផលព្រៃឈើ តាមរយៈវិធីសាស្ត្រផ្សេងៗដូចជាតាមរយៈបច្ចេកទេសប្រមូលផល ប្រកបដោយនិរន្តរភាព ការបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីការបង្កើនផលិតផល និងការបង្កើតឲ្យមានទីផ្សារលក់។

➢គួរដាក់បញ្ចូលគម្រោងកាត់បន្ថយការបំភាយឧស្ម័ន និងការខូចរេចរឹលនៃព្រៃឈើ (REDD +) ដែលបានសិក្សាស្រាវជ្រាវកាលពីឆ្នាំ២០១១ ចូលទៅក្នុងផែនការគ្រប់គ្រងតំបន់ទេសភាពនេះ។

➢គួរគៀងគរមូលនិធិឲ្យបានគ្រប់គ្រាន់ដើម្បីគាំទ្រដល់សកម្មភាពខាងលើនេះឱ្យមានប្រសិទ្ធភាព និងអាចធានាបាននូវការការពារតំបន់ទេសភាពដ៏វិសេសវិសាលមួយនេះ។

# ៣. ថនិកសត្វ

ដោយលោក បេន ហាយេស (Ben Hayes)

## *សេចក្តីផ្តើម*

ការសិក្សាស្រាវជ្រាវជាប្រវត្តិសាស្ត្រអំពីថនិកសត្វនៅប្រទេសកម្ពុជា មានចំនួនតិចតួចណាស់ ដែលធ្លាប់បានធ្វើឡើងនៅចន្លោះទសវត្សឆ្នាំ១៩៣០ ដល់ទសវត្សឆ្នាំ១៩៦០ ដោយបានផ្តោតទៅលើប្រភេទសត្វធំៗ ដូចជា គោព្រៃ (Wharton 1957, Osgood 1932)។ ប៉ុន្តែ ដោយសារតែមានជម្លោះស៊ីវិលកើតឡើង ការកាន់កាប់ពីសំណាក់បរទេស និងអស្ថិរភាពក្នុងប្រទេស ទើបធ្វើឲ្យការស្រាវជ្រាវបន្ថែមទៀតត្រូវបានអាក់ខានទៅវិញរហូតដល់ទសវត្សឆ្នាំ១៩៩០។ មុនឈានមកដល់ការអង្កេតស្រាវជ្រាវនេះ ក៏ធ្លាប់មានការស្រាវជ្រាវតិចតួច ទៅលើប្រភេទថនិកសត្វនៅតំបន់ព្រៃឡង់ផងដែរ។ ការដាក់ម៉ាស៊ីនថតរូបស្វ័យប្រវត្តខ្លះ ការពិនិត្យសង្កេតជាទូទៅខ្លះ និងការអង្កេតស្រាវជ្រាវជាក់លាក់ មួយចំនួនទៅលើប្រភេទដោយឡែកមួយចំនួនតូច ត្រូវបានធ្វើឡើងដោយអង្គការអភិរក្សអន្តរជាតិ (CI) អង្គការមូលនិធិសកលសម្រាប់អភិរក្សធម្មជាតិ (WWF) អង្គការសត្វព្រៃនិងរុក្ខជាតិអន្តរជាតិ (FFI) និងអង្គការសង្គមអភិរក្សសត្វព្រៃ (WCS) នៅចន្លោះឆ្នាំ២០០២ និងឆ្នាំ២០០៨ (សូមមើល Olssen and Emmett, 2007)។ ទោះយ៉ាងណាការសិក្សាស្រាវជ្រាវទាំងនេះ ធ្វើឡើងដោយឆាប់រហ័ស ទៅតាមលទ្ធភាពជាក់ស្តែង រួមជាមួយនឹងពេលវេលាចុះសិក្សាដល់ទីកន្លែងដ៏តិចតួចប៉ុណ្ណោះ។

## *វិធីសាស្ត្រស្រាវជ្រាវ*

ខាងក្រោមនេះគឺជាវិធីសាស្ត្រ ដែលបានអនុវត្តក្នុងការអង្កេតស្រាវជ្រាវទៅលើថនិកសត្វៈ

➢**ការដាក់ម៉ាស៊ីនថតរូបស្វ័យប្រវត្ត(អន្ទាក់កាមេរ៉ា)**

ម៉ាស៊ីនថតរូបស្វ័យប្រវត្តប្រភេទ Bushnell ចំនួនដល់ទៅ១៧គ្រឿងត្រូវបានប្រើប្រាស់ ដោយតំឡើងនៅចន្លោះខែកក្កដា ឆ្នាំ២០១៤ ដល់ខែកុម្ភៈ ឆ្នាំ២០១៥។ ទីតាំងនៃការដាក់ម៉ាស៊ីនថតរូប ត្រូវបានដាក់ប្រមូលផ្តុំនៅតំបន់កណ្តាលព្រៃស្រោង (សូមមើលផែនទី៦) ដោយដាក់នៅត្រង់ "ទីតាំងល្អបំផុត" ដូចជានៅតាមផ្លូវដែលសត្វព្រៃធ្វើសកម្មភាព កន្លែងមានប្រភពទឹក និងទីតាំងដែលសត្វចូលចិត្តរកចំណី។ គេបានផ្តោតការយកចិត្តទុកដាក់ជាពិសេសនៅរាល់ទីកន្លែងណា ដែលបានរកឃើញថាមានសញ្ញាថនិកសត្វ។ ម៉ាស៊ីនថតរូបស្វ័យប្រវត្តទាំងនេះត្រូវបានដាក់ចោលនៅក្នុងព្រៃ សម្រាប់រយៈពេលពី៤ទៅ៨សប្តាហ៍ និងបានកំណត់ឲ្យដំណើរការទាំងថ្ងៃទាំងយប់ បន្ទាប់មកត្រូវផ្លាស់ទៅដាក់វិលជុំនៅតាមទីតាំងផ្សេងៗទៀត។ ចំនួនថ្ងៃនៃការដាក់ម៉ាស៊ីនថតរូបឲ្យដំណើរការ គឺបានសម្រាប់ចំនួន៣៥៥៥ថ្ងៃ។ ការងារអង្កេតស្រាវជ្រាវបន្ថែមត្រូវបានអនុវត្តនៅក្នុងតំបន់ភាគខាងជើងនៃព្រៃឡង់ ទាំងនៅក្នុង

និងនៅជុំវិញតំបន់ទួលស្រទាប់ថ្ម Karst នៅជាប់ព្រំប្រទល់ព្រៃការពារខេត្តព្រះវិហារ ក៏ដូចជាដំណើរសិក្សារយៈពេលខ្លីឆ្ពោះទៅកាន់តំបន់ភាគខាងត្បូងនៃព្រៃឡង់។

➢ **ការដៅចំណុចពេលរាត្រី**

គេបានដើរឆ្លងកាត់ផ្លូវនានានៅក្នុងតំបន់សមស្របមួយចំនួនមានដូចជាផ្លូវថ្មើរជើង ជាយព្រៃ និងដងទន្លេស្ងួតទឹក នៅពេលវេលាខុសៗគ្នានៅពេលយប់។ ប្រភេទសត្វនានាត្រូវបានគេប្រទះឃើញដោយការរកមើលពន្លឺចាំងពីភ្នែកសត្វទៅនឹងស្ប៉ិចពណ៌ក្រហម ដោយការប្រើពិលឆ្លុះពាក់លើក្បាល និងពិលបាញ់ពន្លឺបង្រួមកម្លាំង២០០០លុយម៉ង់។

➢**សញ្ញាភិនភាគ**

គេបានដើរកាត់ផ្លូវក្នុងព្រៃនិងបាតខ្សែទឹកនានានៅពេលថ្ងៃ នៅតាមជម្រកសមស្របនានា ដើម្បីស្វែងរកសញ្ញានានា ដូចជាដានជើងសត្វព្រៃ និងកាកសំណល់លាមកសត្វ។ នៅពេលព្រហាមខ្លះ គេបានចំណាយពេលស្តាប់សូរសម្លេងស្រែករបស់ពពួកសត្វទោច។

➢**បទសម្ភាស**

គេបានធ្វើបទសម្ភាសជាមួយអ្នកភូមិនៅមូលដ្ឋាន និងអ្នកបរបាញ់សត្វ ទាក់ទងទៅនឹងព័ត៌មានជាក់លាក់អំពីប្រភេទសត្វបង្គោលមួយចំនួន ការជួញដូរសត្វព្រៃ និងទីតាំងដែលសត្វចូលចិត្តរកចំណីរូងភ្នំ និងលក្ខណៈពិសេសផ្នែកភូមិសាស្ត្រផ្សេងទៀត។

## *លទ្ធផលស្រាវជ្រាវ*

### *ការរកឃើញជារួម*

ជាសរុបថនិកសត្វចំនួន៣៦ប្រភេទត្រូវបានកត់ត្រាតាមរយៈម៉ាស៊ីនថតរូបស្វ័យប្រវត្ត ការដៅចំណុចពេលយប់ និងការងារសង្កេតពិនិត្យពេលថ្ងៃ ក្នុងការពិនិត្យរកសញ្ញាភិនភាគនិងតាមដាន។ ថនិកសត្វចំនួន១៨ប្រភេទក្នុងចំណោមទាំង៣៦ប្រភេទនេះ ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទប្រឈមនឹងការព្រួយបារម្ភសម្រាប់ការអភិរក្ស។ បញ្ជីពេញលេញនៃប្រភេទសត្វដែលបានកត់ត្រាទាំងនេះ មានបង្ហាញនៅក្នុងឧបសម្ព័ន្ធ២។

## *ប្រភេទសត្វសំខាន់ៗ*

**សត្វទន្សោង (Bos javanicus) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទសត្វជិត ផុតពូជ**

ទន្សោងត្រូវបានថតជាប់ដោយម៉ាស៊ីនថតរូបស្វ័យប្រវត្ត ពីទីតាំងជាច្រើននៅក្នុងតំបន់ព្រៃស្រោងភាគកណ្តាលនៃព្រៃឡង់។ សត្វប្រភេទនេះជាធម្មតាច្រើនមានវត្តមាននៅក្នុងតំបន់ព្រៃរបោះធំទូលាយ នៅតាមកន្លែងដែលមានថ្ម និងតាមកន្លែងដែលមានទួលដំបូក។ ទោះបីជាវារស់នៅពេលថ្ងៃតាមលក្ខណៈធម្មជាតិក្តី តែដោយសារការរំខានពីមនុស្សបានបណ្តាលឱ្យវាក្លាយជាសត្វដើរពនេចរក្នុងពេលរាត្រី ក៏ដូចជាទៅជ្រកអាស្រ័យនៅតាមជម្រកដែលមិនសូវមានភាពអនុគ្រោះ ដូចជានៅព្រៃស្រោងចម្រុះ ឬព្រៃស្រោងជាដើម (Timmins etal., 2008C)។ ប្រភេទសត្វនេះត្រូវបានគេប្រទះឃើញមាននៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ដែលរួមប្រទេសភូមា ថៃ ឡាវ វៀតណាម និងកម្ពុជា ក៏ដូចជាមាននៅប្រទេសចិនខាងត្បូង កោះចាវ៉ា និងកោះប័រណេអូ (Francis, 2008)។ នៅប្រទេសកម្ពុជា សត្វប្រភេទនេះត្រូវបានគេប្រទះឃើញមានដាច់ៗពីគ្នា គឺនៅភាគខាងជើងនិងភាគខាងកើត ក៏ដូចជានៅតំបន់ជួរភ្នំក្រវាញផងដែរ ប៉ុន្តែភាគច្រើនមាននៅក្នុងខេត្តមណ្ឌលគីរី (Timmins etal., 2008C)។ គេជឿថា ចំនួនសត្វទន្សោង នៅក្នុងប្រទេសកម្ពុជាបានធ្លាក់ចុះជាង៩០% ចាប់តាំងពីទសវត្សឆ្នាំ១៩៦០មកដោយសារតែការបរបាញ់ចេះតែបន្តកើតមានជាហូរហែរ ក៏ដូចជាដោយសារមនុស្សបង្កការរំខានដល់ទីជម្រករបស់ពួកវា និងដោយសារការប្រែក្លាយទីជំរកវាទៅជាដីកសិកម្ម និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ (Timmins etal., 2008C)។




រូបភាព 11 សត្វទន្សោងដែលថតបានដោយម៉ាស៊ីនថតរូបស្វ័យប្រវត្តក្នុងអំឡុងពេលស្រាវជ្រាវ ក្នុងតំបន់ព្រៃឡង់

**សត្វខ្ទីង (Bos gaurus) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទសត្វងាយរងគ្រោះ**

សត្វខ្ទីងចំនួនពីរក្បាលត្រូវបានថតជាប់នៅក្នុងរូបភាពម៉ាស៊ីនថតរូបនៅអំឡុងពេលស្រាវជ្រាវ នៅទីតាំងដែលសត្វចូលចិត្តរកចំណីមួយកន្លែង។ សត្វនេះក៏ធ្លាប់ត្រូវបានបញ្ជាក់ថាមានចំនួនតិចតួចដែរ តាមរយៈម៉ាស៊ីនថតរូបស្វ័យប្រវត្ត និងសញ្ញាដែលទទួលបានកាលពីលទ្ធផលសិក្សាស្រាវជ្រាវមុនៗ ( Olssen and Emmett, 2007)។ កំណត់ត្រាទាំងអស់នេះបានមកពីតំបន់ព្រៃស្រោងភាគកណ្តាលនៃព្រៃឡង់។ នៅក្នុងប្រទេសកម្ពុជា ចំនួនសត្វខ្ទីងបានធ្លាក់ចុះ៩០% ឬច្រើនជាងនេះនៅក្នុង រយៈពេលចាប់ពីចុងទសវត្សឆ្នាំ១៩៦០ ដល់ដើមទសវត្សឆ្នាំ១៩៩០។ ខ្ទីងមានភាគច្រើនជាងគេនៅតំបន់អភិរក្សជីវៈចម្រុះសីមា និងតំបន់ស្រែពក ហើយចំនួនតិចជាងនេះមាននៅក្នុងតំបន់ទំនាបភាគខាងជើង និងជួរភ្នំក្រវាញភាគកណ្តាល (Duckworth et al, 2008)។ ការបរបាញ់សត្វគឺជាកត្តាគម្រាមកំហែងដ៏ធំមួយទៅលើប្រភេទសត្វមួយនេះ គួបផ្សំនឹងការបាត់បង់ទីជម្រកសមស្រប ដែលមើលទៅឃើញថាតំបន់ដ៏ធំល្វឹងល្វើយដែលជាជម្រកដ៏សមប្រកប បែរជាមានសត្វខ្ទីងរស់នៅតែពីរទៅបីក្បាល ឬគ្មានទាល់តែសោះទៅវិញ។ ការរេចរឹលទីជម្រក ដែលចេះតែបន្តកើតមាន និងការបំផ្លែងដីព្រៃ(ធ្វើកសិកម្ម ហេដ្ឋា

រចនាសម្ព័ន្ធ) កំពុងបន្តធ្វើឲ្យប៉ះពាល់ដល់អត្រារបស់សត្វនេះ។លើសពីនេះទៅទៀត នៅមានការជួញដូរយ៉ាងទូលំទូលាយនូវផ្នែកផ្សេងៗនៃរាងកាយរបស់សត្វទន្សោង ដើម្បីយកទៅធ្វើជាគ្រឿងតាំងលម្អ និងធ្វើជាឱសថទៀតផង (Duckworth et al, 2008)។ ប្រទេសដែលមានចរាចរការជួញដូរបែបនេះ គឺប្រទេសនៅអាស៊ីអាគ្នេយ៍ ហើយក្នុងនោះមានទាំងប្រទេសនេប៉ាល់ ឥណ្ឌា និងប្រទេសចិនភាគខាងត្បូង (Francis, 2008)។

**ដំរី (Elephas maximus) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទជិតផុតពូជ**

សត្វដំរី ត្រូវបានថតជាប់ដោយម៉ាស៊ីនថតស្វ័យប្រវត្តនៅទីតាំងជាច្រើននៅទូទាំងព្រៃស្រោងភាគកណ្តាលនៃព្រៃឡង់។ កំណត់ត្រាភាគច្រើនបានមកពីទីតាំងដែលសត្វទាំងនេះចូលចិត្តរកចំណីនៅភាគខាងលិចនៃព្រៃនេះស្ថិតក្នុងភូមិសាស្ត្រខេត្តស្ទឹងត្រែង។ ដំរីជាច្រើនផ្សេងទៀតត្រូវបានកត់ត្រាថា មាននៅតាមបណ្តោយផ្លូវចាស់មួយនៃដីសម្បទានដែលមានការកាប់ឈើ ស្ថិតនៅក្នុងខេត្តក្រចេះ។ បើយោងតាមការវិភាគជាបឋមទៅលើរូបថតនិងវីដេអូដែលថតបាននោះ មានដំរីយ៉ាង ហោចណាស់ចំនួន១៣ក្បាលដែលគេបានប្រទះឃើញច្បាស់នឹងភ្នែក ដោយមានទាំងវីដេអូមួយ ដែលបង្ហាញថាមានសត្វដំរីចំនួន៥ក្បាលបានដើរឆ្លងកាត់ខាងមុខម៉ាស៊ីនថតរូបស្វ័យប្រវត្ត។ មិនមានទិន្នន័យច្បាស់លាស់ណាមួយទៅលើតួលេខពិតប្រាកដនៃសត្វដំរីនៅក្នុងព្រៃឡង់ ដែលបានមកពីការអង្កេតស្រាវជ្រាវមុនៗទេ ហើយមានឯកសារយោងតែមួយគត់គឺ Maltby & Bourchier (2010) ដែលបានផ្តល់ ការប៉ាន់ស្មានថាមានដំរីចំនួន២០ក្បាល ដោយផ្អែកលើទិន្នន័យដែលបានសម្ភាស។ ការប៉ាន់ប្រមាណ ចុងក្រោយបំផុតអំពីសត្វដំរីនៅក្នុងប្រទេសកម្ពុជា មានចាប់ពី២៥០ទៅ៦០០ក្បាល ដែលក្នុងនោះមានវត្តមាននៅតំបន់ទេសភាពវាលទំនាបភាគខាងកើត ក្នុងខេត្តមណ្ឌលគិរី និងនៅ តំបន់ជួរភ្នំក្រវាញជាទីដែលឃើញមានចំនួនដំរីច្រើនជាងគេបំផុត (Maltby & Bourchier, 2010)។ តំបន់ការពារដែលតភ្ជាប់ដ៏ជិតបំផុតជាមួយតំបន់ព្រៃឡង់ ហើយដែលមាន ដំរីដែរនោះ គឺតំបន់ដែលស្ថិតនៅក្នុងតំបន់ព្រៃការពារខេត្តព្រះវិហារ ដែលតាមការប៉ាន់ប្រមាណអាចមាននៅសល់ចំនួនពី៤-១៦ក្បាល (Brook et al, 2012)។ កត្តាគម្រាមកំហែងដ៏ធំបំផុតទៅលើសត្វដំរី នាពេលបច្ចុប្បន្ននេះ គឺ ការខូចរេចរឹល និងការបំផ្លិចបំផ្លាញទីជម្រក ដែលបណ្តាលមកពីកំណើននៃចំនួនប្រជាជនរស់នៅតំបន់នោះ ហើយឈានទៅដល់ការកើតទំនាស់ រវាងមនុស្សនិងសត្វដំរី នៅពេលដែលសត្វដំរីស៊ី ឬជាន់កម្ទេចផលដំណាំរបស់ប្រជាជន (Choudhury et al, 2008)។ កត្តាគម្រាមកំហែងធំៗផ្សេងទៀតរួមមានការបរបាញ់សត្វដំរីដើម្បីយកភ្លុក និងយកផ្នែកនៃរាងកាយ របស់ដំរី។ ប្រភេទសត្វដំរីនេះ មានវត្តមាននៅក្នុងប្រទេសបង់ក្លាដែស ប៊ូតង់ ឥណ្ឌា នេប៉ាល់ និងស្រីលង្កា នៅតំបន់អាស៊ីខាងត្បូង និងប្រទេសកម្ពុជា ចិន ឥណ្ឌូនេស៊ី (កាលីម៉ាន់តាន់ និងសូម៉ាត្រា) ឡាវ ម៉ាឡេស៊ី (ជ្រោយម៉ាឡេស៊ី និងរដ្ឋសាបាស) មីយ៉ាន់ម៉ា ថៃ និងប្រទេសវៀតណាម នៅទ្វីបអាស៊ីអាគ្នេយ៍។ របាយមួយចំនួន មាននៅក្នុងផ្នែកខ្លះនៃកោះ អានដាមេន (Choudhury et al, 2008)។




រូបភាព 12 ដំរី **Elephas maximus** ដែលថតបានដោយម៉ាស៊ីនថតស្វ័យប្រវត្ត ក្នុងអំឡុងពេលស្រាវ ជ្រាវ នៅតំបន់ព្រៃឡង់

**ឆ្កែព្រៃ (Cuon alpinus) ត្រូវបានកត់ត្រាក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទជិតផុតពូជ**

ក្នុងអំឡុងពេលនៃការអង្កេតស្រាវជ្រាវ មគ្គុទេសដើរព្រៃម្នាក់នៅក្នុងមូលដ្ឋានបានឲ្យដឹងថាគាត់ធ្លាប់បានឃើញឆ្កែព្រៃចំនួន៣ក្បាល។ ការស្រាវជ្រាវត្រូវបានធ្វើឡើងនៅក្នុងព្រៃរបោះ ស្ថិតនៅភាគខាងជើងនៃព្រៃឡង់ជិតព្រំប្រទល់តំបន់ព្រៃការពារខេត្តព្រះវិហារ។ ឆ្កែព្រៃមួយក្បាលក៏ត្រូវបានគេថតជាប់ផងដែរនៅតំបន់ព្រៃស្រោងភាគកណ្ដាល ក្នុងអំឡុងពេលនៃការអង្កេតដោយការដាក់ម៉ាស៊ីនថតរូបស្វ័យប្រវត្តរបស់អង្គការ WWF កាលពីឆ្នាំ២០០៥ នៅតំបន់ព្រៃឡង់។ ការថយចុះនៃលទ្ធភាព រកចំណី និងការបាត់បង់ទីជម្រក និងការប្រែប្រួលនេះ គឺជាកត្តាគម្រាមកំហែងដ៏ធំចំពោះសត្វឆ្កែព្រៃ (Durbin, et al. 2008)។ សត្វទាំងនេះមានវត្តមានរស់នៅទូទាំងអាស៊ីអាគ្នេយ៍ តាំងពីស៊ីបេរីភាគខាងត្បូងទៅដល់ប្រទេសឥណ្ឌា កោះស៊ូម៉ាត្រា និងកោះជ្វា (Francis, 2008)។

**សត្វក្តាន់ (Rusa unicolor) ត្រូវបានកត់ត្រាក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទងាយ រងគ្រោះ**

គ្មានការកត់ត្រាសត្វក្តាន់មួយក្បាលទេ ក្នុងអំឡុងពេលធ្វើការអង្កេតស្រាវជ្រាវបច្ចុប្បន្ននេះ។ ទោះជាយ៉ាងណាក៏ដោយ តាមរយៈការដាក់ម៉ាស៊ីនថតរូបស្វ័យប្រវត្តក្នុងពេលធ្វើអង្កេតស្រាវជ្រាវកាលពីលើកមុន ក្តាន់ត្រូវបានបញ្ជាក់អះអាងថាមាននៅក្នុងព្រៃនេះ (សូមមើល Olssen and Emmett, 2007)។ កំណត់ត្រាទាំងអស់នេះបានមកពីតំបន់ព្រៃស្រោងភាគកណ្តាលនៃព្រៃឡង់។ មគ្គុទេសក៍ដើរព្រៃក្នុងមូលដ្ឋាន និងអ្នកបរបាញ់សត្វ ដែលបានផ្តល់បទសម្ភាសក្នុងអំឡុងពេលអង្កេតស្រាវជ្រាវនេះបានរាយការណ៍ថា សត្វក្តាន់មានចំនួនតិចតួចបំផុត ហើយកម្របរបាញ់បានណាស់។ សត្វក្តាន់ប្រភេទនេះមានវត្តមាន នៅក្នុងព្រៃច្រើនប្រភេទខុសៗគ្នា ដែលរួមមានព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃរបោះ (Timmins et al., 2008B)។ របាយសត្វប្រភេទនេះមាននៅក្នុងតំបន់អាស៊ីអាគ្នេយ៍រួមមានប្រទេសមីយ៉ាន់ម៉ា ថៃ ឡាវ វៀតណាម កម្ពុជា និងជ្រោយម៉ាឡេស៊ី (Francis et al., 2008)។ ដោយសារតែភាពអនុគ្រោះរបស់ក្តាន់ចំពោះការរេចរឹលនៃព្រៃឈើ ទើបជាធម្មតាគេអាចឃើញសត្វប្រភេទនេះមានចំនួនច្រើនបំផុតនៅក្នុងតំបន់ដែលមានជម្រកខូចខាត រួមទាំងតំបន់ចំហាទៅដល់ព្រៃដែលមានលក្ខណៈដូចដើម (Timmins et al., 2008B)។ ការបរបាញ់សត្វ គឺជាកត្តាគម្រាមកំហែងធំជាងគេចំពោះសត្វប្រភេទនេះ ដែលកំពុងរស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (Francis, 2008)។

**សំពោចឥណ្ឌា (Viverra zibetha) ត្រូវបានកត់ត្រាក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទឈានទៅរងការគម្រាមកំហែង**

សំពោចប្រភេទនេះ ជាទូទៅច្រើនតែថតបានដោយម៉ាស៊ីនថតរូបស្វ័យប្រវត្តនៅតំបន់ព្រៃស្រោងភាគកណ្តាល។ ជាធម្មតាទៅហើយ ដែលការបាត់បង់ទីជម្រក និងការខូចខាតជម្រករបស់វា ក៏ដូចជាការបរបាញ់យកទៅធ្វើជាម្ហូបអាហារ និងធ្វើជាឱសថ បានក្លាយជាកត្តាគម្រាមកំហែងចំពោះសត្វប្រភេទនេះ (Duckworth et al, 2008)។ វត្តមានសត្វប្រភេទនេះមាននៅតំបន់អាស៊ីអាគ្នេយ៍ រួមមានប្រទេសនេប៉ាល់ ភាគឥសាន្តប្រទេសឥណ្ឌា និងប្រទេសចិនភាគខាងត្បូង (Francis, 2008)។

**សំពោចធំ (Viverra megaspila) ត្រូវបានកត់ត្រាក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទឈានទៅរងការគម្រាមកំហែង**

សត្វប្រភេទនេះមិនត្រូវបានកត់ត្រាក្នុងអំឡុងពេលធ្វើអង្កេតស្រាវជ្រាវនេះទេ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី វាធ្លាប់ត្រូវបានគេកត់ត្រាម្តងរួចមកហើយតាមរយៈម៉ាស៊ីនថតរូបស្វ័យប្រវត្ត នៅតំបន់ព្រៃស្រោងភាគកណ្តាលនៃព្រៃឡង់ (Olssen and Emmett, 2007)។ គេពិតជាមានការ លំបាកដឹងអំពីចំនួននៃសត្វប្រភេទនេះ ហើយមានកំណត់ត្រាតិចតួចណាស់អំពីវត្តមានរបស់វា (Duckworth et al,

2008)។ កត្តាគម្រាមកំហែងធំៗរួមមាន ការបាត់បង់ ជម្រក និងការបរបាញ់។ វត្តមានរបស់ប្រភេទសត្វនេះមាននៅតំបន់អាស៊ីអាគ្នេយ៍ រួមទាំងប្រទេសចិន ភាគខាងត្បូង(Francis 2008)។

### ខ្លាពពក (Neofelis nebulosa) ត្រូវបានកត់ត្រាក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទងាយរងគ្រោះ

ខ្លាប្រភេទនេះមិនត្រូវបានកត់ត្រាក្នុងអំឡុងពេលធ្វើអង្កេតស្រាវជ្រាវបច្ចុប្បន្ននេះឡើយ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ វាធ្លាប់ត្រូវបានគេកត់ត្រារួចមកហើយ តាមរយៈរូបភាពនៃម៉ាស៊ីនថតរូបស្វ័យប្រវត្ត នៅតំបន់ព្រៃស្រោងភាគកណ្តាលនៃព្រៃឡង់ ក្នុងអំឡុងពេលនៃការស្រាវជ្រាវរបស់អង្គការ WWF កាលពីឆ្នាំ២០០២។ វាក៏ត្រូវបានគេកត់ត្រាយ៉ាងត្រឹមត្រូវនៅតាមព្រៃការពារផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា ដោយភាគច្រើនពីតំបន់ជួរភ្នំក្រវាញ ហើយសត្វនេះមានលក្ខណៈមិនខុសគ្នាពីប្រភេទសត្វឆ្មាធំៗផ្សេងទៀតទេ ពោលគឺគេពិបាករកវាណាស់ និងជាសត្វដែលកម្រឃើញបំផុត។ ខ្លាពពកត្រូវបានគេប្រមាញ់សម្រាប់ជួញដូរដោយខុសច្បាប់ ហើយស្បែកជាច្រើនបំណែកឃើញមានលក់នៅតាមទីផ្សារ។ ចំណែកឆ្អឹងរបស់វាត្រូវបានជួញដូរសម្រាប់យកទៅធ្វើជាឱសថ រីឯសាច់យកទៅធ្វើជាម្ហូប ហើយសត្វដែលនៅរស់ ត្រូវបានគេជួញដូរ (Sandersonet al, 2008)។ សត្វប្រភេទនេះឃើញមានវត្តមាននៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ ដែលរួមមានប្រទេសចិនភាគខាងត្បូង នេប៉ាល់ ឥណ្ឌាភាគឦសាន កោះស៊ូម៉ាត្រា និងប័រណេអូ (Francis, 2008)។

### សត្វភេខ្លួនលោង Smooth–coated Otter (Lutrogale perspicillata) ត្រូវបានកត់ត្រាក្នុងបញ្ជីក្រហម របស់អង្គការ IUCN ថាជាប្រភេទងាយរងគ្រោះ

សត្វភេប្រភេទនេះមិនត្រូវបានគេកត់ត្រា ក្នុងអំឡុងពេលធ្វើអង្កេតស្រាវជ្រាវបច្ចុប្បន្ននេះ ឡើយ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ វាធ្លាប់ត្រូវបានគេកត់ត្រារួចមកហើយ តាមរយៈម៉ាស៊ីនថតរូបស្វ័យប្រវត្ត នៅតំបន់ព្រៃស្រោងភាគកណ្តាលនៃព្រៃឡង់ ក្នុងអំឡុងពេលនៃប្រើប្រាស់ម៉ាស៊ីនថតរូបស្វ័យប្រវត្តរបស់អង្គការអភិរក្សអន្តរជាតិ (CI) កាលពីឆ្នាំ២០០៨។ ការអង្កេតស្រាវជ្រាវជាក់លាក់ លើសត្វភេកាលពីមុននេះ ក៏បានប្រទះឃើញរោមសត្វភេ និងផ្នែកផ្សេងៗនៃរាងកាយរបស់វានៅតាមភូមិជាច្រើន ដែលអ្នកផ្តល់បទសម្ភាសបានរៀបរាប់ថា ពួកគេបានឃើញសត្វភេនាពេលថ្មីៗកន្លងទៅ។ ពួកគេបានបញ្ជាក់ថានៅពេលដែលពួកគេទៅប្រមូលអនុផលព្រៃឈើ ឬពេលបរបាញ់សត្វម្តងៗ ពួកគេតែងតែឃើញសត្វភេហែលទឹក ឬជួនកាលឃើញនៅលើច្រាំងទន្លេ ភាគច្រើននៅជាក្រុមដែលមានចំនួនចាប់ពី២-១០ក្បាល។ ពួកគេបានប្រាប់ថាសត្វភេជាច្រើនក្បាល ភាគច្រើនមាននៅជិតប្រឡាយទឹកអូរលុង អូរចោម អូរសៀមបុក ស្ទឹងពុងរុង និងអូរក្រោក (Olssen and Emmett, 2007)។ កត្តាគម្រាមកំហែងធ្ងន់ធ្ងរចំពោះសត្វភេរអាស៊ី គឺការបាត់បង់ជម្រកដីសើមតាមរយៈគម្រោងសាងសង់វារីអគ្គិសនីខ្នាតធំ ការរានយកដីព្រៃសម្រាប់ការតាំងទីលំនៅនិងធ្វើកសិកម្ម ការកាត់បន្ថយប្បូម៉ាស ការបរ

បាញ់សត្វព្រៃ និងការចម្លងភាពកខ្វក់ចូលទៅក្នុងប្រភពទឹក ដោយសារការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត (Hussain, et al. 2008)។ សត្វប្រភេទនេះ មានវត្តមានរស់នៅតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូង (Francis, 2008)។

**កំប្រុកធំ (Ratufa bicolor) ត្រូវបានកត់ត្រាក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទឈានទៅរងការគម្រាមកំហែង**

សត្វប្រភេទនេះត្រូវបានគេប្រទះឃើញមានជាទូទៅនៅទូទាំងតំបន់ស្រាវជ្រាវនេះ។ គេងាយនឹងឃើញវាណាស់ ដោយសារវារស់នៅតាមដើមឈើធំៗបំផុតនៅក្នុងតំបន់ ហើយភាគច្រើនត្រូវបានប្រទះឃើញជាទៀងទាត់នៅក្នុងគម្របព្រៃខ្ពស់ៗ។ ប្រភេទសត្វនេះ មានច្រើននៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ ដូចជាប្រទេសភូមា ថៃ ឡាវ វៀតណាម កម្ពុជា និងជ្រោយម៉ាឡេស៊ី ប៉ុន្តែចំនួននេះបានធ្លាក់ចុះគួរឱ្យកត់សម្គាល់នៅតាមតំបន់ជាច្រើន ដោយសារការបាត់បង់ព្រៃឈើ និងកាប់យកដើមឈើខ្ពស់ៗ ក៏ដូចជាការបរបាញ់សត្វ (Francis, 2008)។ មនុស្សបានបង្កឲ្យមានការខូចរេចរឹលទីជម្រករបស់វាដោយសារតែការផ្លាស់ប្តូរកន្លែងធ្វើស្រែចំការ ការកាប់ឈើខ្នាតតូច ការឈូសឆាយដីព្រៃ ភ្លើងឆេះព្រៃ ការពង្រីកភូមិដ្ឋានរបស់មនុស្ស និងការប្រមូលផលសម្រាប់ការប្រើប្រាស់ក្នុងស្រុក ដែលសុទ្ធសឹងតែជាការគម្រាមកំហែងដ៏ធំសម្រាប់ប្រភេទសត្វកំប្រុកនេះ (Waltson et al., 2008)។




**រូបភាព 13 កំប្រុកធំ Ratufa bicolor ដែលថតបានពីម៉ាស៊ីនថតរូបស្វ័យប្រវត្តក្នុងអំឡុងពេលស្រាវជ្រាវនៅតំបន់ព្រៃឡង់**

**រញ្ជីប្រផះ (Nycticebus bengalensis) ត្រូវបានកត់ត្រាក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទងាយរងគ្រោះ**

សត្វប្រភេទនេះត្រូវបានគេប្រទះឃើញតែម្តងគត់ ក្នុងអំឡុងពេលនៃការដៅចំណុចនៅពេលយប់ នៅតាមបណ្តោយផ្លូវព្រៃរបោះក្នុងភាគខាងជើងនៃព្រៃឡង់ នៅជិតតំបន់ព្រៃការពារព្រះវិហារ។ សំណាកសាកសពសត្វត្រូវបានប្រទះឃើញនៅក្នុងជំរុំរបស់អ្នកបរបាញ់ម្នាក់នៅក្នុងតំបន់ព្រៃស្រោងភាគកណ្តាលនៃព្រៃឡង់។ សំណាកស្ងួតជាច្រើនត្រូវបានគេឃើញដាក់លក់ផងដែរនៅតាមភូមិនានានៅខាងក្រៅព្រំដែនតំបន់ព្រៃឡង់ក្បែរៗនោះ។ សត្វប្រភេទនេះមានវត្តមានរស់នៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ ហើយក៏មាននៅភាគឦសាននៃប្រទេសឥណ្ឌា បង់ក្លាដែស និងប្រទេសចិនភាគខាងត្បូង។ ចំនួនសត្វនេះបានថយចុះគួរឲ្យគត់សម្គាល់ ដោយសារតែការបាត់បង់ជម្រកព្រៃឈើ ក៏ដូចជាការបរបាញ់ និងការដាក់អន្ទាក់ដើម្បីជួញដូរសត្វរស់ (Francis, 2008)។ ប្រភេទសត្វនេះត្រូវបានគេប្រទះឃើញមាននៅព្រៃការពារជាច្រើន ប៉ុន្តែមានចំនួនមិនច្រើនទេ (Streicher et al., 2008)។

**ស្វាប្រភេទ Macaca leonina ត្រូវបានកត់ត្រាក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទងាយរងគ្រោះ**

សត្វប្រភេទនេះត្រូវបានគេសង្កេតឃើញមានតិចតួចបំផុត ក្នុងកំឡុងពេលអង្កេតស្រាវជ្រាវនៅតំបន់នេះ ដែលការប្រទះឃើញទាំងអស់បានពីតំបន់ព្រៃស្រោងភាគកណ្តាលក្នុងតំបន់ព្រៃឡង់។ ទោះយ៉ាងណា អ្នកបរបាញ់និងមគ្គុទេសក៍ដើរព្រៃមូលដ្ឋានបានរាយការណ៍ថាពិតជាមានប្រភេទសត្វនេះរស់នៅជាធម្មតាក្នុងព្រៃនេះមែន។ គេបានសន្មតថាសត្វនេះមានរស់នៅតែក្នុងតំបន់តូចៗក្នុងព្រៃដែលជាទីមានកម្រិតនៃការរំខានពីមនុស្សតិចតួច និងជាទីដែលគេដឹងថាវាអាចដើររកចំណីបាន យ៉ាងច្រើនលើសលុបនៅលើដី ហើយងាយស្រួលរត់ឡើងលើដើមឈើដើម្បីចាប់ចំណី ប្រសិនបើ មានការរំខានណាមួយ។ នៅក្នុងប្រទេសកម្ពុជា កត្តាគម្រាមកំហែងដ៏ធំទៅលើសត្វប្រភេទនេះ គឺការបរបាញ់សម្រាប់ធ្វើជាអាហារ និងការជួញដូរ (Boonratana, et al, 2008)។ ប្រភេទសត្វស្វានេះ មានវត្តមាននៅតំបន់អាស៊ីអាគ្នេយ៍ រួមមានប្រទេសភូមា ថៃ (នៅភាគខាងត្បូង ត្រង់ចំនុច 8ºN) ឡាវ វៀតណាម និងប្រទេសកម្ពុជា (Francis, 2008)។

**ទោចម្កុដ (Hylobates pileatus) ត្រូវបានកត់ត្រាក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទជិតផុតពូជ**

ក្នុងអំឡុងពេលនៃការអង្កេតស្រាវជ្រាវ ជារឿយៗគេបានឮសូរសម្លេងសត្វទោចប្រភេទនេះស្រែកយំទ្រហឹងព្រៃនៅក្នុងតំបន់ព្រៃស្រោងភាគកណ្តាលនៃព្រៃឡង់ ហើយមានទោចជាច្រើនក្រុម

ត្រូវបានគេឮវាស្រែកចេញពីតំបន់ដែលមានរូងស្រទាប់ថ្មKarst នៅភាគខាងជើងនៃតំបន់ព្រៃឡង់។ ជាធម្មតា គេច្រើនប្រទះឃើញសត្វទាំងនេះរស់នៅអាស្រ័យលើដើមឈើខ្ពស់ៗ និងជាលក្ខណៈក្រុមគ្រួសារតូចៗ។ នៅក្នុងប្រទេសកម្ពុជា តំបន់ដ៏មានសក្តានុពលបំផុតសម្រាប់ពួកវា គឺតំបន់ជួរភ្នំក្រវាញនៅភាគនិរតីនៃប្រទេស ដែលជាតំបន់ព្រៃដ៏ល្អបរិសុទ្ធ និងមានចដង់ស៊ីតេទោចពី១-២ក្រុម ក្នុងមួយគីឡូម៉ែត្រក្រឡា (Brockelman et al.,2008)។ ពពួកសត្វទោចទាំងនេះមានរស់នៅតែក្នុងភាគអាគ្នេយ៍នៃប្រទេសថៃ ភាគឥសាននៃប្រទេសឡាវ និងនៅភាគខាងលិចនៃទន្លេមេគង្គក្នុងប្រទេសកម្ពុជា (Francis, 2008)។ ចំនួនសត្វទោចនៅក្នុងប្រទេសកម្ពុជា មានការធ្លាក់ចុះយ៉ាងខ្លាំងគួរឲ្យកត់សម្គាល់ ដោយសារតែការបំផ្លាញទីជម្រករបស់វា តាមរយៈការកាប់ព្រៃ និងការធ្វើប្រពលវប្បកម្មវិស័យកសិកម្ម នៅតាមតំបន់ជនបទ (Brockelman et al., 2008)។

**ស្វាព្រាម (Trachypithecus germaini) ត្រូវបានកត់ត្រាក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទជិតផុតពូជ**

ប្រភេទសត្វនេះត្រូវបានថតជាប់ដោយម៉ាស៊ីនថតរូបស្វ័យប្រវត្ត ខណៈពេលចុះពិនិត្យនៅតាមទីតាំងដែលសត្វចូលចិត្តរកចំណីជាច្រើនកន្លែងនៅភាគខាងលិចនៃព្រៃស្រោងភាគកណ្តាល។ សត្វទោចដែលរស់នៅជាក្រុមៗ ត្រូវបានកត់ត្រារួចជាស្រេចហើយ តាមរយៈរូបភាពបានពីម៉ាស៊ីនថតរូបស្វ័យប្រវត្ត ប៉ុន្តែមិនបានប្រទះឃើញ ជាក់ស្តែងក្នុងអំឡុងពេលស្រាវជ្រាវពេលនេះ ឬពេលមុនៗនោះទេ។ មគ្គុទេសក៍ដើរព្រៃមូលដ្ឋាននិងអ្នកបរបាញ់សត្វបានរាយការណ៍ថា ស្វាប្រភេទនេះមានរស់នៅជាធម្មតាទូទាំងតំបន់ព្រៃស្រោងភាគកណ្តាលនៃព្រៃឡង់។ ពពួកសត្វនេះ ភាគច្រើនចូលចិត្តរស់នៅតំបន់ទំនាប ដូចជានៅ ក្នុងព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង ព្រៃលាយឡំជាមួយព្រៃរបោះ ព្រៃដុះជាប់មាត់ទឹក និងព្រៃដែលមានរូងថ្មក្រោមដី (Moody et al., 2011)។ ប្រទេសកម្ពុជាត្រូវបានចាត់ទុកថាជាជម្រកមួយដ៏សុខសាន្តសម្រាប់ប្រភេទសត្វស្វាមួយនេះ (Moody et al., 2011)។ កត្តាគម្រាមកំហែងធំៗទៅលើប្រភេទនេះ រួមមានការបាត់បង់ទីជម្រក និងការបរបាញ់ ជាពិសេសសម្រាប់ការប្រើប្រាស់ក្នុងជីវភាពរស់នៅ ធ្វើជាឱសថបុរាណ និងសម្រាប់លក់ដូរសត្វ រស់ផងដែរ (Nadler et al., 2008)។ ប្រភេទសត្វស្វានេះមាននៅភាគអាគ្នេយ៍ នៃប្រទេសថៃ ភាគខាងត្បូងនៃប្រទេសឡាវ និងនៅភាគខាងលិចនៃទន្លេមេគង្គក្នុងប្រទេសកម្ពុជា និងប្រទេសវៀតណាម (Francis, 2008)។

**ខ្លាឃ្មុំ (Helarctos malayanus./Ursus thibetanus) ត្រូវបានកត់ត្រាក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទងាយរងគ្រោះ**

ក្នុងអំឡុងពេលនៃការអង្កេតស្រាវជ្រាវនេះ គេបានថតជាប់ដោយម៉ាស៊ីនថតរូបស្វ័យប្រវត្តនូវសត្វខ្លាឃ្មុំប្រភេទនេះចំនួនមួយក្បាលនៅតំបន់ព្រៃស្រោងភាគកណ្តាល។ ប៉ុន្តែគុណភាពរូបភាពនោះពិបាក ក្នុងការកំណត់អត្តសញ្ញាណប្រភេទរបស់វាណាស់។ ការអង្កេតស្រាវជ្រាវកាលពីមុនក៏ធ្លាប់បាន

កត់ត្រាប្រភេទខ្លាឃ្មុំប្រភេទHelarctos malayanus តាមរយៈការរូបភាពបានពីម៉ាស៊ីនថតរូបស្វ័យប្រវត្ត។ ប្រភេទខ្លាឃ្មុំប្រភេទ Ursus thibetanus ក៏ត្រូវបានគេកត់ត្រាផងដែរពីតំបន់ព្រៃឡង់ ដោយផ្អែកលើទំហំនៃស្នាមដានជើងជាប់នៅលើដើមឈើ (Olssen and Emmett, 2007)។ កត្តាគម្រាមកំហែងដ៏ពីរយ៉ាងទៅលើប្រភេទស្លាឃ្មុំទាំងពីរនេះ គឺការបាត់បង់ទីជម្រក និងការបរបាញ់សម្រាប់ជួញដូរ (Fredriksson et al. 2008)។ ប្រភេទសត្វទាំងពីរនេះមានវត្តមានរស់នៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ (Francis, 2008)។

**ខ្លាឃ្មុំតូចប្រភេទArctonyx collaris ត្រូវបានកត់ត្រាក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទ ជិតឈានទៅទទួលរងការគម្រាមកំហែង**

សត្វប្រភេទនេះត្រូវបានកត់ត្រាទុកចំនួន៣ដងរួចមកហើយក្នុងអំឡុងពេលនៃការធ្វើអង្កេតស្រាវជ្រាវនេះ ដោយការកត់ត្រាតាមរយៈរូបភាពបានពីម៉ាស៊ីនថតរូបស្វ័យប្រវត្តចំនួន២ដង និងសំណាកបានពីអ្នកបរបាញ់ម្តងទៀត។ កំណត់ត្រាទាំងអស់នោះសុទ្ធសឹងតែបានមកពីតំបន់ព្រៃស្រោងភាគកណ្តាល។ ប្រភេទសត្វនេះត្រូវបានគេដឹងថាមានរស់នៅពីតំបន់ព្រៃដែលមានកម្ពស់ ៣.៥០០ ម៉ែត្រ ហើយស៊ីចំណីដូចជា 'មើម ឫសឈើ ជន្លេន សត្វល្អិត និងសត្វតូចៗមួយចំនួនទៀត (Lekagul and McNeely 1977)។ សត្វនេះមានរស់នៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ ហើយក៏មាននៅភាគឥសាននៃប្រទេសឥណ្ឌា ប្រទេសចិន និងកោះស៊ូម៉ាត្រា (Francis, 2008)។ ដោយឡែកនៅប្រទេសកម្ពុជា សត្វប្រភេទនេះមានរស់នៅក្នុងតំបន់វាលទំនាប ក្នុងព្រៃរបោះនិងព្រៃពាក់កណ្តាលស្រោង។ ខ្លាឃ្មុំប្រភេទនេះច្រើនរស់នៅភាគនិរតី និងភាគខាងកើតនៃប្រទេសកម្ពុជា (Timmins et.al, 2008)។

## *ការពិភាក្សា*

ថនិកសត្វចំនួន៣៦ប្រភេទត្រូវបានបញ្ជាក់ថាមាននៅក្នុងតំបន់ព្រៃឡង់។ ក្នុងនោះថនិកសត្វចំនួន១៨ប្រភេទត្រូវបានអង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) ចុះក្នុងបញ្ជីក្រហម ថាជាប្រភេទសត្វរងការគម្រាមកំហែង ដែលទាមទារឲ្យមានការអភិរក្សជាសកល។

ការសង្កេតជារួមទៅលើប្រភេទថនិកសត្វក្នុងអំឡុងពេលធ្វើអង្កេតស្រាវជ្រាវមួយនេះ នៅមានកម្រិតទាបនៅឡើយ នេះបើប្រៀបធៀបជាមួយការធ្វើអង្កេតស្រាវជ្រាវនៅតំបន់ការពារផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា។ ជាពិសេសចំពោះករណីស្រាវជ្រាវទៅលើអំបូរពានរ ឧទាហរណ៍ ទោចម្កុដ ការមើលឃើញផ្ទាល់ចំពោះសត្វនេះមានចំនួនតិចតួច ក្រៅការស្តាប់ឮសូរសម្លេងរបស់វា។ ទោះយ៉ាងនេះក្តី ដោយផ្អែកលើលទ្ធផលម៉ាស៊ីនថតរូបស្វ័យប្រវត្ត គេបានថតជាប់ជាញឹកញាប់នូវប្រភេទសត្វមួយចំនួនដូចជា សំពោចក្រអូប ឬសំពោចត្នោត (Common Palm Civet), ជ្រូកព្រៃ (Wild Pig), ឈ្លូស (Muntjac), ឆ្មាដាវ (Leopard Cat), សំពោចកលឿង (Yellow-throated Marten) និងកាំប្រមា (Malayan

Porcupine)។ ឯប្រភេទសត្វមួយចំនួនដូចជា សត្វពង្រូល (IUCN-រងការគម្រាមកំហែងខ្លាំង) និងខ្លាខិន (IUCN-ឈានទៅរងការគម្រាមកំហែង) មិនត្រូវបានគេប្រទះឃើញនៅក្នុងពេលស្រាវជ្រាវនេះទេ។ ប៉ុន្តែបើផ្អែកលើការសម្ភាសន៍ មានអ្នកខ្លះបានពិពណ៌នាយ៉ាងច្បាស់លាស់ថា វត្តមាននៃប្រភេទសត្វទាំងនេះពិតជាមាននៅក្នុងតំបន់ព្រៃស្រោងភាគកណ្តាលនៃព្រៃឡង។ ជារួម ថនិកសត្វនៅតំបន់ព្រៃឡង់ អាចចាត់ទុកថាមានចំនួនច្រើនជាងការរកឃើញនៃការសិក្សានេះ។ ដូចនេះ ដើម្បីឲ្យ ដឹងពីចំនួននៃប្រភេទសត្វនីមួយៗ បន្ថែមទៀត ចាំបាច់ត្រូវមានការសិក្សាឲ្យបានទូលំទូលាយជាងនេះ បន្តទៅទៀត ។

ចំពោះប្រភេទសត្វមួយចំនួន ដូចជា សត្វខ្លាដំបង ដែលត្រូវបានអង្គការសមាគមអភិរក្សសត្វព្រៃ (WCS) បញ្ជាក់នៅក្នុងលទ្ធផលនៃការស្រាវជ្រាវរបស់ខ្លួននៅតំបន់ព្រៃឡង់កាលពីឆ្នាំ២០០៣ថា គេបានលុបចេញពីបញ្ជីប្រភេទសត្វរួចទៅហើយ ព្រោះថាមិនមានតឹកតាងថ្មីណាមួយដែលបញ្ជាក់ពីវត្តមាននៅរស់របស់សត្វនេះទេ។

ខណៈដែលតំរូវឲ្យមានការស្រាវជ្រាវជាបន្ត ដើម្បីវាយតម្លៃឲ្យបានពេញលេញនៃថនិកសត្វ នៅតំបន់ព្រៃឡង់ ហើយគួបផ្សំជាមួយនឹងផ្នែកធំនៃព្រៃឡង់ដែលមិនទាន់បានធ្វើការសិក្សាផងនោះ វត្តមាននៃប្រភេទសត្វទាំងឡាយដែលមានតែនៅក្នុងតំបន់ និងនៅជុំវិញតំបន់ បញ្ជាក់ថា គេត្រូវផ្តល់អាទិភាពដល់ការអភិរក្សតំបន់ព្រៃឡង់ ដើម្បី ធានាដល់រស់រាននៃថនិកសត្វនៅកម្ពុជា។ សារៈសំខាន់ជាពិសេសម្យ៉ាងទៀត គឺវត្តមាននៃ ប្រភេទសត្វទន្សោង ទោចមុជ ស្វាព្រាម និងដំរី ដែលព្រៃឡង់ផ្តល់ជាជម្រកដល់ប្រភេទសត្វនៅប្រទេសកម្ពុជា ដូច្នេះហើយ ព្រៃឡង់គួរត្រូវបានចាត់ទុកថាជាព្រៃដ៏មានសារៈប្រយោជន៍បំផុតសម្រាប់ការអភិរក្សប្រភេទសត្វទាំងនេះ។

## *កត្តាគម្រាមកំហែង*

ការបរបាញ់សត្វ ការធ្វើខូចខាតទីជម្រក ការឈូសឆាយដីព្រៃសម្រាប់ធ្វើកសិកម្ម ការធ្វើចំណាកស្រុកចូលមករស់នៅក្នុងតំបន់ ការកាប់ឈើ និងភាពខ្វះចន្លោះនៃការអនុវត្តច្បាប់ និងកង្វះកិច្ចការពារ គឺកត្តាគម្រាមកំហែងដ៏ធំចម្បងទៅលើពពួកថនិកសត្វនៅតំបន់ព្រៃឡង់។ ចំនួនអ្នកបរបាញ់សត្វជាច្រើនត្រូវបានប្រទះឃើញ ពិសេសនៅក្នុងតំបន់ព្រៃស្រោងភាគកណ្តាលនៃព្រៃឡង់ ក្នុងអំឡុងពេលអង្កេតស្រាវជ្រាវនេះ។ តាមការសង្កេត ភាគច្រើនបំផុតនៃការចាប់សត្វ គឺបានធ្វើឡើង ដោយការដាក់អន្ទាក់ ដោយការប្រើព្រួញឬស្នា និងសត្វឆ្កែប្រមាញ់។ ក្នុងអំឡុងពេលនៃការធ្វើអង្កេតស្រាវជ្រាវនេះ ក៏បានឮម្តងដែរនូវស្នូរបាញ់កាំភ្លើង ប៉ុន្តែគេមិនបានឃើញអ្នកបរបាញ់ទាំងនោះមានជាប់ជាមួយនូវកាំភ្លើងទេ។ មគ្គុទេសក៍ដើរព្រៃក្នុងមូលដ្ឋាន ក៏បានប្រាប់ឲ្យដឹងផងដែរពីប្រវត្តនៃការប្រើប្រាស់ថ្នាំបំពុលសត្វដែលដាក់នៅតាមទីតាំង សំខាន់ៗ ដូច ដីប្រាប និងប្រភពទឹក និងការដាក់នុយបំពុល។ ទង្វើបែបបានសំលាប់សត្វទន្សោងជាច្រើនក្បាល។ តែថា បច្ចុប្បន្នការអនុវត្តបែបនេះត្រូវបានបញ្ឈប់។ នៅក្នុងអំឡុងនៃការអង្កេតស្រាវជ្រាវ មិនមានភ័ស្តុតាងណាមួយបង្ហាញពីការបំពុលសត្វនោះទេ។

## *ការផ្តល់អនុសាសន៍*

- អនុវត្តការអង្កេតស្រាវជ្រាវជាក់លាក់ទៅលើប្រភេទសត្វសំខាន់ៗ ជាពិសេសផ្តោតទៅលើស្ថានភាព និងរបាយប្រភេទសត្វព្រៃចតុបាទ និងសត្វជំរី។
- រៀបចំឲ្យមានការស្រាវជ្រាវបន្ថែមទៀតទៅលើស្ថានភាពនិងរបាយរបស់អំបូរពានរ ដែលកំពុងរស់នៅក្នុងព្រៃឡង់ ជាពិសេសទៅលើពពួករញីប្រផះ (Bengal Slow Loris), ទោចម្កុដ (Pileated Gibbon) និងស្វាព្រាម (Indochinese Silvered Langur)។
- អង្កេតស្រាវជ្រាវទៅលើពពួកថនិកសត្វតូចៗ ជាពិសេសប្រភេទសត្វកកេរ។
- ដាក់ម៉ាស៊ីនថតរូបស្វ័យប្រវត្តនៅទីតាំងដែលមិនបានដាក់ក្នុងកំឡុងពេលសិក្សានេះ។
- ធ្វើការវាយតម្លៃដោយផ្តោតជាសំខាន់លើទីជម្រក និងការស្រាវជ្រាវជាក់ស្តែងនៅនឹង កន្លែងថាតើមានច្រករបៀងណាខ្លះដែលអាចបង្កើតសំរាប់សត្វព្រៃបំលាស់ទី នៅចន្លោះរវាងព្រៃឡង់និងទីជម្រកអំណោយផលផ្សេងៗទៀត ជាពិសេស ចំណងទំនាក់ទំនងរវាងព្រៃឡង់និងព្រៃការពារព្រះវិហារ នៅភាគខាងជើង។

# ៤. សត្វប្រចៀវ

ដោយលោកបណ្ឌិតនេល ហ្វូរ៉េ (Dr. Neil Furey)

## *សេចក្តីផ្តើម*

សត្វប្រចៀវត្រូវបានបែងចែកជាពីរលំដាប់រង គឺ Yinpterochiroptera (ប្រចៀវRhinolophoid និងប្រចៀវស៊ីផ្លែឈើ) និង Yangochiroptera (សត្វប្រចៀវផ្សេងទៀតទាំងអស់) ដែលមានសមត្ថភាពក្នុងការដឹងពីអ្វីៗនៅជុំវិញខ្លួនវា ដោយការប្រើអេកូដៅកន្លែង រួមជាមួយនឹងការហោះហើរប្រកបដោយថាមពល ដែលអាចឱ្យសត្វនេះធ្វើជាម្ចាស់មេឃានារាត្រីកាល និងអាចមានវិធីរស់នៅគ្រប់ទីកន្លែងក្នុងសកលលោក (Schnitzler et al., 2001; Jones and Teeling, 2006)។ សត្វប្រចៀវជាង១២៥៩ប្រភេទ ត្រូវបានគេស្គាល់នាពេលបច្ចុប្បន្ន (Fenton 2012) ដែលភាគច្រើនជាពពួកចិញ្ចឹមជីវិតដោយសារទឹកដមផ្កានិងផ្លែឈើ ហើយតួលេខនេះនៅតែបន្តកើនឡើងជារៀងរាល់ឆ្នាំ គួបផ្សំនឹងរបកគំហើញនៃប្រភេទថ្មីៗមួយចំនួនទៀត។ ប្រចៀវស៊ីផ្លែឈើជាអ្នកដឹកនាំលំអងផ្កាដ៏សំខាន់នៃរុក្ខជាតិមានសារៈសំខាន់សេដ្ឋកិច្ចនិងអេកូឡូស៊ី (Fujita and Tuttle, 1991; Bumrungsri et al., 2013) ហើយដោយសារប្រភេទប្រចៀវជាច្រើនពាំនាំគ្រាប់ពូជទៅទីឆ្ងាយៗ ទើបវាអាចរួមចំណែកយ៉ាងច្រើនដល់ដំណុះព្រៃឈើឡើងវិញនៅតំបន់ដែលត្រូវបានកាប់បំផ្លាញ (Sritongchuay et al., 2014)។ សត្វប្រចៀវភាគច្រើនដែលប្រើអេកូដៅកន្លែង គឺជាប្រភេទបាណកាសី(ស៊ីសត្វល្អិតជាអាហារ) ហើយជាសត្វស៊ីសត្វល្អិតរាត្រីចរសំខាន់ជាងគេ (Nowak 1994) រួមទាំងសត្វល្អិតចង្រៃបំផ្លាញដំណាំកសិកម្មដ៏ច្រើននៅប្រទេសថៃ (Wanger et al., 2014) ហើយភ្នាក់ងារចម្លងមេរោគដល់មនុស្ស ឧទាហរណ៍ដូចជាសត្វមូសជាដើម។

សត្វប្រចៀវអាចបង្កើតបានជាសមាសភាគុដ៏សំខាន់មួយនៃពពួកថនិកសត្វ នៅតំបន់អាស៊ីអាគ្នេយ៍ ដែលប្រហាក់ប្រហែល៣០%នៃប្រភេទថនិកសត្វក្នុងតំបន់ និងស្មើពាក់កណ្តាលនៃប្រភេទថនិកសត្វទាំងអស់នៅក្នុងតំបន់ព្រៃត្រូពិច (Kingston et al., 2006)។ តំបន់អាស៊ីអាគ្នេយ៍ គឺជាតំបន់ដ៏មានសក្តានុពលសម្រាប់ការអភិរក្សសត្វប្រចៀវជាសកល ដោយសារតំបន់នេះអាចទ្រទ្រង់បានចំនួន២៥%នៃពពួកប្រចៀវទាំងអស់លើពិភពលោក ហើយយ៉ាងហោចណាស់ប្រចៀវចំនួន១៩៧ប្រភេទនៃចំនួនសរុប៣៤២ប្រភេទ ដែលគេស្គាល់នៅក្នុងតំបន់ គឺជាប្រភេទដែលធ្លាប់រស់នៅតែក្នុងតំបន់ប៉ុណ្ណោះ (Kunz et al., 2011)។ ទោះបីជាប្រចៀវផ្តល់ប្រយោជន៍សំខាន់ដល់សេដ្ឋកិច្ចនិងការអភិរក្សក្តី (Kunz et al., 2011) ក៏សមាសភាពនិងជីវភូមិសាស្ត្រនៃប្រចៀវរបស់ប្រទេសកម្ពុជា ត្រូវបានគេស្គាល់តិចតួចនៅឡើយ។ ទោះបីការយល់ដឹងបានកើនឡើងបន្តិចក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះក្តី ក៏សត្វប្រចៀវតែ៧០ប្រភេទប៉ុណ្ណោះ ដែលត្រូវបានកត់ត្រាក្នុងឯកសារព័ត៌មានវិទ្យាសាស្ត្រសម្រាប់ប្រទេសនេះ (Chheang et al. 2013) ហើយជាតួលេខដែលនៅតិចជាងគេ បើប្រៀបធៀបជាមួយប្រទេសជិត

ខាង ដូចជាប្រទេសឡាវមានចំនួន៩២ប្រភេទ (Douangboubpha et al., 2014), ប្រទេសវៀតណាមប្រមាណជា១២០ប្រភេទ (Kruskop, 2013) និងនៅប្រទេសថៃមានចំនួន១១៩ ប្រភេទ (Bumrungsri et al., 2006)។ ជារួម គេបានដឹងតិចតួចណាស់អំពីប្រវត្តិធម្មជាតិសត្វប្រចៀវក្នុងប្រទេសកម្ពុជា បើទោះជាសត្វនេះស្ថិតក្នុងលំដាប់ថនិកសត្វធំជាងគេនៅក្នុងប្រទេសនេះក្តី។

ការអង្កេតស្រាវជ្រាវសត្វប្រចៀវនៅព្រៃឡង់នេះ គឺមានបំណងបំពេញបញ្ជីសារពើភ័ណ្ឌលើកដំបូងអំពីប្រភេទសត្វប្រចៀវនៅតំបន់នោះ វាយតម្លៃពីសារៈសំខាន់នៃតំបន់ព្រៃឡង់សម្រាប់សត្វប្រចៀវប្រទេសកម្ពុជា និងផ្តល់អនុសាសន៍ដើម្បីជំរុញការអភិរក្សឲ្យមានប្រសិទ្ធភាព។

## វិធីសាស្ត្រស្រាវជ្រាវ

ការអង្កេតស្រាវជ្រាវដល់ទីកន្លែងចំនួន៣លើកត្រូវបានធ្វើឡើង ដោយលើកដំបូងធ្វើនៅភាគខាងត្បូង "ស្រែព្រីង" ចាប់ពីថ្ងៃទី១៦ដល់២៥ ខែមិថុនា ឆ្នាំ២០១៤ ហើយលើកទីពីរនិងទីបីធ្វើនៅភាគខាងជើង "ឆែប" និងនៅភាគកណ្តាល "ស្តុង" ចាប់ពីថ្ងៃទី២០ដល់៣០ ខែតុលា និងថ្ងៃទី២២ដល់៣០ ខែធ្នូ ឆ្នាំ២០១៤(សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមមើលឧបសម្ព័ន្ធ 3)។ អំឡុងពេលទាំងនេះគឺជាពេលចាប់ផ្តើម និងពេលបញ្ចប់នៃរដូវវស្សានៅប្រទេសកម្ពុជា។

### ➢ការដាក់អន្ទាក់

ប្រភេទសត្វប្រចៀវប្រែប្រួល ក្នុងការមានអារម្មណ៍ដឹងចំពោះការចាប់វាដោយការប្រើប្រាស់អន្ទាក់មង និងអន្ទាក់រាំង (Francis 1989, Berry et al., 2004)។ ដោយសារបំណងនៃការស្រាវជ្រាវ គឺបំពេញបញ្ជីសារពើភ័ណ្ឌ ទើបតម្រូវឲ្យមានការប្រើប្រាស់ឧបករណ៍ទាំងពីរប្រភេទនេះ សម្រាប់ប្រមូលសំណាកសត្វប្រចៀវ។ ការជ្រើសរើសទំហំអន្ទាក់មងអាស្រ័យលើសណ្ឋានដីមូលដ្ឋាន (ឧ ៣x២ម, ៧x៣ម, ១០x៣ម, ១២x២.៥ម) ដែលសំណាញ់ទាំងអស់នេះប្រើអំបោះលេខ៧០។ គេបានប្រើអន្ទាក់រាំងបួនផ្ទាំង ដែលមានផ្ទៃក្រឡា២,៤$m^2$ សម្រាប់ចាប់ប្រចៀវ។ ដើម្បីធ្វើស្តង់ដាឯកតានៃកម្លាំងប្រមូលសំណាករវាងអន្ទាក់ទាំងពីរ គឺកម្លាំងប្រមូល សំណាកសម្រាប់អន្ទាក់មងត្រូវបានគណនាដោយយកផ្ទៃក្រឡាមង($m^2$) គុណនឹងចំនួនថ្ងៃដែលគេដាក់វា ($m^2$mnh) ចំណែកអន្ទាក់រាំងក៏ដូចគ្នាដែរ គឺគណនាដោយយកផ្ទៃក្រឡានៃអន្ទាក់($m^2$) គុណជាមួយចំនួនថ្ងៃដែលគេប្រើវា ($m^2$hth)។

អន្ទាក់រាំងត្រូវបានគេប្រើប្រាស់ពេញមួយយប់ ក្នុងអំឡុងពេលនៃការធ្វើអង្កេតស្រាវជ្រាវនេះ និងបានពិនិត្យជារៀងរាល់ម៉ោង ចាប់ពីម៉ោង៥:៣០នាទីដល់ម៉ោង៩យប់ ហើយបន្ទាប់មក ពិនិត្យម្តងទៀតនៅពេលព្រឹក ចំណែកអន្ទាក់មងត្រូវដាក់ពង្រាយជារៀងរាល់យប់ ចាប់ពីម៉ោង៥:៣០នាទីដល់

ម៉ោង៩យប់ លើកលែងតែនៅទីកន្លែងណា ដែលមានភ្លៀងធ្លាក់ខ្លាំងមិនអាចវាយអន្ទាក់នេះបាន។ សំណាញ់ត្រូវបានតាមឃ្លាំមើល ជាប្រចាំឥតឈប់ឈរ ខណៈពេលកំពុងប្រើប្រាស់ និងស្រាយទុកវិញនៅពេលចប់កិច្ចការម្តងៗ។ ការជ្រើសរើសទីតាំងដើម្បីប្រមូលសំណាក ផ្តោតទៅលើទីកន្លែងសត្វប្រចៀវហោះហើរ ដែលស្ថិតនៅតាមស្រទាប់គម្របព្រៃខាងក្រោម ដូចជាផ្លូវធ្លាប់ហើរ ផ្លូវទឹកហូរ និងចន្លោះផ្លូវធម្មជាតិនៅក្នុងដំណុះរុក្ខជាតិ ហើយត្រូវជៀសវាងមិនឲ្យមានការដាក់អន្ទាក់នៅយប់ជាប់ៗគ្នានៅត្រង់ទីតាំងដដែលឡើយ។

➢**ការស្វែងរកទ្រនំសត្វប្រចៀវ**

ការស្វែងរកនិងការវាយតម្លៃទីតាំងរស់នៅរបស់សត្វប្រចៀវ ត្រូវបានធ្វើឡើងនៅពេលថ្ងៃ។ ការស្វែងរកទាំងនេះ ភាគច្រើនធ្វើឡើងនៅតាមរូងថ្ម ដែលមានទីតាំងស្ថិតនៅភាគខាងជើង ព្រៃឡង់។ ដោយសារថាប្រភេទសត្វប្រចៀវជាច្រើនបានប្រើប្រាស់រូងថ្មសម្រាប់ធ្វើជាមូលដ្ឋាន បណ្តោះអាសន្នមួយរបស់ខ្លួន ដើម្បីធ្វើជាទ្រនំជ្រកកោនសម្រាប់បង្កើតកូនតាមរដូវកាល ឬសម្រាប់ស្វែងរកចំណីក្នុងពេលរាត្រី ហេតុនេះហើយ អវត្តមានរបស់ពួកវាក្នុងអំឡុងពេលដែលយើងបានទៅស្វែងរកតែមួយលើក មិនមែនមានន័យថាទីតាំងនេះគ្មានពួកវារស់នៅ ឬពួកវាបានបោះបង់ចោលឡើយ។ ការប្រើប្រាស់រូងថ្មរបស់សត្វប្រចៀវ និងពីសំណាក់មនុស្សត្រូវបានកំណត់តាមរយៈការដើរចូលជាក់ស្តែងទៅក្នុងរូងថ្មនីមួយៗ ដើម្បីៈ

**១. ពិនិត្យសង្កេតដោយផ្ទាល់ និងធ្វើជំរឿនសត្វប្រចៀវក្នុងទ្រនំ។** ខណៈពេលដែលប្រភេទសត្វប្រចៀវជាច្រើនចូលចិត្តទុំនៅជាចង្កោម ប្រភេទសត្វប្រចៀវមួយចំនួនទៀតទុំតែឯងៗ រីឯប្រចៀវផ្សេងទៀតចូលចិត្តទុំនៅតាមក្រហែងស្នាមប្រេះ ដែលមិនងាយនឹងមើលឃើញ។ ឧបករណ៍ចាប់សម្លេងអ៊ុលត្រាសោន (សូមមើលតារាងខាងក្រោម) ត្រូវបានគេប្រើប្រាស់ដើម្បី ស្វែងរកប្រភេទសត្វប្រចៀវក្រោយគេនេះ។

**២. ស្វែងរកលាមកប្រចៀវ។** លាមកស្រស់ៗគឺជាភស្តុតាងដ៏ច្បាស់លាស់បំផុតដែលបញ្ជាក់ពីទីកន្លែងរស់នៅថ្មីៗរបស់សត្វប្រចៀវនៅទីតាំងណាមួយ ហើយបរិមាណគំនរលាមកអាចផ្តល់គំនិតត្រួសៗពីចំនួនរបស់ពួកវា និងរយៈពេលនៃការរស់នៅនៃទីតាំងនោះ។ ប្រចៀវស៊ីផ្លែឈើ និងប្រចៀវស៊ីសត្វល្អិត ជុះលាមកចេញមកក៏ខុសគ្នាដែរ ហើយលាមកទាំងនេះត្រូវបានយកមកពិនិត្យដើម្បីកំណត់ពីវត្តមាន របស់ពួកវា។

**៣. វាយតម្លៃពីការប្រើប្រាស់ទ្រនំរបស់សត្វប្រចៀវនាពេលកន្លងមក។** ការវាយតម្លៃនេះអាចកំណត់បានដោយការស្វែងរកសំណល់របស់សត្វប្រចៀវនៅលើដី និងស្នាមប្រឡាក់ជាប់ នៅលើជញ្ជាំង និងពិដានដែលមានសល់ប្រេងរំអិលស្បែក និងទឹកនោមរបស់វា។

**៤. វាយតម្លៃលើការប្រើប្រាស់ទីតាំងនោះពីសំណាក់មនុស្ស។** ភស្តុតាងតួយ៉ាងរួមមានស្នាមជើងមនុស្ស សម្រាមដែលមនុស្សចោល ស្នាមគំនូរលើជញ្ជាំងថ្ម ស្នាមគូសវាសលើជញ្ជាំង រណ្តៅភ្នក់ភ្លើង និងគ្រឿងសក្ការបូជាខាងសាសនាដូចជាកាកសំណល់ទានធូបដែលដុតរួចនិងគ្រឿងតង្វាយផ្សេងៗទៀត។ ប្រសិនបើមើលទៅឃើញមានព្រនង់វែងៗ និងបំណែកនៃសំណាញ់មងបង់ត្រីផងនោះ ពិតជាបង្ហាញថាមានការបរបាញ់សត្វប្រចៀវនៅទីនោះយ៉ាងពិតប្រាកដ។

បន្ទាប់ពីការវាយតម្លៃជាបឋមរួចមក ការដាក់អន្ទាក់ចាប់ប្រចៀវរស់ត្រូវបានអនុវត្តនៅតាមរូងថ្មដែលបានជ្រើស ដើម្បីកំណត់សមាសភាពប្រភេទសត្វប្រចៀវទាំងនេះ។ សកម្មភាពនេះត្រូវបានគេអនុវត្តក្នុងអំឡុងពេលសត្វប្រចៀវទាំងនេះបង្ហាញខ្លួននៅពេលល្ងាច ដោយការប្រើប្រាស់អន្ទាក់មងដែលមានទំហំខុសៗគ្នា (ជាធម្មតាចាប់ពីម៉ោង៥:៣០ដល់ម៉ោង១៧:៣០នាទីល្ងាច)។

**➢ការប្រមូលសំណាកដោយសូរស័ព្ទ**

ឧបករណ៍ចាប់សម្លេងសត្វប្រចៀវ (D240x, Pettersson Electronik AB) ត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃពីសកម្មភាពប្រចៀវនៅពេលយប់ និងកត់ត្រាសម្លេងអេកូដៅកន្លែងនៃប្រភេទប្រចៀវតាម Furey et al. (2009) and Phauk et al. (2013)។ រាល់រលកសញ្ញាទាំងអស់ ដែលបានកត់ត្រាត្រូវបានរក្សាទុកដោយឧបករណ៍ថតសម្លេងឌីជីថលប្រភេទ Edirol HR09 (Roland) និងត្រូវបានវិភាគដោយប្រើប្រាស់ឧបករណ៍ Batsound Standard vers. 3.31 (Pettersson Electronik AB)។

**➢ការកំណត់អត្តសញ្ញាណប្រភេទប្រចៀវ**

សត្វប្រចៀវត្រូវបានគេវាស់វែង ថតរូប និងបានកំណត់អត្តសញ្ញាណនៅនឹងកន្លែង តាមរយៈការប្រើប្រាស់វិធីសាស្ត្រ Francis (ឆ្នាំ២០០៨) និងព្រលែងទៅវិញនៅទីកន្លែងដែលនៅជិតៗ ពីតាំងដែលគេចាប់វាបាន។ លក្ខខណ្ឌបន្តពូជរបស់សត្វប្រចៀវក៏ត្រូវបានកត់ត្រាផងដែរ ដោយយោងតាម Furey et al. (2011)។ ប្រភេទសត្វប្រចៀវចំនួនតិចជាង០.៥% នៃចំនួនសរុបដែលចាប់បាន ត្រូវបានកំណត់អត្តសញ្ញាណថាជាប្រភេទដ៏កម្រនៅក្នុងស្រុក។ នៅទីកន្លែងណាដែលតម្រូវឲ្យមានការបញ្ជាក់ពីអត្តសញ្ញាណរបស់ប្រភេទសត្វប្រចៀវទាំងនេះ នោះគេត្រូវតែរក្សាសត្វប្រចៀវពេញវ័យដែល ស្ថិតក្នុងវ័យបន្តពូជឲ្យបានចំនួនជាអប្បបរមា សម្រាប់ទុកធ្វើជាសំណាក ដោយប្រើប្រាស់សារធាតុអេតាណុល៨០%។ សំណាកលលាដ៍ក្បាល និងឆ្អឹងលិង្គ (ដែលសំខាន់សម្រាប់ធ្វើចំណែកថ្នាក់) ត្រូវបានគេ

យកចេញមកធ្វើពិសោធន៍ជាបន្តបន្ទាប់ ដើម្បីវាស់វែងនិងពិនិត្យប្រៀបធៀបតាមជាក់ស្តែង។ សំណាកដែលប្រមូលបានត្រូវយកទៅដាក់នៅកន្លែងរក្សាសំណាកសត្វសាស្ត្រនៃមជ្ឈមណ្ឌលសម្រាប់អភិរក្សជីវៈចម្រុះ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ចំនួនសំណាកបន្ថែមអាចរកបានពីអ្នកស្រាវជ្រាវដំបូងគេ។ ប្រព័ន្ធចំណែកត្រូវ យកតាម Simmons (ឆ្នាំ២០០៥) ដោយមានការកែប្រែចុងក្រោយថ្មីៗនេះទៅតាម (Bates et al. 2007, Soisook et al. 2008, Csorba et al. 2011)។

## ➢របៀបស្រង់យកស្ថិតិ

ដើម្បីកំណត់ភាពពេញលេញនៃការប្រមូលសំណាកសត្វប្រចៀវនៅតំបន់ព្រៃឡង់ ភាពសំបូរបែបនៃប្រភេទប្រចៀវពិត (Smax) ត្រូវបានគេប៉ាន់ប្រមាណ ដោយប្រើប្រាស់ទិន្នន័យនៃភាពសំបូរបែប និងវិធីសាស្ត្រឈ្មោះច្រើន ដែលបង្កើតឡើងដោយ Solow and Polasky (1999) and Shen et al. (2003)។ ដើម្បីបង្កើតបាន កំរិតប៉ាន់ប្រមាណខ្ពស់បំផុត ឬទាបបំផុតនៃភាពសម្បូរបែបរបស់ប្រភេទសត្វប្រចៀវស្មានទុកមុនត្រូវផ្អែកលើ ការគុណនឹងបួននៃកម្លាំងប្រមូលសំណាក និងភាពពេញលេញនៃបញ្ជីសារពើភ័ណ្ឌ ត្រូវបានគណនាឲ្យទៅជាផលធៀបនៃប្រភេទសត្វដែលត្រូវបានសង្កេតឃើញ (Sobs) ទៅនឹងចំនួនដែលបានប៉ាន់ស្មាន Sobs/Smax x100។

កម្រិតនឹងនៃការផ្តុំគ្នា(E1/D)ត្រូវបានគណនាដោយចែកទំរង់បញ្ច្រាសនៃតម្លៃសន្ទស្សន៍ Simpson អោយចំនួនប្រភេទS។ តម្លៃរបស់កំរិតនឹងនៃការផ្តុំគ្នា E1/D ប្រែប្រួលពី 0–1 ដែលឆ្លុះបញ្ចាំងកំរិតនឹងកើនឡើងនៃភាពសំបូរបែបធៀបរបស់ប្រភេទ។ សមាសភាពប្រភេទរវាងតំបន់ត្រូវបានប្រៀបធៀបដោយប្រើ Chao-Jaccard Abundance-based Similarity Index (CJ-SI) និង Estimator (CJ-SE) (Chao et al. 2005). Values for តម្លៃរបស់CJ-SI និង CJ-SE ប្រែប្រួលពី 0–1 និងឆ្លុះបញ្ចាំងភាពដូចគ្នាកើនឡើងក្នុងសមាសភាពប្រភេទដូចគ្នា។

## ➢កម្លាំងប្រមូលសំណាក

នៅក្នុងរយៈពេលនៃការអង្កេតស្រាវជ្រាវដល់ទីកន្លែងទាំង៣លើក ការដាក់អន្ទាក់សរុបចំនួន ១៨យប់ ស្មើនឹង៣,២៩៦.៣m2mnh(ម៉ោងវាយអន្ទាក់មង) និងចំនួន៧៨៩,៦m2hth (ម៉ោងវាយអន្ទាក់រាំង) ត្រូវបានធ្វើដោយជោគជ័យនៅទីតាំងទាំង៨៩កន្លែងនៅព្រៃឡង់ ក្នុងនោះរួមមានរូងថ្មចំនួន១១ និងទីតាំងក្នុងព្រៃឈើជ្រៅចំនួន៧៣កន្លែង (សូមមើលតារាង៣)។ ការកំណត់ទីតាំងភូមិសាស្ត្រនៃទាំងនេះ មានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធទី៣។

តារាង 3 ការប្រមូលសំណាកក្នុងអំឡុងពេលអង្កេតស្រាវជ្រាវនៅតំបន់ព្រៃឡង់

| ទីកន្លែង | ចំនួនយប់នៃការប្រមូលសំណាក | ទីតាំងប្រមូលសំណាក | ផ្ទៃក្រឡា $m^2$mnh | ផ្ទៃក្រឡា $m^2$hth | កំណត់សម្គាល់ |
|---|---|---|---|---|---|
| តំបន់ភាគខាងជើង | 8 (២២–២៩.១០.១៤) | ៤០ | ១,០៦៣.៥ | ៣៤០.៨ | រូងថ្ម១១កន្លែង, តាមផ្លូវលំ១៩ & ស្ទឹងក្នុងព្រៃ១០កន្លែង |
| តំបន់កណ្តាល | ៥ (២៤–២៨.១២.១៤) | ២៧ | ១,៥៣៨.៣ | ២៤៧.២ | តាមផ្លូវលំ២៦ & ស្ទឹងក្នុងព្រៃ១ កន្លែង |
| តំបន់ភាគខាងត្បូង | ៥ (១៨–២២.០៦.១៤) | ១៧ | ៦៩៤.៥ | ២០១.៦ | តាមផ្លូវលំ១៤ & ស្ទឹងក្នុងព្រៃ៣ កន្លែង |
| **សរុប** | **១៨** | **៨៤** | **៣,២៩៦.៣** | **៧៨៩.៦** | |

ក្នុងចំណោមចំនុចទីតាំងប្រមូលសំណាកទាំង៤០កន្លែងនៅតំបន់ភាគខាងជើង មានចំនុច ទីតាំងចំនួន២៦កន្លែង (រួមមានរូងថ្មចំនួន៧ និងទីតាំងក្នុងព្រៃចំនួន១៩កន្លែង) ស្ថិតក្នុងភូមិសាស្ត្រភ្នំធំ (ចំនុចកណ្តាល UTM ០៥៧៩៥០០, ១៥២៥៤០០) ដែលជាតំបន់ព្រៃសម្បូរទៅដោយថ្មកំបោKarst ដែលដុះចេញពីក្នុងដី ចំណែក១៤កន្លែង(រូងថ្មចំនួន៤និងក្នុងព្រៃចំនួន១០កន្លែង) ដែលនៅសល់មានទីតាំងភូមិសាស្ត្រស្ថិតនៅភ្នំឈ្យាក (ចំនុចចំកណ្តាលទីតាំងសកល UTM ០៥៨០៩០០, ១៥២៣៣០០) ដែលជាទីកន្លែងសម្បូរទៅដោយផ្ទាំងសិលាKarstផុសចេញពីក្នុងដីនៅដាច់ៗពីគ្នា និងដែលស្ថិតនៅចម្ងាយប្រហែល២គីឡូម៉ែត្រទៅភាគអាគ្នេយ៍។ តំបន់មានថ្មដុះទាំងពីរកន្លែងនេះ ត្រូវបានហ៊ុំព័ទ្ធដោយរុក្ខជាតិព្រៃពាក់កណ្តាលស្រោង ដែលមានស្រទាប់គម្របព្រៃខាងលើបិទជិត (រួមបញ្ចូលទាំងតំបន់ដែលមានដើមស្រឡៅ (Lagerstroemia spp.) ដុះនៅជុំវិញទីនោះផង) ហើយស្ថិតនៅក្នុងតំបន់ទេសភាពដែលសំបូរទៅដោយព្រៃរបោះ វាលស្មៅ និងចម្ការនានា។ ទីតាំងប្រមូលសំណាកមានកំពស់ប្រែប្រួលពី១០០-១៧០ម៉ែត្រលើកម្រិតកម្ពស់ទឹកសមុទ្រ ហើយមួយផ្នែកនៃកម្លាំងប្រមូលសំណាកត្រូវជួបផលរំខានដោយសារឥទ្ធិពលភ្លៀងអស់រយៈពេល៤យប់ នៅក្រោយម៉ោង៩យប់។



រូបភាព 14 រូបភាពភ្នំធំថតចំពីខាងត្បូង នៅភាគខាងជើងព្រៃឡង់



រូបភាព 15 ព្រៃដើមស្រឡៅនៅភ្នំធំ ភាគខាងជើងព្រៃឡង់

ក្នុងចំណោមទីតាំងប្រមូលសំណាកទាំង២៧នៅតំបន់កណ្តាល លើកលែងតែតំបន់មួយប៉ុណ្ណោះ (ដែលបានប្រមូលនៅតាមមាត់ទន្លេក្នុងព្រៃមួយកន្លែង) សុទ្ធតែនៅព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោងខ្ពស់ៗមានស្រទាប់គម្របព្រៃបិទជិត ហើយជាតំបន់ព្រៃដែលជន់លិចតាមរដូវកាល រាប់បញ្ចូលទាំងចម្ការជាច្រើនដែលមានរុក្ខជាតិលូតលាស់ឡើងវិញ (ចំណុចទីតាំងសកល UTM ០៥៥៩៨៣០, ១៩៧៣៨០០)។ កម្ពស់ប្រមូលសំណាកប្រែប្រួលពី៨០-១៩០ម៉ែត្រលើកម្ពស់ទឹកសមុទ្រ ហើយមិនមានផលរំខានពីការធ្លាក់ភ្លៀងនោះទេ។ ក្នុងចំណោមទីតាំងប្រមូលសំណាក១៧កន្លែងនៅភាគខាងត្បូង ១៩កន្លែងធ្វើឡើងនៅតាមផ្លូវឆ្លងកាត់ និង៣កន្លែងទៀតនៅជាប់មាត់ទន្លេក្បែរព្រៃពាក់កណ្តាលស្រោងដែលរង ការខូចខាតយ៉ាងធ្ងន់ធ្ងរ (ចំណុចទីតាំងសកល UTM ០៥៧៥៥៩៥, ១៩៥៩១២៨) ដោយការកាប់យកឈើយ៉ាងច្រើន ដោយក្រុមហ៊ុនសម្បទានភាភីមិច (Pheaphimex) កាលពីមុនឆ្នាំ២០០២ និងត្រូវបានកាប់យ៉ាងច្រើនសន្ធឹកសន្ធាប់ជាបន្តបន្ទាប់មកទៀត។ កម្ពស់ប្រមូលសំណាកប្រែប្រួលពី១០០-១៣០ម៉ែត្រលើកម្រិតទឹកសមុទ្រ និងរងផលរំខានដោយសារភ្លៀងធ្លាក់ខ្លាំងក្នុងរយៈពេលប្រមូលសំណាក៥យប់ លើកលើងតែយប់មួយនោះដែលគ្មានភ្លៀងធ្លាក់។

## *លទ្ធផលស្រាវជ្រាវ*

### *ការរកឃើញជារួម*

**មានសត្វប្រចៀវចំនួន២៨ប្រភេទនៅព្រៃឡង់ ដែលស្ថិតក្នុង៦អម្បូរ ត្រូវបានកត់ត្រា (**

តារាង 4)។ ការប្រមាណពីភាពសំបូរបែបនៃប្រភេទសត្វប្រចៀវពិត (Smax) ប្រែប្រួលពី ២៥,0 ទៅ ២៦,៩ ដោយសំដៅទៅដល់សមមាត្រភាពពេញលេញនៃបញ្ជីសារពើភ័ណ្ឌស្មើឡើង ជារួមពី៨៦-៩២%។ សត្វប្រចៀវរកស៊ីពេលល្ងាច (Vespertilionidae) គឺជាប្រភេទប្រចៀវដែលតំណាងឲ្យភាពសម្បូរបែបល្អជាងគេក្នុងចំណោមប្រចៀវទាំង៧ប្រភេទ បើទោះបីចំនួនចាប់វាបានក្នុងចំនួនតិចជាងមុនក្តី (៩,១%នៃចំនួយចាប់បានសរុប) បើប្រៀបធៀបទៅនឹងសត្វប្រចៀវក្រចកសេះ (Rhinolophidae, ៦៧,៩%) ដែល៦ប្រភេទត្រូវបានកត់ត្រារួច។ ប្រចៀវ Leaf-nosed bats ក៏តាងឲ្យប្រចៀវទាំង៦ប្រភេទដែរ ប៉ុន្តែចាប់បានតែ១០,១%ប៉ុណ្ណោះ បន្ទាប់មកគឺប្រចៀវ sheath-tailed bats (Emballonuridae: ២ប្រភេទ គឺ៦,៥%) សត្វប្រចៀវ false vampire bats (Megadermatidae: ២ប្រភេទ គឺ២,៧%) និងប្រចៀវ Old world fruit bats (Pteropodidae: ១ប្រភេទ គឺ៣,៧%)។

កម្រិតនឹងនៃការផ្តុំគ្នាគឺទាបត្រឹម០,២១ ដោយសារភាពសម្បូរបែបហួសប្រមាណនៃប្រភេទប្រចៀវក្រចកសេះ Rhinolophus shameli នៅភាគខាងជើង ដែលតាងឱ្យ៤១,៦% នៃចំនួនចាប់បានសរុប។ ប្រភេទដែលសម្បូរជាងគេបន្ទាប់ គឺប្រភេទប្រចៀវក្រចកសេះ R. acuminatus (ចំនួន១១,១%), ចំណែកឯកតាចំណែកថ្នាក់៤ ដែលកម្រនិងតាងដោយប្រចៀវមួយក្បាលក្នុងមួយប្រភេទ គឺប្រចៀវប្រភេទ Hipposideros cineraceus ប្រចៀវប្រភេទ H. diadema ប្រចៀវប្រភេទ Taphozous melanopogon និងប្រចៀវប្រភេទ Murina walstoni។ មានតែប្រចៀវក្រចកសេះប្រភេទ R. marshalli តែមួយគត់ដែលជាកំណត់ត្រាដំបូងបំផុតរបស់ប្រទេសកម្ពុជា ចំណែកប្រចៀវប្រភេទ M. walstoni ត្រូវស្ថិតក្នុងកំណត់ត្រាទី៤ ដែលគេស្គាល់នៅក្នុងតំបន់ថាជាប្រភេទសត្វរបស់ជាតិ។




រូបភាព 16 ប្រចៀវប្រភេទ **Rhinolophus shameli** នៅតំបន់ព្រៃឡង់




រូបភាព 17 ប្រចៀវប្រភេទ **Rhinolophus acuminatus** នៅតំបន់ព្រៃឡង់




រូបភាព 18 ប្រចៀវប្រភេទ **R. marshalli** នៅតំបន់ព្រៃឡង់




រូបភាព 19 ប្រចៀវប្រភេទ **Murina walstoni** នៅតំបន់ព្រៃឡង់

តារាង 4ប្រភេទសត្វប្រចៀវដែលត្រូវបានកត់ត្រានៅក្នុងតំបន់ចំនួនបីនៃព្រៃឡង់

| # | អម្បូរ / ប្រភេទ | តំបន់ភាគខាងជើង | តំបន់ភាគកណ្តាល | តំបន់ភាគខាងត្បូង |
|---|---|---|---|---|
| | ប្រចៀវ Old world fruit bats, Pteropodidae | | | |
| ១ | Greater short-nosed fruit bat, *Cynopterus sphinx* | | | ១១ |
| | ប្រចៀវ False vampire bats, Megadermatidae | | | |
| ២ | Greater false vampire bat, *Megaderma lyra* | ២ | | |
| ៣ | Lesser false vampire bat, *Megaderma spasma* | ២ | | ៤ |
| | ប្រចៀវ Horseshoe bats, Rhinolophidae | | | |
| ៤ | Acuminate horseshoe bat, *Rhinolophus acuminatus* | | ២៤ | ៩ |
| ៥ | Malayanhorseshoe bat, *Rhinolophus malayanus* | ២៥ | | |
| ៦ | Marshall's horseshoe bat, *Rhinolophus marshalli*[2] | ៣ | | |
| ៧ | Lesser brown horseshoe bat, *Rhinolophus microglobosus* | ១៣ | | |
| ៨ | Leasthorseshoe bat, *Rhinolophus pusillus* | ៤ | | |
| ៩ | Shamel's horseshoe bat, *Rhinolophus shameli* | ១២៣ | | |
| | ប្រចៀវ Leaf-nosed bats, Hipposideridae | | | |
| ១០ | Great leaf-nosed bat, *Hipposideros armiger*[3] | | | |
| ១១ | Ashy leaf-nosed bat, *Hipposideros cineraceus*[1] | ១ | | |
| ១២ | Diadem leaf-nosed bat, *Hipposideros diadema*[1] | | | ១ |
| ១៣ | Cantor's leaf-nosed bat, *Hipposideros galeritus* | ៨ | ១ | ១ |
| ១៤ | Intermediate leaf-nosed bat, *Hipposideros larvatus* [3] | ១៣ | | |
| ១៥ | Large-eared leaf-nosed bat, *Hipposideros* | ៥ | | |

| | | | | |
|---|---|---|---|---|
| | *Pomona* | | | |
| | ប្រចៀវ Sheath-tailed bats, Emballonuridae | | | |
| ១៦ | Black-bearded tomb bat, *Taphozous melanopogon* [1] | ១ | | |
| ១៧ | Theobald′stomb bat, *Taphozous theobaldi* [3] | ១៨ | | |
| | ប្រចៀវ Evening bats, Vespertilionidae | | | |
| ១៨ | Titania's woolly bat, *Kerivoulatitania* | | ២ | |
| ១៩ | Hardwicke′s woolly bat, *Kerivoulahardwickii* | | ៣ | ៣ |
| ២០ | Round-eared tube-nosed bat, *Murinacyclotis* | | | ២ |
| ២១ | Walston′s tube-nosed bat, *Murina walstoni* [1] | | ១ | |
| ២២ | Peter′s myotis, *Myotis ater* | | ៧ | |
| ២៣ | Least pipistrelle, *Pipistrellustenuis* | ១ | ១ | |
| ២៤ | Blanford's bat, *Hesperoptenus blanfordi* | | ៥ | ២ |
| | **សរុប** | **២១៩** | **៩៤** | **៣៣** |

**សម្គាល់:** 1 = ប្រភេទសត្វប្រចៀវកម្រនៅក្នុងប្រទេស (<0,៥%នៃចំនួនចាប់បានសរុប), 2 = កំណត់ត្រាថ្មីរបស់ប្រទេស, 3 = កូឡូនីរូងថ្មធំៗរបស់ប្រភេទប្រចៀវទាំងនេះដែលគេបាន ប្រទះឃើញ មាននៅតំបន់ភាគខាងជើង (មើលតារាងខាងក្រោមនេះ) -ដោយតួលេខដែលមាននៅខាងស្តាំ នេះមិនមានរួមបញ្ចូលកូឡូនីទាំងនេះទេ។

ភោគទ្រព្យនិងភាពសំបូរបែបនៃប្រភេទសត្វប្រចៀវ គឺមានច្រើនបំផុតនៅភាគខាងជើងដែលមានចំនួន១៥ប្រភេទ និង៧៤%នៃចំនួនចាប់បានសរុប បន្ទាប់មកគឺនៅភាគកណ្តាលដែលមានចំនួន៨ប្រភេទ និង១៤,៩%នៃចំនួនចាប់បានសរុប រីឯនៅភាគខាងត្បូងមានចំនួន៨ប្រភេទដែរ និង ១១,១%នៃចំនួនចាប់បានសរុប។ ការប្រមាណភាពសំបូរបែបនៃប្រភេទសត្វប្រចៀវពិត (Smax) គឺស្ថិតនៅចន្លោះពី១៦,២-១៧,៦នៅភាគខាងជើង និង ១២,២-១៣,២នៅភាគកណ្តាល ទៅដល់៩,0-១0,0 នៅភាគខាងត្បូង ដែលសមាមាត្រភាពពេញលេញនៃបញ្ជីសារពើភ័ណ្ឌស្មើឡើងគឺ៨0-៨៦%, ៦១-៦៦% និង ៨0-៨៩% តាមលំដាប់រៀងគ្នា។ កំរិតនឹងនៃការផ្តុំគ្នាគឺទាបទៅមធ្យមត្រឹម 0,២១ (នៅភាគខាងជើង), 0.៣៨ (នៅភាគកណ្តាល) និង 0,៦៥ (នៅភាគខាងត្បូង)។ ភាពស្រដៀងគ្នាជាគូៗនៃសមាសភាពប្រភេទប្រចៀវជាមួយគ្នា មានកម្រិតទាបរវាងតំបន់ទាំង៣ (តម្លៃ CJ-SI: 0,0២៣–0,៣៣៨) ហើយបានកើនឡើងបន្តិចបន្តួចប៉ុណ្ណោះនៅពេលរងឥទ្ធិពលពីប្រភេទសត្វប្រចៀវដូចគ្នាមើលមិនឃើញត្រូវបានបញ្ចូល (តម្លៃ CJ-SE: 0,0៣៧–0,៣៥២)។

➢ កូឡូនីប្រចៀវក្នុងរូងថ្ម

រូងថ្មចំនួន១១ត្រូវបានប្រទះឃើញក្នុងអំឡុងពេលធ្វើអង្កេតស្រាវជ្រាវ នៅតំបន់ភាគខាងជើងនៃព្រៃឡង់។ រូងថ្មមួយក្នុងចំណោមទាំង៧ ដែលរកឃើញនៅភ្នំធំ ប៉ុន្តែមានមួយកន្លែង (C4: មានទីតាំងស្ថិតនៅខាងក្នុងព្រៃជ្រៅភាគខាងកើត) មានទីតាំងស្ថិតនៅលើចំខាងមុខភាគខាងត្បូងភ្នំ ហើយមានតែមួយកន្លែងប៉ុណ្ណោះ (C6) មិនឃើញមានវត្តមានសត្វប្រចៀវទេ ឬគ្មានភស្តុតាងណាមួយបង្ហាញពីការកាន់កាប់របស់ពពួកសត្វប្រចៀវនៅទីកន្លែងនោះទេនាពេលកន្លងមក។ រូងថ្មទាំង៤ ដែលគេបានអង្កេតស្រាវជ្រាវនៅភ្នំឈ្សាក គឺជាទីកន្លែងរស់នៅរបស់កូឡូនីប្រចៀវ ប៉ុន្តែមានតែមួយកន្លែងគត់ (C8) ដែលមានលទ្ធភាពក្នុងការទ្រទ្រង់ជីវិតប្រចៀវប្រភេទ T. theobaldi រាប់ពាន់ក្បាល។ លទ្ធផលនៃការអង្កេតស្រាវជ្រាវនៅតាមរូងថ្មនីមួយៗ មានបង្ហាញនៅក្នុងតារាងទី៥ ដូចខាងក្រោម។

តារាង ៥ រូងថ្ម (ឬល្អាងភ្នំ) ដែលត្រូវបានអង្កេតស្រាវជ្រាវនៅចំនុចភាគខាងជើងនៃព្រៃឡង់

| លេខរៀង | កាលបរិច្ឆេទអង្កេតស្រាវជ្រាវ | លក្ខណៈល្អាងភ្នំសង្ខេប |
|---|---|---|
| C1 | ២២ ខែតុលា ឆ្នាំ ២០១៤ | ភ្នំធំ (Phnom Thom), ស្ថិតនៅខាងលើតំបន់ទំនាបលិចទឹក (ចំណុចទីតាំងសកល UTM: 0579103, 1525235)។ ល្អាងនេះមានរូងគ្របដោយផ្ទាំងថ្ម មានផ្លូវដើរចូលក្នុងល្អាងខាងឆ្វេង និងខាងស្តាំ។ ផ្លូវដើរចូលក្នុងល្អាងខាងស្តាំលាតសន្ធឹងចម្ងាយតែ៣ ឬ៤ម៉ែតប៉ុណ្ណោះ ចំណែកផ្លូវដើរចូលក្នុងល្អាងខាងឆ្វេងមានចម្ងាយចូល ប្រហែល៥០ម៉ែត្រ ដែលមានសភាពចោតខ្លាំងនៅខាងដើម និងមានជម្រាលទាបទៅៗ។ នៅតាមផ្លូវដើរចូលល្អាងខាងឆ្វេងគេឃើញមានដូចជា ទីសក្ការៈបូជាតូចមួយ ទីទួលកើតឡើងពីថ្មសឹករេចរឹលជាច្រើន និងច្រកពន្លឺមួយ។ ទោះបីជាឃើញមានស្នាមប្រឡាក់លាមកប្រចៀវជាច្រើនពាសពេញល្អាងក៏ដោយ ប៉ុន្តែគេបានប្រទះឃើញមានប្រភេទប្រចៀវស៊ីសត្វល្អិតចំនួនតែ ៤-៥ ក្បាលប៉ុណ្ណោះ (រួមទាំង H. armiger) , ហើយលាមកចាស់ៗរបស់ប្រចៀវស៊ីសត្វល្អិត នៅលើផ្លូវទឹកតាមរដូវ។ |
| C2 | ២២ ខែតុលា ឆ្នាំ ២០១៤ | ភ្នំធំ (Phnom Thom), ជាល្អាងស្ថិតនៅ ខាងលើតំបន់ទំនាបលិចទឹក (ចំណុចតាំងសកល UTM: 0579089, 1525251)។ ល្អាងនេះមានរូងថ្មធំមួយ មានរាងស្ទើររង្វង់ ដែលមានអង្កត់ផ្ចិតប្រហែល១០ម៉ែត្រ ដែលសម្បូរដោយសសរថ្មហូរនៅកណ្តាល (central flowstone column)។ ទួលថ្មធំៗកើតពីសំណឹកថ្ម នៅផ្នែកខាងក្រោយមានស្នាមប្រឡាក់ មានលាមកប្រចៀវកំរាស់៣-៤ សម។ អ្នកនាំផ្លូវបានរាយការណ៍ថា កាលពីប្រាំឆ្នាំមុន មានប្រចៀវរាប់ពាន់ក្បាល ប៉ុន្តែមានប្រចៀវប្រហែល ២០ ក្បាលប៉ុណ្ណោះ ដែលបានប្រទះឃើញ។ ភស្តុតាងនៃការបរបាញ់ប្រចៀវក៏ត្រូវបានធ្វើកត់ត្រាផងដែរ។ ប្រចៀវពីរប្រភេទត្រូវបានធ្វើកត់ត្រា គឺ H. larvatus និង T. melanopogon។ |
| C3 | ២៣ ខែតុលា ឆ្នាំ | ភ្នំធំ (Phnom Thom), ជាល្អាងស្ថិតនៅ ខាងលើតំបន់ទំនាបលិចទឹក (ចំណុចទីតាំងសកល UTM: 0579500, |

| | | |
|---|---|---|
| | ២០១៤ | 1525281)។ ល្អាងនេះមានថ្មលយចេញប៉ប្រេះបញ្ឈរពីរ នៅលើខាងមុខ ចោតខ្លាំង ដែលគេពិបាកនិងឡើងដល់ (រូបភាព១៥)។ ប្រចៀវប្រភេទ H. larvatus ប្រហែល១៥០ក្បាល ត្រូវបានគេប្រទះឃើញរស់នៅក្នុងល្អាងនេះ។ |
| C4 | ២៣ ខែតុលា ឆ្នាំ ២០១៤ | ភ្នំធំ (Phnom Thom), ជាល្អាងមានរយៈកម្ពស់ខ្ពស់ជាងគេ (ចំណុចទីតាំងសកល UTM: 0580539, 1525120)។ ល្អាងនេះមានរូងទំហំទទឹងធំជាងកម្ពស់ (ca. ៧x៥ម) ដែលមានថ្មលយចេញចំកណ្តាល ខាងក្រោយនៃល្អាង។ នៅខាងក្រោយនៃល្អាង ជាផ្នែកខាងលើនៃទូលកើតពីថ្មរងសំណឹក ដែលមិនអាចដើរចូលទៅបាន។ ស្នាមប្រឡាក់ដោយប្រចៀវ និងភស្តុតាងនៃបរបាញ់ប្រចៀវត្រូវបានសង្កេតឃើញជាក់ស្តែងនៅក្នុងរូងនោះ ដែល ប្រចៀវប្រភេទ R. shameli, R. malayanus និង H. larvatus ត្រូវបានកត់ត្រា។ |
| C5 | ២៥ ខែតុលា ឆ្នាំ ២០១៤ | ភ្នំធំ (ចំណុចទីតាំងសកល UTM: 0577543, 1525882)។ ច្រកចូលល្អាងមានសភាពទាប ស្ថិតនៅជើងភ្នំថ្ម Karstពីលើ តំបន់ទំនាបលិចទឹក។ វាមានចំណោតចោតខ្លាំងនៅខាងដើម និងមានដុំថ្មធំៗជាច្រើន។ តាមការសង្កេតតាមទ្រនំ ឃើញមានប្រចៀវប្រភេទ H. armiger និង H. larvatus ប្រហែល១០០០ ក្បាល។ គេបានប្រទះឃើញភស្តុតាងជាក់ស្តែងនៃការបរបាញ់សត្វប្រចៀវ និងការប្រមូលយកលាមកប្រចៀវ(លាមកប្រចៀវត្រូវបានគេច្រកចូលក្នុងបាវអង្ករ : រូបភាព១៦) ប៉ុន្តែក្រោយមក ប្រហែលជាគ្មានការរំខាន ឬការប្រមូលលាមកទៀតទេ ទើបលាមកប្រចៀវក្នុងល្អាងនេះមានចំនួនក្រាសក្រៃល និងនៅថ្មីៗ ដែលគេបានប្រទះឃើញនៅតាមកន្លែងជាច្រើន។ |
| C6 | ២៦ ខែតុលា ឆ្នាំ ២០១៤ | ភ្នំធំ (ចំណុចទីតាំងសកល UTM: 0577734, 1525747)។ ល្អាងនេះមានថ្មលយចេញដែលបង្កើតជារូងថ្មរាក់ ( ca. ជម្រៅ៤ម)។ ផ្លូវដើរចូលល្អាងមួយចុះទៅខាងស្តាំរូងត្រូវបានគេធ្វើការស្រាវជ្រាវ ប៉ុន្តែត្រូវបានបញ្ចប់ទៅវិញ បន្ទាប់ពីដើរបានប៉ុន្មានម៉ែត្រតែប៉ុណ្ណោះ។ គេពុំបានប្រទះឃើញសត្វប្រចៀវ និងភស្តុតាងនៃការកាន់កាប់ល្អាង ពីអតីតកាលឡើយ។ |

| | | |
|---|---|---|
| C7 | ២៦ ខែតុលា ឆ្នាំ ២០១៤ | ភ្នំធំ (ចំណុចទីតាំងសកល UTM: 0577735, 1525713)។ ល្អាងនេះស្ថិតនៅក្បែរ និងមានលក្ខណៈប្រហាក់ប្រហែលនឹងល្អាង C6។ នៅច្រកចូលទៅក្នុងល្អាង មានថ្មលយចេញនៅខាងមុខ ។ ផ្លូវដើរចូលល្អាងធំនៅខាងស្តាំ ហើយចុះទៅបានបីទៅបួនម៉ែត្រដល់ផ្លូវចូលទៅរូងធំតែម្តង (មានអង្កត់ផ្ចិត និងកម្ពស់ប្រហែល១០–១៥ម) ជាទីដែលមានទ្រនំរបស់ប្រចៀវប្រភេទ H. armiger និង H.larvatus មានចំនួនពី ៣០០–៤០០ ក្បាល (H. armiger មានចំនួនច្រើនជាងៈ រូបភាព១៧)។ បន្តពីរូងនេះទៅ មានផ្លូវដើរចូលពីរទៀត ដែលក្នុងនោះផ្លូវដើរមួយដែលទាបជាង អាចដើរបាន និងបញ្ចប់ក្នុងប្រវែងប្រហែល៤០ម៉ែត្រ។ គេពុំបានប្រទះឃើញភស្តុតាងនៃការរំខានណាមួយឡើយ។ |
| C8 | ២៧ ខែតុលា ឆ្នាំ ២០១៤ | ភ្នំឈ្យាក (ចំណុចទីតាំងសកល UTM: 0580878, 1523241)។ នៅជើងភ្នំមានច្រកចូលតូចមួយ។ ល្អាងនេះមានរូងលយចេញ ដោយចាប់ផ្តើចេញពីរូងរួមតូច ហើយបន្តទៅរូងធំមួយទៀតដែលមានស្នាមប្រឡាក់លាមកប្រចៀវ និងប្រេងចេញពីស្បែក និងមានច្រកពន្លឺមួយនៅផ្នែកខាងក្រោយរូង។ ភស្តុតាងជាច្រើននៃការប្រមូលលាមក និងការបរបាញ់ប្រចៀវ ត្រូវបានកត់ត្រា (រូបភាព១៩ និង២០) ហើយមានប្រចៀវប្រភេទ T. theobaldi រាប់ពាន់ក្បាលត្រូវបានកត់ត្រានៅត្រង់រូងខាងក្រោយ។ ល្អាងតូចចំនួនពីរទៀតស្ថិតនៅខាងឆ្វេងច្រកចូល។ ល្អាងមួយដែលនៅជិតជាង មានស្នាមប្រឡាក់លាមកប្រចៀវច្រើនជាង ប៉ុន្តែគ្មានវត្តមានប្រចៀវត្រូវបានកត់ត្រាចេញពីល្អាងទាំងពីរនេះឡើយ។ |
| C9 | ២៨ ខែតុលា ឆ្នាំ ២០១៤ | ភ្នំឈ្យាក (ចំណុចទីតាំងសកល UTM: 0580388, 1523087)។ ល្អាងនេះស្ថិតនៅជើងភ្នំក្នុងព្រៃដែលមានការរំខានខ្លាំង និងជាតំបន់ដែលងាយស្រួលចូលទៅដល់ក្នុង តាមផ្លូវប្រវែងប្រហែល១៥ម៉ែត្រពីតំបន់រូងប្រចៀវ។ ល្អាងនេះរួមមានទូលកើតពីសំណឹកថ្មតូចធំ ហើយត្រូវលិចទឹកនៅផ្នែកខាងក្រោយរូង។ គេសង្កេតឃើញមានស្នាមប្រឡាក់ជាច្រើន ប៉ុន្តែគេបានប្រទះឃើញមានតែប្រចៀវប្រភេទ Taphozous spp. មួយចំនួនប៉ុណ្ណោះដែលត្រូវបានកត់ត្រានៅត្រង់ច្រកចូលល្អាង។ គេឃើញមានភស្តុតាងជាច្រើនទាក់ទងនឹងការរំ |

| | | |
|---|---|---|
| | | ខាន និងការបរបាញ់ ដែលត្រូវបានកត់ត្រា។ |
| C10 | ២៨ ខែតុលា ឆ្នាំ ២០១៨ | ភ្នំឈ្យាក (ចំណុចទីតាំងសកល UTM: 0580881, 1523138)។ ល្អាងនេះមានសភាពខ្ពស់ខ្លាំងដែលមានច្រកចូលទាបតែមួយមានកម្ពស់ប្រហែល១០ ម៉ែត្រ នៅ ខាងលើជើងភ្នំ ផ្ទៃចោត និងយ៉ាងហោចណាស់មានច្រកពន្លឺចំនួន៥ ទៅខាងលើនិងខាងក្រោមនៃរូង។ រូងធំមានផ្ទាំងថ្មពាសពេញ និងថ្មហូរ (flowstones) ជាថ្នាក់ៗ។ រូងនេះមានកម្ពស់ប្រហែល២០–៣០ ម៉ែត្រ និងអង្កត់ផ្ចិត ប្រហែល៤០–៥០ ម៉ែត្រ។ ទោះបីជាមានស្នាមប្រឡាក់ច្រើនកន្លែងក៏ដោយ ក៏គេបានអង្កេតឃើញប្រចៀវប្រភេទ Taphozous spp ប្រហែលជា១០០ក្បាលតែប៉ុណ្ណោះ។ ភស្តុតាងជាច្រើននៃការប្រើប្រាស់ក្នុងទម្រង់ជាការបរបាញ់ប្រចៀវដោយប្រើឈើវាយ ការប្រមូលលាមកប្រចៀវ និងការដុតធូបបន់ស្រន់ និងជុំរុំលាក់ខ្លួបជាដើមនៅត្រង់ច្រកចូលល្អាងក៏ត្រូវបានសង្កេតឃើញដែរ។ |
| C11 | ២៨ ខែតុលា ឆ្នាំ ២០១៨ | ភ្នំឈ្យាក (ចំណុចទីតាំងសកល UTM: 0580933, 1523138)។ ល្អាងទាបដែលមានច្រកចូលពីរមានកម្ពស់ប្រហែល២៥ម៉ែត្រ លើជើងភ្នំ, មានតែផ្នែកខាងឆ្វេងនៃល្អាងប៉ុណ្ណោះដែលត្រូវបានស្រាវជ្រាវ (ផ្នែកខាងស្តាំល្អាងមិនអាចដើរចូលទៅដល់ទេ)។ ល្អាងនេះរួមផ្សំឡើងដោយរូងចំនួន៣: ក្នុងរូងទីពីររួមមានច្រកពន្លឺតូចមួយ និងរូងទីបីជារូងតូចចង្អៀត។ ប្រចៀវប្រភេទ H. armiger ចំនួន២០ក្បាល និង H. galeritus ចំនួនពីរក្បាល ត្រូវបានកត់ត្រានៅទីនោះ ហើយស្នាមប្រឡាក់នៅលើជញ្ជាំង មានចំនួនតិចតួច បើប្រៀបធៀបជាមួយល្អាងផ្សេងទៀត។ ភស្តុតាងនៃការប្រើប្រាស់រូងនេះ រួមមានការគូសវាស់លើជញ្ជាំងថ្មក្នុងល្អាង ការបរបាញ់ និងការប្រមូលលាមកប្រចៀវ។ |

## *ប្រភេទសត្វប្រចៀវសំខាន់ៗ*

ប្រភេទសត្វប្រចៀវទាំងអស់ដែលមាននៅព្រៃឡង់ ត្រូវបានអង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN ឆ្នាំ២០១៤) បានកត់ត្រាក្នុងពេលបច្ចុប្បន្ននេះថាជាប្រភេទរងគ្រោះតិចតួចតែប៉ុណ្ណោះ។ យ៉ាងណាក៏ដោយ នេះអាចជាការយល់ច្រឡំ ដោយហេតុថាចំនួនសត្វប្រចៀវសរុប (ការកំណត់ចំនួនប្រភេទសត្វប្រចៀវទាំងនេះស្ថិតនៅក្រោមប្រភេទក្នុងបញ្ជីក្រហម) គឺភាគច្រើននៃសត្វប្រចៀវបច្ចុប្បន្នមិនត្រូវបានគេស្គាល់អស់នោះទេ។ លើសពីនេះទៀត ដោយវិសាលភាពដ៏ធំល្វឹងល្វើយនៃទីជម្រកដែលមិនទាន់បានសិក្សា រួមទាំងការប្រមូលសំណាកដែលនៅមានកំណត់នៅឡើយ រហូតមកដល់ពេលនេះសបញ្ជាក់ឲ្យឃើញថាគួរតម្រូវឲ្យមានការសិក្សាស្រាវជ្រាវនាពេលអនាគតបន្តទៀត ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់ពីវត្តមានរបស់ប្រភេទសត្វប្រចៀវផ្សេងៗ ទៀតដែលកំពុងរស់នៅក្នុងតំបន់ព្រៃឡង់។ ដូច្នេះ គេគួរតែផ្តោតការយកចិត្តទុកដាក់ទៅលើសារៈសំខាន់នៃការអភិរក្សតំបន់ព្រៃឡង់ សម្រាប់សត្វប្រចៀវឲ្យបានច្រើនជាងការកត់ត្រានាពេលបច្ចុប្បន្ន។ ទោះជាដូច្នេះក្តី ក្រៅពីជួយទ្រទ្រង់យ៉ាងហោចណាស់មួយភាគបីនៃពពួកសត្វព្រៃនៃប្រទេស តំបន់ព្រៃឡង់នេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ដល់ការអភិរក្សសត្វប្រចៀវនៅកម្ពុជា។

ប្រចៀវក្រចកសេះប្រភេទ R. marshalli ចំនួនពីរក្បាលត្រូវចាប់បាន ដោយអន្ទាក់មងនៅផ្លូវចូលព្រៃមួយ (F13, ឧបសម្ព័ន្ធទី៣) នៅក្នុងពេលព្រលប់នៃថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៤ នៅភាគខាងជើង ចំណែកមួយក្បាលទៀតត្រូវគេចាប់បាននៅពេលយប់ជ្រៅ ក្នុងយប់តែមួយដោយអន្ទាក់រាំងនៅតាមផ្លូវចូលព្រៃ (F12, ឧបសម្ព័ន្ធទី៣)។ លក្ខណៈសម្គាល់ ខាងក្រៅ ធ្មេញ លលាដ៍ក្បាល ស្វរស័ព្ទ និងប្រវែងនៃសត្វប្រចៀវទាំង៣នេះត្រូវគ្នានឹងប្រភេទ R. marshalli ។ ប្រភេទប្រចៀវនេះមិនសូវឃើញមានទេ ហើយអ្នកជំនាញខាងលុករូងថ្មក្នុងព្រៃបានបញ្ជាក់ថាគេធ្លាប់ឃើញមានតែនៅតំបន់រប៉ាត់រប៉ាយក្នុងប្រទេសថៃ ប្រទេស ឡាវ ភាគខាងជើង វៀតណាម និងឧបទ្វីបម៉ាឡេស៊ី តែប៉ុណ្ណោះ (Francis, 2008) ។ កំណត់ត្រាដែលបានពីព្រៃឡង់ គឺជាកំណត់ត្រលើកដំបូងបំផុតសម្រាប់ប្រទេសកម្ពុជា។

ប្រចៀវប្រភេទ Murina walstoni តែមួយគត់ដែលគេចាប់បានដោយអន្ទាក់រាំងនៅតាមផ្លូវចូលព្រៃមួយ (F31, ឧបសម្ព័ន្ធទី៣) នៅពេលព្រលប់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៤ នៅភាគកណ្តាលនៃព្រៃឡង់។ ប្រចៀវមួយក្បាលនេះមានលក្ខណៈស៊ីគ្នានឹងការវិនិច្ឆ័យរបស់ Csorba et al. (2011) ដែលថ្មីៗនេះបានពិពណ៌នាថា វាជាប្រភេទសត្វប្រចៀវមានប្រភពចេញពីស្រុករីនសៃនៃខេត្តរតនគិរី រួមទាំងមានសំណាកពីខេត្តកោះកុងនៃប្រទេសកម្ពុជា និងខេត្តដាក់ឡាក់នៃប្រទេសវៀតណាមផងដែរ។ ចាប់តាំងពីពេលនោះមក ក៏មាននៅកំណត់ត្រានានាបន្ថែមទៀតដែលបានពីខេត្តព្រះវិហារ (Furey, ទិន្នន័យដែលមិនទាន់ផ្សព្វផ្សាយ) នៅប្រទេសឡាវ និងវៀតណាម (Francis and Eger 2012)។ ទោះជាអ្នកជំនាញផ្នែកខាងលុកព្រៃបានចាត់ទុកជារួមថាប្រចៀវក្នុងពួក Murina ទាំងអស់រស់អាស្រ័យនៅក្នុង

ស្លឹកឈើក្តី ក៏គេឃើញមានប្រភេទប្រចៀវ M. walstoni ប្រើប្រាស់ជម្រកដែលមានលក្ខណៈចំហជាង និងស្ងួតជាងសមាជិកផ្សេងទៀតនៃពួកប្រចៀវនេះ (Furey et al. 2010, Kingston 2013)។

## *ការពិភាក្សា*

ព្រៃឡង់អាចទ្រទ្រង់យ៉ាងហោចណាស់មួយភាគបី (ស្មើនឹង២៨/៧១) នៃពពួកសត្វប្រចៀវព្រៃនៅក្នុងប្រទេសកម្ពុជាដែលគេស្គាល់ ហើយទ្រទ្រង់រាល់ជីវិតសត្វផ្សេងទៀតថែមទៀតផង។ ទោះជាមានការបង្ហាញពីភាពពេញលេញនៃបញ្ជីសារពើភ័ណ្ឌនៃ៨៦-៩២%ក៏ដោយ ក៏ការប្រមូលសំណាកត្រូវតែបន្តធ្វើទៀតដើម្បីរកឲ្យឃើញនូវប្រភេទសត្វប្រចៀវបន្ថែមទៀតនៅតំបន់ព្រៃឡង់នេះ។ បទពិសោធន៍ការងារជាក់ស្តែងដល់ទីកន្លែង គាំទ្រការសិក្សាស្រាវជ្រាវបន្ថែមទៀតនេះយ៉ាងពេញទំហឹង ពីព្រោះនៅមានពូកនិងប្រភេទតួយ៉ាងជាច្រើន ដែលគេបានប្រទះឃើញមាននៅតាមព្រៃនៃប្រទេសកម្ពុជា នៅពុំទាន់បានកត់ត្រានៅក្នុង របាយការណ៍នេះអស់នៅឡើយទេ តួយ៉ាងដូចជា Megaerops spp., Myotis spp. និង Tylonycteris spp។ នេះសបញ្ជាក់ឲ្យឃើញច្បាស់ណាស់ថា ការខិតខំប្រឹងប្រែងលើការប្រមូលសំណាកដែលបាន ធ្វើនៅតំបន់ភាគកណ្តាលនិងភាគខាងត្បូងព្រៃឡង់ គឺនៅមានកម្រិតនៅឡើយទេ។

គេបានកត់សម្គាល់ឃើញថាសារៈប្រយោជន៍នៃរូងថ្ម ដែលស្ថិតនៅតាមកូនភ្នំដាច់ស្រយ៉ាលទាំងនេះ មិនមែនមានត្រឹមតែសត្វប្រចៀវរស់នៅប៉ុណ្ណោះទេ ប៉ុន្តែក៏រួមមានសត្វឥតឆ្អឹងកង ដែលរស់នៅក្នុងដីពឹងអាស្រ័យលើចំណីដែលជាលាកមរបស់ពពួកសត្វប្រចៀវទាំងនេះផងដែរ។ ដោយសារតែលទ្ធផលនៃការផ្តុំគ្នាច្រើនយ៉ាងដូច្នេះហើយ ទើបនាបច្ចុប្បន្នរូងថ្មទាំងនោះ ត្រូវបានចាត់ថ្នាក់ក្នុងចំណោមរូងថ្មនានាថា ជាទីដែលសម្បូរទៅដោយជីវចម្រុះច្រើនជាងគេបំផុតនៅលើពិភពលោក (sensu Myers et al. 2000) ក្នុងន័យនៃកម្រិតនៃការគម្រាមកំហែង និងលក្ខណៈជីវសាស្ត្រដែលរស់នៅតែក្នុងតំបន់របស់ប្រភេទសត្វទាំងនេះ (Whitten 2009)។

## *កត្តាគម្រាមកំហែង*

ភ័ស្តុតាងដ៏ច្បាស់លាស់នៃការបរបាញ់សត្វប្រចៀវ គេប្រទះឃើញនៅចំណុចរូងថ្មចំនួន៧ក្នុងចំណោមរូងថ្មទាំង១០ ដែលជាជម្រករបស់សត្វប្រចៀវស្ថិតនៅភាគខាងជើងនៃព្រៃឡង់។ គេក៏បានរកឃើញផងដែរនូវភ័ស្តុតាងដែលអាចបញ្ជាក់ថាចំនួនប្រចៀវធ្លាក់ចុះ នៅតាមរូងថ្មមួយចំនួន។ ចំណុចនេះបង្កឲ្យមានក្តីបារម្ភដ៏ធំមួយ ដោយហេតុថាជាធម្មតាសត្វប្រចៀវមានការចាប់អារម្មណ៍ជាខ្លាំងចំពោះការប្រមូលផ្តុំគ្នារស់នៅតាមតំបន់ដ៏ទាក់ទាញទាំងនេះ ដែលជាទីកន្លែងតំណាងឱ្យចំនួនប្រចៀវក្នុងស្រុកមួយភាគធំ ហើយអាចប្រឈមនឹងភាពងាយរងគ្រោះខ្លាំងបំផុតដោយសារការរំខានរបស់

មនុស្ស (Furey និង Racey បញ្ជាក់ក្នុងសារព័ត៌មាន)។ គេក៏បានសង្កេតឃើញផងដែរថាមានការប្រមូលយកលាមកប្រចៀវ និងការប្រើប្រាស់រូងថ្មផ្សេងទៀតនៅតាមតំបន់មួយចំនួន ហើយតំបន់រូងថ្មទាំងនោះក្លាយទៅជាទីកន្លែងមិនអំណោយផល ជាពិសេសក្នុងអំឡុងពេលបង្កាត់ពូជ ដូចជាបង្កឲ្យទៅជាការពពោះយឺតយ៉ាវ ប៉ះពាល់ដល់ការបំបៅដោះកូន និងការផ្តាច់ដោះជាដើម (Furey et al. 2011)។ ផ្ទុយទៅវិញ គេបានឃើញតែមួយភ្លែតគត់ចំពោះករណីបរបាញ់សត្វប្រចៀវនៅតំបន់ភាគកណ្តាល ហើយគ្មានឃើញភស្តុតាងអ្វីទាក់ទងនឹងការបរបាញ់សត្វប្រចៀវនៅតំបន់ភាគខាងត្បូងនោះទេ។ បើនិយាយពីទស្សនៈវិស័យលើការអភិរក្សវិញ តំបន់រូងថ្មទាំងនេះពិតជាមានសារៈប្រយោជន៍ណាស់ ពីព្រោះហាក់ដូចជាគ្មានរូងថ្ម នៅឯណា (ឬយ៉ាងហោចណាស់មានតិចតួចប៉ុណ្ណោះ) ដែលមានចំនួនប្រចៀវក្នុងតំបន់អាចនឹងមានរបាយស្មើជាងនៅទីនេះ និងអាចបង្កភាពងាយរងគ្រោះតិចជាងនៅទីនេះពីការបំផ្លិចបំផ្លាញរបស់មនុស្សនោះទេ។

ការបន្តរីករាលដាលនៃការកាប់ឈើខុសច្បាប់នៅក្នុងតំបន់ព្រៃឡង់ ត្រូវបានចងក្រងទុកជាឯកសារយ៉ាងត្រឹមត្រូវ ហើយវាក៏ជាការបង្កនូវក្តីបារម្ភដ៏ធំមួយផងដែរចំពោះការអភិរក្ស។ ការសិក្សាស្រាវជ្រាវនានានៅប្រទេសវៀតណាម បានបង្ហាញពីការធ្លាក់ចុះយ៉ាងខ្លាំងនៃចំនួនសត្វប្រចៀវនៅចន្លោះតំបន់ព្រៃធម្មជាតិនានា បើប្រៀបធៀបនឹងតំបន់ដែលមានគម្របព្រៃតិចជាង (Furey et al., 2010)។ ការកាប់យកចេញនូវដើមឈើដែលមានអាយុកាលយូរ និងដើមឈើធំៗ បានបង្ហាញពីការព្រួយបារម្ភយ៉ាងខ្លាំង ដោយហេតុថាដើមឈើទាំងនេះ អាចផ្តល់ប្រហោងនិងក្រហែងថែមទៀតសម្រាប់ប្រភេទ ដែលរស់នៅអាស្រ័យជម្រកមានស្លឹកឈើបិទបាំងស្រដៀងគ្នានេះដែរ ពពួកប្រចៀវមួយភាគធំ ដែលគេស្គាល់ថាមាននៅព្រៃឡង់ (១៨ប្រភេទក្នុងចំណោម២៥ប្រភេទ ឧទាហរណ៍ប្រភេទក្នុងអម្បូរ Rhinolophidae និង Hipposideridae ក៏ដូចជាតំណាងសត្វភាគច្រើនបំផុតក្នុងអម្បូររង Murininae និង Kerivoulinae) ត្រូវបានអ្នកជំនាញខាងលុកព្រៃបញ្ជាក់ថា ជាប្រភេទប្រចៀវដែលពិបាកសម្របសម្រួលខ្លួនទៅនឹង ការស្វែងរកចំណីនៅតាមទីកន្លែងចំហណាស់ (Kingston 2013)។ ដូច្នេះការបែកខ្ញែក រប៉ាត់រប៉ាយនៃទីជម្រកផ្នែកខាងក្នុងទំនងជាបន្ថយប្រសិទ្ធភាពនៃការស្វែងរកចំណីរបស់ពួកវា និងបង្កើនហានិភ័យនៃការផុតពូជសត្វប្រចៀវក្នុងស្រុក។ ការព្រួយបារម្ភទាំងអស់នេះ ក៏រឹតតែពាក់ព័ន្ធបន្ថែមទៀតទៅនឹងការប្រែប្រួលអាកាសធាតុនៅលើសកលលោក ដែលធ្វើឱ្យប្រភេទសត្វទាំងនេះត្រូវផ្លាស់ប្តូរលឿនជាងការស្មាន (Jones and Rebelo 2013)។

## *ការផ្តល់ជាអនុសាសន៍*

➢ធ្វើការអង្កេតស្រាវជ្រាវបន្ថែមទៀត ដើម្បីចងក្រងជាឯកសារពេញលេញអំពីសារៈសំខាន់នៃការអភិរក្សតំបន់ព្រៃឡង់សម្រាប់ពពួកសត្វប្រចៀវ ជាពិសេសនៅតំបន់ភាគខាងជើងដែលជាទីកន្លែងមានភ្នំថ្មKarst និងរូងថ្មជាច្រើនទៀត មិនទាន់បានវាយតម្លៃនៅឡើយទេ។

➢ការពារកុំឲ្យមានការបរបាញ់សត្វប្រចៀវនៅតាមរូងថ្មទាំងអស់ ដែលជាទីជម្រករបស់ពពួកប្រចៀវរស់នៅតំបន់ព្រៃឡង់។ ការហាមឃាត់នេះមិនចាំបាច់តម្រូវឲ្យមានចំពោះការប្រមូលលាមកប្រចៀវនោះទេ ព្រោះសកម្មភាពនេះអាចត្រូវបានលើកទឹកចិត្តឲ្យអនុវត្តដើម្បីជួយទ្រទ្រង់ដល់ជីវភាពរបស់ប្រជាសហគមន៍មូលដ្ឋាន និងស្របតាមគោលបំណងអភិរក្សតាមរយៈការលើកកម្ពស់បច្ចេកទេសក្នុងការប្រមូលផលប្រកបដោយនិរន្តរភាព (e.g. IUCN SSC 2014)។

➢ផ្តល់ជាអាទិភាពលើការការពារជម្រកព្រៃឈើ ដោយការផ្តោតជាពិសេសលើការរក្សាភាពប្រទាក់គ្នានៃព្រៃឈើឲ្យនៅគង់វង្ស និងការការពារតំបន់ព្រៃដែលហ៊ុំព័ទ្ធដោយប្រភពទឹក ដូចជា ព្រៃជាំទឹកដែលស្ថិតខាងក្នុងតំបន់កណ្តាលជាដើម។

# ៥. សត្វស្លាប

ដោយ ឈិន សុភា

## សេចក្តីផ្តើម

សត្វស្លាបត្រូវបានគេចាត់ទុកជាក្រុមមួយក្នុងប្រព័ន្ធចំណែកថ្នាក់ សម្រាប់ធ្វើការសិក្សាអំពីផលប៉ះពាល់នៃការប្រែប្រួលទីជម្រកទៅលើជីវៈចម្រុះនៅក្នុងព្រៃតំបន់ត្រូពិច ព្រោះសមាសភាពនៃពពួកសត្វស្លាប អាចទទួលឥទ្ធិពលយ៉ាងខ្លាំងពីការរំខានទៅលើរចនាសម្ព័ន្ធព្រៃឈើ។ សត្វស្លាបក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងមុខងារអេកូឡូស៊ីក្នុងព្រៃតំបន់ត្រូពិច ដូចជានាទីក្នុងដំណើរលម្អង ការពង្រាយគ្រាប់ពូជរុក្ខជាតិ និងជាសត្វរំពា (Felton et al., 2008)។ ជាងនេះទៅទៀត ការវាយតម្លៃផ្អែកបរិមាណនៅក្នុងបញ្ជីក្រហមរបស់អង្គការ IUCN បានបង្ហាញថា ចាប់តាំងពីឆ្នាំ១៩៨៨មក ស្ថានភាពសត្វស្លាបនៅលើពិភពលោក កាន់តែមានសភាពអាក្រក់ឡើងៗ (Butchart et al., 2004) ក្នុងនោះ ៩៣% នៃសត្វស្លាបដែលរងការគម្រាមកំហែង គឺត្រូវបានរកឃើញនៅក្នុងព្រៃតំបន់ត្រូពិច (BirdLife International, 2004)។

ការសិក្សាពីសត្វស្លាបដំបូងបំផុតនៅប្រទេសកម្ពុជា គឺមានតាំងពីចុងសតវត្សទី១៩។ ជាង១០០ឆ្នាំក្រោយមក ការសិក្សាពីសត្វស្លាបនៅតែតិចតួចនៅឡើយ បើប្រៀបធៀបជាមួយប្រទេសជិតខាង។ យោងតាមឯកសាររបស់ Delacour (Eames et al., 2001), រហូតដល់ពាក់កណ្តាលទស្សវត្សឆ្នាំ១៩៩០ ការសិក្សាអំពីសត្វស្លាបនៅប្រទេសកម្ពុជាសំខាន់ៗ គឺមានបីប្រភព៖ ប្រភពទី១ គឺ the 4th Franco-British Expedition to Indochina from 1927-28 ដោយ Jean Delacour, Pierre Jabouille និង Willoughby Lowe ដែលអ្នកបានធ្វើការស្រាវជ្រាវជាលើកដំបូងបំផុតនៅតំបន់ជួរភ្នំក្រវាញ។ ការស្រាវជ្រាវនោះបានបោះពុម្ពផ្សាយដោយ Delacour នៅឆ្នាំ១៩២៩ និងធ្វើសេចក្តីសង្ខេបឡើងវិញ នៅឆ្នាំ១៩៣១ ចេញផ្សាយចំនួន៤លេខនៅក្នុង Les Oiseaux de Indochine Francaise។ ប្រភពទី២ គឺព័ត៌មានបានមកពី Paul Englebach ជាវេជ្ជបណ្ឌិតជនជាតិបារាំង ដែលបានមករស់នៅប្រទេសកម្ពុជាតាំងពីទសវត្សឆ្នាំ១៩៣០ដល់ទសវត្សឆ្នាំ១៩៤០ ដោយគាត់បានបោះពុម្ពឯកសារជាច្រើនស្តីអំពីអត្តសញ្ញាណ និងស្ថានភាពសត្វស្លាបនៅប្រទេសកម្ពុជា។ ប្រភពទី៣ គឺឯកសារដែលមិនបានបោះពុម្ពមានចំណងជើងថា "បញ្ជីសត្វស្លាបបឋមរបស់ប្រទេសកម្ពុជា" រៀបរាងឡើងនៅឆ្នាំ១៩៦៤ ដោយ William W. Thomas ដែលជាអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា និងបានរស់នៅទីក្រុងភ្នំពេញពីឆ្នាំ១៩៥៩ដល់១៩៦១។ ឯកសារទី៣នេះ នៅតែជាឯកសារសង្ខេបដែលអាចជឿជាក់បានអំពីសត្វស្លាប នៅប្រទេសកម្ពុជារហូតដល់ឆ្នាំ២០០៣។

នៅឆ្នាំ១៩៩២ អ្នកបក្សីសាស្ត្រជាជនបរទេសដំបូងគេបានត្រឡប់មកកាន់កម្ពុជាជាថ្មី ប៉ុន្តែដោយសារស្ថានភាពសុវត្ថិភាពដែលបន្សល់ពីសង្គ្រាមរ៉ាំរ៉ៃមិនអំណោយផល បានរារាំងដល់ការចុះ

សិក្សាស្រាវជ្រាវរបស់ពួកគេ។ ពេលនោះក៏មានការចូលមកដល់របស់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដែលធ្វើការផ្នែកអភិរក្ស ដូចជាអង្គការសហភាពអភិរក្សពិភពលោក (IUCN) អង្គការមូលនិធិពិភពលោកសម្រាប់ធម្មជាតិ (WWF) អង្គការសមាគមអភិរក្សសត្វព្រៃ (WCS) ដែលបានចាប់ផ្តើមបង្កលក្ខណៈឲ្យមានការចុះសិក្សាស្រាវជ្រាវ និងបោះពុម្ពឯកសារជាបន្តបន្ទាប់ (Daltry & Momberg, 2000)។ នៅក្នុងឆ្នាំ២០០៣ លោក តាន់ សេដ្ឋា ជាអ្នកអភិរក្សជនជាតិកម្ពុជា និងលោក Colin Pool អ្នកបក្សីសាស្ត្រ បានសហការគ្នាចងក្រងសៀវភៅណែនាំអំពីសត្វស្លាប នៅប្រទេសកម្ពុជា ដែលមានបង្ហាញសត្វស្លាបសរុបចំនួន៥៣៥ប្រភេទ (Setha & Poole, 2003)។ រហូតដល់ចុងឆ្នាំ២០១២ សត្វស្លាបសរុបចំនួន៥៩៩ប្រភេទត្រូវបានកត់ត្រា និងបញ្ជាក់ថាមានវត្តមាននៅប្រទេសកម្ពុជា។ ក្នុងនោះ២ភាគ៣នៃសត្វស្លាបទាំងអស់ គឺរស់នៅជាប្រចាំក្នុងប្រទេសកម្ពុជា និង១ភាគ៤ជាសត្វស្លាបដែលមានវត្តមានតែនៅរដូវរងារតែប៉ុណ្ណោះ។ ទាំងនេះសបញ្ជាក់អំពីនានាភាពខ្ពស់នៃប្រទេសដែលមានសណ្ឋានដីភាគច្រើនជាដីទំនាប។ ជាក់ស្តែង បើធៀបនៅអ៊ឺរ៉ុបខាងលិចទាំងមូល ដែលមានផ្ទៃដីធំជាងប្រទេសកម្ពុជាសរុបប្រហែលជា២០ដង មានសត្វស្លាបតែប្រមាណ៦៥០ប្រភេទតែប៉ុណ្ណោះ (Goes, 2013)។ ទោះជាយ៉ាងនេះក្តី ប្រទេសកម្ពុជាមានសត្វស្លាបដែលរស់នៅតែក្នុងតំបន់ចំនួនតែពីរប្រភេទប៉ុណ្ណោះគឺ ចករ៉ែកកម្ពុជា (Cambodian laughing thrush Garrulax ferrarius) និងចាបតេតចតុមុខ Cambodian tailorbird Orthotomus chaktomuk) និងប្រភេទសត្វស្លាបដែលរស់នៅតំបន់ក្បែរៗនោះដែរចំនួនពីរប្រភេទគឺ ក្រួចសំពៅ (Chestnut-headed Partridge Arborophila cambodiana) និងខ្ញប់ដីទន្លេមេគង្គ (Mekong Wagtail Motacilla samveasnae) ដែលមានវត្តមាននៅប្រទេសជិតខាងផងដែរ។ សត្វស្លាបចំនួន១៣ប្រភេទរងផ្សេងទៀតរស់នៅតែក្នុងតំបន់ជួរភ្នំក្រវាញតែប៉ុណ្ណោះ។

## វិធីសាស្ត្រស្រាវជ្រាវ

ប្រភេទសត្វស្លាបទាំងអស់ដែលមាននៅក្នុងបញ្ជីនៃរបាយការណ៍វាយតម្លៃនេះ គឺបានមកពីផ្សំបញ្ចូលគ្នារវាងប្រភពបន្ទាប់បន្សំនានា ដូចជាលទ្ធផលនៃការស្រាវជ្រាវពាក់ព័ន្ធអំពីសត្វព្រៃ ព័ត៌មានបានពីការធ្វើសម្ភាសជាមួយប្រជាជននៅមូលដ្ឋាន និងការចុះប្រមូលសំណាកសត្វដោយផ្ទាល់នៅតាមមូលដ្ឋាននានា (តារាងទី៦)។

តារាង 6 កាលបរិច្ឆេទ និងទីតាំងនៃការប្រមូលសំណាកសត្វស្លាបនៅព្រៃឡង់

| កាលបរិច្ឆេទ | តំបន់អង្កេតស្រាវជ្រាវ |
|---|---|
| ថ្ងៃទី១៦-២៥ | ការស្រាវជ្រាវចាប់ផ្តើមចេញពីចំណុចភូមិស្រែព្រីង ជាទីដែលក្រុមអ្នកស្រាវជ្រាវ បាន |

| | |
|---|---|
| ខែមិថុនា ឆ្នាំ ២០១៤ | ស្នាក់អាស្រ័យចំនួនមួយយប់ ហើយធ្វើដំណើរបន្តទៅស្នាក់នៅជុំរុំ ដែលស្ថិតនៅកណ្តាលទ្រូងព្រៃឡង់ ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ធំចំនួនមួយយប់ បន្ទាប់មកផ្លាស់ទីទៅជុំរុំទី២ដែលមានចម្ងាយជាង២គីឡូម៉ែត្រពីជុំរុំទី១ បូករួមទាំងការចំណាយពេលអស់ចំនួនបីថ្ងៃដើម្បីបន្តការស្រាវជ្រាវនៅភ្នំជី នាភាគខាងត្បូងព្រៃឡង់។ |
| ថ្ងៃទី២០-៣០ ខែវិច្ឆិកា ឆ្នាំ ២០១៤ | ក្រុមអ្នកស្រាវជ្រាវបានចំណាយពេលអស់២យប់ នៅត្រង់ភូមិថ្នាំង ឃុំអន្លង់ជ្រៃ ស្រុកឆែប ខេត្តព្រះវិហារ, ក្នុងនោះ៤យប់នៅភ្នំធំ និង៣យប់នៅភ្នំឈ្មោក។ |
| ថ្ងៃទី២២-៣០ ខែធ្នូ ឆ្នាំ២០១៤ | ការស្រាវជ្រាវចាប់ផ្តើមចេញពីភូមិភ្វាក់រលឹក ឃុំផ្លា ស្រុកជ័យសែន ខេត្តព្រះវិហារ បន្ទាប់មកឆ្ពោះទៅភូមិស្តង់ដែលជាចំណុចប្រសព្វគ្នារវាងខេត្តបីគឺ ខេត្តព្រះវិហារ កំពង់ធំ និងស្ទឹងត្រែង។ គេបានបោះតង់ (ជុំរុំស្រាវជ្រាវ) នៅក្នុងព្រៃជាំទឹក ដែលមានចម្ងាយប្រមាណ១៨គីឡូម៉ែត្រពីភូមិស្តង់។ |

ការស្រាវជ្រាវអំពីសត្វស្លាបនេះ ត្រូវបានប្រើប្រាស់វិធីសាស្ត្រ៣យ៉ាងបញ្ចូលគ្នាគឺ ការសង្កេតកាត់ផ្លូវធ្វើដំណើរ (line transect) ការរាយអន្ទាក់សំណាញ់ (mist-netting) និងការស្វែងរកទៅតាមឱកាសដែលមាន។ ការបញ្ចូលគ្នានូវវិធីសាស្ត្រទាំងអស់នេះ មានសារសំខាន់ណាស់សម្រាប់ការសិក្សាទៅលើភាពសំបូរបែបនិងវត្តមាននៃសត្វស្លាប (Blake & Loiselle, 2001; Wang & Finch, 2002) ហើយវិធីសាស្ត្រនេះអាចជួយបំពេញឲ្យគ្នាទៅវិញទៅមក ទាក់ទងនឹងប្រភេទសត្វស្លាបដែលបានជួបប្រទះ។ សត្វស្លាបត្រូវបានគេតាមអង្កេតជារៀងរាលថ្ងៃ នៅតាមបណ្តោយផ្លូវមានស្រាប់នៅក្នុងព្រៃ ដោយចាប់ផ្តើមពីម៉ោង៥ដល់ម៉ោង១១និង៣០នាទីព្រឹក និងនៅពេលរសៀលចាប់ពីម៉ោង៣ដល់ម៉ោង៦ល្ងាច។

អន្ទាក់សំណាញ់ត្រូវបានគេប្រើប្រាស់តែប៉ុន្មានថ្ងៃមុនពេលបញ្ចប់ដំណើរស្រាវជ្រាវ ពោលគឺនៅពេលដែលតំបន់ភាគច្រើននៃជុំរុំនីមួយៗត្រូវបានអង្កេតចប់សព្វគ្រប់។ សំណាញ់មងត្រូវបានគេប្រើប្រាស់ដើម្បីចាប់សត្វស្លាបទាំងឡាយដែលរស់នៅក្នុងស្រទាប់គម្របព្រៃខាងក្រោម ហើយជាពពួកសត្វស្លាបដែលមានទំហំតូចៗ និងពិបាកស្វែងរក។ សំណាញ់បីទំហំ(12m × 2.5m x 3 sets, 15m × 2.5m x 4 sets and 10m x3m x 1 set) នៃមងអំបោះសម្រាប់សត្វស្លាបមាឌតូច (ទំហំក្រឡាគឺ 16 × 16mm និង 19 × 19mm) ត្រូវបានប្រើប្រាស់អាស្រ័យទៅលើស្ថានភាពជាក់ស្តែងនៃទីជម្រក។ សំណាញ់ត្រូវបានប្រើបាស់នៅតែជុំរុំទី២ប៉ុណ្ណោះ ដោយចាប់បើកចំហដើម្បីចាប់សត្វស្លាបចាប់ពីម៉ោង៥:៣០នាទីព្រឹករហូតដល់ម៉ោង៥ល្ងាច ហើយត្រួតពិនិត្យរៀងរាល់មួយម៉ោងម្តង។

ការស្វែងរកទៅតាមឱកាសដែលមាន ត្រូវបានធ្វើឡើងដើម្បីកត់ត្រាប្រភេទសត្វស្លាបគោលដៅកូឡូនី និងទីតាំងសំបុក ដែលមានទីតាំងនៅឆ្ងាយពីផ្លូវដែលមានស្រាប់ ជាពិសេសនៅពេលដែលក្រុម

អ្នកសង្កេតបានឃើញមានដើមឈើដែលមានផ្លែ ឬនៅពេលដែលបាន ឮសម្លេងពួកវាស្រែក។ កែវយឺតត្រូវបានប្រើប្រាស់ជាជំនួយដល់ការអង្កេតនេះ។ ឧបករណ៍ថតសម្លេងឌីជីថល (Edirol R-09HR) ត្រូវបានប្រើប្រាស់ ដើម្បីថតយកសម្លេងសត្វស្លាបតាមទីកន្លែងចាំបាច់ទុកសម្រាប់កំណត់រកអត្តសញ្ញាណនៅពេលក្រោយ។

ការកំណត់អត្តសញ្ញាណសត្វស្លាបភាគច្រើនត្រូវធ្វើឡើង តាមរយៈការមើលឃើញជាក់ស្តែង និងការស្តាប់សូរសម្លេងរបស់វា។ រីឯការចាប់ទុក ធ្វើឡើងតែនៅពេលដែលមានតម្រូវការចាំបាច់ដើម្បីបញ្ជាក់ពីអត្តសញ្ញាណរបស់វាឲ្យបានច្បាស់លាស់តែប៉ុណ្ណោះ។ ការកំណត់អត្តសញ្ញាណសត្វស្លាបត្រូវពឹងផ្អែកជាគោលលើសៀវភៅណែនាំនៃការចុះសិក្សាដល់ទីកន្លែង (Robson, 2008; Setha & Poole, 2003; Goes, 2013) និងនៅលើគេហទំព័រ www.xeno-canto.org ដែលមានបង្ហាញពីសូរស័ព្ទរបស់សត្វស្លាប។ ចំណែកស្ថានភាពនៃការអភិរក្ស និងសារៈសំខាន់របស់សត្វស្លាបនីមួយៗ គឺយោងតាមសៀវភៅណែនាំរបស់ Goes 2013។

## *លទ្ធផលស្រាវជ្រាវ*

### *ការរកឃើញជារួម*

សត្វស្លាបសរុបចំនួន២៦៦ប្រភេទ នៅក្នុង៦១អម្បូរ ត្រូវបានកត់ត្រានៅព្រៃឡង់ តាមរយៈ ការប្រើប្រាស់វិធីសាស្រ្តជាច្រើនដែលរួមបញ្ចូលគ្នា គឺមានការសង្កេតកាត់ផ្លូវធ្វើដំណើរ ការវាយអន្ទាក់សំណាញ់ ការថតដោយម៉ាស៊ីនថតរូបស្វ័យប្រវត្ត និងការស្វែងរកទៅតាមឱកាសដែលមាន។ នៅពេលបូកបន្ថែមលទ្ធផលនៃការសង្កេតពីកំណត់ត្រាផ្សេងៗទៀតនៃសត្វស្លាប (Olsson & Emmett, 2007) រួមទាំងការធ្វើសម្ភាសនៅតាមមូលដ្ឋានផងនោះ មានសត្វស្លាបលើសពី២៦៦ប្រភេទនៃ៦១អម្បូរ (សូមមើលឧបសម្ព័ន្ធ៩)។

ក្នុងចំណោមប្រភេទទាំងអស់នៃសត្វស្លាបខាងលើ មានសត្វស្លាប១៥ប្រភេទត្រូវបានកត់ត្រាក្នុងបញ្ជីក្រហមរបស់អង្គការ IUCN។ ៥៦ប្រភេទកំពុងរងការគម្រាមកំហែងនៅក្នុងតំបន់ ដូចជានៅប្រទេសឡាវ និងប្រទេសថៃជាដើម។ ចំណែកសត្វស្លាបចំនួន៣៨ប្រភេទទៀត កំពុងស្ថិតក្នុងបញ្ជីប្រភេទរងការគម្រាមកំហែងនៅក្នុងប្រទេសកម្ពុជា។ គេចាំបាច់ត្រូវស្វែងរកព័ត៌មានបន្ថែមអំពីប្រភេទសត្វស្លាបទាំងនេះ (សូមមើលឧបសម្ពន្ធ៩)។

### *ប្រភេទសត្វស្លាបសំខាន់ៗ*

**សត្វត្រយងចំកំកស (Pseudibis davison) ត្រូវបានចុះក្នុងបញ្ជីរបស់អង្គការ IUCN ថាជាប្រភេទ រងគ្រោះខ្លាំងបំផុត**

ត្រយងចំកំកស តែងតែឃើញមានរស់នៅក្នុងព្រៃរបោះ តាមវាលស្មៅ និងតាមដងទន្លេតំបន់ទំនាមដែលគ្មានការរំខាន។ សត្វប្រភេទនេះស្វែងរកចំណីភាគច្រើននៅតាមថ្លុកត្រពាំង តាមវាលស្មៅ តាមវាលស្រែ និងតាមដងទន្លេ (Goes 2013)។ យោងតាមការអង្កេតជាក់ស្តែង ព្រៃឡង់គឺជាទីដែលសម្បូរទៅដោយជម្រកយ៉ាងច្រើន ហើយដែលមានអំណោយផលសម្រាប់ការរស់នៅរបស់បក្សីប្រភេទនេះនៅក្នុងតំបន់ព្រៃឡង់ (តួយ៉ាងដូចជានៅទីតាំងស្រាវជ្រាវទី២និងទី៣ជាដើម)។ ពុំមានត្រយងចំកំកសណាមួយត្រូវបានគេប្រទះឃើញ ក្នុងកំឡុងពេលស្រាវជ្រាវនេះទេ ប៉ុន្តែប្រជាជននៅមូលដ្ឋានជាច្រើនបានពណ៌នានិងអះអាងថា ប្រភេទសត្វស្លាបនេះពិតជាមានវត្តមាននៅក្នុងព្រៃឡង់នេះមែន។ មូលហេតុនៃការថយចុះយ៉ាងច្រើន សន្ទឹកសន្ទាប់នៃចំនួនសត្វស្លាបប្រភេទនេះនៅសតវត្សទី២០នេះ គឺបណ្តាលមកពីការបាត់បង់ទីជម្រក (ការប្រែក្លាយដីដ៏ធំធេងសម្រាប់ធ្វើកសិកម្ម) និងការបរបាញ់សត្វស្លាបពេញវ័យ ការយកពង និងការចាប់កូនសត្វស្លាបធ្វើជាអាហារ (Birdlife International Cambodia Programme, 2012)។

**សត្វត្រយងយក្ស (Pseudibis gigantean) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទរងគ្រោះខ្លាំងបំផុត**

ត្រយងយក្ស គឺជាបក្សីតំណាងឲ្យប្រទេសកម្ពុជា។ នៅត្រង់តំបន់សិក្សាទី២ នៅក្នុងព្រៃឡង់មើលទៅទំនងដូចជាទីជម្រកដ៏សុខសាន្តរបស់បក្សីប្រភេទនេះ ដោយសារយើងឃើញមានត្រពាំងជាច្រើន ហើយត្រពាំងនោះទៀតសោតមានចម្ងាយឆ្ងាយពីការរំខានរបស់មនុស្ស ដែលជាហេតុធ្វើឲ្យមានភាពងាយស្រួលដល់ការការពារខ្លួនរបស់ពួកវា។ ក្នុងកំឡុងពេលស្រាវជ្រាវនេះ គេពុំបានប្រទះឃើញបក្សីប្រភេទនេះទេ ព្រោះត្រពាំងទាំងអស់មានទឹកពេញប្រៀបតែម្តង។ ត្រយងយក្សត្រូវវិនាសផុតពូជទៅហើយនៅក្នុងប្រទេសថៃ ប៉ុន្តែបច្ចុប្បន្នមាននៅតែប្រទេសកម្ពុជាប៉ុណ្ណោះ ស្របពេលដែលគេបានឃើញសត្វនេះម្តងម្កាលនៅក្នុងប្រទេសឡាវ និងវៀតណាម។ តាមការប៉ាន់ស្មាន ត្រយងយក្សមានចំនួនសរុបទាំងអស់តិចជាង ៤០០ក្បាល (BirdLife International, 2015)។

**ក្ងោកបៃតង (Pavo muticus) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទជិតផុតពូជ**

ក្នុងកំឡុងពេលស្រាវជ្រាវនេះ គេបានឮសូរសម្លេងក្ងោកមួយក្រុមនៅទីតាំងស្រាវជ្រាវទី១ នៅក្នុងព្រៃពាក់កណ្តាលស្រោង និងមួយក្រុមទៀតនៅទីតាំងទី២ ឮចេញពីនៅជម្រកព្រៃរបោះ និងព្រៃពាក់កណ្តាលស្រោងតិចតួច ស្ថិតនៅជិតជើងភ្នំធំ និងភ្នំឈ្មោក។ សត្វស្លាបប្រភេទនេះបានវិនាសផុតពូជទៅហើយពីតំបន់ខ្លះនៃប្រទេសឥណ្ឌា និងបង់ក្លាដែស ហើយបច្ចុប្បន្នមាននៅតែប្រទេសភូមា ចិន

ថៃ ឥណ្ឌូនេស៊ី កម្ពុជា វៀតណាម និងឡាវ តែប៉ុណ្ណោះ (BirdLife International, 2015)។ កត្តាគម្រាមកំហែងធំៗទៅលើសត្វស្លាបប្រភេទនេះគឺ ការបរបាញ់សម្រាប់ធ្វើជាអាហារ និងការជួញដូរនៅតាមតម្លៃទីផ្សារខ្ពស់សំរាប់ស្លាបវា និងសត្វរស់ (Goes, 2013)។


រូបភាព 20 ក្ងោកបៃតង

**ត្រដក់ធំ (Leptoptilos dubius) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទស ជិតផុតពូជ**

ត្រដក់ធំពេញវ័យមួយក្បាលត្រូវបានគេប្រទះឃើញនៅក្នុងត្រពាំងមួយ ក្នុងទីតាំងស្រាវជ្រាវ ទី២ ស្ថិតនៅចម្ងាយប្រមាណ៥គីឡូម៉ែត្រពីទីតាំងបោះជុំរុំ។ ចំណែកមួយក្បាលទៀត ត្រូវបាន ប្រទះឃើញនៅទីតាំងស្រាវជ្រាវទី៣ ដែលកំពុងស៊ីចំណីជាមួយកុកពាក់អំបោះមួយក្បាល (Woolly-necked Stork) ក្នុងត្រពាំងដែលរីងទឹកអស់ខ្លះទៅហើយនៅរដូវប្រាំង ចម្ងាយប្រមាណជា១០០ម៉ែត្រ ពីស្ទឹងធំ។

សត្វត្រដក់ធំងាយនឹងច្រឡំជាមួយត្រដក់តូចណាស់ (Birdlife International Cambodia Programme, 2012)។ ត្រដក់ធំចូលចិត្តរស់នៅតាមតំបន់ដីសើមទឹកសាបនៃតំបន់ទំនាប។ នៅប្រទេសកម្ពុជា ភាគច្រើននៃសត្វនេះ រស់នៅតាមព្រៃជាំទឹកក្នុងបឹងទន្លេសាប តាមវាលស្មៅ និងព្រៃរបោះ។ កត្តាគម្រាមកំហែងធំៗទៅលើត្រដក់ធំ គឺការបាត់បង់ទីជម្រក ការបរបាញ់សម្រាប់ធ្វើជាអាហារ និងរងការពុលដោយប្រយោលនិងដោយផ្ទាល់ពីថ្នាំពុលដែលប្រើលើដំណាំកសិកម្ម (Goes 2013)។

### ត្រដក់តូច (Leptoptilos javanicus) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទ ងាយរងគ្រោះ

ក្នុងកំឡុងពេលស្រាវជ្រាវ គេបានប្រទះឃើញសត្វត្រដក់តូចជាច្រើនក្បាល ដូចជានៅទីតាំងស្រាវជ្រាវទី១ គេឃើញត្រដក់តូចមួយក្បាលកំពុងទំនៅលើចុងឈើ ក្បែរផ្លូវទៅកាន់ភូមិ ស្រែព្រីង និងបីក្បាលទៀតកំពុងស៊ីចំណីនៅក្នុងវាលស្មៅក្បែរត្រពាំងធំមួយ តាមបណ្តោយផ្លូវពីភូមិកំណាប់ទៅភ្នំដី។ នៅទីតាំងស្រាវជ្រាវទី២ គេបានឃើញត្រដក់តូចចំនួនពីរក្បាលកំពុងហើរនៅលើត្រពាំង និងវាលស្មៅមួយកន្លែងដែលមានចម្ងាយប្រមាណ៥គីឡូម៉ែត្រពីទីតាំងបោះជុំរុំ។ គេក៏បានឃើញផងដែរនូវសំណល់ស្លាបនិងក្បាលរបស់ត្រដក់តូច ដែលនៅសេសសល់ពីការបរបាញ់ នៅជិតមាត់ព្រៃកដែលតភ្ជាប់ពីស្ទឹងទៅបឹងធំ។ ចំណែកនៅទីតាំងស្រាវជ្រាវទី៣ ត្រដក់តូចចំនួន៤ក្បាលត្រូវបានគេឃើញកំពុងរកស្វែងចំណីជាមួយក្រុមកុកពាក់អំបោះ និងពីរក្បាលទៀតកំពុងតែហើរនៅពីលើត្រពាំង និងវាលស្មៅចាស់មួយ។ ត្រដក់តូចមានរស់ទូទាំងតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ និងនៅប្រទេសឥណ្ឌូនេស៊ី ហើយទូទាំងពិភពលោកវាអាចមានចំនួនប្រមាណពី៦៥០០ ទៅ៨០០០ក្បាល ក្នុងនោះ ចំនួនពី២៥០០ ទៅ៤០០០ក្បាល ត្រូវបានគេជឿថាកំពុងមានវត្តមាននៅក្នុងប្រទេសកម្ពុជា (BirdLife International, 2015)។ ការបាត់បង់ទីជម្រក ការបរបាញ់ ការលួចយកពងនិងកូនពីសំបុក សុទ្ធសឹងជាកត្តាគម្រាមកំហែងធំបំផុតទៅលើសត្វត្រដក់តូច (Birdlife International Cambodia Programme, 2012)។



រូបភាព 21 ត្រដក់តូច នៅតំបន់ព្រៃឡង់

**ត្រសេះធំប្រផេះ (Mulleripicus pulverulentus) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទងាយរងគ្រោះ**

គេបានប្រទះឃើញត្រសេះធំប្រផេះពីរក្បាលនៅទីតាំងទី១ មួយក្បាលនៅក្នុងព្រៃរបោះ តាមផ្លូវទៅភូមិស្រែខះ និងមួយក្បាលទៀតឮសូរសម្លេងស្រែកពីចម្ងាយប្រមាណជា៣គីឡូម៉ែត្រពីទីតាំងបោះជុំរុំ។ នៅទីតាំងទី២ គេបានឃើញត្រសេះធំប្រផេះប្រាំក្បាលកំពុងស្រែកជាមួយ ក្រុមត្រសេះធំពោះស (White-bellied Woodpeckers) ក្នុងព្រៃរបោះ។ ទីតាំងស្រាវជ្រាវទី២នេះ គឺជាជម្រកដ៏សុខសាន្តសម្រាប់ត្រសេះប្រភេទនេះ ក៏ដូចជាត្រសេះប្រភេទផ្សេងទៀតដែរ។ម្យ៉ាងទៀត ទីកន្លែងនេះ គួរតែពិចារណារៀបចំឲ្យទៅជាកន្លែងដ៏ទាក់ទាញសម្រាប់ការទស្សនាកំសាន្តលើសត្វត្រសេះ ហើយក៏ជាកន្លែងដ៏មានសក្តានុពលសម្រាប់ការអភិរក្សយូរអង្វែងចំពោះបក្សីប្រភេទនេះផងដែរ។ ការសិក្សាកន្លងមកបានលើកឡើងថា ត្រសេះធំប្រផេះចូលចិត្តរស់នៅលើដើមឈើចាស់ៗ (Lammertink et al., 2009) ដូច្នេះគេចាំបាច់ត្រូវតែអភិរក្សតំបន់ព្រៃនៅទីតាំងទី២ ដើម្បីអាចទ្រទ្រង់ដល់ការរស់នៅរបស់បក្សីប្រភេទ

នេះបាន។ មិនខុសពីត្រសេះធំពោះសទេ ត្រសេះធំប្រផេះងាយនឹងរងឥទ្ធិពលខ្លាំង ប្រសិនបើដើមឈើធំៗនិងព្រៃឈើនៅតាមមាត់ទឹកត្រូវបានបាត់បង់។

**ចាបព្រៃវែងពោះលឿង (Emberiza aureola) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទងាយរងគ្រោះ**

មានចាបព្រៃវែងពោះលឿងតែពីរក្បាលប៉ុណ្ណោះ ត្រូវបានគេប្រទះឃើញនៅក្នុងវាលស្មៅ ដែលហ៊ុំពទ្ធ័ជុំវិញទៅដោយព្រៃរបោះ ក្នុងទីតាំងស្រាវជ្រាវទី២។ ចាបព្រៃវែងពោះលឿងច្រើនផ្លាស់ទីរយៈចម្ងាយឆ្ងាយនៅក្នុងរដូវរងារ នៅតាមវាលស្រែ វាលស្បូវ វាលស្មៅ និងវាលភក់ក្នុងតំបន់វាលទំនាប។ កាលពីឆ្នាំ២០០៤ ចាបព្រៃវែងពោះលឿងត្រូវបានចាត់ថ្នាក់ជាប្រភេទឈានទៅរងការគម្រាមកំហែងជាសាកល ហើយបន្ទាប់មកនៅឆ្នាំ២០០៨ វាត្រូវបានគេចាត់ថ្នាក់ជាប្រភេទងាយរងគ្រោះតែម្តង ដោយសារតែការបាត់បង់ទីជម្រកសម្រាប់បង្កាត់ពូជនៅតាមទីតាំងដែលវាផ្លាស់ទី និងនៅតាមទីជម្រកក្នុងរដូវរងារ និងការដាក់អន្ទាក់ចាប់យ៉ាងច្រើនសម្បើមសម្រាប់ធ្វើជាអាហារ ក៏ដូចជាការចាប់យកទៅលក់សម្រាប់ព្រលែងសូមសេចក្តីសុខ (BirdLife International 2015; Gilbert et al., 2012) ។

**ឥន្ទ្រីយ៍ព្រៃ (Aquila hastate) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទ ងាយរងគ្រោះ**

គេបានប្រទះឃើញឥន្ទ្រីយ៍ព្រៃមួយក្បាលទំនៅលើដើមឈើមួយដើមក្នុងព្រៃរបោះ នៅក្បែរចំណុចប្រសព្វរវាងត្រពាំងបីកន្លែង ក្នុងចំងាយប្រមាណ៥គីឡូម៉ែត្រពីកន្លែងបោះជុំរុំ នៅក្នុងទីតាំងស្រាវជ្រាវទី២។ ឥន្ទ្រីយ៍ព្រៃនេះមើលទៅស្រដៀងគ្នាទៅនឹងអកពស់ព្រៃដៃរ (Serpent-crested Eagle) តែយើងអាចចំណាំវាបានត្រង់ថាបក្សីនេះមានចំនុចពណ៌សជាច្រើននៅក្រោមពោះ និងគ្មានឆ្នូតស នៅកន្ទុយទេ។ កាលពីឆ្នាំ២០០៩ គេធ្លាប់កត់ត្រាវាម្តងរួចមកហើយនៅក្នុងស្រុកឆែប ខេត្តព្រះវិហារ (Goes 2013)។ កំណត់ត្រានេះ គឺជាជំនួយសំរាប់កំណត់អត្តសញ្ញាណសត្វប្រភេទនេះ។

**ក្រៀលក្បាលក្រហម (Grus antigone) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទងាយរងគ្រោះ**

ក្នុងកំឡុងពេលស្រាវជ្រាវ គេមិនបានជួបប្រទះសត្វក្រៀលក្បាលក្រហមមួយក្បាល ទាល់តែសោះ ប៉ុន្តែព័ត៌មានបានពីការសម្ភាសជាមួយប្រជាជនមូលដ្ឋាន ដែលរស់នៅក្នុងតំបន់សិក្សាទាំងបីកន្លែង បានអះអាងថាតំបន់ទាំងនេះពិតជាមានវត្តមានសត្វក្រៀលក្បាលក្រហម ដោយពួកគាត់បានសម្គាល់ថាសត្វនោះមានកម្ពស់ខ្ពស់ជាងសត្វស្លាបឯទៀត និងមានក្បាលពណ៌ក្រហមខុសពីសត្វស្លាបដទៃ។ ក្រុមអ្នកអង្កេតស្រាវជ្រាវបានចាត់ទុកការអះអាងនេះថា សត្វក្រៀល ក្បាលក្រហមពិតជាមានវត្តមាននៅក្នុងតំបន់ព្រៃឡង់ប្រាកដមែន។ ក្រៀលក្បាលក្រហមច្រើនរស់នៅតាមវាលស្មៅនៃតំបន់ទំនាបនិងដីរាបស្មើដែលមានវាលស្មៅ និងកន្លែងមានទឹកដក់នៅក្នុងព្រៃរបោះ (Goes 2013)។ ដោយ

ឡែកនៅប្រទេសកម្ពុជា របាយធំបំផុតនៃចំនួនក្រៀលក្បាលក្រហម មាននៅអាងត្រពាំងថ្ម ក្នុងខេត្តបន្ទាយមានជ័យ។ នៅឆ្នាំ២០១៥ អង្គការសត្វស្លាបអន្តរជាតិ (Birdlife International) បានលើកឡើងថាសត្វស្លាបប្រភេទនេះកំពុងប្រឈមនឹងហានិភ័យនៅក្នុងប្រទេសឡាវ និងបានវិនាសផុតពូជទៅហើយនៅប្រទេសថៃ។ កត្តាគម្រាមកំហែងធំៗទៅលើសត្វស្លាបប្រភេទនេះ រួមមានការបាត់បង់ទីជម្រកតំបន់ដីសើម និងការរំខានពីមនុស្ស ដូចជាការបំពុលដោយប្រយោលនិងដោយផ្ទាល់ និងការបរបាញ់សម្រាប់យកទៅធ្វើជាអាហារ (BirdLife International, 2015)។



រូបភាព 22 សត្វក្រៀលក្បាលក្រហម

**ពពូលក្បាលព្រលែត (Columba punicea) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទងាយរងគ្រោះ**

នៅទីតាំងស្រាវជ្រាវទី២ ពពូលក្បាលព្រលែតមួយក្បាលត្រូវបានគេប្រទះឃើញនៅក្នុងព្រៃរបោះនាជើងភ្នំធំ។ នៅប្រទេសកម្ពុជា កំណត់ត្រាបក្សីប្រភេទនេះភាគច្រើនមាននៅខេត្ត មណ្ឌលគិរី និងថ្មប៉ោយ ក្នុងខេត្តព្រះវិហារ (Goes 2013)។ បើទោះបីជាសត្វប្រភេទនេះអាចរងផលប៉ះពាល់ ដោយ ថៃដន្យពីការបរបាញ់ និងការប្រើថ្នាំបំពុលក៏ដោយ ក៏គេមិនទាន់ដឹងពីស្ថានភាពនៃការអភិរក្ស សត្វនេះនៅប្រទេសកម្ពុជាទេ ដោយសារគេមិនទាន់បានដឹងពីកត្តាគម្រាមកំហែងជាក់លាក់ណាមួយ ទៅលើវាឡើយ (Goes 2013)។

**ទទាទ្រូងលឿង (Arborophila davidi) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទ ជិតឈានទៅរកការគម្រាមកំហែង**

ទទាទ្រូងលឿងមួយក្បាល ត្រូវបានគេប្រទះឃើញ និងឮវាយំនៅចន្លោះព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោងក្នុងទីតាំងស្រាវជ្រាវទី២។ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ពីអត្តសញ្ញាណនៃប្រភេ ទសត្វនេះ គេបានដាក់ពង្រាយអន្ទាក់សំណាញ់ និងការស្វែងយល់តាមឱកាសជាក់ស្តែង ប៉ុន្តែមិនទទួលបានលទ្ធផលអ្វីទេ។ សត្វប្រភេទនេះកម្រមានណាស់នៅតំបន់ព្រៃឡង់ ប៉ុន្តែកំណត់ត្រាភាគច្រើនមាននៅខេត្តមណ្ឌលគិរី ជាពិសេសនៅក្នុងតំបន់ព្រៃការពារសីម៉ា (Goes 2013)។ ទទាទ្រូងលឿងត្រូវបានគេដឹងថា វារស់នៅតែនៅតាមព្រៃទំនាបភាគខាងត្បូងអាណ្ណាមប៉ុណ្ណោះ។ ការរកឃើញបក្សីប្រភេទនេះនៅព្រៃឡង់បានជួយបំពេញនូវគម្លាតជីវភូមិសាស្ត្រនៅភាគភាគកណ្តាលនៃប្រទេសកម្ពុជា ដោយបានបង្ហាញថាទទាទ្រូងលឿងមិនមែនមាននៅតែតំបន់អាណ្ណាមទេ ប៉ុន្តែយ៉ាងណាក៏ដោយ គេចាំបាច់ត្រូវតែតម្រូវឲ្យមានការស្រាវជ្រាវបន្ថែមទៀតអំពីរបាយសត្វប្រភេទនេះ ដើម្បីបញ្ជាក់ពីបញ្ហានេះ។ ភាពសំបូរបែបនៃប្រភេទសត្វនេះពិតជាមានការពិបាកក្នុងការវាយតម្លៃណាស់ ព្រោះសត្វបក្សីប្រភេទនេះមិនងាយនឹងបង្ហាញខ្លួនឲ្យយើងឃើញទេ ជាសត្វកម្របញ្ចេញសម្លេង និងពិបាកក្នុងការកំណត់ពីរបាយរបស់វាផង (BirdLife International, 2015)។ ដូច្នេះបើតាមការប៉ាន់ស្មាន ប្រសត្វភេទសត្វនេះមានចំនួនតិច ដែលមានប្រហែលជាមិនដល់រយក្បាលផង។

**រនាលពណ៌ (Mycteria leucocephala) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទ ជិតឈានទៅរកការគម្រាមកំហែង**

គេសង្កេតឃើញសត្វនេះមានវត្តមានច្រើនណាស់នៅតាមវាលទំនាបតំបន់ដីសើម ដូចជានៅព្រៃជាំទឹក វាលស្មៅ និងវាលភក់ នៅតាមឆ្នេរសមុទ្រ ជលដ្ឋាន ដងទន្លេ វាលដីសើម (Goes 2013)។ ក្នុងកំឡុងពេលស្រាវជ្រាវនៅព្រៃឡង់ យើងបានប្រទះឃើញរនាលពណ៌ពីរក្រុម គឺមួយក្រុមមានចំនួន៣ក្បាលនៅក្នុងព្រៃជាំទឹកមួយកន្លែង និងមួយក្រុមទៀតមានចំនួន៥ក្បាលនៅក្នុងត្រពាំងក្នុងព្រៃរបោះ

នៃទីតាំងស្រាវជ្រាវទី២។ ការបរបាញ់ពីសំណាក់មនុស្សសម្រាប់យកទៅធ្វើជាអាហារ គឺជាកត្តាគម្រាមកំហែងដ៏ធំជាងគេដល់ប្រភេទសត្វស្លាបមួយនេះ(Goes 2013)។

**ស្មោញ (Anhinga melanogaster) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទ ឈានទៅរងការគម្រាមកំហែង**

ស្មោញត្រូវបានគេបញ្ជាក់ថា មានវត្តមាននៅតាមតំបន់ដីសើមទឹកសាប ក្នុងនោះមានព្រៃជាំទឹក បឹងបួ ទន្លេ ជលផ្លាន វាលភក់លិចទឹក នឹងតាមព្រែកនានានៃដងទន្លេមេគង្គលើ (Robson, 2008; Goes, 2013)។ គេបបានប្រទះឃើញស្មោញមួយក្បាលកំពុងទំលើចុងឈើ ប្រហែលជា៥គីឡូម៉ែត្រពីជុំរុំ នៅទីតាំងស្រាវជ្រាវទី២ នៅក្នុងព្រៃឡង់ ហើយមួយក្បាលទៀតកំពុងស៊ីចំណីជាមួយក្រុមក្អែកទឹកតូច (Little Cormorants) ក្នុងព្រៃជាំទឹកតាមបណ្តោយផ្លូវពីទីតាំងស្រាវជ្រាវទី៣។ ការប្រមូលពងនិងកូនយកទៅធ្វើជាអាហាររបស់មនុស្ស គឺជាកត្តាគម្រាមកំហែងធំបំផុតទៅលើស្មោញ (Goes 2013)។

**ស្ទាំងស្លាបស្រួចចុងខ្នងស (Polihierax insignis) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទឈានទៅរងការគម្រាមកំហែង**

ក្រុមអ្នកស្រាវជ្រាវបានប្រទះឃើញស្ទាំងស្លាបស្រួចចុងខ្នងសជាច្រើនក្បាលនៅតាមបណ្តោយផ្លូវពីជុំរុំទីតាំងស្រាវជ្រាវទី១ទៅខាងភ្នំជី។ ជាទូទៅ គេឃើញសត្វប្រភេទនេះរស់នៅក្នុងព្រៃរបោះ និងតាមកូនភ្នំទាបៗ។ ដោយឡែក ព្រៃរបោះស្ងួតល្វឹងល្វើយនៅក្នុងប្រទេសកម្ពុជា អាចជួយទ្រទ្រង់ ដល់ប្រភេទសត្វនេះបានចំនួនច្រើនជាងគេបំផុតនៅលើពិភពលោក។ មូលហេតុដែលធ្វើឲ្យសត្វប្រភេទនេះមិនសូវជាបង្ហាញខ្លួនឲ្យគេឃើញ ប្រហែលជាដោយសារសត្វនេះមានអារម្មណ៍ថា ខ្លួនកំពុងស្ថិតនៅទីកន្លែងដែលមានដង់ស៊ីតេទាប។ ទោះជាយ៉ាងណា រហូតមកដល់ពេលនេះ គ្មានហេតុផលណាមួយ ដែលអាចឲ្យគេជឿថាចំនួនសត្វនេះកំពុងតែថយចុះ ឬក៏កំពុងតែជួបហានិភ័យ ទាល់តែសោះ ពីព្រោះវត្តមានរបស់វាមាននៅសឹងគ្រប់ទីកន្លែង និងត្រូវបានកត់ត្រាជាប្រចាំនៅតាម គ្រប់តំបន់ដែលគេបានរុករកមើលសត្វស្លាបមួយនេះ។ បច្ចុប្បន្ន ដោយសារកំណើននៃការផ្តល់ដី សម្បទានសេដ្ឋកិច្ចជាពិសេសនៅជុំវិញតំបន់ព្រៃទំនាបភាគខាងជើង និងភាគពាយ័ព្យសាន បូករួមទាំង នៅក្នុងរង្វង់ ព្រៃការពារផង នឹងអាចក្លាយទៅជាកត្តាព្រួយបារម្ភដ៏ធំបំផុតចំពោះប្រភេទស្ទាំងស្លាបស្រួចចុងខ្នងស ទៅថ្ងៃអនាគតជាក់ជាមិនខាន។ ម្យ៉ាងទៀត ការធ្វើឲ្យរប៉ាត់រប៉ាយ និងបង្កការខូចរេចរឹលនៃព្រៃរបោះ អាចបង្កជាផលប៉ះពាល់ធ្ងន់ធ្ងរដល់សត្វប្រភេទនេះ ហេតុដូច្នេះគេចាំបាច់ត្រូវតែតាមដានពិនិត្យឲ្យបានទៀតទាត់ទៅលើស្ថានភាពរស់នៅរបស់វា (Goes 2013)។

**កេងកងធំ (Buceros bicornis) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទ ជិតឈាន ទៅរកការគម្រាមកំហែង**

កេងកងធំ ហាក់ដូចជាមានចំនួនច្រើនគួរសមនៅក្នុងព្រៃឡង់ ដោយសារគេបានប្រទះឃើញវា នៅគ្រប់ទីតាំងស្រាវជ្រាវទាំងអស់។ នេះអាចដោយសារតែនៅព្រៃឡង់នៅមានដើមឈើធំៗ និងខ្ពស់ៗជាច្រើនដែលផ្តល់សុវត្ថិភាព ទីជម្រក និងប្រភពអាហារគ្រប់គ្រាន់ដល់ពួកវា។ នៅប្រទេស កម្ពុជា កេងកងធំ ធ្លាប់មានប្រវត្តិរងគ្រោះ និងមានចំនួនថយចុះនាពេលថ្មីៗនេះ។ ការស្រាវជ្រាវផ្សេងៗ បានសន្មតថា ជួរភ្នំក្រវាញនិងជួរភ្នំដំរីគឺជាតំបន់ដែលមានសត្វកេងកងធំនេះរស់នៅច្រើនជាងគេ បន្ទាប់មកគឺនៅផ្នែកកណ្តាលភាគខាងត្បូងនៃខេត្តមណ្ឌលគិរី។ ចំណែកឯពពួកសត្វផ្សេង ទៀតក្នុងអំបូរនេះកំពុងរងគ្រោះ កាន់តែខ្លាំងឡើងៗ។ កត្តារងគ្រោះរបស់កេងកងធំភាគច្រើនបណ្តាលមកពីការបរបាញ់សម្រាប់ធ្វើជាអាហារ និងជាគ្រឿងលម្អ ការបាត់បង់ទីជម្រក និងការខូចរេចរឹលនៃព្រៃឈើ ជាពិសេសដោយសារការកាប់បំផ្លាញដើមឈើធំៗដែលជាទ្រនំរបស់វា ( Goes 2013)។

## *ការពិភាក្សា*

ទោះបីជាការអង្កេតស្រាវជ្រាវនេះត្រូវបានធ្វើឡើងក្នុងរយៈពេលមួយឆាប់រហ័សក្តី ពោលគឺបានធ្វើឡើងតែនៅក្នុងរដូវវស្សា និងគ្របដណ្តប់លើទំហំផ្ទៃដីតូច ក៏ការស្រាវជ្រាវនេះបានក្លាយជារបាយការណ៍វាយតម្លៃបឋម ដែលបង្ហាញថាព្រៃឡង់ពិតមានវត្តមានសត្វស្លាបរហូតដល់ជិត៥៥%នៃសត្វស្លាបត្រូវបានកត់ត្រាសរុបទាំងអស់នៅប្រទេសកម្ពុជា។ កាលពីមុន គេអាចយល់ដឹងតិចតួចបំផុតអំពីជីវភូមិសាស្ត្រ និងស្ថានភាពរស់នៅរបស់សត្វស្លាបនៅក្នុងតំបន់ព្រៃឡង់ បើទោះបីព្រៃនេះត្រូវ បានគេចាត់ទុកថាជាព្រៃទំនាបធំជាងគេបំផុតដែលនៅសេសសល់ក្នុងតំបន់ក៏ដោយ។ អ្វីដែល គួរឲ្យ ចាប់អារម្មណ៍បំផុតនោះគឺ វត្តមានរបស់សត្វទទាទ្រូងលឿងដែលត្រូវបានកត់ត្រានៅតំបន់នេះ ព្រោះ ជាទូទៅគេឃើញមានតែនៅភាគឦសាននៃប្រទេសតែប៉ុណ្ណោះ ប៉ុន្តែបច្ចុប្បន្នគេឃើញមាននៅព្រៃឡង់ដែរ។ ដូចគ្នានេះដែរ បច្ចុប្បន្នសត្វក្ងោកបៃតងឃើញមានចំនួនយ៉ាងច្រើននៅតាមទីជម្រកនៃព្រៃឡង់។ ទោះបីជាគេមិនបានជួបប្រទះដោយផ្ទាល់ ភ្នែកចំពោះសត្វត្រយ៉ងយក្ស ត្រយងចំកំកស និងក្រៀលក្បាលក្រហម ក្នុងអំឡុងពេលស្រាវជ្រាវនេះក្តី ក៏គេអាចដឹងបានតាមរយៈការសាកសួរព័ត៌មានពី ប្រជាសហគមន៍មូលដ្ឋាន និងការអង្កេតដោយផ្ទាល់ថាសត្វស្លាបទាំងប៉ុន្មានខាងលើនេះពិតជាមាន វត្តមាននៅក្នុងព្រៃឡង់ ហើយគេអាចមើលឃើញពួកវានៅរដូវប្រាំង ពោលគឺនៅពេលដែលទឹកចាប់ ផ្តើមស្រកហូតនៅសល់តិចតួចក្នុងត្រពាំង។

ការស្រាវជ្រាវនេះមានរយៈពេលខ្លីពេក និងធ្វើនៅត្រឹមតែទីជម្រកចំនួនពីរទៅបីប្រភេទតែប៉ុណ្ណោះ ដូច្នេះគេមិនអាចទាញសេចក្តីសន្និដ្ឋានជារួមអំពីសារៈសំខាន់ដែលមានទាំងប៉ុន្មានរបស់ទី

ជម្រកខុសៗគ្នាដទៃទៀតបានទេ។ ទីជម្រកទាំងអស់នេះភាគច្រើនស្ថិតនៅក្នុងព្រៃរបោះ ព្រោះជាទីដែលងាយស្រួលធ្វើដំណើរចូលទៅដល់នៅរដូវវស្សា ប៉ុន្តែការអង្កេតស្រាវជ្រាវនេះពិតជាមានការលំបាកធ្វើជាងនៅទីជម្រកក្នុងព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង ដែលភាគច្រើនមាននៅតំបន់កណ្តាលភាគខាងជើង (ទីតាំងស្រាវជ្រាវទី១)។ បន្ថែមពីលើនេះទៅទៀត នៅមានទីតាំងស្រាវជ្រាវដ៏មានសក្តានុពលនៅក្នុងព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង ពីព្រោះជាតំបន់ព្រៃចាស់ដែលទើបដុះឡើងវិញ រួមជាមួយនឹងគម្របព្រៃស្រទាប់ក្រោមនិងព្រៃស្រទាប់ជាន់ក្រោមដែលមានសភាពស៊ុបទ្រុបបំផុត ហើយបានបង្កការលំបាកក្នុងការមើលឃើញនឹងភ្នែកនិងស្តាប់ឮសម្លេងពពួកសត្វស្លាប។

## *កត្តាគម្រាមកំហែង*

តាមរយៈការស្រាវជ្រាវនេះ កត្តាគម្រាមកំហែងចម្បងៗទៅលើសត្វស្លាបនៅព្រៃឡង់ មានដូចតទៅ៖

- **ការខូចខាតព្រៃឈើនិងទីជម្រក។** សត្វស្លាបត្រូវរងការគម្រាមកំហែងដោយសារការបាត់បង់និងការបែកខ្ញែកនៃទីជម្រក ដោយសារការកាប់ព្រៃឈើ (មានគ្រប់ទីកន្លែងក្នុងព្រៃឡង់) និងការរានដីព្រៃសម្រាប់ធ្វើកសិកម្ម។ គេបានសង្កេតឃើញមានចំការមិនត្រឹមតែនៅជិតភូមិប៉ុណ្ណោះទេ វាក៏មានផងដែរនៅជិតៗតំបន់ដែលមានការដេងជ័រទឹកនិងជ័រចុង។ ចំនួនកើនឡើងនៃផ្លូវដែលគេប្រើប្រាស់សម្រាប់ការចូលទៅកាប់ និងដឹកជញ្ជូនឈើចេញពីក្នុងព្រៃក៏អាចជាលទ្ធភាពមួយដែលនាំឲ្យមានការកើនឡើងនូវសម្ពាធនៃការបរបាញ់ចំពោះសត្វស្លាបផងដែរ។

- **ការបរបាញ់សម្រាប់ធ្វើជាអាហារនៅក្នុងមូលដ្ឋាន។** គេបានរកឃើញមានភស្តុតាងនៃការបរបាញ់សត្វស្លាបមាន ដូចជាសំណល់ស្លាបសត្វ ដែលនៅសេសសល់ពីការបរបាញ់ និងសត្វស្លាបដែលបានសម្លាប់រួចកាន់យួរដោយព្រានព្រៃ និងសត្វស្លាបមិនទាន់ស្លាប់ដែលជាប់សំណាញ់អន្ទាក់ដែលគេដាក់នៅតាមព្រៃជាំទឹក។ មងអាកាសដែលបានដាក់ពង្រាយនោះមិនត្រឹមតែចាប់សត្វស្លាបប៉ុណ្ណោះទេ ពោលគឺអាចចាប់បានរាល់សត្វទាំងឡាយដែលហើរមកជាប់មងនោះទៀតផង។ មានមនុស្សជាច្រើន ដែលចូលទៅក្នុងព្រៃ មិនថាចាស់ឬក្មេងទេ គឺសុទ្ធតែមានកាន់ចំពាមកៅស៊ូ ឬក៏កាំភ្លើងស្នប់កែច្នៃ។ ក្រុមអ្នកស្រាវជ្រាវបានសង្កេតឃើញផងដែរថាការបរបាញ់ គឺមិនចំពោះតែសត្វស្លាបធំៗនោះទេ ប៉ុន្តែឃើញមានតាំងពីសត្វស្លាបតូចៗចាប់ពីពួកអន្ទេបរបាហួតដល់ត្រដក់តូច។



រូបភាព 23 សំណល់ស្លាបត្រដក់តូចដែលព្រានព្រៃបានបន្សល់ចោល នៅក្នុងព្រៃឡង់

## *ការផ្តល់អនុសាសន៍*

- ការពារតំបន់ព្រៃឡង់ដោយអនុទ្យោមតាមច្បាប់ស្តីពីព្រៃឈើជាតិ។
- ធ្វើឲ្យប្រសើរឡើងចំពោះចំណាត់ការនៃអនុវត្តច្បាប់នាពេលបច្ចុប្បន្ន គឺមិនត្រឹមតែចាត់វិធានការច្បាប់ទៅលើការកាប់ព្រៃឈើទេ ប៉ុន្តែរាប់ទាំងការបរបាញ់សត្វ និងការរុករានដីព្រៃផងដែរ។

- រៀបចំឲ្យមានកម្មវិធីអប់រំស្តីពីសារៈសំខាន់នៃសត្វស្លាប ជាពិសេសនៅកម្រិតសហាគមន៍ ដោយគួរចាប់ផ្តើមជាមួយនឹងក្រុមយុវវ័យជាមុន។
- អនុវត្តការសិក្សាស្រាវជ្រាវឲ្យបានយូរជាងនេះបន្ថែមទៀតនៅតាមតំបន់ដែលបានធ្វើកន្លងមក និងពង្រីកទៅទីតាំងផ្សេងៗទៀតនៅក្នុងព្រៃឡង់។
- បង្ហាត់បង្រៀនបច្ចេកទេសកត់ត្រាសត្វស្លាបទៅដល់មន្ត្រីអនុវត្តច្បាប់ ដែលជាអ្នកចូលព្រៃញឹកញាប់ ដើម្បីឲ្យពួកគេចេះកត់ត្រាទិន្នន័យសត្វស្លាប។
- បង្កើតឲ្យមានទីកន្លែងសម្រាប់មើលសត្វស្លាបកំសាន្តនៅតាមតំបន់ដែលមានសក្តានុពលសត្វស្លាប ដូចជានៅទីតាំងស្រាវជ្រាវទី២ក្នុងព្រៃរបោះ មិនត្រឹមតែសម្រាប់ការកំសាន្តរបស់អ្នកទេសចរប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់ជាការផ្តល់ឱកាសសិក្សាដល់អ្នកស្រាវជ្រាវក្នុងប្រទេសផងដែរ។

# ៦. ថលជលិកនិងឧរង្គសត្វ

ដោយលោក នាង ធី

## សេចក្តីផ្តើម

ពពួកថលជលិក-ឧរង្គសត្វ (Herpetofauna) គឺសំដៅលើអំបូរកង្កែប និងល្មូនអថេរកំដៅ ដែលសីតុណ្ហភាពរាងកាយប្រែប្រួលចុះឡើងទៅតាមបរិស្ថានជុំវិញដែលពួកវារស់នៅ។ ថលជលិករួមមានពពួកកង្កែប ពពួកអំបូរកង្កែបគ្មានជើង និងពពួកសាឡាម៉ង់ ទោះបីពពួកពីរចុងក្រោយគ្មាននៅប្រទេសកម្ពុជាក៏ដោយ (Neang & Holden, 2008)។ ចំណែកឧរង្គសត្វរួមមានពពួកក្រពើ ពពួកអណ្តើក ពពួកជីងចក់ ពពួកពស់ និងពពួកបង្គួយTuatara (Cox et al., 1999; Das, 2010) និងជាថ្មីម្តងទៀត ពពួកបង្គួយចុងក្រោយគេនេះគ្មាននៅប្រទេសកម្ពុជាទេ។

ការសិក្សាថលជលិក-ឧរង្គសត្វ នៅកម្ពុជានៅមានកំរិតតិចតួចបំផុត។ ការសិក្សាថលជលិក-ឧរង្គសត្វនេះនៅប្រទេសកម្ពុជាបានត្រូវផ្តួចផ្តើមជាដំបូងដោយ Günther (ឆ្នាំ១៨៦១, ១៨៦៤) និង Bourret (ឆ្នាំ១៩៣៦, ១៩៤១, ១៩៤២) បន្ទាប់មកដោយ Smith (ឆ្នាំ១៩៤៣), Shibata (ឆ្នាំ១៩៦៧) និង Saint Girons (ឆ្នាំ១៩៧២) មុនពេលកើតមានសង្គ្រាមស៊ីវិលក្នុងប្រទេស នៅឆ្នាំ១៩៧៥។ ដោយសារតែជម្លោះអូសបន្លាយរយៈពេលជិត៣ទសវត្សរ៍ និងដោយសារគ្មានលទ្ធភាពចេញចូលតំបន់ជាច្រើនផងនោះ ចំណេះដឹងទាក់ទងនឹងថលជលិក-ឧរង្គសត្វ នៅប្រទេសកម្ពុជានៅតែខ្សត់ខ្សោយ ហើយតាមមិនទាន់ប្រទេសជិតខាងរបស់ខ្លួន ដូចជាប្រទេសថៃ(Taylor, ១៩៦២, ១៩៦៣, ១៩៦៥), ប្រទេសឡាវ (Stuart, ១៩៩៩, ២០០៥) និងប្រទេសវៀតណាម (Inger et al. ១៩៩៩; Orlov et al., ២០០២)។

ការស្រាវជ្រាវពីថលជលិក-ឧរង្គសត្វ ក្រោយពីចប់ជម្លោះ ភាគច្រើនផ្តោតទៅលើតំបន់ជួរភ្នំក្រវាញស្ថិតនៅភាគនីរតីនៃប្រទេសកម្ពុជា (Grismer et al., 2008; Neang et al., 2014; Ohler et al., 2002; Stuart & Emmett, 2006) និង តំបន់ភាគឦសាននៃប្រទេសកម្ពុជា (Rowley et al., 2010; Stuart et al., 2006, 2010)។ ការអង្កេតស្រាវជ្រាវដាច់ៗពីគ្នាខ្លះៗក៏ត្រូវបានដំណើរការនៅតាមបណ្តោយទន្លេមេគង្គ (Bezuijen et al., 2009), នៅបឹងទន្លេសាប (Brook et al., 2007a, 2007, 2009) និងនៅជុំវិញខេត្តសៀមរាប (Hartmann et al., 2013)។ Brook et al., (2007a, 2007, 2009)ក៏បានវាយតម្លៃផងដែរ ទៅលើផលប៉ះពាល់នៃការបរបាញ់សត្វ និងការជួញដូរពស់ត្រីនៅបឹងទន្លេសាប។ ការអង្កេតស្រាវជ្រាវទាំងនេះត្រូវបានអនុវត្តនៅក្នុងតំបន់ក្បែរៗព្រៃឡង់។ ទោះជាយ៉ាងណាក៏ដោយ ព្រៃឡង់ស្ទើរតែគ្មានជីវវិទូណាធ្លាប់ចូលទៅសិក្សា។

មានករណីពិសេសមួយទាក់ទងនឹងបញ្ហានេះ គឺថាការអង្កេតស្រាវជ្រាវម្តងពីប្រភេទថលជលិក និងឧរង្គសត្វត្រូវបានធ្វើឡើងដោយ Rowley (ឆ្នាំ២០០៧) ហើយការស្រាវជ្រាវពីប្រភេទសត្វអណ្តើក ត្រូវបានធ្វើឡើងនៅក្នុងព្រៃស្រោងភាគកណ្តាលនៃព្រៃឡង់ ដោយ Olsson & Emmett (ឆ្នាំ២០០៧)។



រូបភាព 24 កញ្ចាញ់ចេកប្រភេទHylarana erythraea នៅក្នុងព្រៃឡង់

ហេតុដូច្នេះហើយការអង្កេតស្រាវជ្រាវនេះ គឺជាការសិក្សាអំពីថលជលិក-ឧរង្គសត្វ ដ៏ទូលំទូលាយលើកដំបូងនៅព្រៃឡង់ សំដៅបង្ហាញសក្ខីកម្មយ៉ាងត្រឹមត្រូវអំពីសារៈសំខាន់នៃថលជលិក-ឧរង្គសត្វ ទុកដូចជាគុណតម្លៃជីវៈចម្រុះរបស់តំបន់មួយនេះ ក៏ដូចជាផ្តល់ការកំណត់ ឲ្យបានច្បាស់លាស់អំពីការគម្រាមកំហែង នានាទៅលើ ពពួកសត្វនោះនៅព្រៃឡង់ សំដៅធ្វើអនុសាសន៍ឲ្យមានការចាត់វិធាន ការអភិរក្សជាក់ស្តែង ដើម្បីរក្សាតំបន់ព្រៃទំនាប ដែលនៅសេសសល់ចុងក្រោយរបស់ព្រៃឡង់ឲ្យនៅគង់វង់។

## វិធីសាស្ត្រស្រាវជ្រាវ

ការចុះសិក្សាស្រាវជ្រាវដល់ទីកន្លែងជាងលើកដំបូង ត្រូវបានធ្វើឡើងនៅចន្លោះថ្ងៃទី១៦និងថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៤ នៅជុំវិញទីតាំងស្រាវជ្រាវ C1 និងC2 (សូមមើលតារាង៧ដែលមានបង្ហាញពីទីតាំងភូមិសាស្ត្រទាំងនេះ)។ ការរុករករយៈពេលខ្លីមួយបន្ទាប់ពីមានភ្លៀងធ្លាក់នៅពេលយប់ ត្រូវបានគេអនុវត្តផងដែរនៅក្នុងភូមិសាស្ត្រភូមិស្រែព្រីង នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៤។ ចំណែក ការអង្កេតស្រាវជ្រាវដល់ទីកន្លែងលើកទីពីរ ត្រូវបានធ្វើឡើងនៅចន្លោះពីថ្ងៃទី២០និងទី២៧ ខែកក្កដា ឆ្នាំ២០១៤ នៅជុំវិញភ្នំដែលសម្បូរដោយស្រទាប់ថ្ម Karst (តំបន់C3)។ ការអង្កេតស្រាវជ្រាវ រប៉េះរប៉ោះមួយចំនួនទៀត ក៏ត្រូវបានអនុវត្តផងដែរនៅក្នុងភូមិស្រែខាស និងអូរក្រាក់ នៅតំបន់ព្រៃឡង់ (សូមមើលតារាង 7 )។ តំបន់ដែលបានស្រាវជ្រាវភាគច្រើន សុទ្ធតែត្រូវរងផលប៉ះពាល់អាក្រក់ ដោយសារសម្បទានកាប់ឈើកន្លងមករបស់ក្រុមហ៊ុនភាភីមិច (Pheaphimex)។ ប្រភេទដើមឈើ ប្រណីតពីរប្រភេទគឺ ដើមឈើទាលគ្រើះ (Dipterocarpus costatus) និងផ្គាត (Anisoptera costata) ដែលធ្លាប់តែសម្បូរនៅព្រៃពាក់កណ្តាលស្រោង ត្រូវបានគេកាប់យកក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ និង ដើមទសវត្សរ៍ឆ្នាំ២០០០។ ផ្លូវបត់បែនដែលគេចូលទៅកាប់ឈើក្នុងព្រៃឡង់ នៅតែមានជនល្មើសអាច

ចេញចូលដើម្បីកាប់និងដឹកឈើចេញ ហើយអ្នកបរបាញ់សត្វ និងអ្នកប្រមូលអនុផលព្រៃឈើ ក៏នៅតែប្រើប្រាស់ផ្លូវបត់បែនមួយនេះផងដែរ។ កាលបរិច្ឆេទនិងកិច្ចខិតខំប្រឹងប្រែងអង្កេតស្រាវជ្រាវទាំងអស់មានបង្ហាញនៅក្នុងតារាង៧ខាងក្រោមនេះ។

តារាង 7 កាលបរិច្ឆេទនិងទីតាំងនៃការអង្កេតស្រាវជ្រាវថលជលិក-ឧរង្គសត្វ

| កាលបរិច្ឆេទស្រាវជ្រាវ | ទីតាំងស្រាវជ្រាវ | ចំណុចទីតាំងសកល UTM (WG84) | | រយៈកម្ពស់ | ប្រភេទជម្រក |
|---|---|---|---|---|---|
| ១៧-មិថុនា ២០១៤ | ភូមិស្រែព្រីង (SPV) | 0563859 | 1431573 | ៥៨ ម | ព្រៃរបោះដែលសម្បូរដោយត្រពាំង ស្រះ និងថ្លុក នៅសងខាងផ្លូវ |
| ១៨-២១-មិថុនា ២០១៤ | ជុំរុំទី១ (C1) | 0575570 | 1454149 | ១០១ ម | តំបន់ទំនាបពាក់កណ្ដាលស្រោង ដែលរង ការកាប់ឈើនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ និងឆ្នាំ ២០០០ |
| ២២-២៤ មិថុនា ២០១៤ | ភ្នំជី (C2) | 0571918 | 1430036 | ៣២០ ម | ព្រៃពាក់កណ្ដាលស្រោងលើភ្នំតូចៗដែលសម្បូរទៅដោយដើមឈើយកជ័រធំៗនៅសេសសល់ |
| ២០-២៧ កក្កដា ២០១៤ | ភ្នំធំ ទីមានផ្ទាំងសីលា (C3) | 0579149 | 1524759 | ១២០ ម | ភ្នំធំ ព្រៃពាក់កណ្ដាលស្រោង និងព្រៃរបោះព័ទ្ធជុំវិញស្រទាប់ថ្ម Karst |
| ១០-តុលា ២០១៤ | ស្រែខាស (C4) | 0584807 | 1464460 | ៨៩ ម | វាលស្រែតាមរដូវកាលព័ទ្ធជុំជិតដោយព្រៃពាក់កណ្ដាលស្រោង |
| ១៩-វិច្ឆិកា ២០១៤ | អូក្រាក់ (C5) | 0588174 | 1449162 | - | ព្រៃពាក់កណ្ដាលស្រោង |

ការស្វែងរកពពួកថលជលិកនិងឧរង្គសត្វទៅតាមឱកាសល្អៗ ត្រូវបានធ្វើឡើងទាំងថ្ងៃទាំងយប់ទៅតាមជម្រកធំនិងតូចភាគច្រើន នៅជុំវិញទីតាំងស្រាវជ្រាវ។ សកម្មភាពសិក្សាស្រាវជ្រាវទាំងនេះរួមមានការស្វែងរកនៅតាមទីទឹករាក់ៗ តាមដងអូរ តាមខ្សែទឹកហូរឃើតនិងលឿន តាមបណ្តោយផ្លូវក្នុងព្រៃ តាមតំបន់វាលភក់ តាមជុំវិញស្រះ ត្រពាំង ថ្លុក តាមមែកឈើ តាមរូងភ្នំ និងរូងថ្មស្រទាប់Karst។ កំណាត់ឈើហ៊ុបមួយចំនួនត្រូវបានគេកាប់ផ្តួលរំលំចោលនៅតាមទីកន្លែងមួយចំនួន។ ចំពោះប្រភេទសត្វដែលយើងបានចាប់បាន តើងត្រូវថតរូប និងលែងទៅវិញតាមលទ្ធភាពដែលអាចធ្វើទៅបានដោយមិនធ្វើឲ្យវារងរបួសឡើយ។ ថលជលិកនិងឧរង្គសត្វត្រូវបានកំណត់ អត្តសញ្ញាណ ដោយការប្រើប្រាស់សៀវភៅមគ្គុទ្ទេសស្តីពីថលជលិកនៃប្រទេសកម្ពុជា *"Field Guide to Amphibians of Cambodia"* (Neang & Holden, 2008) សៀវភៅមគ្គុទេសស្តីពីឧរង្គសត្វនៅ តំបន់អាស៊ីអាគ្នេយ៍ *"Reptiles of Southeast Asia"* (Cox et al. 1999; Das 2010) និងសៀវភៅ មគ្គុទេសស្តីពីសត្វអណ្តើកនៃប្រទេសថៃឡាវ វៀតណាម និងប្រទេសកម្ពុជា *Turtles of Thailand, Laos, Vietnam and Cambodia* (Stuart et al. 2001)។

## *លទ្ធផលស្រាវជ្រាវ*

ការរកឃើញជារួម

ជាសរុបថលជលិក-ឧរង្គសត្វចំនួន៦៧ប្រភេទ ត្រូវបានបញ្ជាក់ជាលើកដំបូងតាមរយៈការអង្កេតស្រាវជ្រាវដល់ទីកន្លែងនិងឯកសារផ្សព្វផ្សាយស្តីពីព្រៃឡង់។ ប្រភេទទាំងនេះរួមមានថលជលិកចំនួន២២ប្រភេទ (ក្នុង៥អម្បូរ និង១៤ពួក) ហើយឧរង្គសត្វមានចំនួន៤៥ប្រភេទ (ក្នុង១៤អម្បូរ និង៣៥ពួក)។ Olsson & Emmett (2007) ក៏បានឲ្យដឹងផងដែរថា មានកង្កែបចំនួនពីរប្រភេទ អណ្តើកចំនួន៤ប្រភេទ និងពស់ចំនួនពីរប្រភេទ ដែលការសិក្សាស្រាវជ្រាវ នាពេលបច្ចុប្បន្ននេះមិនបានប្រទះឃើញឡើយ។ លើសពីនេះទៀត ក្រុមអ្នកស្រាវជ្រាវបានប្រទះឃើញពស់វែករនាមមួយក្បាល (king cobra) និងពស់វែកក្របីមួយក្បាល (monocellate cobra) ជាបន្តបន្ទាប់ក្នុងពេលបំពេញការងារស្រាវជ្រាវដល់ទីកន្លែងនៅក្នុងព្រៃឡង់នៃខេត្តកំពង់ធំ នៅឆ្នាំ១៩៩៩ និងឆ្នាំ២០០១។ ការអង្កេតស្រាវជ្រាវ បានផ្តល់លទ្ធផលនៃការរកឃើញថលជលិក-ឧរង្គសត្វចំនួន៥៧ប្រភេទ (ថលជលិកចំនួន២០ប្រភេទ និងឧរង្គសត្វចំនួន៣៧ប្រភេទ)។ ទោះជាយ៉ាងណាក៏ដោយ គេជឿថានៅមាន ថលជលិកសត្វ និងឧរង្គសត្វជាច្រើនប្រភេទទៀតនៅក្នុងតំបន់ ព្រៃឡង់ ដែលមិនទាន់បានរកឃើញអស់នៅឡើយទេ លុះណាតែមានកិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវដល់ទីកន្លែងបន្ថែមទៀត ដើម្បីរុករកឲ្យឃើញនូវប្រភេទសត្វថ្មីៗជាច្រើនទៀតដែលមាននៅទីនោះ។ ប្រភេទសត្វដែលគេរំពឹងថានឹងអាចរកឃើញ ប៉ុន្តែនៅតែបាត់ពីបញ្ជីកំណត់ត្រាដែលមាន ដូចជាថ្លែនកន្ទុយក្រហម (Butterfly Lizard), ពស់ថ្លាន់តូច (Burmese Python)

និងពស់ជាច្រើន ប្រភេទផ្សេងៗទៀត។ បញ្ជីរាយនាមប្រភេទថលជលិក-ឧរង្គសត្វ ទាំងអស់ដែលកំពុងរស់នៅព្រៃឡង់មានបង្ហាញនៅក្នុង (ឧបសម្ព័ន្ធ៥)។

ភាគច្រើននៃប្រភេទសត្វដែលត្រូវបានរកឃើញមាន៨៥% គឺជាប្រភេទសត្វតំណាងឲ្យជម្រកប្រែប្រួលដោយសារឥទ្ធិពលរបស់មនុស្ស ហើយសត្វទាំងនេះមានវត្តមាននៅក្នុងតំបន់ទំនាបនៅទូទាំងប្រទេសកម្ពុជា។ ប្រភេទសត្វចំនួន៦ ដែលរួមគឺង្កក់ស្រុក (Ingerophrynus macrotis), កង្កែប Hylarana mortenseni, កញ្ចាញ់ចេករន្ធឈើមានអុច (Theloderma stellatum) អណ្ដើកក្អែកខ្មៅ (Siebenrockiella crassicolis) បង្កួយមានពុកមាត់ (Calotes mystaceus) និងថ្លែនអុចខ្មៅស្ទើរចំហៀងខ្លួន (Sphenomorphus stellatus) ធ្លាប់បានកត់ត្រាពីមុនរួចមកហើយ នៅក្នុងតំបន់ ជួរភ្នំក្រវាញ (Emmett & Olsson 2005; Grismer et al. 2008; Ohler et al. 2000; Stuart & Emmett, 2006) និងក្នុងខេត្តសៀមរាប (Hartmann et al. 2013)។ កង្កែបពីរប្រភេទគឺកង្កែបអាណ្ដាមក្បាលធំ (Limnonectes dabanus) និងកង្កែបប្រភេទ Pelochylax lateralis និងអណ្ដើកពីរប្រភេទ គឺអណ្ដើកសោមឈ្មោល (Cyclemys oldhemii) និងអណ្ដើកសោមញី (Heosemys Grandis) ត្រូវបានកត់ត្រានៅក្នុងខេត្តក្រចេះ និងនៅទន្លេមេគង្គ (Benzuijen et al. 2007; Neang & Holden 2008; Stuart & Platt 2004), និងក្រោយមកទៀតប្រភេទចំនួនបីទៀត ត្រូវបានគេរកឃើញផងដែរនៅឯខេត្តសៀមរាប (Hartmann et al. 2013) ។

លទ្ធផលនៃការស្រាវជ្រាវនេះបានផ្ដល់មកនូវការបន្តពង្រីកវិសាលភាពបន្ថែមទៀតចេញពីព្រំប្រទល់ដែនខាងកើតបំផុតដែលមានសេចក្ដីរាយការណ៍អំពីប្រភេទសត្វដែលមាននៅតំបន់ជួរភ្នំក្រវាញ និងចេញពីព្រំប្រទល់ដែនភាគខាងលិចបំផុតដែលមានសេចក្ដីរាយការណ៍អំពីប្រភេទសត្វដែលមាននៅភាគខាងកើតនៃប្រទេសកម្ពុជា (ខាងកើតទន្លេមេគង្គ)។ កំណត់ត្រាអំពីសត្វកង្កែបអាណ្ដាមក្បាលធំ (Limnonectes dabanus) ដែលមាននៅតំបន់ព្រៃឡង់ គឺជាកំណត់ត្រាថ្មីមួយដ៏គួរឱ្យចាប់អារម្មណ៍ ដោយសារតែឥឡូវនេះយើងអាចបញ្ជាក់ថាវាមានវត្តមាននៅភាគខាងលិចផង និងភាគខាងកើតផងនៃទន្លេមេគង្គ ដែលមើលទៅហាក់ដូចជាលទ្ធផលនៃការបង្កើតទីតាំងភូមិសាស្ត្រដាច់ចេញពីគ្នានៃ តំបន់ទន្លេមេគង្គកាលពីប្រហែល៥០០០ឆ្នាំមុន (Woodruff 2010)។ កង្កែប Hylarana morternseni ដែលមាននៅតំបន់ព្រៃឡង់ត្រូវបានកំណត់អត្តសញ្ញាណខុសពីការអះអាងថាជា H. nigrovittata ដោយ Rowley (2007) ដូច្នេះគេនៅតែអះអាងថាវត្តមាននៃប្រភេទសត្វនេះមាននៅតែក្នុងភាគខាងលិចនៃប្រទេសកម្ពុជា (មិនមែនភាគខាងកើតទេ) ដោយសារថាប្រភេទសត្វនេះមានតែនៅតំបន់ជួរភ្នំក្រវាញ និងខេត្តសៀមរាបតែប៉ុណ្ណោះ។

សំខាន់ជាងនេះទៅទៀត ឧរង្គសត្វមួយប្រភេទ គឺតុកកែក្រាំងថ្ម (Gekko petricolus) ត្រូវបានរកឃើញជាលើកដំបូងនៅក្នុងព្រៃឡង់នៃប្រទេសកម្ពុជា។ កំណត់ត្រានៃប្រភេទសត្វនេះក្នុងប្រកាស

ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៧ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថាជាប្រភេទតុកកែត្រូវបានធ្វើឡើងមុនកាលកំណត់ ព្រោះមិនទាន់មានឯកសារ របាយការណ៍ រូបថត ឬសំណាកផ្សេងៗទៀតដែលអាចបញ្ជាក់ថាសត្វនេះពិតជាវត្តមាននៅក្នុងប្រទេសកម្ពុជានៅពេលនោះទេ។ ឧរង្គសត្វប្រភេទ cincella rupicola ត្រូវបានរកឃើញជាលើកទីពីរ បន្ទាប់ពីវាត្រូវបានគេរកឃើញ ជាលើកដំបូងនៅខេត្តសៀមរាប (Hartmann et al. in prep.)។ ប្រភេទឧរង្គសត្វទាំងពីរខាងលើនេះ ទំនងជាមានតែនៅក្នុងតំបន់ជុំវិញព្រៃឡង់ និងនៅភាគខាងជើងតាមព្រំដែនប្រទេសថៃ ដោយមាន លក្ខណៈជីវភូមិសាស្ត្រដាច់ពីតំបន់ជួរភ្នំក្រវាញ និងពីភាគខាងកើតនៃប្រទេសកម្ពុជា។

ថ្លែនមួយប្រភេទ (Lygosoma sp.) ដែលទើបតែត្រូវបានរកឃើញនៅក្នុងតំបន់ជួរភ្នំក្រវាញក្នុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ (នាងធី: ទិន្នន័យមិនទាន់ផ្សព្វផ្សាយ) និងត្រូវបានរកឃើញនៅព្រៃឡង់ក្នុងពេលស្រាវជ្រាវបច្ចុប្បន្ននេះ គឺអាចជារបកគំហើញថ្មីផ្នែកវិទ្យាសាស្ត្រ។ ការវិភាគហ្សែនរបស់សត្វថ្លែនមួយប្រភេទនេះកំពុងតែដំណើរការពិនិត្យ។

កន្ធាយក្បាលកង្កែប (Pelochelys cantorii) គឺជាឧរង្គសត្វម្យ៉ាង ដែលមានទំហំធំ និងរស់នៅក្នុងទឹកជ្រៅ ត្រូវបានបញ្ជាក់ថាមានតែនៅក្នុងទន្លេមេគង្គតែប៉ុណ្ណោះ (Benzuijen et al. 2007; Stuart & Platt, 2004)។ ម្យ៉ាងទៀត ទោះបីវាអាចមានលទ្ធភាពទន្ទ្រានចូលទៅក្នុងតំបន់ក្បែរៗព្រៃឡង់ក៏ដោយក៏ប្រហែលជាគ្មានបឹងបួណាធំ និងមានជម្រៅសមល្មមសម្រាប់ការរស់នៅរបស់ប្រភេទសត្វកន្ធាយនេះនៅក្នុងព្រៃឡង់ដែរ (Olsson & Emmett 2007)។ ដូច្នេះហើយបានជាគេមិនរាប់បញ្ចូលសត្វប្រភេទនេះក្នុងកំណត់ត្រាបច្ចុប្បន្នឡើយ។ ក្រពើភ្នំត្រូវបានអ្នកភូមិជ្វង់បានរៀបរាប់ថាមានរស់នៅក្នុងជម្រកទឹកទន្លេជ្រៅជិតតំបន់ស្រទាប់ថ្មKarst។ បើយោងតាមការរៀបរាប់របស់មគ្គុទេសក៍ដើរព្រៃមូលដ្ឋាន ដែលរួមមាន លោកសុខ លោកស៊ិន និងលោកព្រំ កាលពីឆ្នាំ២០០៣ ពួកគាត់ជឿថាពិតជាធ្លាប់មានសត្វក្រពើរស់នៅក្នុងតំបន់ព្រៃឡង់។

យោងតាមការរៀបរាប់ដដែលនេះបានឲ្យដឹងថា ពង់បារាំង គ្រង់ចំណុចទីតាំងសកល (UTM 0558785, 144958) ស្ថិតក្នុងឃុំមានរិទ្ធិ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ គឺទីតាំងដ៏មានសក្កានុពល ល្អបំផុតសម្រាប់សត្វក្រពើភ្នំរស់នៅ។ ក្នុងបទសម្ភាសន៍មួយកាលពីពេលថ្មីៗនេះដោយលោកឈិន សុភាជាមួយមគ្គុទេសក៍ព្រៃឈើមានបទពិសោធន៍ម្នាក់នៅមូលដ្ឋានឈ្មោះលោកស៊ី រស់នៅភូមិជ្វង់ ស្រុកស្អាង បានអះអាងថាមានក្រពើនៅក្នុងទន្លេ (អូរធំ)ដែលមានចម្ងាយប្រហែល៥គីឡូម៉ែត្រ នៅភាគខាងជើងភូមិភ្នំធំ។ គាត់បានអះអាងថាកាលពី១០ឆ្នាំមុន គាត់តែម្នាក់ឯងធ្លាប់ចាប់បានក្រពើជាង២០០ក្បាល។ គាត់បានបញ្ជាក់ថែមទៀតថាបើបូករួមជាមួយពួកអ្នកចាប់បានផ្សេងៗទៀត មានចំនួនសរុបប្រហែលជា២០០០ក្បាល ដែលត្រូវបានគេលក់ទៅឱ្យពួកឈ្មួញកណ្ដាល។ កាលពីដើមរដូវប្រាំងឆ្នាំ

២០១៣ គាត់បានប្រទះឃើញសត្វក្រពើពីរក្បាល នៅខណៈពេលទៅមើលមងដាក់ត្រីរបស់គាត់នៅទន្លេ។ ដោយសារតែមិនបានឃើញផ្ទាល់ភ្នែក ឬគ្មានកំណត់ត្រាណាមួយ សូម្បីតែលាមករបស់វាក្រោយពីសិក្សាស្រាវជ្រាវរួចមក ទើបនៅក្នុងរបាយការណ៍នេះ គេមិនបានដាក់បញ្ចូលប្រភេទសត្វក្រពើភ្នំនេះនៅក្នុងតារាងឈ្មោះឧរង្គសត្វទេ។ ប៉ុន្តែយ៉ាងណាក៏ដោយ គេគួរតែព្យាយាមស្រាវជ្រាវបន្ថែមទៀតនៅតាមតំបន់ទាំងនោះនៅក្នុងរដូវប្រាំង ដើម្បីបញ្ជាក់ឲ្យបានច្បាស់ថាតើមានវត្តមានក្រពើភ្នំ ឬគ្មាន។

## *ប្រភេទសត្វបង្គោល*

ក្នុងចំណោមថលជលិកទាំង២២ប្រភេទ មានសត្វកង្កែបមួយប្រភេទត្រូវបានចុះក្នុងបញ្ជីរបស់អង្គការ IUCN កាលពីឆ្នាំ២០១៤ ថាពុំទាន់មានទិន្នន័យគ្រប់គ្រាន់ រីឯពីរប្រភេទទៀតត្រូវបានចុះបញ្ជីក្រហមថាជាប្រភេទឈានទៅរងការគម្រាមកំហែង និង១៨ប្រភេទទៀតថាជាប្រភេទរងការគម្រាមកំហែងតិចតួច។ ក្នុងចំណោមឧរង្គសត្វសរុបទាំងអស់ចំនួន៤៧ប្រភេទ អណ្តើកលើគោកមួយក្បាលត្រូវបានចុះក្នុងបញ្ជីថាជាប្រភេទជិតផុតពូជ ៦ប្រភេទជាប្រភេទងាយរងគ្រោះ ១៣ប្រភេទជាប្រភេទរងការព្រួយបារម្ភតិចតួច ហើយប្រភេទចំនួន២៦ទៀតជាប្រភេទដែលមិនទាន់បានវាយតម្លៃនៅឡើយ។ របាយលម្អិត និងស្ថានភាពនៃប្រភេទទាំងនេះ ដែលបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទរងការគម្រាមកំហែងមានបង្ហាញនៅក្នុងតារាងទី៨ ខាងក្រោម។

តារាង 8 សេចក្តីសង្ខេបនៃប្រភេទថលជលិក-ឧរង្គសត្វនៅព្រៃឡង់ដែលត្រូវបានចុះបញ្ជីដោយ IUCN

| បញ្ជីក្រហមស្តីពីចំណាត់ថ្នាក់រងការគម្រាមកំហែងរបស់ IUCN | ថលជលិក | ឧរង្គសត្វ | សរុប |
|---|---|---|---|
| ជិតផុតពូជ (EN) | ០ | ១ | ១ |
| ងាយរងគ្រោះ (VU) | ០ | ៦ | ៧ |
| មិនទាន់មានទិន្នន័យគ្រប់គ្រាន់ (DD) | ១ | ០ | ១ |
| ឈានទៅរងការគម្រាមកំហែង (NT) | ២ | ០ | ២ |
| រងការព្រួយបារម្ភតិចតួច (LC) | ១៩ | ១២ | ៣១ |
| មិនទាន់បានវាយតម្លៃ (NE) | | ២៦ | ២៦ |
| **សរុប** | **២២** | **៤៥** | **៦៧** |

➢ថលជលិក

**កង្កែបអាណ្ណាមក្បាលធំ (Limnonectes dabanus) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់ IUCN ថាជាប្រភេទសត្វស្ថិតក្នុងកង្វះទិន្នន័យ (Smith, 1922)**

ប្រភេទកង្កែបនេះត្រូវបានកត់ត្រាពីមុនរួចហើយ នៅភាគខាងកើតនៃប្រទេសកម្ពុជា (Neang & Holden, 2008; Stuart et al., 2006) និងនៅប្រទេសវៀតណាម (Nguyen et al., 2009)។ កំណត់ត្រានៃប្រភេទសត្វនេះនៅព្រៃឡង់ គ្រប់ដណ្តប់លើវិសាលភាពនៅត្រឹមភាគខាងលិចតំបន់ទំនាប ត្រង់ចំនុច ១០១ម៉ែត្រលើកម្រិតកម្ពស់ទឹកសមុទ្រ។ នេះអាចនិយាយបានថារយៈកម្ពស់ទាបជាងគេបំផុតដែលធ្លាប់បានកត់ត្រាទាក់ទងនឹងកង្កែបប្រភេទនេះ Stuart et al., (2006) ដែលបានរៀបរាប់ថាមានកម្ពស់លើស៤៥០ម៉ែត្រ លើកម្រិតកម្ពស់ទឹកសមុទ្រ។ ចំនួនសត្វកង្កែបប្រភេទនេះនៅក្នុងព្រៃឡង់ ហាក់ដូចជាទាបនៅឡើយ ដោយសារតែគេបានប្រទះឃើញសត្វនេះតែពីរបីក្បាលតែប៉ុណ្ណោះក្នុងពេលស្រាវជ្រាវ។ ដោយសារតែរបាយរបស់វាមានតែមួយកន្លែង ទើបអង្គការ IUCN បានចុះក្នុងបញ្ជីថាមិនទាន់មានទិន្នន័យគ្រប់គ្រាន់។

**កង្កែបព្រៃម័រថេនសេន (Hylarana mortenseni) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់ IUCN ថាជាប្រភេទឈានទៅរងការគម្រាមកំហែង (Boulenger, 1903)**

កង្កែបប្រភេទនេះ ត្រូវបានកត់ត្រាពីមុននៅក្នុងតំបន់ជួរភ្នំក្រវាញនៃប្រទេសកម្ពុជា (Ohler et al., 2000; Stuart & Emmett, 2006; Neang et al., 2010) និងនៅភាគអាគ្នេយ៍នៃប្រទេសថៃ (Chanard, 2003)។ កំណត់ត្រានៃប្រភេទសត្វនេះនៅព្រៃឡង់បានពង្រីកវិសាលភាពគ្របដណ្តប់របស់វាទៅទិសខាងកើត ប្រហែលជាមានរយៈកម្ពស់ទាបបំផុត១០១ម៉ែត្រលើកម្រិតកម្ពស់ទឹកសមុទ្រ។ ដោយសារតែរបាយរបស់វាមានតែមួយកន្លែង ហើយជម្រករបស់ត្រូវរងការខូចខាតផងនោះ ទើបប្រភេទសត្វនេះត្រូវបានគេចុះក្នុងបញ្ជីថាជាប្រភេទជិតឈានទៅរងការគម្រាមកំហែង។ កង្កែបដែលមានទំហំមធ្យមមួយនេះត្រូវបានគេរាយការណ៍ថា រងការបរបាញ់សម្រាប់ធ្វើជាអាហារនៅតាមមូលដ្ឋានទាំងអស់ដែលមានវត្តមានរបស់វា នៅក្នុងប្រទេសកម្ពុជា។

**កញ្ចាញ់ចេករន្ធឈើមានអុច (Theloderma stellatum) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់ IUCN ថាជាប្រភេទឈានទៅរងការគម្រាមកំហែង (Taylor, 1962)**

កញ្ចាញ់ចេកប្រភេទនេះត្រូវបានកត់ត្រាពីមុនទាំងនៅក្នុងតំបន់ជួរភ្នំក្រវាញ និងភាគឦសាននៃប្រទេសកម្ពុជា (Neang & Holden 2008) និងនៅប្រទេសវៀតណាម (Nguyen et al. 2009)។ ការរកឃើញនៃប្រភេទសត្វនេះ នៅព្រៃឡង់ បានជួយបំពេញគម្លាតនៃជីវភូមិសាស្ត្រនៅភាគ កណ្តាលនៃប្រទេសកម្ពុជា ដោយបានបង្ហាញថាប្រភេទសត្វនេះមានវត្តមាននៅទូទាំងប្រទេស តែម្តង។ សត្វប្រភេទនេះ មិនត្រូវបានរងផលប៉ះពាល់ពីការបរបាញ់នោះទេ ប៉ុន្តែត្រូវប៉ះពាល់ដោយសារការកាប់ដើមឈើធំៗដែលមានរន្ធ ជាពិសេសដើមឈើទាលគ្រើះ (Dipterocarpus costatus), ដើមឈើទាលទឹក (D.

alatus), និងដើមឫស្សី។ ដោយសារបោយរបស់សត្វប្រភេទ នេះមានតែមួយកន្លែង ហើយជម្រករបស់វាត្រូវរងការខូចខាតផងនោះ ទើបអង្គការ IUCN បានចុះក្នុងបញ្ជីក្រហមរបស់ខ្លួនថា ជាប្រភេទឈានទៅរងការគម្រាមកំហែង។

➢ **ឧរង្គសត្វ**

**អណ្តើកបិតមុខស្នូកខ្មៅ (Cuora amboinensis) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់ IUCN ថាជាប្រភេទងាយរងគ្រោះ (Daudin, 1802)**

អណ្តើកប្រភេទនេះត្រូវបានស្គាល់ច្រើននៅទូទាំងអាស៊ីអាគ្នេយ៍ (Cox et al., 1999; Das, 2010)។វាត្រូវបានកត់ត្រារួចហើយកាលពីមុននៅក្នុងតំបន់ភាគច្រើនបំផុតនៅទិសបស្ចឹមនៃប្រទេសកម្ពុជា (Daltry & Chheang, 2000; Hartmann et al., 2013; Olsson & Emmett, 2007; Stuart & Platt, 2004) ហើយទំនងជាមានវត្តមានរស់នៅជាធម្មតា។ ប៉ុន្តែ នៅក្នុងព្រៃឡង់សត្វនេះ ហាក់ដូចជាកាន់តែកម្រមាន ដោយសារអណ្តើកនេះត្រូវគេប្រមូលផលច្រើនលើសលុបគ្រប់ទីកន្លែងសម្រាប់យកទៅធ្វើជាអាហារនិងលក់ដូរ។ ដោយសារតែការទាញផលច្រើនហួសប្រមាណ និងការខូចរេចរឹលនៃជម្រកផងនោះ ទើបសត្វប្រភេទនេះត្រូវបានចុះក្នុងបញ្ជីថា ជាប្រភេទងាយរងគ្រោះ។

**អណ្តើកសោមញី (Heosemys grandis) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់ IUCN ថាជាប្រភេទងាយរងគ្រោះ (Gray, 1860)**

អណ្តើកប្រភេទនេះ ត្រូវបានកត់ត្រានៅក្នុងប្រទេសភាគច្រើននៅអាស៊ីអាគ្នេយ៍ (Das 2010; Stuart et al., 2001)។ គេបានរាយការណ៍ថា សត្វប្រភេទនេះមាននៅច្រើនកន្លែងណាស់ក្នុងប្រទេសកម្ពុជា (Hartmann et al., 2013)។ ការរកឃើញអណ្តើកប្រភេទនេះក្នុងតំបន់ព្រៃឡង់ បានជួយបំពេញគម្លាតនៃជីវភូមិសាស្រ្ត រវាងភាគខាងកើតនិងខាងលិចនៃប្រទេសកម្ពុជា ដោយបានបង្ហាញថា ប្រភេទសត្វនេះមានវត្តមាននៅទូទាំងប្រទេសតែម្តង។ មិនខុសពីប្រភេទសត្វអណ្តើកផ្សេងៗទៀតទេ ប្រភេទអណ្តើកមួយនេះត្រូវបានគេប្រមូលផលយកនៅគ្រប់ទីកន្លែង ទើបអង្គការ IUCN បានចុះក្នុងបញ្ជីរបស់ខ្លួនថា ជាប្រភេទងាយរងគ្រោះ។

**អណ្តើកក្អែកខ្មៅ (Siebenrockiella crassicollis) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់ IUCN ថាជាប្រភេទងាយរងគ្រោះ (Gray, 1830)**

អណ្តើកប្រភេទនេះ ត្រូវបានកត់ត្រានៅក្នុងប្រទេសកម្ពុជា វៀតណាម ថៃ ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី (Das, 2010; Stuart et al. 2001)។ ដោយឡែកនៅប្រទេសកម្ពុជា សត្វប្រភេទនេះត្រូវបានកត់ត្រាពីមុននៅក្នុងតំបន់ជួរភ្នំក្រវាញ និងខេត្តកំពង់ធំ (Stuart & Platt, 2004; Som et al., 2005) និងនៅឧទ្យានជាតិគូលែនព្រហ្មទេព ស្ថិតនៅក្នុងខេត្តសៀមរាប(Hartmann et al., 2013)។ កំណត់ត្រានៃ

ប្រភេទសត្វនេះនៅព្រៃឡង់ បានពង្រីកវិសាលភាពគ្របដណ្តប់របស់វាទៅតំបន់ទំនាប ភាគកណ្តាលនៃប្រទេសកម្ពុជា។ អណ្តើកមិនទាន់ពេញវ័យចំនួនពីរក្បាល ត្រូវបានគេប្រទះ ឃើញក្នុងអំឡុងពេលនៃការអង្កេតស្រាវជ្រាវនេះ ដែលបង្ហាញថាចំនួនអណ្តើកពេញវ័យមាននៅរស់សំរាប់ការបន្តពូជ ប៉ុន្តែប្រហែលជាមានចំនួនថយចុះដោយសារ ការប្រមាញ់ (Olsson & Emmett, 2007)។ ដោយសារតែប្រភេទអណ្តើកមួយនេះត្រូវបានគេធ្វើអាជីវកម្មហួសកំរិត ហើយជម្រករបស់វាត្រូវរងការខូចខាតផងនោះ ទើបអង្គការ IUCN បានចុះក្នុងបញ្ជីថាជាប្រភេទងាយរងគ្រោះ។



រូបភាព 25 អណ្តើកក្អែកខ្មៅ (Siebenrockiella crassicolis) ប្រភេទងាយរងគ្រោះក្នុងតំបន់ព្រៃឡង់

**កន្ធាយអាស៊ី (Amyda cartilaginea) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់ IUCN ថាជាប្រភេទ ងាយរងគ្រោះ (Boddaert, 1770)**

កន្ធាយប្រភេទនេះមានរស់នៅក្នុងប្រទេសភាគច្រើននៃតំបន់អាស៊ីអាគ្នេយ៍ (Das 2010; Stuart et al., 2001)។ ដោយឡែកសត្វប្រភេទនេះ ត្រូវបានគេប្រទះឃើញគ្រប់ទីកន្លែងនៃប្រទេសកម្ពុជា (Hartmann et al., 2013) ប៉ុន្តែចំនួនសត្វនេះបានធ្លាក់ចុះនៅគ្រប់ទីកន្លែង ដោយសារតែការប្រមាញ់ច្រើនហួសប្រមាណ។ ដោយសារតែតម្រូវការខ្ពស់សម្រាប់ការយកទៅធ្វើជាអាហារ និងជួញដូរផងនោះ ទើបអង្គការ IUCN បានចុះក្នុងបញ្ជីថាជាប្រភេទងាយរងគ្រោះ។

**អណ្តើកព្រិច (Indotestudo elongate) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់ IUCN ថាជាប្រភេទជិតផុតពូជ (Blyth, 1853)**

ប្រភេទអណ្តើករស់នៅលើដីគោកនេះត្រូវបានគេកត់ត្រានៅក្នុងបណ្តាប្រទេសភាគច្រើន នៅតំបន់អាស៊ីអាគ្នេយ៍ (Das, 2010; Stuart et al., 2001)។ វាត្រូវបានគេរាយការណ៍ថាមានវត្តមាន រស់នៅទូទាំងប្រទេសកម្ពុជា (Bezuijen et al., 2009; Emmett & Olsson, 2005; Hartmann et al., 2013; Stuart and Platt, 2004)។ វត្តមានរបស់អណ្តើកប្រភេទនេះ បានជួយបំពេញគម្លាតនៃ ជីវភូមិសាស្ត្ររវាងតំបន់ជួរភ្នំក្រវាញនិងតំបន់ទំនាបភាគខាងកើត។ ដោយសារតែធម្មជាតិរបស់វា ជាសត្វរស់នៅលើដីគោក របាយរបស់វាត្រូវទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរនៅគ្រប់ទីកន្លែង ដោយសារមូលហេតុនៃការកាប់ព្រៃឈើ និងជាពិសេសដោយសារការប្រមាញ់របស់ព្រានព្រៃ និងសត្វឆ្កែ។ សត្វអណ្តើកនេះត្រូវបានអង្គការ IUCN ចុះក្នុងបញ្ជីថាជាប្រភេទសត្វជិតផុតពូជ ដើម្បីបង្ហាញឲ្យឃើញពីសារៈសំខាន់ក្នុងការអភិរក្សសត្វប្រភេទនេះ។

**ពស់វែកជំបូក (Naja siamensis) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់ IUCN ថាជាប្រភេទងាយរងគ្រោះ (Laurenti, 1768)**

ពស់ប្រភេទនេះបានត្រូវកត់ត្រាពីមុនមកថាមាននៅក្នុងតំបន់ឥណ្ឌូភូមា (Cox et al., 1999; Das, 2010)។ ពស់វែកព្រួសពិសនេះត្រូវបានកត់ត្រាថាមានវត្តមាននៅទូទាំងប្រទេសកម្ពុជា (Grismer et al., 2008; Wüster & Thorpe, 1994)។ ប្រភេទសត្វពអាសិរពិសមួយនេះ ត្រូវទទួលរងផលប៉ះពាល់យ៉ាងខ្លាំង ដោយសារការប្រមាញ់យកទៅធ្វើជាឱសថបុរាណ សម្រាប់ធ្វើជាអាហារ និងសម្រាប់ជួញដូរផងដែរ ដូច្នេះហើយទើបអង្គការ IUCN បានចុះក្នុងបញ្ជីថាជាប្រភេទងាយរងគ្រោះ។

**ពស់វែករនាម (Ophiophagus Hannah) ត្រូវបានចុះក្នុងបញ្ជីក្រហមរបស់ IUCN ថាជាប្រភេទងាយរងគ្រោះ (Cantor, 1836)**

ពស់នេះគឺជាប្រភេទពស់ដែលមានទំហំធំជាងគេ ប្រវែងវែងជាងគេ និងមានពិសសាហាវជាងគេបំផុតក្នុងចំណោមពស់នៅលើពិភពលោក។ វាត្រូវបានគេរាយការណ៍ថាមានវត្តមាននៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ (លើកលែងតែប្រទេសហ្វីលីពីន) មាននៅប្រទេសនេប៉ាល់ និងឥណ្ឌាផងដែរ (Cox et al., 1999; Das, 2010)។ ពស់ប្រភេទនេះ ត្រូវបានកត់ត្រានៅទូទាំងប្រទេសកម្ពុជា (Daltry & Chheang, 2000; Saint Girons, 1972; Stuart et al., 2006)។ ដោយសារតែការប្រមូលយកផល ច្រើនហួសប្រមាណសម្រាប់ធ្វើឱសថបុរាណ សម្រាប់ធ្វើជាអាហារក្នុងស្រុក និងសម្រាប់ជួញដូរ ផងនោះទើបអង្គការ IUCN បានចុះក្នុងបញ្ជីថាជាប្រភេទងាយរងគ្រោះ។ កាលពីខែកក្កដា ឆ្នាំ២០១៤ អ្នកចុះស្រាវជ្រាវបានឃើញជនជាតិដើមភាគតិចរស់នៅស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង អាចលក់ពស់វែករនាមបានតម្លៃ៤០ដុល្លារអាមេរិកក្នុងមួយគីឡូក្រាម។

## ការពិភាក្សា

លទ្ធផលនៃការស្រាវជ្រាវនេះបង្ហាញថា តំបន់ព្រៃឡង់ជួយទ្រទ្រង់ដល់សត្វច្រើនប្រភេទណាស់ ដែលរងការគម្រាមកំហែងនៅក្នុងតំបន់ និងនៅលើសកលលោក ក្នុងអត្រាមួយយ៉ាងខ្ពស់ដោយយ៉ាងហោចណាស់ ១០ប្រភេទនៃថលជលិក-ឧរង្គសត្វ (ឬស្មើនឹង១៥%) ដែលត្រូវបានអង្គការ IUCN ចុះក្នុងបញ្ជីចំណាត់ថ្នាក់នៃប្រភេទរងការគម្រាមកំហែង។ ទោះបីជានៅមានសត្វចំនួន២៦ប្រភេទមិនទាន់វាយតម្លៃនៅឡើយក្តី ក៏ការរកឃើញថ្មីៗនាពេលបច្ចុប្បន្ន និងការបង្ហាញពីរបាយនៃសត្វទាំងនេះនាពេលនេះ អាចនឹងផ្តល់ជាប្រយោជន៍សម្រាប់ការវាយតម្លៃរបស់អង្គការ IUCN ទៅថ្ងៃអនាគត។

## កត្តាគម្រាមកំហែង

នានាភាពខ្ពស់ និងសមាមាត្រខ្ពស់គួរសមនៃប្រភេទថលជលិក-ឧរង្គសត្វ ដែលរងការគម្រាមកំហែងជាសកលនៅក្នុងតំបន់ព្រៃឡង់ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ដោយសារវាជាសូចនាករនៃបរិស្ថានល្អ (Hartwell et al. 1998)។ បច្ចុប្បន្ននេះ ថលជលិក-ឧរង្គសត្វដែលមាននៅព្រៃឡង់ហាក់ដូចជាកំពុងរងការគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរ ដោយសារសកម្មភាពគ្មាននិរន្តរភាពជាច្រើន។ គេបានសង្កេតឃើញមានការគម្រាមកំហែងជាច្រើនដែលរួមមាន ការប្រែក្លាយដីព្រៃទៅជាការសាងសង់លំនៅដ្ឋាន ទៅជាការប្រកបរបរកសិកម្ម និងការអភិវឌ្ឍ ក៏ដូចជាបែកខ្ញែកនៃទីជម្រក ដោយការ សាងសង់ហេដ្ឋារចនាសម្ព័ន្ធ។ ការកាប់ព្រៃឈើដោយសម្រិតសម្រាំងទាំងនៅអតីតកាល និងបច្ចុប្បន្ន បានធ្វើឲ្យផ្លាស់ប្តូរដល់សមាសភាព និងរចនាសម្ព័ន្ធព្រៃឈើ ដែលនាំទៅដល់ការផ្លាស់ប្តូរអាកាសធាតុ នៅទីនោះ និងកំណើនកំណកំទេចនៅក្នុងប្រព័ន្ធធារាសាស្ត្រ ដែលអាចធ្វើឲ្យរបបទឹករីតតែរាក់ទៅៗ ក៏ដូចជាបង្កឲ្យទៅជាលក្ខខណ្ឌមិនអំណោយផលសម្រាប់ការចិញ្ចឹមជីវិត និងការជ្រកអាស្រ័យនៃ ប្រភេទសត្វទាំងឡាយដែលពឹងអាស្រ័យជាចាំបាច់ទៅលើប្រភពទឹក។

ក្រៅពីអ្នកបរបាញ់អាជីព អ្នកកាប់ឈើនៅជុំវិញតំបន់អភិវឌ្ឍន៍តែងតែព្យាយាមបរបាញ់សត្វព្រៃគ្រប់ប្រភេទ ដើម្បីបំពេញបន្ថែមតម្រូវការម្ហូបអាហាររបស់ពួកគេថែមទៀតផង។ នៅក្នុងអំឡុងពេលនៃការអង្កេតស្រាវជ្រាវនេះ គេបានសង្កេតឃើញមានព្រានព្រៃជាច្រើនក្រុមប្រដាប់ទៅដោយអន្ទាក់សត្វជាច្រើនប្រភេទ ដែលអាចសបញ្ជាក់ឲ្យឃើញថា ប្រាក់ចំណូលសម្រាប់ការចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់សមាជិកសហគមន៍ជាច្រើនដែលរស់នៅជុំវិញព្រៃឡង់ គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើមុខរបរបរបាញ់សត្វ។ ថលជលិកនិងឧរង្គសត្វធំៗត្រូវបានគេបរបាញ់សម្រាប់យកទៅធ្វើជាម្ហូបអាហារ ដូចជាកង្កែបព្រៃម័រថេនសេន (mortenseni Hylarana), កង្កែបក្ងូប (Hoblobatrachus rugulosus) និងហ៊ីងក្របី (Kaloula

pulchra) ចំណែកឧរង្គសត្វនានា ត្រូវបានបរបាញ់យកសាច់សម្រាប់ធ្វើជាអាហារផង និងជួញដូរផង។ សត្វត្រកួត (Varanus bengalensis) ត្រូវបានគេឃើញព្យួរលក់នៅតាមតូបនានានៅក្នុងភូមិបឹង ស្ថិតនៅក្នុងតំបន់ព្រៃឡង់។ សត្វកន្ទ្រងជាច្រើនក្បាល (Physignathus cocincinus) ត្រូវបានគេឃើញព្រានព្រៃកាន់យួររណោងនៅក្នុងតំបន់ដែលគេបានចុះស្រាវជ្រាវក្នុងអំឡុងខែសីហា ឆ្នាំ២០១៤។



រូបភាព 26 សត្វកន្ទ្រង **Physignathus cocincinus** នៅក្នុងព្រៃឡង់

ប្រភេទសត្វពស់ថ្លាន់ធំ (Reticulate Python) និងសត្វអណ្តើកគ្រប់ប្រភេទត្រូវបានប្រមាញ់យកទៅធ្វើជាអាហារនិងលក់ដូរ នេះបើយោងតាមការឲ្យដឹងពីប្រជាពលរដ្ឋ (តាមរយៈការសាកសួរព័ត៌មានពីសមាជិកសហគមន៍រស់នៅសៀមបូក ស្រែព្រីង និងថ្នាំង)។ ឈ្មួញដែលជាអ្នកទិញសត្វអណ្តើកចំនួនពីរនាក់ ម្នាក់រស់នៅក្នុងស្រុកសណ្តាន់ និងម្នាក់ទៀតរស់នៅភូមិអូរលាំង ក្នុងស្រុកសៀមបូក ត្រូវបានគេរាយការណ៍ថា ជាអ្នកទទួលទិញសត្វអណ្តើកព្រៃទាំងអស់ដែលចាប់បានពីព្រៃឡង់ និងពីតំបន់ក្បែរៗនោះ (ibid)។



រូបភាព 27 សត្វស្កាធំ (Herpestes urva) ជាប់អន្ទាក់ទាក់អណ្តើក នៅក្នុងព្រៃឡង់




រូបភាព 28 ត្វអណ្តើកដែលត្រូវអ្នកលួចប្រមាញសត្វចាប់បាន នៅក្នុងព្រៃឡង់

ជារួម ការថយចុះនៃទីជម្រកសំខាន់ៗដោយសារការប្រែក្លាយដីព្រៃទៅជាកាប់យកឈើ និងសម្រាប់ប្រកបរបរកសិកម្ម គួបផ្សំនិងការបរបាញ់សត្វព្រៃសម្រាប់ធ្វើជាអាហារនិងជួញដូរទាំងនេះហើយដែលបានធ្វើឲ្យចំនួនរបាយនៃប្រភេទថលជលិក-ឧរង្គសត្វខ្លះថយចុះ។

## *ការផ្តល់ជាអនុសាសន៍*

- ➢គួរជំណើរការការអនុវត្តច្បាប់ ដើម្បីទប់ស្កាត់ការកាប់ឈើខុសច្បាប់ និងការប្រែក្លាយដីព្រៃទៅជាការសាងសង់លំនៅដ្ឋាន និងការប្រកបរបរកសិកម្ម។ សកម្មភាពដែលគ្មាននិរន្តរភាពទាំងនេះនឹងធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ថលជលិក-ឧរង្គសត្វ ក្នុងរយៈពេលវែង។

- ➢គួរទប់ស្កាត់កុំឲ្យអ្នកចំណូលថ្មី ធ្វើចំណាកស្រុកមករស់នៅក្នុងតំបន់ព្រៃឡង់ ពីព្រោះនិន្នាការនេះមិនត្រឹមតែអាចឈានទៅដល់ការកែប្រែដីព្រៃទៅជាការសាងសង់លំនៅដ្ឋាន និងការប្រកបរបរកសិកម្ម ប៉ុន្តែថែមទាំងឈានទៅដល់ការបរបាញ់សត្វព្រៃផងដែរ។

- ➢ត្រូវធានាការការពារភ្នំជី ដែលជាទីកន្លែងគ្របដណ្តប់ដោយផ្ទាំងសិលាធំៗ និងបិតបាំងទៅដោយព្រៃស្រោង ដែលជាទីជម្រកយ៉ាងសំខាន់សម្រាប់ពពួកឧរង្គសត្វជាច្រើន។ ភ្នំជីគឺជាភ្នំមួយដែលហ៊ុំព័ទ្ធទៅដោយព្រៃរបោះស្ងួត ដូច្នេះហើយបានជាវាមានសារៈប្រយោជន៍ខ្លាំងណាស់សម្រាប់ពពួកសត្វដទៃទៀតក្នុងការស្វែងរកទីជម្រក នៅពេលមានភ្លើងឆេះព្រៃនារដូវប្រាំង។

- ➢គួរថែរក្សាឲ្យបាននូវតំបន់ដីសើម ខ្សែទឹកសំខាន់ៗ និងទន្លេធំៗទុកសម្រាប់ប្រភេទសត្វទាំងឡាយដែលរស់អាស្រ័យលើទឹកទាំងនោះ រួមមានសត្វពស់ត្រី (Enhydris longicauda) ដែលមានតែនៅក្នុងបឹងទន្លេសាប សត្វអណ្តើកគ្រប់ប្រភេទទាំងអស់ និងប្រភេទកង្កែបអាណ្ណាមក្បាលធំ (Limnonectes dabanus)។

- ➢គួរកំណត់ឲ្យបានច្បាស់លាស់ពីតម្រូវការរបស់សហគមន៍មូលដ្ឋាន ហើយផ្តល់ការគាំទ្រលើការធ្វើឲ្យប្រសើរឡើងក្នុងវិស័យកសិកម្ម ដើម្បីកាត់បន្ថយការពឹងអាស្រ័យទៅលើធនធានព្រៃឈើ និងសត្វព្រៃដែលមាននៅក្នុងតំបន់នេះ។

➢គួរផ្តល់ការអប់រំ និងការផ្សព្វផ្សាយការយល់ដឹងទៅដល់ប្រជាពលរដ្ឋ ដើម្បីឲ្យពួកគាត់យល់ជ្រួតជ្រាបអំពីគុណប្រយោជន៍នៃសត្វព្រៃ និងច្បាប់ពាក់ព័ន្ធនានា ដើម្បីទ្រទ្រង់អេកូឡូស៊ីរបស់ព្រៃឡង់ឲ្យមាននិរន្តរភាព។

➢គួរអនុវត្តការចុះសិក្សាស្រាវជ្រាវដល់ទីកន្លែងទៅលើថលជលិក-ឧរង្គសត្វបន្ថែមទៀត ដើម្បីទទួលបានសារពើភ័ណ្ឌប្រភេទសត្វពេញលេញជាងនេះ។

➢ គួរអង្កេតស្រាវជ្រាវឡើងវិញ ទៅលើសត្វក្រពើភ្នំ នៅរដូវប្រាំង ដើម្បីបញ្ជាក់ឲ្យបានច្បាស់ពីស្ថានភាពពិតប្រាកដរបស់សត្វក្រពើនេះនៅតំបន់ព្រៃឡង់។ ប្រសិនបើ សត្វក្រពើនេះនៅមាននៅឡើយ គួរតែអភិរក្សតំបន់នេះឱ្យបានល្អដើម្បីធ្វើឲ្យចំនួនវាកើនឡើងវិញ ដោយប្រើប្រាស់សត្វក្រពើនេះជាចំនួនសូ្វរក្នុងកិច្ចការពារព្រៃឡង់។

➢គួរកំណត់ឲ្យឃើញច្បាស់ និងបញ្ឈប់ឲ្យបាននូវសកម្មភាពចាប់សត្វអណ្តើក និងការលួចបរបាញ់ថលជលិក-ឧរង្គសត្វ ដែលកំពុងរងការគម្រាមកំហែង ក៏ដូចជាការជួញដូរសត្វព្រៃនៅជុំវិញតំបន់ព្រៃឡង់។

# ៧. សេចក្តីសង្ខេប

## *សារៈសំខាន់នៅក្នុងតំបន់និងលើសកលលោក*

តំបន់ទេសភាពព្រៃឡង់ គឺតំបន់គ្របដណ្តប់ដោយតំបន់ព្រៃឈើដ៏ធំបំផុតរបស់ប្រទេសកម្ពុជា ដែលមិនស្ថិតនៅក្រោមការការពារជាផ្លូវការរបស់រដ្ឋាភិបាលនៅឡើយ។ តំបន់នេះស្ថិតក្នុងចំណាត់ថ្នាក់ថាជាតំបន់មួយដ៏មានសក្តានុពល ក្នុងចំណោមតំបន់ជាច្រើនទៀតនៃទំនាបព្រៃស្រោង ក្នុងតំបន់ឥណ្ឌូភូមា ដែលជាតំបន់ជីវៈចម្រុះសំខាន់ជាងគេមួយក្នុងចំណោមតំបន់សំខាន់ជាងគេបំផុតទាំង១០ នៅលើពិភពលោក ពោលគឺស្ថិតក្នុងចំណោមតំបន់ដែលមានភាពសម្បូរបែបបំផុតផ្នែកជីវសាស្ត្រ និងរងការគម្រាមកំហែងបំផុតនៅលើភពផែនដីនេះ។ តំបន់ជីវៈចម្រុះសំខាន់ជាងគេនៃតំបន់ឥណ្ឌូភូមារួមមានតំបន់ដែលមិនស្ថិតនៅជាប់មាត់សមុទ្រទាំងអស់នៃប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងប្រទេសវៀតណាម បូករួមទាំងផ្នែកខ្លះៗទៀតនៃភាគខាងត្បូងប្រទេសចិន។

ជាលក្ខណៈជីវសាស្ត្រ ពពួកសត្វទាំងអស់នៅតំបន់ព្រៃឡង់គួរត្រូវបានចាត់ទុកថាជាប្រភេទសត្វចម្រុះ ដែលមានអំណោយផលបំផុត ហើយរហូតមកដល់បច្ចុប្បន្ននេះ សត្វចំនួន៥៥ប្រភេទត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទដែលកំពុងរងការគម្រាមកំហែង។ តំបន់ទេសភាពមួយនេះ អាចជួយទ្រទ្រង់ទាំងនៅក្នុងប្រទេស និងនៅក្នុងតំបន់ដល់ប្រភេទសត្វ សំខាន់ៗជាច្រើនដែលកំពុងរងការគម្រាមកំហែងនៅលើសកលលោក។ លើសពីនេះទៀត តាមរយៈកិច្ចសម្ភាសន៍ និងទិន្នន័យដែលបានពីការអង្កេតស្រាវជ្រាវកាលពីលើកមុន បានបង្ហាញថាប្រសិនបើគេអាចបញ្ជាក់ឲ្យបានច្បាស់លាស់ពីវត្តមាននៃប្រភេទសត្វមួយចំនួននៅក្នុងតំបន់ព្រៃឡង់ នោះគេក៏នឹងអាចធ្វើឲ្យមានការយល់ដឹងបន្ថែមទៀត អំពីសារៈសំខាន់នៃការអភិរក្សតំបន់ទេសភាពនេះផងដែរ។ សត្វមួយចំនួនទាំងនោះមានដូចជាភេរោមច្រមុះ (Lutra sumatrana) ដែលអង្គការ IUCN បានចុះក្នុងបញ្ជីថាជាប្រភេទជិតពុតពូជ។ ក្រពើភ្នំ (Crocodylus siamensis) និង និងត្រយងយក្ស (Thaumatibis gigantea) ដែលអង្គការ IUCNចុះក្នុងបញ្ជីថាជាប្រភេទជិតផុតពូជបំផុត។ ដោយសារតែការអង្កេតស្រាវជ្រាវភាគច្រើនត្រូវបានធ្វើឡើងយ៉ាងឆាប់រហ័យពេក និងដោយសារតំបន់ទាំងនោះមានទំហំធំល្វឹងល្វើយមិនអាចស្រាវជ្រាវអស់នៅឡើយ ទើបគេជឿថានៅមានប្រភេទសត្វជាច្រើនទៀតដែលនឹងត្រូវដាក់បញ្ចូលក្នុងបញ្ជី តាមរយៈការស្រាវជ្រាវបន្ថែមទៀត ក៏ដូចជាការផ្សព្វផ្សាយចំណេះដឹងទូទៅស្តីពីជីវចម្រុះនៅតំបន់ព្រៃឡង់។

ជាលក្ខណៈរុក្ខសាស្ត្រ ភាពស្រស់បំព្រងនៃជម្រកខុសប្លែកគ្នាចំនួន៨ ដែលស្ថិតនៅភាគ កណ្តាលនៃព្រៃស្រោង គឺជាផ្នែកដែលនៅជាប់ៗគ្នាធំជាងគេបំផុត។ តំបន់នេះក៏មានរួមមានទាំង ព្រៃស្រោងជាំទឹកដែលនៅក្នុងរបាយការណ៍បឋម បានបង្ហាញថាមានតែនៅភាគកណ្តាលនៃប្រទេសកម្ពុជាតែ

ប៉ុណ្ណោះ។ ចំណុចនេះផ្អែកលើសារៈសំខាន់និងកេរ្តិ៍ឈ្មោះល្បី សមាសភាពប្រភេទសត្វនិងរុក្ខជាតិ រចនាសម្ព័ន្ធ ភាពសម្បូរបែបលើសលប់របស់ប្រភេទសត្វនិងរុក្ខជាតិ និងបាតុភូតជីវិតនៃសត្វនិងរុក្ខជាតិ (McDonald, 2004)។

តំបន់តូចមួយដែលមានស្រទាប់ថ្ម Karst ជាច្រើននៅជាប់ស្រយាលនាភាគខាងជើងព្រៃឡង់ គឺទីកន្លែងដ៏វិសិដ្ឋមួយ។ ទំរង់ថ្មទាំងនោះច្រើនតែផ្សារភ្ជាប់ជាមួយជីវៈចម្រុះដ៏វិសេសវិសាល ទាំងផ្នែកខាងលើនិងខាងក្រោមដី ដោយមានការប្រមូលផ្តុំនៃប្រភេទផ្សេងគ្នាគួរឱ្យកត់សម្គាល់នៃផ្នែកផ្សេងគ្នារបស់ពិភពលោក (Vermeulen and Whitten 1999)។ លក្ខណៈធម្មជាតិដែលមានតែនៅកន្លែងមួយនេះ និងនានាភាព គឺជាក្រឹត្យក្រមធម្មជាតិដ៏ពិសេសនៃស្រទាប់ថ្ម Karst ដែលនៅជាប់ស្រយាលក្នុងតំបន់ត្រូពិចនេះ (Clements et al.2006)។ តំបន់ទេសភាពផ្ទាំងស្រទាប់ថ្មនេះកម្រមានណាស់ក្នុងប្រទេសកម្ពុជា និងជាពិសេសកំពុងក្លាយជាតំបន់តំណាងឲ្យបណ្តាញនៃតំបន់ព្រៃការពាររបស់ប្រទេសកម្ពុជា។

ព្រៃឡង់ គឺមានសារៈសំខាន់យ៉ាងច្រើនសន្ធឹងសន្ធាប់ដល់ប្រជាសហគមន៍កួយដែលរស់នៅពឹងផ្អែកលើអនុផលព្រៃឈើដែលរកបានពីក្នុងព្រៃ ហើយពេញនិយមជាទីបំផុតចំពោះបុខរបរយកជ័រឈើ (ជ័រទឹកនិងជ័រចុង) សម្រាប់ធ្វើជាមូលដ្ឋានចិញ្ចឹមជីវិតរបស់ខ្លួន។ ដូចដែលបានរៀបរាប់ខាងដើមនៅក្នុងរបាយការណ៍នេះ ព្រៃឡង់គឺជាប្រភពអនុផលព្រៃឈើជាច្រើនដែលកំពុងមានការចាប់អារម្មណ៍ខ្ពស់នៅលើទីផ្សារអន្តរជាតិ និងអាចធានាដល់ការរុករកអនុផលទាំងនោះ ជាជាងការកាប់បំផ្លាញ។

ដោយសារមើលឃើញពីគុណតម្លៃជីវចម្រុះប្លែកៗគ្នានៅតំបន់ព្រៃឡង់ ដែលជាតំបន់ទេសភាពមានប្រភពទឹកសំខាន់ៗ និងមានសក្តានុពលខ្ពស់សម្រាប់គម្រោងសាកល្បងរេដបូក (REDD+) ផងនោះ ទើបគេអាចផ្តល់ហេតុផលត្រឹមត្រូវថាគួរតែតម្រូវឲ្យមានការការពារក្នុងកម្រិតខ្ពស់បំផុត។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលបានរៀបរាប់ពីខាងដើម តំបន់ទេសភាពមួយនេះកំពុងឈានទៅវិនាសអន្តរាយ ហើយអត្រានៃការហិនហោចដែលមិនធ្លាប់មានពីមុនមកនឹងរឹតតែកើនឡើង (សូមមើលត្រង់ចំណុចកត្តាគម្រាមកំហែងដូចខាងក្រោម) ហើយប្រសិនបើគ្មានការចាត់វិធាការឲ្យបានទាន់ពេលវេលាដើម្បីការពារតំបន់នេះទេនោះ គុណតម្លៃនៃជីវៈចម្រុះទាំងប៉ុន្មាននឹងត្រូវវិនាសហិនហោចអស់ជាក់ជាមិនខាន។



រូបភាព 29 អ្នកប្រមូលជ័រឈើ នៅក្នុងព្រៃឡង់

## កន្លាគម្រាមកំហែង

### ➢ការកាប់ឈើ

តាំងពីដើមរៀងមក ព្រៃឡង់ត្រូវបានគេកាប់យកឈើអស់ជាច្រើន ហើយក្រុមហ៊ុនសម្បទានកាប់ឈើចំនួនបីដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនភាភីមិច (Pheapimex Fuchan), ក្រុមហ៊ុនអេវើប្រាយ (Everbright CIG Wood Co. Ltd.,) និងក្រុមហ៊ុន Colexim Forest Concession បានធ្វើសកម្មភាពយ៉ាងសកម្មនៅក្នុងតំបន់នេះ រហូតដល់ឆ្នាំ ២០០២ (Schmidt and Theilade, 2010)។ សព្វថ្ងៃនេះ ការកាប់ឈើកំពុងកើតមានក្នុងអត្រាមួយខ្ពស់បំផុតនេះ បើតាមការសង្កេតឃើញរបស់ក្រុមអ្នកស្រាវជ្រាវ។ បើតាមការឃើញផ្ទាល់ភ្នែកក្នុងអំឡុងអង្កេតស្រាវជ្រាវនេះ ការកាប់ឈើភាគច្រើនកើតមាននៅតំបន់ព្រៃស្រោងភាគកណ្តាល ហើយហាក់ដូចជាមាន ការដឹកជញ្ជូនឈើចេញពីក្នុងព្រៃ ដោយប្រើប្រាស់មធ្យោបាយផ្សេងៗ។ រហូតមកដល់ពេលនេះ សកម្មភាពកាប់និងដឹកជញ្ជូនឈើបានបន្តកើតមានដោយគ្មានការទប់ស្កាត់ទាល់តែសោះ។



រូបភាព 30 ការដឹកជញ្ជូនឈើចេញពីក្នុងព្រៃដោយរទេះគោ នៅតំបន់ព្រៃឡង់

### ➢ការបរបាញ់និងការជួញដូរសត្វព្រៃ

ទន្ទឹមនឹងមានការកាប់ឈើ ក៏ហាក់ដូចជាមានការបរបាញ់សត្វដោយសេរីនៅជុំវិញតំបន់ទេសភាពនេះទៀតផង នេះបើយោងតាមការសង្កេតឃើញផ្ទាល់របស់ក្រុមអ្នកស្រាវជ្រាវ។ ការអង្កេតស្រាវជ្រាវកាលពីលើកមុនបានឲ្យដឹងថា ការបរបាញ់សត្វ និងការជួញដូរសត្វព្រៃ បានប្រព្រឹត្តឡើងជាប្រព័ន្ធមួយ ដោយបានធ្វើការដឹកជញ្ជូនសត្វដែលរកបានទាំងនោះឆ្ពោះទៅខេត្តស្ទឹងត្រែង ក្រចេះ និងកំពង់ធំសម្រាប់លក់យកប្រាក់ (Olssen and Emmett, 2007)។ ការបរបាញ់សត្វប្រចៀវ ក៏កើតមានផងដែរនៅតាមរូងថ្មស្ថិតនៅភាគខាងជើង ដែលការបរបាញ់នេះទំនងជានឹងបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើចំនួនសត្វប្រចៀវនៅទីនោះ។

### ➢ការឈូសឆាយ និងការទន្ទ្រានដីព្រៃយកធ្វើជាកម្មសិទ្ធិ

ដោយសារតែទីតាំងភូមិសាស្ត្ររបស់ព្រៃឡង់មានសណ្ឋានដីរាបស្មើ ទើបមានភាពងាយស្រួលក្នុងការចូលទន្ទ្រានយកពីគ្រប់ច្រកល្ហកទាំងអស់ រាប់ចាប់តាំងពីសកម្មភាពនៃការបរបាញ់សត្វ និងការកាប់ឈើនៅទីនោះ រហូតដល់ការឈូសឆាយដីព្រៃនៅទូទាំងតំបន់ទេសភាពដោយគ្មានការទប់ស្កាត់។ បញ្ហាមួយនេះកើតមានជាទូទៅនៅក្នុងតំបន់ភាគខាងត្បូងនិងភាគខាងជើងនៃព្រៃឡង់។ ការឈូសឆាយដីព្រៃក្នុងទំហំតូច ត្រូវបានគេសង្កេតឃើញកើតមានជាទូទៅនៅក្នុងតំបន់នេះ ក៏ដូចជាការឈូសឆាយដីព្រៃជាច្រើនកន្លែងដែលមានទំហំធំជាងនេះសម្រាប់ធ្វើចម្ការដាំដុះផលដំណាំផ្សេងៗ ឬជាកាប់ផ្តួលរំលំដើមឈើចោលពេញព្រៃតែម្តង។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនាពេលថ្មីៗនេះ និងជាពិសេសការកសាងផ្លូវថ្មីឆ្លងកាត់ពីខេត្តស្ទឹងត្រែងទៅត្បែងមានជ័យ បានបង្កជាចលនានៃការចូលមករស់នៅរបស់អ្នកចំណូលថ្មី ដែលអ្នកទាំងអស់នោះបានចាប់ផ្តើមឈូសឆាយដីព្រៃសម្រាប់ ប្រកបរបរកសិកម្ម។ នៅជុំវិញតំបន់ភ្នំដីក៏មាចំនួននអ្នកចំណូលថ្មីច្រើនផងដែរ ដែលអ្នកទាំងនោះបានចូលមករស់នៅនិងរុករករ៉ែមាស (តាមការសង្កេតឃើញរបស់ក្រុមអ្នកស្រាវជ្រាវ) ហើយមួយចំនួនធំទៀតជាប់ពាក់ព័ន្ធនឹងសកម្មភាពដំណាំកៅស៊ូ (តាមការសង្កេតឃើញរបស់ Seiha, H.)។ ចលនានេះទៀតសោត ក៏បានបង្កើតឱ្យមានផ្លូវចេញចូលថ្មីៗមួយចំនួន និងជាមូលហេតុដែលបន្ថែមសម្ពាធទៅលើធនធានធម្មជាតិនៅតំបន់ទេសភាពមួយនេះ។ ជារួមនេះ បញ្ហាទាំងនេះបានបណ្តាលឲ្យតំបន់ព្រៃឡង់រឹតតែទទួលរងការខូចខាតច្រើនជាងបន្ថែមទៀត។

## *ការផ្តល់អនុសាសន៍និងការពិចារណាលើការគ្រប់គ្រង*

➢ គួរកំណត់ជាអាទិភាពលើការបោះបង្គោលព្រំដីព្រៃឲ្យបានច្បាស់លាស់ និងការកំណត់ឲ្យបានច្បាស់អំពីនិយមន័យនៃព្រំដែនព្រៃឡង់ បូករួមជាមួយនឹងការកំណត់ទីតាំងតំបន់អភិរក្សសំខាន់ៗនានា ដូចជានៅតំបន់ព្រៃស្រោងភាគកណ្តាល តំបន់កូនភ្នំដែលមានផ្ទាំងថ្ម Karst ធំៗ និង សក្តានុ

ពលតភ្ជាប់ជាមួយតំបន់ព្រៃការពារខេត្តព្រះវិហារ។ គួរផ្តួចផ្តើមឲ្យមានការការពារព្រៃឡង់ ដោយការកំណត់ថាជាតំបន់ព្រៃការពារ ដែលស្ថិតក្រោមការយកចិត្តទុកដាក់ខ្ពស់នៅក្រោម អំណាចច្បាប់នៃប្រទេសកម្ពុជា និងធានាឲ្យមានរាល់កិច្ចខិតខំប្រឹងប្រែង ដើម្បីដាក់បញ្ចូលតំបន់ ទេសភាពព្រៃឡង់ឲ្យទៅជាតំបន់អាទិភាពខ្ពស់នៅក្នុងរបៀបវារៈស្តីពីការអភិរក្សថ្នាក់ជាតិនិងអន្តរជាតិ។

➢គួរចាប់ផ្តើមបណ្តុះបណ្តាល និងបំពាក់បរិក្ខាឲ្យបានភ្លាមៗទៅដល់ក្រុមល្បាតព្រៃ ដើម្បីអាចឲ្យពួកគេមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចាប់ផ្តើមអនុវត្តច្បាប់ ដើម្បីការពារសត្វព្រៃ និងជម្រកធម្មជាតិរបស់វា។ គួរបញ្ឈប់ជាបន្ទាន់នូវសកម្មភាពកាប់ឈើខុសច្បាប់ទាំងឡាយ និងការឈូសឆាយដីព្រៃដែលកំពុងកើតមាននៅទូទាំងតំបន់ព្រៃឡង់។

➢គួរបង្ការកុំឲ្យប្រជាជនធ្វើចំណាកស្រុកចូលមករស់នៅបន្ថែមទៀត ក្នុងតំបន់ទេសភាពព្រៃឡង់ ជាពិសេសអ្នកដែលចូលទៅរុករករ៉ែមាស នៅក្នុងតំបន់ភាគខាងត្បូងនៃព្រៃឡង់និងនៅជុំវិញភ្នំជី ក៏ដូចជានៅតាមបណ្តោយផ្លូវពីស្ទឹងត្រែងទៅត្បែងមានជ័យ។

➢គួរបង្ការកុំឲ្យមានការផ្តល់ដីសម្បទានសេដ្ឋកិច្ចណាមួយបន្ថែមទៀតនៅតំបន់ព្រៃឡង់ និងត្រូវត្រួតពិនិត្យឲ្យបានហ្មត់ចត់លើការអនុវត្តសកម្មភាពរបស់ក្រុមហ៊ុនសម្បទានសេដ្ឋកិច្ច និងក្រុមហ៊ុនធ្វើអាជីវកម្មរុករករ៉ែទាំងអស់ដែលកំពុងមានវត្តមាននៅជុំវិញតំបន់ព្រៃឡង់។

➢គួរធ្វើការស្រាវជ្រាវលម្អិតបន្ថែមទៀត ដើម្បីវាយតម្លៃឲ្យបានលម្អិតបន្ថែមទៀតអំពីស្ថានភាពរស់នៅរបស់សត្វព្រៃ របាយសត្វព្រៃ និងកត្តាគម្រាមកំហែងនានាទៅលើប្រភេទសត្វបង្គោល និងដើម្បីបង្កើតជាយុទ្ធសាស្ត្រសមស្របមួយសម្រាប់ការអភិរក្ស និងត្រួតពិនិត្យ ជាពិសេសទៅលើការគ្រប់គ្រងទំនាស់ដែលអាចកើតមានរវាងសត្វដំរី និងមនុស្ស។

➢គួរបង្កើតឲ្យមានកិច្ចសន្ទនាឲ្យបានល្អប្រសើរជាងមុនជាមួយភាគីពាក់ព័ន្ធទាំងអស់ទាក់ទង នឹងការអភិរក្សតំបន់ព្រៃឡង់ ក៏ដូចជាការចូលរួមចែករំលែកមូលដ្ឋានបទពិសោធន៍ជំនាញឲ្យបានទូលំទូលាយជាងនេះទៀត។ ការបើកឱកាសឲ្យមានការចូលរួមបែបនេះ នឹងអាចបញ្ចៀសកុំឱ្យមានទស្សនៈយល់ថាការខិតខំប្រឹងប្រែងក្នុងកិច្ចការអភិរក្ស គឺជាភារកិច្ចដឹកនាំសម្រាប់តែអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការផ្នែកអភិរក្សតែឯកឯងប៉ុណ្ណោះ ក៏ដូចជាអាចផ្តល់ឱកាសក្នុងការបង្កើនសមត្ថភាពលើការគ្រប់គ្រងតំបន់ព្រៃឡង់ឲ្យបានកាន់តែល្អប្រសើរឡើង។

➢គួរបង្កើតឲ្យមានយុទ្ធនាការផ្សព្វផ្សាយតាមសហគមន៍ និងការចងក្រងបណ្តាញផ្សព្វផ្សាយសង្គម ដើម្បីលើកកម្ពស់តម្រូវការបន្ទាន់ក្នុងការការពារតំបន់ព្រៃឡង់។

➢គួរអនុវត្តការអង្កេតស្រាវជ្រាវឲ្យបានទូលំទូលាយបន្ថែមទៀត នៅតាមតំបន់ទាំងឡាយណាដែលមិនទាន់បានទៅដល់ ក្នុងអំឡុងពេលសិក្សាស្រាវជ្រាវកន្លងទៅនេះ ជាពិសេសនៅត្រង់ចំណុចភាគខាងលិចនៃតំបន់ព្រៃស្រោងភាគកណ្តាល។ គួរធ្វើការវាយតម្លៃទៅលើទំនាក់ទំនងរវាងជម្រក និងច្រករបៀងឆ្លងកាត់នានារបស់សត្វព្រៃនៅតំបន់ព្រៃការពារខេត្តព្រះវិហារ និងគួរកំណត់ផែនទី ភូមិសាស្ត្រដែលមានលក្ខណៈពិសេសសម្រាប់សត្វព្រៃ បូករួមទាំងភូមិសាស្ត្រនៃទន្លេ ស្ទឹង ត្រពាំង និងទីកន្លែងសត្វនិយមស្វែងរកចំណីជាដើម។

# ឯកសារយោង

Aruna technology, 2009. Rapid Assessment of Prey Lang Forest.
Ashwell, AD. 1997. *Cambodia: A National Biodiversity Prospectus*. IUCN, Phnom Penh.

Bates, P.J.J., Struebig, M.J., Hayes, B., Furey, N.M., Khin Mya Mya, Vu D.T., Pham D.T., Nguyen T.S., Harrison, D.L., Francis, C.M., Csorba, G. (2007). A new species of *Kerivoula* (Chiroptera: Vespertilionidae) from South-East Asia. *Acta Chiropterologica* 9: 323–338.

Berry, N., O'Connor, W., Holderied, M. W., Jones, G. (2004) Detection and avoidance of harp traps by echolocating bats. *Acta Chiropterologica* 6: 335–346.

Birdlife International 2005. Ecosystem profile, Indo-Burma hotspot, Indochina Region. _ CEPF.

BirdLife International. (2004). *State of the world's birds 2004 : indicators for our changing world*. Cambridge UK: BirdLife International.

BirdLife International. (2015). IUCN Red List for birds. Retrieved from Http://www.birdlife.org

Birdlife International Cambodia Programme. (2012). *The biodiversity of the proposed Western Siem Pang Protected Forest, Stung Treng Province, Cambodia*. Phnom Penh, Cambodia: BirdLife International Cambodia Programme.

Blake, G. J., & Loiselle, A. B. (2001). Bird Assemblages in Second-Growth and Old-Growth Forest, Costa Rica: Perspectives from Mist nets and Point Counts. *The Auk*, *118*(2), 304–326.

Butchart, S. H. M., Stattersfield, A. J., Bennun, L. A., Shutes, S. M., Akçakaya, H. R., Baillie, J. E. M., … Mace, G. M. (2004). Measuring Global Trends in the Status of Biodiversity: Red List Indices for Birds. *Prey LangoS Biology*, *2*(12), e383. doi:10.1371/journal.pbio.0020383

Boyce, P. Khou Eanghourt, & Ma Sophal M. 2002. Higher Plants, *in*: *Social and Ecological Surveys of Phnom Aural Wildlife Sanctuary, Cardamom Mountains, Cambodia*. Fauna & Flora International, Phnom Penh.

Burgess, S. & I. Theilade, 2003. *Forest Gene Conservation Strategy, Part A: Conservation of forest genetic resources*. Cambodia Tree Seed Project, Danida, Phnom Penh.

Bumrungsri, S., Harrison, D.L., Satasook, C., Prajukjitar, A., Thong-Aree, S., Bates, P.J. (2006) A review of bat research in Thailand with eight new species records for the country. *Acta Chiropterologica* 8: 325–359.

Bumrungsri, S., Lang, D., Harrower, C., Sripaoraya, E., Kitpipit, K., Racey, P.A. (2013) The dawn bat, *Eonycteris spelaea* Dobson (Chiroptera: Pteropodidae) feeds mainly on pollen of economically important food plants in Thailand. *Acta Chiropterologica* 15: 95–104.

Benzuijen, M. R., Timmin, R., Seng, T. (ed.). (2007) Biological surveys of the Mekong River between Kratie and Stung Treng Towns, northeast Cambodia, 2006-2007, 220pp.

Bezuijen, M.R., Bunna V. & Lieng S. (2009) A collection of amphibians and reptiles from the Mekong River, north-eastern Cambodia. *Hamadryad,* 34, 134–164.

Bourret, R. (1936) *Les Serpents de L'Indochine. Volumes I and II.* Imprimerie Henri Basuyau & Cie., Toulouse,France.

Bourret, R. (1941) Les tortues de l'Indochine. *Institut Océanographique de l'Indochine*, 38, 1–235.

Bourret, R. (1942) Les batrachiens de l'Indochine. *Mémoires de l'Institut Océanographique de l'Indochine,* 6, 1–547.

Boonratana, R., Das, J., Yongcheng, L., Htun, S. & Timmins, R.J 2008. *Macaca leonina*. The IUCN Red List of Threatened Species. Version 2014.3. <www.iucnredlist.org>. Downloaded on 08 February 2015.

Brockelman, W., Geissmann, T., Timmins, T. & Traeholt, C. 2008. *Hylobates pileatus*. The IUCN Red List of Threatened Species. Version 2014.3. <www.iucnredlist.org>. Downloaded on 08 February 2015.

Brook, S. E., Allison, E. H., Gill, J. A., Reynolds, J. D. (2009) Reproductive and Trophic Ecology of an Assemblage of Aquatic and Semi-Aquatic Snakes in Tonle Sap, Cambodia. *Copeia* 2009, No. 1, 7–20.

Brooks, S. E., E. H. Allison, and J. D. Reynolds. 2007a. Vulnerability of Cambodian water snakes: initial assessment of the impact of hunting at Tonle Sap Lake. *Biological Conservation* 139:401–414.

Brooks, S. E., J. D. Reynolds, E. H. Allison, and B. Touch. 2007b. The exploitation of homalopsid water snakes at Tonle Sap Lake, Cambodia, p. 31–38. In: Homalopsid Snakes: Evolution in the Mud. J. C. Murphy (ed.). Krieger Publishing Company, Malabar, Florida.

Brook, S.E., Neang.T, Daltry.J,. 2012. National Elephant Workshop: Summary of proceedings. August 2012, Phnom Penh Cambodia, FFI

Chan-ard, T. 2003. *A photographic guide to amphibians of Thailand.* Darnsutha Press Co., Ltd., Bangkok. 175 pp.

Chao, A., Chazdon, R. L., Colwell, R. K., Shen, T.-J. (2005) A new statistical approach for assessing similarity of species composition with incidence and abundance data. *Ecology Letters* 8: 148–159.

Chheang, S., Bates, P.J.J., Boughey, K., Csorba, G., Hayes, B., Ith, S., Mould, A., Phauk, S., Furey, N.M. (2013) Further new country records of four bat species (Chiroptera: Mammalia) from Cambodia and a call for information. *Cambodian Journal of Natural History* 2013(2): 73–82.

Choudhury, A., Lahiri Choudhury, D.K., Desai, A., Duckworth, J.W., Easa, P.S., Johnsingh, A.J.T., Fernando, P., Hedges, S., Gunawardena, M., Kurt, F., Karanth, U., Lister, A., Menon, V., Riddle, H., Rübel, A. & Wikramanayake, E. (IUCN SSC Asian Elephant Specialist Group) 2008. *Elephas maximus*. The IUCN Red List of Threatened Species. Version 2014.3. <www.iucnredlist.org>. Downloaded on 09 February 2015.

Clements, R., Sodhi, N.S., Schilthuizen, M. and Ng, P.K.L.(2006) Limestone karsts of Southeast Asia: imperiled arks of biodiversity. BioScience 56(9), p. 733-742.

Csorba, G., Son N.T., Saveng, I. & Furey, N.M. (2011) Revealing cryptic bat diversity: three new *Murina* and redescription of *M. tubinaris* from Southeast Asia. *Journal of Mammalogy* 92(4): 891–904.

Cox, J.M., Dijk, v. P.P., Nabhaitabhata, J., Thirakhupt, K. 1999. *A photographic guide to snakes and other reptiles of Peninisular Malaysia, Singapore and Thailand*.

Conservation International, 2011. REDD+ in the Prey Lang Area.

CTSP (Cambodia Tree Seed Project), 2003. *Gene-Ecological Zonation of Cambodia*. Institutional Capacity Building of the Tree Seed Sector. Forestry Administration, Danida, and German Development Service.

Daltry, J. C., & Momberg, F. (2000). Cardamom Mountains Biodiversity Survey 2000. Fauna & Flora International. Phnom Penh, Cambodia.

Durbin, L.S., Hedges, S., Duckworth, J.W., Tyson, M., Lyenga, A. & Venkataraman, A. (IUCN SSC Canid Specialist Group - Dhole Working Group) 2008. *Cuon alpinus*. The IUCN Red List of Threatened Species. Version 2014.3. <www.iucnredlist.org>. Downloaded on 09 February 2015.

Deharveng, L., Bedos, A. (2012) Diversity patterns in the tropics. In: White, W.B., Culver, D.C. (eds) Encyclopedia of Caves. Academic Press, Chennai, p. 238–250.

Douangboubpha, B., Xayaphet, V., Sanamxay, D., Thomas, N., Bumrungsri, S., Bates, P.J.J. (2014) First confirmed records of *Taphozous longimanus* and *Myotis annamiticus* (Chiroptera) from Lao PDR. *Tropical Natural History* 14(1): 27–34.

Duckworth, J.W., Wozencraft, C., Wang Yin-xiang, Kanchanasaka, B. & Long, B. 2008. *Viverra zibetha*. The IUCN Red List of Threatened Species. Version 2014.3. <www.iucnredlist.org>. Downloaded on 07 February 2015.

Duckworth, J.W., Timmins, R.J., Olsson, A., Roberton, S., Kanchanasaka, B., Than Zaw, Jennings, A. & Veron, G. 2008. *Viverra megaspila*. The IUCN Red List of Threatened Species. Version 2014.3. <www.iucnredlist.org>. Downloaded on 07 February 2015.

Duckworth, J.W., Steinmetz, R., Timmins, R.J., Pattanavibool, A., Than Zaw, Do Tuoc & Hedges, S. 2008. *Bos gaurus*. The IUCN Red List of Threatened Species. Version 2014.3. <www.iucnredlist.org>. Downloaded on 08 February 2015.

Dy Phon, P. 1970. *La Vegetation du Sud-Oeast du Cambodge: Secteur Baie de Kompong Som, Chaine de l'Elephant et Plateau de Kirirom*. Ann. Fac. Sc. Phnom Penh. 3:1-136.

Dy Phon, P. & B. Rollet. 2002. *Lexique des Arbres Forestiers du Cambodge*. ONF: Les dossiers forestiers, no. 5.

Daltry, J.C. & Chheang D. (2000) Reptiles. In *Cardamom Mountains Biodiversity Survey 2000* (eds J.C.Daltry & F. Momberg), pp. 99–110. Fauna & Flora International, Cambridge, UK.

Das, I. (2010) A *field guide to the Reptiles of South-east Asia*. New Holland Publishers (UK) Ltd, London-Cape Town-Sydney- Auckland, 376 pp.

Eames, J. C., Steinheimer, F. D., & Bansok, R. (2002). A collection of birds from the Cardamom Mountains, Cambodia, including a new subspecies of Arborophila cambodiana. *Forktail*, 67–86.

Emmett, D.A. & Olsson, A. (Editors) (2005). Biological Surveys in the Central Cardamom Mountains. Conservation International Cambodia Program and Forestry Administration, Phnom Penh

Emmet, D. and Olsson, A. (eds) 2007. A floral and faunal biodiversity assessment of Prey Lang. Conservation international, forestry administration. - For. Landsc., Denmark, research Rep.

Everbright, 2003a. *Forest Management Plan for Kratie/Stung Treng Forest Concession*. Phnom Penh, Cambodia.

Felton, A., Wood, J., Felton, A. M., Hennessey, B., & Lindenmayer, D. B. (2008). Bird community responses to reduced-impact logging in a certified forestry concession in lowland Bolivia. *Biological Conservation*, *141*(2), 545–555. doi:16/j.biocon.2007.11.009

Fenton, M.B. (2012) Bats and white-nose syndrome. *Proceedings of the National Academyof Sciences* 109(18): 6794–6795.

Francis, C.M. (1989) A comparison of mist nets and two types of harp traps for capturing bats. *Journal of Mammology* 70: 865–870.

Francis, C.M. (2008) *A guide to the mammals of Southeast Asia*. Princeton University Press, USA.

Francis, C.M., Eger, J.L (2012) A review of tube-nosed bats (*Murina*) from Laos with a description of two new species. *Acta Chiropterologica* 14: 15–38.

Fredriksson, G., Steinmetz, R., Wong, S. & Garshelis, D.L. (IUCN SSC Bear Specialist Group) 2008. *Helarctos malayanus*. The IUCN Red List of Threatened Species. Version 2014.3. <www.iucnredlist.org>. Downloaded on 08 February 2015.

Fujita, M.S., Tuttle, M.D. (1991) Flying foxes (Chiroptera: Pteropodidae): threatened animalsof key ecological and economic importance. *Conservation Biology* 5: 455–463.

Furey, N.M., Mackie, I.J., Racey, P.A. (2009) The role of ultrasonic bat detectors in improving inventory and monitoring surveys in Vietnamese karst bat assemblages. *Current Zoology* 55: 327–341.

Furey, N.M., Mackie, I.J., Racey, P.A. (2010) Bat diversity in Vietnamese limestone karst areas and the implications of forest degradation. *Biodiversity and Conservation* 19: 1821–1838.

Furey, N.M., Mackie, I.J., Racey, P.A. (2011) Reproductive phenology of bat assemblages in Vietnamese karst and its conservation implications. *Acta Chiropterologica* 13(2): 341–354.

Furey, N.M., Racey, P.A. in press. Conservation ecology of cave bats. In: Kingston, T., Voigt, C. (eds.) *Bats in the Anthropocene: Conservation of bats in a changing world*. Springer, USA.

Gilbert M., Chear Sokha, Joyner P., Thomson R. & Pool C.(2012) Characterizing the trade of wild birds for merit release in Phnom Penh, Cambodia and associated risks to health and ecology. Biological Conservation , 153, 10-16

Goes, F. (2013). *The Bird of Cambodia: An Annotated Checklist.* Centre for Biodiversity Conservation, Fauna & Flora International Cambodia Programme and Royal Unversity of Phnom Penh, Cambodia.

Grismer, L.L., Neang, T., Chav, T. & Grismer, J.L. (2008) Checklist of the amphibians and reptiles of the Cardamom region of Southwestern Cambodia. *Cambodian Journal of Natural History*, 2008 (1), 12–28.

Günther, A. (1861) Second list of Siamese reptiles. *Proceedings of the Zoological Society of London,* 1861, 187–189.

Günther, A.C.L.G. (1864) *The Reptiles of British India.* Taylor and Francis, London, UK.

Hartwell, H., J. R. Welsh, and L. M. Oliver. 1998. Stream Amphibians as Indicators of Ecosystem Stress: A Case Study from California Redwoods. *Ecological Applications* 8: 1118-1132.

Hartmann, T., Ihlow, F., Edwards, S., Sovath, S., Handschuh, M. & Böhme, W. (2013c) A preliminary annotated checklist of the amphibians and reptiles of the Kulen Promtep Wildlife Sanctuary in northern Cambodia. *Asian Herpetological Research* 4(1): 36-55.

Hussain, S.A., de Silva, P.K. & Mostafa Feeroz, M. 2008. *Lutrogale perspicillata*. The IUCN Red List of Threatened Species. Version 2014.3. <www.iucnredlist.org>. Downloaded on 07 February 2015

Ida Theilade, Lars Schmidt, Phourin Chhang and J. Andrew McDonald, 2011. *Evergreen swamp forest in Cambodia: floristic composition, ecological characteristics, and conservation status*.

Ida Theilade and Lars Schmidt, 2011. *REDD+ and Conservation of Prey Lang Forest, Cambodia Summary of Scientific Findings 2007-2010*. Faculty of Life Sciences, University of Copenhagen.

Inger, R. F. Orlov, N. & Daresky, I. (1999)Frogs of Vietnam: a report on new collections. Fieldiana: Zoology (New series) 92:1–46.

IUCN (2014) IUCN Red List of Threatened Species. Version 2010.4. <www.iucnredlist.org>.
IUCN SSC (2014) IUCN SSC guidelines for minimizing the negative impact to bats and other cave organisms from guano harvesting. Ver. 1.0. IUCN, Gland.

Jones, G., Teeling, E.C. (2006) The evolution of echolocation in bats. *Trends in Ecology and Evolution* 21: 149–156.

Jones, G., Rebelo, H. (2013) Responses of bats to climate change: learning from the past and predicting the future. In: Adams, R.A., Pedersen, S.C. (eds) Bat Evolution, Ecology, and Conservation. Springer, New York, p. 457–478.

James F. Maxwell, Khou Eanghourt, Pranee Palee, Martin van de Bult, Sai Jai Ngundahn and Choeung Hong Narith, 2007. Biological surveys of the Mekong River between Kratie and Stung Treng towns, northeast Cambodia. *VEGETATION AND FLORA*. Page 42-52.

Johns, A.D., 1985. Selective logging and wildlife conservation in tropical rain-forest: Problems and recommendations. *Biological Conservation* 31:355-375.

Kingston, T. (2010) Research priorities for bat conservation in Southeast Asia: a consensus approach. *Biodiversity Conservation* 19: 471–484.

Kingston, T. (2013) Response of bat diversity to forest disturbance in Southeast Asia: insights from long-term research in Malaysia. In: Adams, R.A., Pedersen, S.C. (eds) Bat Evolution, Ecology, and Conservation. Springer, New York, p. 169–185.

Kingston, T., Liat, L.B., Akbar, Z. (2006) *Bats of Krau Wildlife Reserve*. Penerbit Universiti Kabangsaan Malaysia Bangi, Malaysia.

Kruskop, S.V. (2013) *Bats of Vietnam, checklist and an identification manual*. Joint Russian Vietnamese Science and Technological Tropical Centre, Hanoi, Vietnam.

Kunz, T.H., Braun de Torrez, E., Bauer, D., Lobova, T. and Fleming, T.H. (2011) Ecosystem services provided by bats. Annual. N. Y. Acad. Sci. Doi: 10.1111/j.1749-6632.2011.06004.x

Lammertink, M., Setiorini, U., Thet Zaw Naing, Duckworth, J. W., & Menken, S. B. J. (2009). Globall population decline of the Great slaty woodpecker (Mulleripicus pulverulentus). *Biological Conservation*, *142*, 166–179.

Le Compte, & H. Guibier. 1936. *Les Bois de L'Indochine*. Agence Economique de L'Indochine, Paris

Legris, P. & F. Blasco. 1972. Notice *de la Carte: Carte Internationale de Tapis Vegetal*. Etraits des travaux de la Scetion Scientifique et Technique de l'Institut Francaise de Pondichery: hors serie No. 1, Toulouse, France.

Maltby, M. & Bourchier (2010) Current Status of Asian Elephants in Cambodia. *Gajah* 35 (2011) 35-41

McDonald, J. A. (2004) Ecological Survey of Prey Lang, Kampong Thom. A Proposal for the Conservation of Indochina' Undisturbed Lowland Rainforest.

McDonald, J.A. & Sam Veasna, 1996. *Floristic and Biotic Resource Reconnaissance of Prek Sramaoch lake and Vicinity, Tonle Sap*. FAO, Participatory Natural Resource Management in the Tonle Sap Region, Cambodia.

McDonald, J.A. , 2004.*Botanical Reconnaissance of Snuol Wildlife Sanctuary and Environs, Mondulkiri, Cambodia*, World Wildlife Conservation, CambodiaProgram, Phnom Penh.

McDonald, J. A. 2004. Ecological survey of Prey Lang, Kampong Thom. Plant Resources Center, Univ. of Texas, Austin.

Moody.J, An Dara, Camille N Z Coudrat, Tom Evans, Tom Gray, Matt Maltby, Men Soriyun, Nut Meng Hor, Hannah O Kelly, Pech Bunnat, Phan Channa, Edward Pollard, Hugo J Rainey, Benjamin M Rawson, Rours Vann, Song Chansocheat, Tan Setha, Thong Sokha. (2011). A summary of the conservation status, taxonomic assignment and distribution of the Indochinese Silvered Langur Trachypithecus germaini (sensu lato) in Cambodia. Asian Primate Journal 12/2012; 2(1):21-28.

Myers, N., Mittermeier, R.A., Mittermeier, C.G. (2000) Biodiversity hotspots for conservation priorities. *Nature* 403: 853–858.

Nadler, T., Timmins, R.J. & Richardson, M. 2008. *Trachypithecus germaini*. The IUCN Red List of Threatened Species. Version 2014.3. <www.iucnredlist.org>. Downloaded on 12 February 2015.

Niels Strange, Ida Theilade, So Thea, Arvid Sloth, Finn Helle, 2007. Integration of species persistence, costs and conflicts: An evaluation of tree conservation strategies in Cambodia.

Neang, T. Grismer, L. L, Onn, K. C. Grismer, J. L., Wood, P. L. Jr., Youmans, T. M. (2010) First report on the herpetofauna of Dalai Mountain in Phnom Samkos Wildlife Sanctuary, southwestern Cardamom Mountains, Cambodia. *Cambodian Journal of Natural History*, 2, 127-143.

Neang, T., Hartmann, T., Hun, S. Souter, N. J. & Furey, N. M. (2014) A new species of wolf snake (Colubridae: Lycodon Fitzinger, 1826) from Phnom Samkos Wildlife Sanctuary, Cardamom Mountains, southwest Cambodia. *Zootaxa* 3814 (1): 068–080.

Neang T. & Holden, J. (2008) *A Field Guide to the Amphibians of Cambodia.* Fauna & Flora International,Phnom Penh, Cambodia. pp. 132.

Nguyen, V.S., Ho, T.C. & Nguyen, T.Q. (2009) *Herpetofauna of Vietnam*. Edition Chimaira, Frankfurt am Main, 768 pp.

Nowak, R.M. (1994) *Walker's bats of the world.* John Hopkins University Press, Baltimore and London.

Olsson, A., & Emmett, D. E. (2007). *A Floral and Fuanal Biodiversity Assessment of Prey Lang*. Conservation Internatioinal, Forest & Landscape, University of Copenhagen, and Forestry Administration. Phnom Penh, Cambodia.

Ohler, A., Swan, S.R. & Daltry, J.C. (2002) A recent survey of the amphibian fauna of the Cardamom Mountains, southwest Cambodia with descriptions of three new species. *Raffles Bulletin of Zoology,* 50, 465–481.

Osgood, W.H. 1932. Mammals of the Kelley-Roosevelts and Delacour Asiatic Expeditions. *Publ. Field Mus. Nat. Hist., Zool. Ser.* 18: 193-339.

Orlov, N. L., Murphy R. W., Ananjeva N. B., Ryabov S. A., and Ho T. C. (2002), 'Herpetofauna of Vietnam. A checklist. Part I. Amphibia,' *Russ. J. Herpetol*., 9(2), 81 – 104

Phauk, S., Phen, S., Furey, N.M. (2013) Cambodian bat echolocation: A first description of assemblage call parameters and assessment of their utility for species identification. *Cambodian Journal of Natural History* 2013(1): 16–26.

Robson, C. (2008). *A Field Guide to The Birds of South-East Asia*. London, Cape Town, Sydney, Auckland: New Holland.

Rollet, B. 1972. La Vegetation du Cambodge. *Rev. Bois et For. des Trop*. 144:3-16; 145:23-38; 146:3-20.

Rundel, P.W. 1999. *Forest Habitats and Flora in Lao PDR, Cambodia, andVietnam*. WWF Desk Study, Indochina Programme Office, Hanoi.

Rowley, J. (2007) *'Amphibians, Snakes & Lizards' In Olsson, A. and Emmett, D. E. (Eds). A Faunal Biodiversity Assessment of Prey Lang. Conservation International and Forestry Administration, Phnom Penh, Cambodia.*

Rowley, J.J.L., Stuart, B.L., Neang T. & Emmett, D.A. (2010) A new species of *Leptolalax* (Anura: Megophryidae) from northeastern Cambodia. *Zootaxa,* 2567, 57–68.

Saint Girons, H. 1972. Les serpents du Cambodge. *Me´moires du Muse´um National d'Histoire Naturelle, Paris*, 74:1–170.

Sanderson, J., Khan, J.A., Grassman, L. & Mallon, D.P. 2008. *Neofelis nebulosa*. The IUCN Red List of Threatened Species. Version 2014.3. <www.iucnredlist.org>. Downloaded on 07 February 2015.

Schmidt, L. and Theilade, I. 2010. Conservation of Prey Lang Forest Complex, Cambodia Working papers nr.50-2010. Forest & Landscape.

Setha, T., & Poole, C. M. (2003). *The Field Guide to Birds of Cambodia*. Phnom Penh: JSRC.

Smith, J. (2001). *Biodiversity The Life of Cambodia Cambodia's Biodiversity Status Report-2001*. Cambodia Biodiversity Enabling Activities, Phnom Penh, Cambodia.

Schnitzler, H-U., Kalko, E.K.V., Denzinger, A. (2001) Evolution of echolocation and foraging behaviour in bats. In: Thomas, J. A., Moss, C. F., Vater, M. (eds). Echolocation in bats and dolphins. The University of Chicago Press, Chicago and London, pp. 330–338.

Shen, T-J., Chao, A., Lin, C-F. (2003) Predicting the number of new species in further taxonomic sampling. *Ecology* 84: 798–804.

Simmons, N.B. (2005) Order Chiroptera. Pp. 312–529, *in* Mammal species of the World: a taxonomic and geographic reference, 3rd edition (D. E. Wilson and D. M. Reeder, eds.). Johns Hopkins University Press, Baltimore, USA.

Soisook, P., Bumrungsri, S., Satasook, C., Thong, V.D., Bu, S.S.H., Harrison, D.L., Bates, P.J.J. (2008) A taxonomic review of *Rhinolophus stheno* and *R. malayanus* (Chiroptera: Rhinolophidae) from continental Southeast Asia: an evaluation of echolocation call frequency in discriminating between cryptic species. *Acta Chiropterologica* 10: 221–242.

Solow, A.R., Polasky, S. (1999) A quick estimator for taxonomic surveys. *Ecology* 80: 2799–2803.

Sritongchuay, T., Gale, G. A. Stewart, A., Kerdkaew, T., Bumrungsri, S. (2014) Seed rain in abandoned clearings in a lowland evergreen rain forest in southern Thailand. *Tropical Conservation Science* 7(3): 572–585.

Shibata, Y. (1967) A small collection of amphibians from Cambodia collected by the Osaka City University Expedition 1962-65. *Bull. Osaka Mus. nat. Hist.,* No. 20, 11-12.

Smith, M.A. (1943) The Fauna of British India, Ceylon and Burma, including the whole of the Indo-Chinese Sub-region. Reptilia and Amphibia. Vol. III. - Serpentes. Taylor and Francis, London, xii + 583pp.

Sok, K. & Prum, S. (2003) Short report about crocodile in Colexim forest concession in Kampong Thom province from 17 to September 24, 2003

Sok, K. & Sin, P. (2003) Short report about crocodile in Colexim forest concession in Kampong Thom province from May 27 to June 22, 2003.

Som, S., Chey, C., & Sun, Y. 2005. Tortoise and Freshwater Turtle Conservation in the Cardamom Mountains. Cambodian Turtle Conservation Project, Phnom Penh, Cambodia.

Stuart, B. L. (2005) New Frog Records from Laos. *Herpetological Review*, 2005, 36(4), 473–479.

Stuart, B. L. (1999) Amphibians and reptiles. pp:43–67. In: Wildlife in Lao PDR: 1999 Status Report. J. W. Duckworth, R. E. Salter & K. Khounboline (compilers). IUCN–The World Conservation Union / Wildlife Conservation Society / Centre for Protected Areas and Watershed Management, Vientiane. 275 pp.

Streicher, U., Singh, M., Timmins, R.J. & Brockelman, W. 2008. *Nycticebus bengalensis*. The IUCN Red List of Threatened Species. Version 2014.3. <www.iucnredlist.org>. Downloaded on 08 February 2015.

Stuart, B.L. & Emmett, A.E. (2006) A collection of amphibians and reptiles from the Cardamom Mountains, southwestern Cambodia. *FieldianaZoology,* 109, 1–27.

Stuart, B.L. & Platt, S.G. (2004) Recent records of turtles and tortoises from Laos, Cambodia and Vietnam. *Asiatic Herpetological Research,* 10, 129–150.

Stuart, B. L., Van Dijk, P. P., & Hendrie, D. B. (2001) *A photographic guide to the turtles of Thailand, Laos, Vietnam and Cambodia.*

Stuart, B.L., Rowley, J.J.L., Neang, T., Emmett , D.A. & Som S. (2010) Significant new records of amphibians and reptiles from Virachey National Park, northeastern Cambodia. *Cambodian Journalof Natural History*, 2010, 38–47.

Stuart B.L., Sok, K. & Neang, T. (2006) A collection of amphibians and reptiles from hilly eastern Cambodia. *The Raffles Bulletin of Zoology,* 54, 129–155.

Traeholt, C., Bonthoeun, R., Rawson, B., Samuth, M., Virak, C. and Sok Vuthin (2005). Status review of pileated gibbon, *Hylobates pileatus* and yellow-cheeked crested gibbon, *Nomascus gabriellae*, in Cambodia.

